ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារស្វ័យសិក្សា
# ស្ដីពី
# ការរៀបចំសាលារៀនសុវត្ថិភាព


មុខសញ្ញាគ្រោះថ្នាក់


ភាពងាយរងគ្រោះ





ហានិភ័យ
គ្រោះមហន្តរាយ


ការឆ្លើយតប


ការអប់រំកាត់បន្ថយហានិភ័យ

លេខាធិការដ្ឋាន គ្រប់គ្រងគ្រោះមហន្តរាយ
ក្រសួងអប់រំ យុវជន និងកីឡា
២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦០៩ អយក.ប្រក

# ប្រកាស
# ស្ដីពី
# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
# ឯកសារស្វ័យសិក្សាស្ដីពីការរៀបចំសាលារៀនសុវត្ថិភាព

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្ដីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងលិខិតលេខ ០៧៨/២៤/ស.ក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ របស់អង្គការសង្គ្រោះកុមារកម្ពុជា
- យោងរបាយការណ៍សង្ខេបស្ដីពី ដំណើរការរៀបចំឯកសារស្វ័យសិក្សាលើការរៀបចំសាលារៀនសុវត្ថិភាព ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤
- យោងលិខិតលេខ ១៥៩ អគ.អរ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានអប់រំ

## សម្រេច

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយ «**ឯកសារស្វ័យសិក្សាស្តីពីការរៀបចំសាលារៀនសុវត្ថិភាព**» របស់អង្គការសង្គ្រោះកុមារអន្តរជាតិកម្ពុជា ដើម្បីបោះពុម្ពប្រើប្រាស់ជាឯកសារស្វ័យសិក្សាសម្រាប់គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ ក្នុងការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានអប់រំ អគ្គនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកដ្ឋានយុវជន អគ្គនាយកដ្ឋានកីឡា អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គាធិការដ្ឋាន លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀនមធ្យមសិក្សាចំណេះទូទៅ សាលារៀនបឋមសិក្សា និងអង្គការសង្គ្រោះកុមារអន្តរជាតិកម្ពុជា មានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

**កន្លែងទទួល៖**
- គ្រប់សាលារាជធានីខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី «ដើម្បីជ្រាបជាព័ត៌មាន»
- ដូចប្រការ២ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## I. **គណៈកម្មការគ្រប់គ្រង**

១.លោកជំទាវ **ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការ

២.លោក **ស៊ុន ប៊ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៣.លោក **ម៉ូត សាណា** នាយកគ្រប់គ្រងកម្មវិធី និងភាពជាដៃគូរ អង្គការសង្គ្រោះកុមារអន្តរជាតិប្រចាំនៅកម្ពុជា

៤. លោក **ស្រី បូរិន** ប្រធានគ្រប់គ្រងជាន់ខ្ពស់កម្មវិធីអប់រំ អង្គការសង្គ្រោះកុមារអន្តរជាតិប្រចាំនៅកម្ពុជា

## II. **គណៈកម្មការនិពន្ធ**

១. លោកស្រី **ម៉ៅ តាន់ណារី**

២. លោកស្រី **វ៉ាន់ សុភី**

៣. លោកស្រី **ស ហន**

៤. លោក **ស៊ឹម ចាន់ សុវណ្ណារិទ្ធ**

៥. លោក **ដាំ បេង**

## III. **គណៈកម្មការពិនិត្យ**

១. លោក **យិន ធី**

២. លោក **ព្រៃ សំបូរ**

៣. លោក **ង៉ិន សុតារា**

៤. លោក **សុខ បញ្ញាវឌ្ឍន៍**

៥. កញ្ញា **លន់ ច័ន្ទម៉ាឡា**

៦. លោកស្រី **ផាន់ សុជាតា**

៧. លោក **នៅ ចាន់មករា**

## IV. **ទីប្រឹក្សាបច្ចេកទេស**

១. លោក **រស់ ច័ន្ទបូរិទ្ធិ**

២. លោក **គង់ សាកែម**

៣. លោក **សុខ សេង**

## V. **អ្នករៀបរៀង និងរចនា**

១. លោក **ដាំ បេង**

២. លោក **សុខ បញ្ញាវឌ្ឍន៍**

## VI.**គណៈកម្មការពិគ្រោះយោបល់**

១. លោក **ង៉ែត ឡឹង** ប្រធាន មន្ទីរអយក. ខេត្តកោះកុង

២. លោក **សុខ វីន** អនុប្រធាន មន្ទីរអយក. ខេត្តកោះកុង

៣. លោក **ស៊ឹម ប្រិម** ប្រធានមន្ទីរ អយក.ខេត្តកំពង់ឆ្នាំង

៤. លោក **គិត មិនារិទ្ធ** អនុប្រធានមន្ទីរ អយក.ខេត្តកំពង់ឆ្នាំង

# សេចក្តីផ្តើម

បច្ចុប្បន្ននេះ បញ្ហាគ្រោះមហន្តរាយ បង្កឡើងដោយធម្មជាតិ បច្ចេកវិទ្យា សុខភាព ការប្រែប្រួលអាកាសធាតុ ជម្លោះនិងអំពើហិង្សាបានផ្តល់ផលប៉ះពាល់និងអាចរារាំងដល់ប្រទេសនីមួយៗពីការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ កុមារជិតមួយភាគបួននៅលើពិភពលោកកំពុងរស់នៅក្នុងស្ថានភាពប្រឈមនឹងគ្រោះមហន្តរាយ និងរងផលប៉ះពាល់ដោយជម្លោះ ជាមួយនឹងការរឹតត្បិតពីការទទួលបានការអប់រំពេញលេញរបស់ពួកគេ។

កម្ពុជាត្រូវបានគេចាត់ទុក ជាប្រទេសដែលរងគ្រោះដោយគ្រោះធម្មជាតិខ្លាំងក្នុងចំណោមប្រទេសមួយចំនួនលើពិភពលោក។ គ្រោះធម្មជាតិដែលបានទទួលការគំរាមកំហែងធ្ងន់ធ្ងរ រួមទាំងទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះខ្លាំង ព្យុះទីហ្វុង និងរន្ទះបាញ់។ ម្យ៉ាងទៀត កម្ពុជាក៏បានរងគ្រោះដោយអគ្គីភ័យ រន្ទះបាញ់ និងការបាក់ដីផងដែរ។ កម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសអាស៊ីទាំងប្រាំដែលស្ថិតក្នុងប្រភេទហានិភ័យខ្ពស់ជាងគេ។ វាជាប់ចំណាត់ថ្នាក់ទី ១៦ នៅទូទាំងពិភពលោកក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតពីគ្រោះមហន្តរាយធម្មជាតិ។ គ្រោះមហន្តរាយធម្មជាតិ បានបង្កឱ្យមានការខាតបង់ និងការខូចខាតដល់សេដ្ឋកិច្ច អាយុជីវិតមនុស្ស ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ផលិតកម្មកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងសង្គម។

ចំពោះវិស័យអប់រំ យើងឃើញថា ទឹកជំនន់បានធ្វើឱ្យទទួលរងផលប៉ះពាល់ស្ទើររៀងរាល់ឆ្នាំ ហើយបង្កការខូចខាតច្រើនជាងគ្រោះរាំងស្ងួត ។ ចុងក្រោយនេះ ទឹកជំនន់ បានធ្វើឱ្យសត្វ និងមនុស្សរាប់រយនាក់ស្លាប់ ខូចខាតដំណាំរាប់ពាន់ហិកតា និងសាលារៀនរាប់ពាន់ខ្នង។ សិស្សរាប់ពាន់នាក់បានអាក់ខានការសិក្សារបស់ពួកគេ ឬមិនអាចចូលរៀនជាមួយនឹងប្រតិទិនសិក្សាធម្មតា (MOEYS_2014a)។

នៅចុងឆ្នាំ ២០១៣ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ថាសាលារៀនចំនួន ១២៨០ ត្រូវបានរងផលប៉ះពាល់ដោយទឹកជំនន់។ សាលារៀន ១៥៥ ត្រូវបានផ្អាកសម្រាប់រយៈពេលពី ១ ទៅ ៩ សប្តាហ៍ កុមារយ៉ាងហោចណាស់ ៥០០០០នាក់ បានអាក់ខានការសិក្សា របស់ពួកគេ។ ការបាត់បង់និងការខូចខាតក្នុងវិស័យអប់រំដោយសារទឹកជំនន់ក្នុងឆ្នាំ២០១៣ ត្រូវបានគេប៉ាន់ប្រមាណថាមានតម្លៃ ១៥ លានដុល្លារ (MoEYS, 2013) ។

ការរៀបចំ «ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់កម្រិតសាលារៀន» ជាការចាំបាច់សម្រាប់ការលើកកម្ពស់សុវត្ថិភាពរបស់កុមារនៅក្នុងសាលារៀន ដែលជាកត្តាចាំបាច់ជុំរុញឱ្យលទ្ធផលនៃការសិក្សា របស់កុមារបានប្រសើរឡើង។ ផ្អែកតាមផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៩-២០២៣ ក្របខណ្ឌសេនដាយ២០១៥-២០៣០ ដែលចំណុចអាទិភាពទី៤ លើកកម្ពស់ការត្រៀមបម្រុងគ្រោះមហន្តរាយ (ការឆ្លើយតប ស្តារបនា និងស្តារឡើងវិញ) កិច្ចព្រមព្រៀងអាស៊ានការគ្រប់គ្រងគ្រោះមហន្តរាយនិងការឆ្លើយតបគ្រោះអាសន្នបន្ទាន់១៥ កុម្ភៈ២០១៨ ដែលផ្តល់ជូននូវយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយថ្នាក់ជាតិ សហការតំបន់ និងអន្តរជាតិ ។ ពិសេស គោលនយោបាយកម្មវិធីសាលាកុមារមេត្រី សមាសភាពទី៣ ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីឆ្លើយតប ការការពារសុខភាព សុវត្ថិភាពនិងការការពារកុមារ ព្រមទាំងអ្នកសិក្សា អ្នកអប់រំ និងបុគ្គលិកអប់រំ ពីការស្លាប់ របួស អំពើ

ហិង្សា និងប៉ះពាល់ដល់សាលារៀន និងកន្លែងសិក្សាផ្សេងៗទៀត។ ពិសេសការរៀបចំផែនការសម្រាប់ការអប់រំ ដើម្បីការការពារជាបន្តបន្ទាប់ និងការកាត់បន្ថយការរំខានផ្សេងៗ ដល់ការសិក្សារបស់កុមារ ក្នុងគោលដៅរៀនសម្របខ្លួនទៅនឹងភាពតក់ស្លុត ភាពតានតឹង មុខសញ្ញាគ្រោះថ្នាក់ និងការគំរាមកំហែង គ្រប់ប្រភេទ។ លើកកម្ពស់ចំណេះដឹង និងជំនាញរបស់សិស្ស និងអ្នកកាន់កាតព្វកិច្ច រួមចំណែកដល់ការកាត់បន្ថយហានិភ័យ ការកសាងភាពធន់ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៥ - ២០៣០។

# អារម្ភកថា

ឯកសារណែនាំគ្រូសម្រាប់"ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុកម្រិតសាលារៀន" នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងក្រុមការងារលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ក្រុង ខណ្ឌ ស្រុក នាយកសាលា លោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលាគោលដៅពាក់ព័ន្ធ និងព្រមទាំងអង្គការសង្គ្រោះកុមារអន្តរជាតិ «Save the Children.International» តាមរយៈគម្រោង ការវិលត្រឡប់មកសាលារៀនដោយសុវត្ថិភាព ផ្លូវឆ្ពោះទៅរកសមធម៌ និង ភាពធន់នៃការអប់រំ ហៅកាត់ថា "PEER" ។

ឯកសារនេះ បានរៀបចំឡើងដោយផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ក្របខណ្ឌសេនដាយ ក្របខណ្ឌសាលារៀនសុវត្ថិភាព និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ ២០១៩ ។ គោលបំណងសំខាន់នៃការរៀបចំឯកសារនេះ គឺបង្កើនការយល់ដឹងពីទស្សនទានជុំវិញការងារគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀននិងគំនិតជាមូលដ្ឋាន ដែលជាបច្ច័យក្នុងការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់កម្រិតសាលារៀន។ ពិសេសសំដៅចូលរួមកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយដែលជាការបង្ហាញផ្លូវក្នុងការត្រៀមលក្ខណៈទុកជាមុនក្នុងការងារត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ឯកសារនេះ នឹងបានជាជំនួយស្មារតី ក្នុងធ្វើផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន ។ គំនិតសំខាន់ៗក្នុងការរៀបចំនេះ ផ្តោតលើខ្លឹមសារមេរៀននិងបទពិសោធដែលឆ្លងកាត់ និងការសហការរួមគ្នា គ្រប់ភាគីពាក់ព័ន្ធដើម្បីធ្វើយ៉ាងណាឱ្យសាលារៀននីមួយៗនៅទូទាំងប្រទេសក្លាយជា "សាលារៀនសុវត្ថិភាព" ស្របតាមក្របខណ្ឌកម្មវិធីសាលាកុមារមេត្រីដែលផ្តោតលើ"សុខភាព សុវត្ថិភាព និងការការពារកុមារ" ហើយសហគមន៍ ក៏ដូចជាមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សមានការអបអរសាទរនិងគាំទ្រផងដែរ។

គណៈកម្មការរៀបចំឯកសារ សង្ឃឹមថាឯកសារនេះនឹងបានជួយពង្រឹងដល់ការងារគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀន កាន់តែប្រសើរឡើង។ ពិសេស ការចូលរួមអន្តរាគមន៍ទាន់ពេលវេលា ធានាបាននូវការប្រើប្រាស់ធនធានដែលមានស្រាប់ ព្រមទាំងធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់ស្គាល់ច្បាស់ពីតួនាទី ភារកិច្ចនិងការទទួលខុសត្រូវ ក្នុងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយសាលារៀនក៏ដូចជាការផ្សព្វផ្សាយចំណេះដឹង និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

គណៈកម្មការរៀបចំឯកសារ សង្ឃឹមនិងជឿជាក់ថា ឯកសារនេះនឹងក្លាយជាឯកសារដ៏មានសារៈសំខាន់បំផុត សម្រាប់ប្រើប្រាស់នៅតាមសាលារៀននិងបានរួមចំណែកមួយយ៉ាងសំខាន់ ជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ សំដៅចូលរួមកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យអប់រំ ក៏ដូចជាក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលប្រកបដោយសុខសុវត្ថិភាព ។

គណៈកម្មការរៀបចំឯកសារ

# មាតិកា


សេចក្តីផ្តើម ........ i

អារម្ភកថា ........ iii

ជំពូកទី១ ច្បាប់ បទដ្ឋានគតិយុត្ត និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀន .. ១

មេរៀនទី១៖ ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងបទដ្ឋានគតិយុត្ត ........ ២

មេរៀនទី២៖ ក្របខណ្ឌសាលារៀនសុវត្ថិភាព ........ ១០

មេរៀនទី៣៖ នីតិវិធីទូទៅ និងដំណើរការនៃការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀន ........ ១៩

មេរៀនទី៤៖ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន ........ ២៤

ជំពូកទី២ យន្តការគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន ........ ២៨

មេរៀនទី១៖ ការរៀបចំឬពិនិត្យឡើងវិញនូវយន្តការ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន ........ ២៩

មេរៀនទី២៖ តួនាទីក្រុមការងារសាលារៀនសុវត្ថិភាព ........ ៣៥

មេរៀនទី៣៖ ការពិនិត្យសមត្ថភាពយេនឌ័រ និងបរិយាបន្ន ក្នុងការងារការបន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ........ ៤១

ជំពូកទី៣ មុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ ........ ៤៧

មេរៀនទី១៖ មុខសញ្ញាគ្រោះថ្នាក់ ........ ៤៨

មេរៀនទី២៖ ប្រភេទហានិភ័យ ........ ៦៦

មេរៀនទី៣៖ ការវិភាគមុខសញ្ញាគ្រោះថ្នាក់ ........ ៧១

មេរៀនទី៤៖ ផែនទីមុខសញ្ញាគ្រោះថ្នាក់ ........ ៧៧

មេរៀនទី៥៖ វិភាគសមត្ថភាព និងចំនុចខ្វះខាត ........ ៨៦

ជំពូកទី៤ ផែនការកាត់បន្ថយហានិភ័យ ........ ៩០

មេរៀនទី១៖ ការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់សាលារៀន ........ ៩១

មេរៀនទី២៖ សុវត្ថិភាពអគារសិក្សា និងការរៀបចំអគារសិក្សាធន់នឹងការប្រែប្រួលអាកាសធាតុ ........ ៩៦

ជំពូកទី៥ ការរៀបចំនីតិវិធីប្រតិបត្តិ បទដ្ឋានស្តង់ដា (SOP) និងលំហាត់សមយុទ្ធ ........ ១០៧

មេរៀនទី១៖ ការរៀបចំផែនការបន្តការសិក្សាក្នុងគ្រាមានអាសន្ន ........ ១០៨

មេរៀនទី២៖ ការតាមដានហានិភ័យ ........ ១១១

មេរៀនទី៣៖ ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដា SOP និងណែនាំលំហាត់សមយុទ្ធ ........ ១២០

មេរៀនទី៤៖ លំហាត់សមយុទ្ធ ........ ១៣១

ជំពូកទី៦ ការរៀបចំនិរន្តរភាពសាលារៀនមានសុវត្ថិភាព ........ ១៤៣

**មេរៀនទី១៖ ការបញ្ចូលសកម្មភាពផែនការសាលារៀនសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ សង្កាត់** .......... ១៤៤

**មេរៀនទី២៖ ការរៀបចំសារអប់រំ សម្រាប់សាលារៀនមានសុវត្ថិភាព** .......... ១៤៩

**ឧបសម្ព័ន្ធ** .......... ១៥៤

ជំពូកទី១ មេរៀនទី១ .......... ១៥៥

ជំពូកទី១ មេរៀនទី៣ .......... ១៥៥

ជំពូកទី១ មេរៀនទី៤ .......... ១៥៧

ជំពូកទី២ មេរៀនទី១ .......... ១៥៩

ជំពូកទី២ មេរៀនទី៣ .......... ១៦៣

ជំពូកទី៣ មេរៀនទី១ .......... ១៨៤

ជំពូកទី៣ មេរៀនទី៣ .......... ១៨៧

ជំពូកទី៣ មេរៀនទី៤ .......... ១៩៣

ជំពូកទី៣ មេរៀនទី៥ .......... ១៩៤

ជំពូកទី៤ មេរៀនទី១ .......... ១៩៦

ជំពូកទី៥ មេរៀនទី១ .......... ២១៨

ជំពូកទី៥ មេរៀនទី៣ .......... ២២៦

ជំពូកទី៥ មេរៀនទី៥ .......... ២៣៩

ជំពូកទី៦ មេរៀនទី១ .......... ២៤០

ជំពូកទី៦ មេរៀនទី២ .......... ២៤៣

**ឯកសារពិគ្រោះ** .......... ២៤៤

# ជំពូកទី១  ច្បាប់ បទដ្ឋានគតិយុត្ត និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀន

**សេចក្តីណែនាំ**

ជំពូកនេះ  យើងនឹងសិក្សាប្រធានបទអំពីច្បាប់  បទដ្ឋានគតិយុត្ត  និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀន។ នៅក្នុងជំពូកនេះ មានមេរៀនចំនួន៤ដែល បង្ហាញពី(១)ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងបទដ្ឋានគតិយុត្ត (២)ក្របខណ្ឌការងារសាលារៀនសុវត្ថិភាព(៣)នីតិវិធីទូទៅ និងដំណើរការនៃការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន(៤)ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន។

# មេរៀនទី១៖ ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងបទដ្ឋានគតិយុត្ត

## ១- វត្ថុបំណង

- ពណ៌នាបានពីច្បាប់ និងបទដ្ឋានគតិយុត្តនានាទាំងក្នុងតំបន់ និងក្នុងប្រទេសជាគោលសម្រាប់ការងារគ្រប់គ្រងនិង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- កំណត់បានពីទំនាក់ទំនងរវាងច្បាប់ និងបទដ្ឋានគតិយុត្តសំខាន់ៗដែលអាចយកមកធ្វើជាផែនទីបង្ហាញផ្លូវក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយដែលអាច ឆ្លើយតបវត្ថុបំណង ចក្ខុវិស័យនិងបេសកកម្ម ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយក៏ដូចការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយ តាមសាលារៀន។
- បង្កើនការយកចិត្តទុកដាក់ គោរព ប្រតិបត្តិច្បាប់ដែលបានកំណត់ និងជាទុនសម្រាប់តម្រង់ទិសអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុក្នុងជីវិតរស់នៅប្រកបដោយសុវត្ថិភាព។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

នៅក្នុងមេរៀននេះខ្លឹមសារដែលត្រូវសិក្សារួមមាន(១)-ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (២)- ក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយ និង(៣)-នានាភាពបទដ្ឋានគតិយុត្ត។

ការសិក្សាអំពីច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងបទដ្ឋានគតិយុត្តមួយចំនួន គឺដើម្បីឱ្យមានការយល់ដឹងជាមូលដ្ឋានសម្រាប់ការរៀបចំការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យអប់រំ ព្រមទាំងចូលរួមកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅតាមសាលារៀនប្រកបដោយគុណភាពនិងប្រសិទ្ធភាព។ ដូច្នេះ យើងត្រូវដឹងអំពីច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងបទដ្ឋានគតិយុត្តនានាដែលមានក្នុងមេរៀននេះជាមុនសិន។

### ២- ២ ពាក្យគន្លឹះ

**តើច្បាប់ជាអ្វី?**







ច្បាប់មានន័យច្រើនយ៉ាង

***១.តាមន័យទស្សនវិជ្ជា៖*** ច្បាប់គឺជាក្បួនសម្រាប់បំភ្លឺផ្លូវអេយុត្តិធម៌ ។ជាក្បួនសម្រាប់បង្ហាញការពិត ។ ជាក្បួនសម្រាប់ដឹកកកាយការមិនពិត ឬ ជាអាថ៌កំបាំងឱ្យស្តែងចេញមក។ ជាឧបករណ៍សម្រាប់គ្រប់គ្រងសង្គម ធ្វើឱ្យសង្គមមាន សណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អ។ ជាឧបករណ៍សម្រាប់បង្ហាញមាគ៌ាសន្តិភាពមិនអាចខ្វះបាន។

*២.តាមវចនានុក្រមសម្តេចព្រះសង្ឃរាជជួនណាត៖* ច្បាប់គឺជាសេចក្តីបញ្ញត្តិសម្រាប់ឱ្យប្រជារាស្ត្រប្រតិបត្តិ ជាក្បួន ឬ ជាវិន័យសម្រាប់ប្រដៅមនុស្សឱ្យប្រព្រឹត្តល្អ។

*៣.តាមន័យនីតិសាស្ត្រ៖* ច្បាប់គឺជាបញ្ញត្តិទាំងអស់សម្រាប់គ្រប់គ្រងរដ្ឋ រាប់ទាំងរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជាគោលនយោបាយ យុទ្ធសាស្ត្រ ទំនៀមទំលាប់ គោលការណ៍ទូទៅនៃនីតិ ។ ជាវិធានដែលអនុម័តដោយអង្គការនីតិប្បញ្ញត្តិ។ ជាសំណុំវិធានទាំងអស់ដែលគ្រប់គ្រងការរស់នៅក្នុងសង្គមធ្វើយ៉ាងណាឱ្យសង្គមមនុស្សទាំងមូលមានរបៀបរបប មានសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងរីកចម្រើន។

*-ក្របខណ្ឌសិនដាយ(២០១៥- ២០៣០)៖* គឺជាផែនការដែលពណ៌នាយ៉ាងលម្អិតអំពីការងារដែលតម្រូវឱ្យវិស័យនិងតួអង្គផ្សេងៗ បន្តវិធានការដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ(បន្តពីហ៊ីយ៉ូហ្គោ ២០០៥-២០១៥)។

### ២- ៣ ខ្លឹមសារមេរៀន

### ២.៣.១ ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

**តើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយជាអ្វី?**




ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១៥ មកម្លេះ។ ច្បាប់នេះ មាន១០ ជំពូក និង៤៨ មាត្រា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ ។ ព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។ ចុងក្រោយត្រូវបាន ព្រះមហាក្សត្រឡាយព្រហស្តលេខានិងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥។

យោងតាមន័យនីតិសាស្ត្រ "*ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ*" មានន័យប្រហាក់ប្រហែលទៅនឹង បញ្ញត្តិទាំងអស់សម្រាប់គ្រប់គ្រងរដ្ឋ រាប់ទាំងរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជា គោលនយោបាយ យុទ្ធសាស្ត្រ ទំនៀមទំលាប់ គោលការណ៍ទូទៅនៃនីតិ ។ ជាសំណុំវិធានទាំងអស់ដែលគ្រប់គ្រងការរស់នៅក្នុងសង្គមធ្វើយ៉ាងណាឱ្យសង្គមមនុស្សទាំងមូលមានរបៀបរបប មានសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និង ភាពរីកចម្រើន។ ដូច្នេះដើម្បីឱ្យសង្គមមនុស្សទាំងមូលមានរបៀបរបប មានសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និង ភាពរីកចម្រើន ដើម្បីសង្គមមានសុខសុវត្ថិភាពនិងគ្មានការរំខានដល់ការអភិវឌ្ឍ សេដ្ឋកិច្ច សង្គមនិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងសាលារៀនមានសុវត្ថិភាព យើងទាំងអស់គ្នា ត្រូវប្រតិបត្តិរួមគ្នាអនុវត្តច្បាប់ឱ្យបានហ្មត់ចត់។ ហេតុនេះហើយទើបជារាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ បង្កើតឱ្យមានច្បាប់និងបទដ្ឋានគតិយុទ្ធមួយចំនួនសម្រាប់អនុវត្ត។

**តើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយមានគោលបំណងដូចម្តេច?**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងគ្រោះមហន្តរាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានគោលដៅចំនួន ៣ គឺ (១) ត្រៀមបង្ការ បន្សាំ កាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយដែលបង្ក

ឡើងដោយធម្មជាតិ ឬមនុស្ស (២) ឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ និង (៣)ស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ គ្រោះមហន្តរាយ ។ ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការងារគ្រប់គ្រងគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិ ឬមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**តើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយមានមាត្រាសំខាន់ៗណាខ្លះដែលពាក់ព័ន្ធនឹងវិស័យអប់រំ?**

សម្រាប់អ្នកអនុវត្តទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសសាលារៀន ចំបាច់ត្រូវសិក្សាមាត្រាមួយចំនួនទាក់ទងនឹងវិស័យអប់រំ ដើម្បីជាប្រយោជន៍ក្នុងការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក៏ដូចជាផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន។

ការរៀបចំនិងមានផែនការទាំងនេះ មានសារៈសំខាន់បំផុត សម្រាប់សាលារៀនយកទៅអនុវត្ត ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលនឹងកើតមានឡើងនៅតាមសាលារៀន ដោយសារទឹកជំនន់ ភាពរាំងស្ងួត ខ្យល់ព្យុះ គ្រោះថ្នាក់ចរាចរណ៍ឬជំងឺឆ្លងផ្សេងៗជាដើម ។

ខាងក្រោមនេះ គឺជាមាត្រាសំខាន់ៗមួយចំនួនដែលសម្រាប់ជាជំនួយក្នុងការរៀបចំយន្តការគ្រប់គ្រងគ្រោះមហន្តរាយ និងការងារគ្រប់គ្រងគ្រោះមហន្តរាយៈ

១- ការរៀបចំរចនាសម្ព័ន្ធ ឬយន្តការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ***មាត្រា ៨*** *- ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួននិងត្រូវចាត់ឱ្យមន្ត្រីបង្គោលដើម្បីសម្របសម្រួលនិងធ្វើការប្រាស្រ័យទាក់ទងជាប្រចាំជាមួយអគ្គលេខាធិការដ្ឋាននៃគ- ជ- គ- ម ។*

២- ការរៀបចំផែនការកាត់បន្ថយ និងផែនការត្រៀមបម្រុងឆ្លើយតប

***-មាត្រា ១០*** *- សកម្មភាពត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ត្រូវ ផ្តោតលើដំណាក់កាល មុនពេលមានគ្រោះមហន្តរាយ ដោយស្រាវជ្រាវរកអត្តសញ្ញាណកើតចេញពីមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗកសាងលិខិតបទដ្ឋានគតិយុត្តិ និងវិធានការពង្រឹងសមត្ថភាពអប់រំការយល់ដឹងជាសាធារណៈនិងសហប្រតិបត្តិការ ក្នុងការកសាង និងអនុវត្តកម្មវិធីបង្ការមុខសញ្ញាគ្រោះថ្នាក់ ដែលបង្កើតឱ្យមានហានិភ័យរួមទាំងការ បន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។*

***-មាត្រា១១*** *- សកម្មភាពត្រៀមរៀបចំគ្រោះមហន្តរាយត្រូវផ្តោតលើដំណាក់កាល មុនពេលកើតមានគ្រោះមហន្តរាយដោយចាត់វិធានការរៀបចំ បង្កើតប្រព័ន្ធប្រកាសឱ្យដឹងមុន កសាងយុទ្ធសាស្ត្រ និងផែនការត្រៀមបម្រុងឆ្លើយតបស-ង្គ្រោះបន្ទាន់ ដើម្បីបន្ថយការបាត់បង់ ពីគ្រោះមហន្តរាយ នីតិវិធីប្រតិបត្តិការជាគំរូ ក្នុងកិច្ចប្រតិបត្តិការជំនួយគ្រោះមហន្តរាយ ធ្វើលំហាត់ទ្រឹស្តី លំហាត់សមយុទ្ធ។*

- ***មាត្រា១២*** *- សកម្មភាពឆ្លើយតបសង្គ្រោះបន្ទាន់ ត្រូវផ្តោតលើដំណាក់កាល ក្នុងពេលមានគ្រោះមហន្តរាយ ដោយចាត់វិធានការបន្ទាន់ ដឹកនាំសម្របសម្រួលបញ្ជារាល់ប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់ កៀរគរជំនួយមនុស្សធម៌ និងគ្រឿងបរិក្ខារមូលដ្ឋាន សម្ភារៈធនធានមនុស្ស និងហិរញ្ញវត្ថុ សម្រាប់ជំនួយគ្រោះមហន្តរាយ។*

*មាត្រា ១៣ - សកម្មភាពស្តារឡើងវិញ ត្រូវផ្តោតលើដំណាក់កាល ក្រោយពេលមានគ្រោះមហន្តរាយ ដោយធ្វើឲ្យប្រសើរឡើងវិញ និងការកសាងឡើងវិញ។*

**២.៣.២ នានាភាពបទដ្ឋានគតិយុត្ត**

**តើបទដ្ឋានគតិយុត្តសកល និងក្នុងតំបន់ទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយមានអ្វីខ្លះ?**

បទដ្ឋានគតិយុត្តិមួយចំនួនទៀតសកលនិងក្នុងតំបន់ដែលបាននិងកំពុងត្រូវបានយកមកអនុវត្ត នៅប្រទេសកម្ពុជាមានដូចជា៖

- ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយូហ្គោ (Hyogo)២០០៥-២០១៥
- ក្របខ័ណ្ឌសេនដាយ (Sendai)សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០១៥-២០៣០

បទដ្ឋានគតិយុត្តទាំងនេះ ជាមគ្គុទ្ទេសក៍បង្ហាញផ្លូវក្នុងការរួមគ្នាឆ្ពោះទៅកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និង មានសារៈសំខាន់បំផុតនៅក្នុងតំបន់។

***ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយូហ្គោ*** (The Hyogo Framework for Action) គឺជាផែនការសកលសម្រាប់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកំឡុង ឆ្នាំ ២០០៥ ដល់ ២០១៥ ។ ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនេះ ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៥ នៅក្នុងសន្និសីទពិភពលោកស្តីពីការកាត់បន្ថយគ្រោះមហន្តរាយ ដែលធ្វើឡើងនៅទីក្រុងកូបេ (Kobe) ទីក្រុងហ៊ីយូហ្គោ (Hyogo) ប្រទេសជប៉ុន។ គោលបំណង ក្របខ័ណ្ឌការងារនេះ គឺដើម្បីកាត់បន្ថយការខាតបង់យ៉ាងខ្លាំងពីគ្រោះមហន្តរាយ លើជីវិត សង្គម សេដ្ឋកិច្ច ទ្រព្យសម្បត្តិបរិស្ថាននៃសហគមន៍ និងប្រទេសត្រឹមឆ្នាំ ២០១៥។

ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយូហ្គោ បានកំណត់អាទិភាពចំនួនប្រាំសម្រាប់ធ្វើសកម្មភាព៖

- ធានាថាការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជាអាទិភាពថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែលជាស្ថាប័នរឹងមាំសម្រាប់ការអនុវត្ត
- កំណត់អត្តសញ្ញាណ វាយតម្លៃ និងតាមដានហានិភ័យគ្រោះមហន្តរាយ និងបង្កើនប្រព័ន្ធប្រកាសអាសន្នឱ្យដឹងមុន
- ប្រើប្រាស់ចំណេះដឹង ការច្នៃប្រឌិត និងការអប់រំ ដើម្បីកសាងវប្បធម៌សុវត្ថិភាព និងភាពធន់នៅគ្រប់កម្រិត
- កាត់បន្ថយកត្តាហានិភ័យមូលដ្ឋាន
- ពង្រឹងការត្រៀមបំរុងគ្រោះមហន្តរាយសម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត

ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយូហ្គោ បានជំរុញឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍស្ថាប័ន គោលនយោបាយ និងច្បាប់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ អ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់បានពង្រឹងសមត្ថភាពរបស់ពួកគេសម្រាប់ការវាយតម្លៃហានិភ័យ និងការកំណត់អត្តសញ្ញាណ ការត្រៀមលក្ខណៈសម្រាប់គ្រោះមហន្តរាយ ការឆ្លើយតប និងការប្រកាសអាសន្នឱ្យដឹងមុន។

ទោះជាយ៉ាងណាក៏ដោយ វឌ្ឍនភាពឆ្ពោះទៅរកការគ្រប់គ្រងអ្នកបើកបរហានិភ័យគ្រោះមហន្តរាយនៅមានកម្រិតនៅក្នុងប្រទេសភាគច្រើន។ ជាទូទៅ ក្របខ័ណ្ឌស្ថាប័ន នីតិប្បញ្ញត្តិ និងគោលនយោបាយ មិនបានជួយសម្រួលគ្រប់គ្រាន់ក្នុងការពិចារណាបញ្ចូលហានិភ័យគ្រោះមហន្តរាយទៅក្នុងការសម្រេចចិត្តនានាក្នុងការងារអភិវឌ្ឍន៍។ អាស្រ័យហេតុនេះ ការប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ និងទាបបានកើនឡើងលឿនជាងភាពងាយរងគ្រោះបានថយចុះ។ ហានិភ័យថ្មីបានបង្កើនលឿនជាងហានិភ័យមានស្រាប់ដែលត្រូវបានកាត់បន្ថយ។

នៅចុងបញ្ចប់នៃការអនុវត្ត ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយហ៊ីយូហ្គោ រដ្ឋសមាជិកបានទទួលស្គាល់ថាកិច្ចខិតខំប្រឹងប្រែងមិនបាននាំឱ្យមានការកាត់បន្ថយការខាតបង់មូលដ្ឋានសម្ភារៈ និងផលប៉ះពាល់សេដ្ឋកិច្ចទេ។ ពួកគេបានសន្និដ្ឋានថា ការផ្តោតការយកចិត្តទុកដាក់របស់ជាតិ និងអន្តរជាតិត្រូវតែផ្លាស់ប្តូរពីការការពារការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចទល់នឹងការប៉ះទង្គិចពីខាងក្រៅ ទៅជាការធ្វើឱ្យមានកំណើន និងការអភិវឌ្ឍន៍ ដើម្បីគ្រប់គ្រងហានិភ័យឱ្យបានគ្រប់ជ្រុងជ្រោយ។

ការសន្និដ្ឋាននេះបានបង្កើតមូលដ្ឋានសម្រាប់អភិវឌ្ឍន៍ក្របខ័ណ្ឌការងារសេនដាយ (Sendai) ដែលជាឧបករណ៍ស្នងបន្តពីក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយូហ្គោ និងត្រូវបានអនុម័តក្នុងឆ្នាំ ២០១៥ ។

***ក្របខ័ណ្ឌសេនដាយ (Sendai)*** សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០១៥-២០៣០ គឺជាក្របខ័ណ្ឌគោលនយោបាយសកលដែលត្រូវបានអនុម័តនៅក្នុងសន្និសីទពិភពលោកលើកទី ៣ របស់អង្គការសហប្រជាជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៤ ដល់ ១៨ ខែមីនា ឆ្នាំ ២០១៥ នៅទីក្រុង សេនដាយ ខេត្តមីយ៉ាហ្គី ប្រទេសជប៉ុន ។

ក្របខណ្ឌសេនដាយ គឺជាផែនការដែលពណ៌នាយ៉ាងលម្អិតពីការងារដែលតម្រូវ ឱ្យវិស័យនិងតួអង្គផ្សេងៗបន្តវិធានការដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ ក្របខណ្ឌសកម្មភាពការងារនេះ ត្រូវបានរៀបចំ និងព្រមព្រៀងគ្នាជាមួយដៃគូជាច្រើន ដែលមានតួនាទីចាំបាច់ក្នុងការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ ដែលមានដូចជា រាជរដ្ឋាភិបាល ភ្នាក់ងារអន្តរជាតិ អ្នកជំនាញការផ្នែកគ្រោះមហន្តរាយ និងអ្នកដទៃទៀត ដោយរៀបចំឱ្យមាន ប្រព័ន្ធរួមមួយក្នុងការសម្របសម្រួល។ ក្របខណ្ឌសកម្មភាពការងារនេះ

គូសបញ្ជាក់ពីផែនការ សកម្មភាពជាអាទិភាព ចំនួន៤ ដែលផ្តល់ជាគោលការណ៍ណែនាំ និងមធ្យោបាយជាក់ស្តែង ក្នុងការសម្រេចបាននូវភាពធន់ទ្រាំនឹងគ្រោះមហន្តរាយ។

គោលបំណងក្របខណ្ឌសកម្មភាពការងារសេនដាយគឺដើម្បីកសាងនូវភាពធន់ទ្រាំនៃប្រជាជាតិ និងសហគមន៍ទប់ទល់នឹងគ្រោះមហន្តរាយ ។ សំដៅកាត់បន្ថយ ការខាតបង់ក្នុងកម្រិតអតិបរមាដល់អាយុជីវិត ធនធាន សង្គម សេដ្ឋកិច្ច និងបរិស្ថាន នៅពេលមានគ្រោះមហន្តរាយកើតឡើងឱ្យបានសម្រេចនៅត្រឹមឆ្នាំ ២០៣០ ។ សកម្មភាពជាអាទិភាពទាំងនោះ ត្រូវបានយកចិត្តទុកដាក់គិតគូរ ផ្អែកលើបទពិសោធន៍ ក្របខណ្ឌសកម្មភាពការងារយូហ្គោ ២០១៥ និងបន្តគោលដៅ លទ្ធផលរំពឹងទុក ជាការចាំបាច់សម្រាប់សកម្មភាពដែលផ្តោតលើគ្រប់វិស័យទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តំបន់ និងកម្រិតសកលលោក នៅក្នុងវិស័យអាទិភាព៤ ដូចខាងក្រោម៖

អាទិភាពទី១៖ ការយល់ដឹងពីហានិភ័យគ្រោះមហន្តរាយ

អាទិភាពទី២៖ ការពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយ

អាទិភាពទី៣៖ ការវិនិយោគនៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់ភាពធន់

អាទិភាពទី៤៖ បង្កើនការត្រៀមបង្ការ សម្រាប់ឆ្លើយតបគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាពនិង "ការស្ថាបនាឡើងវិញឱ្យប្រសើរជាងមុន" ក្នុងការស្តារឡើងវិញនីតិសម្បទានកម្ម និងស្ថាបនាឡើងវិញ។

**តើបទដ្ឋានគតិយុត្ត ឬសេចក្តីណែនាំអនុវត្តនៅកម្ពុជាទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយមានអ្វីខ្លះ?**

លើសពីបទដ្ឋានគតិយុត្តសកល និងក្នុងតំបន់ យើងមានបទដ្ឋានគតិយុត្ត ឬសេចក្តីណែនាំនៅកម្ពុជាទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ដែលជាមគ្គុទ្ទេសក៍បង្ហាញផ្លូវក្នុងការរួមគ្នាឆ្ពោះទៅការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ក្នុងនោះរួមមាន៖

- គោលនយោបាយកម្មវិធីសាលាកុមារមេត្រី ជាពិសេសឯកសារកម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ អំពី«សាលារៀនសុវត្ថិភាព» ផ្តោតលើការលើកកម្ពស់សុខភាព សុវត្ថិភាព និងការការពារកុមារនៅក្នុងសាលារៀន។
- ក្របខណ្ឌការងារសាលារៀនសុវត្ថិភាព។

(ខ្លឹមសារលំអិតនៃក្របខណ្ឌការងារសាលារៀនសុវត្ថិភាព នឹងបង្ហាញនៅមេរៀនទី៣ នៃជំពូក១)

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១៥ និងមាន១០ ជំពូក និង៤៨ មាត្រា ។
- ការរៀបចំរចនាសម្ព័ន្ធ ៖ ស្ថាប័នរដ្ឋ រួមទាំងសាលារៀនត្រូវមានការរៀបចំរចនាសម្ព័ន្ធឬយន្តការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់សាលាអនុវត្ត ។

- សាលារៀនតម្រូវឱ្យមានការរៀបចំផែនការកាត់បន្ថយ និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយ។
- ការរៀបចំផែនការកាត់បន្ថយ និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយនេះ នឹងមាន (ក) សកម្មភាពត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ (ខ)សកម្មភាពត្រៀមរៀបចំគ្រោះមហន្តរាយ (គ) សកម្មភាពឆ្លើយតបសង្គ្រោះបន្ទាន់ និង (ឃ) សកម្មភាពស្តារឡើងវិញ។
- បទដ្ឋានគតិយុត្តសកល និងក្នុងតំបន់ទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយរួមមាន (ក)
- ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយូហ្គោ (Hyogo) ២០០៥-២០១៥ ដែលបានកំណត់អាទិភាពចំនួនប្រាំសម្រាប់ធ្វើសកម្មភាព និង (ខ) ក្របខ័ណ្ឌសេនដាយ (Sendai) សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ ដែលបានកំណត់វិស័យអាទិភាពចំនួន៤។
- ក្រៅពីច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងអប់រំ យុវជន និងកីឡា មានឯកសារគតិយុត្ត ឬសេចក្តីណែនាំអនុវត្តទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយដូចជា គោលនយោបាយកម្មវិធីសាលាកុមារមេត្រី ដែលមានឯកសារកម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ អំពី«សាលារៀនសុវត្ថិភាព» ផ្តោតលើការលើកកម្ពស់សុខភាព សុវត្ថិភាព និងការការពារកុមារនៅក្នុងសាលារៀន និង ក្របខណ្ឌការងារសាលារៀនសុវត្ថិភាព។

**២-៥ ឯកសារសិក្សាបន្ថែម**

ឯកសារសិក្សាគួរបន្ថែមពាក់ព័ន្ធនឹងមេរៀននេះរួមមាន៖

- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១៥ ( https://data.opendevelopmentcambodia.net/km/laws_record/law-on-disaster-management/resource/2ffa4e48-ae42-41e7-8131-f512dc049967 )
- ឯកសារក្របខ័ណ្ឌសេនដាយ ២០១៥- ២០៣០
- ក្របខ័ណ្ឌសាលារៀនសុវត្ថិភាព

**២- ៦ ការអនុវត្ត**

បន្ទាប់ពីរៀនមេរៀននេះរួច៖

១- តើអ្នក រៀនបានចំណុចសំខាន់ៗអ្វីខ្លះពីមេរៀននេះ ?

២- តើអ្នកចែករំលែកចំណេះដឹងពីមេរៀននេះ ដល់អ្នកអ្នកពាក់ព័ន្ធក្នុងសាលារៀន ឬស្ថាប័នអប់រំ តាមវិធីណាដើម្បីឱ្យពួកគាត់យល់អំពីខ្លឹមសារច្បាប់ បទដ្ឋានគតិយុត្តនានាឱ្យបានច្បាស់លាស់ សម្រាប់បន្ត និងចូលរួមកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ?

៣- តើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ បង្កើតឡើងក្នុងគោលបំណងអ្វី ?

៤- តើនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ មានមាត្រាណាខ្លះដែលអ្នកយល់ថាមានសារៈសំខាន់សម្រាប់ការងាររៀបចំផែនការនិងការឆ្លើយតបគ្រោះមហន្តរាយក្នុងវិស័យអប់រំឬសាលារៀនរបស់អ្នក? ចូររៀបរាប់បង្ហាញ។

៦- តើក្របខណ្ឌសេនដាយ ជាអ្វី? បង្កើតឡើងក្នុងគោលបំណងអ្វី? មានគោលដៅអ្វីខ្លះ ដើម្បីសម្រេចបាននូវភាពធន់និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅឆ្នាំ២០៣០?

៧- តើច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួនដែលបានសិក្សារួចមកនេះមានសារៈសំខាន់អ្វីខ្លះចំពោះការងារគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀន?

# មេរៀនទី២៖ ក្របខណ្ឌសាលារៀនសុវត្ថិភាព

## ១- វត្ថុបំណង

- ប្រាប់បានពីធាតុផ្សំសំខាន់ៗនៃក្របខណ្ឌសាលារៀនសុវត្ថិភាព រួមទាំងគោលបំណង លទ្ធផលរំពឹងទុកនិងទម្រង់គ្រោះថ្នាក់ និងហានិភ័យនៅតាមសាលារៀន ។
- អនុវត្តបានគោលការណ៍ និងយុទ្ធសាស្ត្រសាលារៀនសុវត្ថិភាពក្នុងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅតាមសាលារៀន ។
- ជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌសាលារៀនសុវត្ថិភាព ដោយកៀរគរអ្នកពាក់ព័ន្ធចូលរួមពង្រឹង និងពង្រីកសាលារៀនសុវត្ថិភាព។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ នឹងបង្ហាញពី *ក្របខណ្ឌការងារសាលារៀនសុវត្ថិភាព* ដែលក្នុងនោះយើងនឹងសិក្សាអំពីអត្ថន័យ គោលបំណង ទម្រង់គ្រោះថ្នាក់ និងហានិភ័យ សមាសធាតុគន្លឹះសំខាន់ៗ និងការផ្សារភ្ជាប់ទៅនឹងក្របខណ្ឌគតិយុត្ត និងគោលនយោបាយសំខាន់ៗរបស់ថ្នាក់ជាតិ-អន្តរជាតិ។

### ២-២ ពាក្យគន្លឹះ

- *វេទនាសម្ព័ន្ធសាលារៀនសុវត្ថិភាព* គឺជាការរៀបចំ និងធ្វើឱ្យសម្រេចនូវប្រព័ន្ធ និងគោលនយោបាយ បរិក្ខារសិក្សាសុវត្ថិភាព ការគ្រប់គ្រងសាលារៀនសុវត្ថិភាព និងការបន្តការអប់រំ ការអប់រំការកាត់បន្ថយហានិភ័យ និងភាពធន់នៅតាមសាលារៀន។
- *សាលារៀនមានសុវត្ថិភាព* សំដៅដល់កន្លែងសិក្សាដែលកុមារនិងមនុស្សពេញវ័យអាចរំពឹងទុកថាពួកគេនឹងមិនត្រូវបានរងរបួស ឬស្លាប់នៅលើបរិវេណសាលា ហើយសិស្សទាំងនោះទទួលបាននូវសិទ្ធិក្នុងការអប់រំជាមូលដ្ឋានប្រកប ដោយគុណភាពនិងមិនគិតថ្លៃ ហើយមិនត្រូវបានគំរាមកំហែងពីមុខសញ្ញាគ្រោះថ្នាក់ដែលបានដឹង ឬរំពឹងទុកជាមុន។

### ២- ៣ ខ្លឹមសារមេរៀន

#### ២-៣-១ អត្ថន័យនៃក្របខណ្ឌការងារសាលារៀនសុវត្ថិភាព

*ក្របខណ្ឌការងារសាលារៀនសុវត្ថិភាព* គឺជាគោលនយោបាយនៃក្របខណ្ឌការងារថ្នាក់ពិភពលោក ថ្នាក់តំបន់ និងថ្នាក់ជាតិ ដែលត្រូវបានទទួលស្គាល់ដោយ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចខំប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងបញ្ហាសុវត្ថិភាពរបស់សាលារៀនដែលជួបប្រទះ។ ជាពិសេស ជាឯកសារក្របខណ្ឌគតិយុត្ត ដើម្បីរួមចំណែកការងារសម្រេចគោលនយោបាយកម្មវិធីសាលាកុមមាត្រី និងផែនការយុទ្ធសាស្ត្រអប់រំ។

កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ អំពី«សាលារៀនសុវត្ថិភាព» ផ្តោតលើ ការលើកកម្ពស់សុខភាព សុវត្ថិភាព និងការការពារកុមារនៅក្នុងសាលារៀន។ ឯកសារគាំទ្រការអនុវត្ត ស្តីពី «សាលារៀនសុវត្ថិ

ភាព» ត្រូវបានកសាងឡើងផ្អែកលើគំនិតផ្តួចផ្តើម នៃគោលនយោបាយកម្មវិធីសាលាកុមារមេត្រី និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយដោយរួមបញ្ចូលទាំងការពង្រឹងសមត្ថភាពនៅក្នុងសាលារៀន តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹង ស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយដល់ក្រុមប្រឹក្សាកុមារ គណៈកម្មការទ្រទ្រង់សាលា គ្រូបង្រៀន និងការបញ្ចូលការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិធីសិក្សា។

### ២-៣-២ គោលបំណង និង លទ្ធផលរំពឹងទុកនៃក្របខណ្ឌសាលារៀនសុវត្ថិភាព

**តើក្របខណ្ឌសាលារៀនសុវត្ថិភាពមានគោលបំណងអ្វី?**

គោលបំណងនៃក្របខណ្ឌសាលារៀនសុវត្ថិភាព គឺដើម្បីធានាសន្តិសុខ និងសុវត្ថិភាព កុមារ អ្នកអប់រំ និងបុគ្គលិកដទៃទៀតពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុង និងជុំវិញសាលារៀនដែលពិពណ៌នាលម្អិត នោះដូចខាងក្រោម៖

(១) ការពារអ្នកសិក្សា អ្នកអប់រំ និងបុគ្គលិកដទៃទៀតពីការស្លាប់ របួស អំពើហិង្សា និងគ្រោះថ្នាក់នៅក្នុងសាលារៀន និងកន្លែងសិក្សាផ្សេងទៀត។

(២) ផ្តល់ការណែនាំក្នុងការរៀបចំផែនការសម្រាប់ការអប់រំ និងការការពារកុមារឱ្យមានជាប់ជាបន្ត និងកាត់បន្ថយការរំខានផ្សេងៗ ដល់ការសិក្សារបស់កុមារ ពេលដែលមានភាពតក់ស្លុត ភាពតានតឹង គ្រោះថ្នាក់ និងការគំរាមកំហែងគ្រប់ប្រភេទ។

(៣) លើកកម្ពស់ចំណេះដឹង និងជំនាញរបស់សិស្ស និង អ្នកមានកាតព្វកិច្ច ដើម្បីរួមចំណែកកាត់បន្ថយហានិភ័យ ការកសាងភាពធន់ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

**លទ្ធផលរំពឹងទុក**

ដើម្បីឆ្លើយតបគោលបំណងដ៏សំខាន់នៃការអនុវត្តក្របខណ្ឌសាលារៀនសុវត្ថិភាព និងធានាបាននូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមសាលារៀន យើងរំពឹងថា៖

១- កុមារ និងបុគ្គលិកអប់រំទាំងអស់ទទួលបានសុវត្ថិភាពនៅក្នុងសាលារៀន និងនៅតាមផ្លូវទៅសាលារៀន បានធ្វើឱ្យប្រសើរឡើង

២- ប្រព័ន្ធភាពធន់របស់វិស័យអប់រំត្រូវបានពង្រឹងឱ្យឆ្លើយតបនឹងមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ៖

- បង្កើតប្រព័ន្ធនិងអនុវត្តគោលនយោបាយឱ្យបានគ្រប់ជ្រុងជ្រោយនិងគោលការណ៍ អាទិភាពនៅគ្រប់កម្រិតដើម្បីលើកកម្ពស់សុវត្ថិភាពកុមារ
- ការវិនិយោគលើភាពធន់ក្នុងវិស័យអប់រំ ជាយន្តការរក្សាសុវត្ថិភាពនិងកាបន្ថយចំណាយ លើការស្តារឡើងវិញ
- យន្តការសាលារៀនសុវត្ថិភាព និងដំណើរគ្រប់គ្រងបន្តការអប់រំ ត្រូវបានអនុវត្តនៅកម្រិតសាលារៀនការកាត់បន្ថយហានិភ័យ និងភាពធន់ក្នុងវិស័យអប់រំត្រូវបានធ្វើឱ្យប្រសើរឡើង

- អ្នកពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលារៀន និងអាជ្ញាធរបានពង្រឹងសមត្ថភាពលើការកាត់បន្ថយគ្រោះមហន្តរាយ ក្នុងសាលារៀន និងលើកកម្ពស់សុវត្ថិភាពសម្រាប់កុមារ។

៣- ឧបសគ្គផ្នែកអប់រំដែលកត្តាងាយរងគ្រោះបំផុតសម្រាប់សិស្សានុសិស្ស ដែលបណ្តាលមកពីអាយុ ភេទ ពិការភាពនិងបរិយាបន្ន ត្រូវបានដោះស្រាយ និងធ្វើឱ្យមានភាពកាន់តែប្រសើរឡើង

៤- កិច្ចសហប្រតិបត្តិការអន្តរអ្នកពាក់ព័ន្ធនិងការកៀរគរធនធានសម្រាប់អនុវត្តសកម្មភាពសាលារៀនសុវត្ថិភាពមាន

**២-៣-៣ ទម្រង់គ្រោះថ្នាក់ និងហានិភ័យ**

ទម្រង់គ្រោះថ្នាក់ និងហានិភ័យរួមមាន៖

- ការប្រែប្រួលអាកាសធាតុ និងធម្មជាតិ ( ទឹកជំនន់ គ្រោះរាំងស្ងួត រលកកំដៅ ខ្យល់ព្យុះ ភ្លើងឆេះព្រៃ...)
- បច្ចេកវិជ្ជា (ការគំរាមកំហែងពី ជីវសាស្ត្រ វិទ្យុសកម្ម និងគីមី ដូចជា ធាតុគ្រោះថ្នាក់ និងកាកសំណល់ ថ្នាំសម្លាប់សត្វល្អិត ថ្នាំលាប ...)
- ជីវសាស្ត្រ និងសុខភាព (ជំងឺរាតត្បាត អាហារមិនមានសុវត្ថិភាព ទឹកមិនគ្រប់គ្រាន់ ការបំពុលខ្យល់ ការបំពុលទឹក...)
- ជម្លោះ និងហិង្សា ( ការប្រើអំពើហិង្សាលើរាងកាយ និងធ្វើឱ្យអាម៉ាស់ ការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ ការគំរាមកំហែងតាមអ៊ីនធឺណិត អំពើហិង្សាក្រុមក្មេងទំនើង ជម្លោះស៊ីវិល និងយោធា ការវាយប្រហារលើសាលារៀន សិស្ស និងបុគ្គលិកអប់រំ...)
- គ្រោះថ្នាក់ និងការគំរាមកំហែងប្រចាំថ្ងៃ (គ្រោះថ្នាក់ចរាចរណ៍ លង់ទឹក គ្រោះថ្នាក់នៅសួនកុមារ ការបង្ខំឱ្យប្រើប្រាស់គ្រឿងស្រវឹង និង សារធាតុញៀនផ្លូវដែលមិនមានសុវត្ថិភាពទៅកាន់សាលារៀន ពលកម្មកុមារ...)

សម្រាប់អ្នកអប់រំ វាមានសារៈសំខាន់ក្នុងការចាត់វិធានការឆ្លើយគ្រប់ទម្រង់គ្រោះថ្នាក់ទាំងអស់ ដែលបណ្តាលមកពីធម្មជាតិ បច្ចេកវិទ្យា ជីវសាស្ត្រ សុខភាព ជម្លោះ អំពើហិង្សា និងគ្រោះថ្នាក់ប្រចាំថ្ងៃ។

**២-៣-៤ សមាសធាតុគន្លឹះសំខាន់ៗ នៃក្របខណ្ឌសាលារៀនសុវត្ថិភាព**

**តើក្របខណ្ឌសាលារៀនសុវត្ថិភាពមានសមាសធាតុអ្វីខ្លះ ?**

សមាសធាតុគន្លឹះសំខាន់ៗ ចំនួន៤ នៃសាលារៀនសុវត្ថិភាព គឺរួមបញ្ចូលទាំង មូលដ្ឋានគ្រឹះពាក់ព័ន្ធ និងសសរស្តម្ភចំនួន៣។ សមាសធាតុនីមួយៗបានបង្ហាញ ពីវិសាលភាពជាក់លាក់ អ្នកពាក់ពន្ធ័ការទទួលខុសត្រូវ និងយុទ្ធសាស្ត្រ។ ខាងក្រោមនេះ គឺជាការបង្ហាញលម្អិតសមាសធាតុគន្លឹះសំខាន់ៗចំនួន៤ នៃសាលារៀនសុវត្ថិភាព៖

**មូលដ្ឋានគ្រឹះ៖ ធ្វើឱ្យសម្រេចនូវប្រព័ន្ធ និងគោលនយោបាយ**

**សសរស្តម្ភទី១៖ បរិស្ថានសិក្សាសុវត្ថិភាព**

**សសរស្តម្ភទី២៖ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្តការសិក្សា**

**សសរស្តម្ភទី៣៖ ការអប់រំស្ដីពីការកាត់បន្ថយហានិភ័យ និងភាពធន់**




*(ប្រភព៖ ឯកសារគាំទ្រការអនុវត្តក្របខណ្ឌការងារសាលារៀនសុវត្ថិភាពរបស់ក្រសួង អយក)*

**មូលដ្ឋានគ្រឹះ ៖ ធ្វើឱ្យសម្រេចនូវប្រព័ន្ធ និងគោលនយោបាយ**

មូលដ្ឋានគ្រឹះនៃការអនុវត្តក្របខណ្ឌការងារសាលារៀនសុវត្ថិភាព ផ្តោតលើការពង្រឹងភាពធន់របស់ប្រព័ន្ធអប់រំ។ មូលដ្ឋានគ្រឹះនេះរួមបញ្ចូលទាំងការធ្វើឱ្យសម្រេចនូវប្រព័ន្ធ និងគោលនយោបាយដែលមានគោលបំណងការពារសុវត្ថិភាព សុខភាព និងសុខុមាលភាពនៃសហគមន៍សាលារៀនទាំងមូល ព្រមទាំងធ្វើអន្តរាគមន៍ឱ្យមានការអប់រំជាបន្តប្រកបដោយប្រសិទ្ធភាព ការពារការវិនិយោគលើវិស័យអប់រំ និងលើកកម្ពស់វប្បធម៌សុវត្ថិភាព និងភាពធន់។ ដំណោះស្រាយផ្នែកគោលនយោបាយ និងផែនការស្របតាមហានិភ័យ ត្រូវបានប្រើដើម្បីកែលម្អសមធម៌ ការពារ និងកាត់បន្ថយហានិភ័យ និងបង្កើនសមត្ថភាពដល់អ្នកពាក់ព័ន្ធរបស់សាលារៀន។

**សសរស្តម្ភទី១ ៖ បរិស្ថានសិក្សាសុវត្ថិភាព**

បរិស្ថានសិក្សាសុវត្ថិភាពគឺដោះស្រាយបញ្ហាទាំងឡាយ ដែលទាក់ទងនឹងបរិក្ខារសិក្សាថ្មី និងមានស្រាប់រួមទាំងការកសាង ការដំឡើងឱ្យមានមានសុវត្ថិភាព មានភាពធន់ និងបៃតងជាងមុន។ សម្រាប់បរិក្ខារសិក្សាថ្មី គឺផ្តោតលើការជ្រើសរើសទីតាំង ការរចនាគ្រឿងបរិក្ខារសិក្សា និងការសាងសង់ ដើម្បីធានាឱ្យសាលារៀនមានសុវត្ថិភាព និង ភាពធន់ពីការគំរាមកំហែងដោយធម្មជាតិ ជីវសាស្ត្រ គីមី និងសង្គម ដើម្បីបង្កើនគុណភាពនៃកន្លែងសិក្សា និងការពារសុខភាព និងសុខុមាលភាពរបស់អ្នកប្រើប្រាស់ទាំងអស់។ ចំពោះបរិក្ខារសិក្សាដែលមានស្រាប់ គឺផ្តោតលើការកំណត់មុខសញ្ញា និងផ្តល់អាទិភាពនៃបរិក្ខារដែលត្រូវជួសជុល កែលម្អឡើងវិញ ការជំនួស ឬការផ្លាស់ប្តូរទីតាំង ព្រមទាំងការថែទាំបរិក្ខារបរិស្ថានសិក្សា។

សសរស្តម្ភនេះ គាំទ្រដល់គោលដៅនៃប្រព័ន្ធអប់រំដែលមានភាពធន់ និងនិរន្តរភាពបរិស្ថាន។ សម្ភាររូបវន្តសាលារៀនមានសុវត្ថិភាព និងងាយស្រួលចូលប្រើបាស់រួមមាន រចនាសម្ព័ន្ធនៃអគាររឹងមាំ គ្រឿងបំពាក់ផ្សេងៗនៃអគារមានសុវត្ថិភាព ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារក្នុងទីធ្លាសាលារៀនមានធន់ និងបរិយាបន្ន (រួមមានផ្លូវធ្វើដំណើរមានសុវត្ថិភាព លទ្ធភាពចូលប្រើប្រាស់ពីអ្នកមានពិការភាព និងយេនឌ័រ មានគ្រឿងបរិក្ខារទឹកស្អាត និងអនាម័យគ្រប់គ្រាន់ មានវិធីសាស្ត្រជម្លៀសប្រកបដោយប្រសិទ្ធភាព មានខ្យល់ចេញចូលគ្រប់គ្រាន់ជាដើម) ព្រមទាំងមានឧបករណ៍ និងសេវាកម្មដើម្បីគាំទ្រដល់សុវត្ថិភាព និងការរៀនសូត្រជាប់ជាបន្តដល់អ្នកសិក្សា (រួមទាំងប្រព័ន្ធប្រកាសអាសន្នជាមុន។)។

**តើមានធាតុសំខាន់ៗអ្វីខ្លះដើម្បីឱ្យបរិស្ថានសិក្សាមានសុវត្ថិភាព?**

ជាតុសំខាន់ៗដើម្បីឱ្យបរិស្ថានសិក្សាមានសុវត្ថិភាពមានដូចជា៖

- សំណង់អគារសាងសង់ថ្មីគួរតែធន់ទ្រាំនឹងគ្រោះមហន្តរាយ(ជ្រើសរើសទីតាំង ប្លង់សំណង់ លទ្ធកម្មសម្ភារៈ ការត្រួតពិនិត្យការសាងសង់ និងសវនកម្មហិរញ្ញវត្ថុ ការថែទាំសាលារៀន)
- សំណង់អគារមានស្រាប់ដែលត្រូវជួសជុល ឬ កែលម្អឡើងវិញគួរកំណត់មុខសញ្ញា និងផ្តល់អាទិភាព ព្រមទាំងមានការថែទាំបានល្អ

- កំណត់មុខសញ្ញាគ្រោះថ្នាក់ក្នុងនិងជុំវិញសាលារៀនឱ្យនៅកម្រិតទាបបំផុត
- ការយកចិត្តទុកដាក់លើសុវត្ថិភាពក្នុងការធ្វើដំណើរទៅមកសាលារៀនរបស់សិស្ស
- ការលើកកម្ពស់អនាម័យនិងទឹកស្អាតក្នុងសាលារៀនការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ
- រៀបចំឱ្យមានការអប់រំពីអនាម័យ ការការពារនិងគ្រប់គ្រងជំងឺឆ្លងផ្សេងៗ
- ការយកចិត្តទុកដាក់លើអាហារូបត្ថម្ភ សុវត្ថិភាព និងសុខុមាលភាពចំណីអាហារ
- វិធានការការពារកុមារ ជាពិសេសកុមារដែលមានពិការភាពនិងយេនឌ័រ។
- បង្កើនបរិស្ថានបៃតង និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

## សសរស្តម្ភទី២ ៖ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្តការសិក្សា

ការគ្រប់គ្រងគ្រោះមហន្តរាយនៅសាលារៀន (ការគ្រប់គ្រងសុវត្ថិភាពសាលារៀន) គឺមានការរៀបចំផែនការប្រកបដោយសមធម៌សម្រាប់សុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ ដែលធានាបាននូវការបន្តការអប់រំ ឆ្លើយតបនឹងគ្រប់ទម្រង់គ្រាអាសន្ន និងហានិភ័យ ចំពោះកុមារ និងបុគ្គលិកក្នុងវិស័យអប់រំ។ ការផ្តោតសំខាន់នៃផ្នែកនេះ គឺជាការធ្វើឱ្យប្រាកដថា អ្នកពាក់ព័ន្ធនៃ សាលារៀន និង សហគមន៍ មានសមត្ថភាពក្នុងការប៉ាន់ប្រមាណហានិភ័យ ទប់ទល់បន្ថយផលប៉ះពាល់ សម្របខ្លួន និង ផ្លាស់ប្តូរបង្កីតថ្មីស្ថានភាពប្រែប្រួល សម្រាប់ឱ្យមានភាពធន់ ដោយមានការចូលរួម និងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់។ នេះរាប់បញ្ចូលទាំងដំណើរការវាយតម្លៃហានិភ័យគ្រប់ជ្រុងជ្រោយ ការធ្វើផែនការ ការពារ និងកាត់បន្ថយហានិភ័យ ការត្រៀមឆ្លើយតប និងការស្តារ និងកសាងត្រឡប់ ឡើងវិញកាន់តែប្រសើរ។ ការគ្រប់គ្រងសាលារៀនសុវត្ថិភាព និងការបន្តការសិក្សា នឹងធ្វើឱ្យប្រាកដថា គណៈគ្រប់គ្រងសាលារៀន គណៈកម្មកាគ្រប់គ្រងសាលារៀន គ្រូបង្រៀន កុមារ និង សហគមន៍ មានការចូលរួមយ៉ាងសកម្មក្នុងការកំណត់ និង គ្រប់គ្រងហានិភ័យ ការធ្វើផែនការបន្តការសិក្សាគ្រាមានអាសន្ន និងអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាសាលារៀនសុវត្ថិភាព ឆ្លើយតបទៅនឹងផែនការគ្រាមានអាសន្នដោយមានប្រសិទ្ធភាពទៅតាមពេលវេលា។

**តើមានធាតុសំខាន់ៗអ្វីខ្លះក្នុងការគ្រប់គ្រងគ្រោះមហន្តរាយនៅសាលារៀន និងការបន្តការសិក្សា?**

ធាតុសំខាន់ៗក្នុងការគ្រប់គ្រងគ្រោះមហន្តរាយនៅសាលារៀន និងការបន្តការសិក្សារួមមាន៖

- បង្កើតគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយក្នុងសាលារៀន
- បង្ហាញពីតួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន
- កំណត់មុខសញ្ញាគ្រោះថ្នាក់ក្នុងសាលារៀន
- បង្កើតផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយក្នុងសាលារៀន
- អនុវត្តផែនការ និងធ្វើលំហាត់សមយុទ្ធជាប្រចាំ(យ៉ាងហោចណាស់២ដងក្នុងមួយឆ្នាំ)។

**សសរស្តម្ភទី៣ ៖ ការអប់រំស្តីពីការកាត់បន្ថយហានិភ័យ និងភាពធន់**

ការអប់រំស្តីពី កាត់បន្ថយហានិភ័យនិងភាពធន់ គឺផ្តោតលើការរៀបចំឱ្យមានវិធានការទាំងឡាយ ដែលមានគោលបំណងបង្កើតខ្លឹមសារ ដំណើរការ និងឱកាសសិក្សាសម្រាប់កុមារ បុគ្គលិកអប់រំ និងសហគមន៍សាលារៀន រួមទាំងឪពុកម្តាយផងដែរ ដើម្បីអភិវឌ្ឍភាពធន់ជាបុគ្គល និងកម្រិតសហគមន៍ ទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ ដែលពួកគេប្រឈម។ សសរស្តម្ភនេះ រួមមាន ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់សុខភាព និងជំងឺរាតត្បាត ការការពារកុមារ អំពើហិង្សា និងការការពារជម្លោះ ការដោះស្រាយជម្លោះ ការពង្រឹងភាពស្អិតរមួតក្នុងសង្គម និងសុខុមាលភាពផ្លូវចិត្ត។

**តើមានធាតុសំខាន់ៗអ្វីខ្លះក្នុងការអប់រំស្តីពីការកាត់បន្ថយហានិភ័យ និងភាពធន់?**

ធាតុសំខាន់ៗក្នុងការអប់រំស្តីពីការកាត់បន្ថយហានិភ័យ និងភាពធន់រួមមាន៖

- ការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងកម្មវិធីសិក្សា
- ការបំប៉នសមត្ថភាពគ្រូបង្រៀន និងការអប់រំសុខភាពផ្លូវចិត្ត
- ការកសាងសមត្ថភាពគណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការគ្រប់គ្រោះមហន្តរាយក្នុងសាលារៀន និងក្រុមប្រឹក្សាកុមារ
- ការបំប៉នជំនាញសង្គ្រោះបឋមនៅក្នុងសាលារៀន។

**២-៣-៥ ក្របខណ្ឌសាលារៀនសុវត្ថិភាពផ្សារភ្ជាប់ទៅនឹងក្របខណ្ឌគតិយុត្ត និងគោលនយោបាយសំខាន់ៗរបស់ថ្នាក់ជាតិ-អន្តរជាតិ**

**ការផ្សារភ្ជាប់ទៅនឹងគោលនយោបាល និងយុទ្ធសាស្ត្រធំៗកម្រិតអន្តរជាតិ**

- អនុសញ្ញា ស្តីពីសិទ្ធិកុមារ ១៩៨៩
- គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ២០១៥ - ២០៣០
- ក្របខណ្ឌសេនដាយ ស្តីពីការកាត់បន្ថយគ្រោះមហន្តរាយ ២០១៥-២០៣០
- កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ
- ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ២០៣០
- យុទ្ធសាស្ត្រទាំង ៧ ដើម្បីបញ្ចប់អំពើហិង្សា (INSPIRE)
- សេចក្តីប្រកាសសាលារៀនសុវត្ថិភាព (ការពារការអប់រំក្នុងជម្លោះប្រដាប់អាវុធ)
- បណ្តាញអន្តរទីភ្នាក់ងារសម្រាប់ការអប់រំក្នុងគ្រាអាសន្ន ស្តង់ដាអប្បបរមាសម្រាប់ការអប់រំ ការត្រៀមខ្លួន ការឆ្លើយតប និងការស្តារឡើងវិញ (INEE-Standard)
- ការប្តេជ្ញាចិត្តស្នូលសម្រាប់កុមារក្នុងសកម្មភាពមនុស្សធម៌
- ស្តង់ដាអប្បបរមាសម្រាប់ការការពារកុមារក្នុងសកម្មភាពមនុស្សធម៌

- ក្របខណ្ឌសុខភាពពេលគ្រាអាសន្ន និងការគ្រប់គ្រងហានីភ័យគ្រោះមហន្តរាយ
- អនុសាសន៍ស្តីពីការអប់រំសម្រាប់ការយល់ដឹងអន្តរជាតិ កិច្ចសហប្រតិបត្តិការ និងសន្តិភាព។

## ការផ្សារភ្ជាប់ទៅនឹងគោលនយោបាល និងយុទ្ធសាស្ត្រធំៗកម្រិតថ្នាក់ជាតិ

- ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣
- ផែនការយុទ្ធសាស្ត្រជាតិស្តីពីកាត់បន្ថយគ្រោះមហន្តរាយ ២០១៩ - ២០២៣
- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ២០១៥
- ផែនការយុទ្ធការប្រែប្រួលអាកាសធាតុសម្រាប់វិស័យអប់រំ ២០១៣
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩ - ២០២៣ គោលនយោបាយកម្មវិធីសាលាកុមារមេត្រី ២០១៦
- គោលនយោបាយកិច្ចការពារកុមារ ក្នុងសាលារៀន
- យន្តការគ្រប់គ្រងគ្រោះមហន្តរាយ វិស័យអប់រំ ២០១៩
- ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ ២០១៩



**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

- សុវត្ថិភាពគឺជាអាទិភាពចម្បង៖ ការបង្កើតបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព គឺជាកត្តាសំខាន់សម្រាប់សុខុមាលភាព និងភាពជោគជ័យរបស់សិស្ស និងបុគ្គលិក។
- តម្រូវឱ្យមានកំណត់ការគម្រាមកំហែង៖ អ្នកដឹកនាំសាលាគួរតែដឹងពីឧប្បត្តិហេតុគ្រោះថ្នាក់ និងហានិភ័យផ្សេងៗដែលអាចកើតឡើងនៅក្នុងសាលារៀន និងយល់ពីផលប៉ះពាល់របស់វា។
- សសរស្តម្ភទី១៖ ផ្តោតទៅលើបរិស្ថានសិក្សាសុវត្ថិភាពដែលមានដូចជា (១)-សុវត្ថិភាព និងបរិស្ថានបៃតង (២)-បទដ្ឋាន និងស្តង់ដា (៣)-ការត្រួតពិនិត្យគុណភាពសាងសង់ (៤)-ការប៉ាន់ប្រមាណនិងគំនិតផ្តួចផ្តើម (៥)-ទឹកស្អាតនិងអនាម័យ ។
- សសរស្តម្ភទី២៖ ផ្តោតទៅលើការគ្រប់គ្រងសាលារៀនសុវត្ថិភាព និងបន្តការអប់រំ ដែលមានដូចជា (១)- ការការពារហានិភ័យផ្នែករាងកាយ បរិស្ថាន និងសង្គម (២)-ជំនាញឆ្លើយតបនិងស

គ្រោះ (៣)-ការចូលរួមគ្រប់ហានិភ័យ (៤)-ផែនការបន្តការសិក្សាក្នុងគ្រាមានអាសន្ន (៥)-នីតិវិធីប្រតិបត្តិស្តង់ដា (៦)- ផែនការគ្រាមានអាសន្ន។

- សសរស្តម្ភទី៣៖ ផ្តោតទៅលើការអប់រំ ការកាត់បន្ថយហានិភ័យ និងភាពធន់ដែលមានដូចជា (១)-កម្មវិធីអប់រំក្នុង និងក្រៅប្រព័ន្ធ (២)-ការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពគ្រូ (៣)-សារគន្លឹះគ្រោះមហន្តរាយសម្រាប់ការអប់រំ (៤)-គុណភាពសម្ភារៈសិក្សា...។
- ធាតុផ្សំនៃក្របខណ្ឌសាលារៀនសុវត្ថិភាព៖ រួមមានវិធានការបង្ការ ការត្រៀមលក្ខណៈ ការឆ្លើយតប និងវិធានការស្តារឡើងវិញ ដើម្បីដោះស្រាយការគំរាមកំហែងពីគ្រោះថ្នាក់ និងហានិភ័យ។
- ការអនុវត្ត និងវាយតម្លៃ៖ វាមានសារៈសំខាន់ណាស់ក្នុងការអនុវត្តក្របខណ្ឌសាលារៀនសុវត្ថិភាពឱ្យមានប្រសិទ្ធភាព និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តជាប្រចាំដើម្បីធ្វើការកែលម្អ។

**២- ៥ ឯកសារសិក្សាបន្ថែម**

- ឯកសារកម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ អំពី«*ក្របខណ្ឌសាលារៀនសុវត្ថិភាព*» ដែលផ្តោតលើការលើកកម្ពស់សុខភាព សុវត្ថិភាព និងការការពារកុមារនៅក្នុងសាលារៀន។

**២-៦ ការអនុវត្ត**

បន្ទាប់ពីរៀនមេរៀននេះរួច៖

១- តើអ្នករៀនបានចំណុចសំខាន់ៗអ្វីខ្លះពីមេរៀននេះ?

២- តើអ្នកអាចចែករំលែកចំណេះដឹងពីមេរៀននេះដល់អ្នកអ្នកពាក់ព័ន្ធក្នុងសាលារៀន ឬស្ថាប័នអប់រំតាមវិធីណាដើម្បីឱ្យពួកគាត់យល់អំពីខ្លឹមសារក្របខណ្ឌការងារសាលារៀនសុវត្ថិភាព?

៣- តើក្របខណ្ឌសាលារៀនសុវត្ថិភាពជាអ្វី?

៤- តើក្របខណ្ឌសាលារៀនសុវត្ថិភាពបង្កើតឡើងក្នុងគោលបំណងអ្វី?

៥- តើអ្នកគិតថា ការអនុវត្តក្របខណ្ឌការងារសាលារៀនសុវត្ថិភាពមានសារៈសំខាន់អ្វីខ្លះចំពោះសាលារៀនរបស់អ្នក?

៦- តើសាលារៀនសុវត្ថិភាពមានសសរស្តម្ភអ្វីខ្លះ? ចូររៀបរាប់ខ្លឹមសារសំខាន់ៗនៃសសរស្តម្ភនីមួយៗ?

៧- ចូរអ្នកកំណត់ការគំរាមកំហែង(ទម្រង់គ្រោះថ្នាក់ និងហានិភ័យ)ដែលសាលារៀនរបស់អាចប្រឈម?

៨- តើកត្តាសំខាន់ៗអ្វីខ្លះដែលត្រូវពិចារណា នៅពេលបង្កើតផែនការសកម្មភាពសុវត្ថិភាពសាលារៀនរបស់អ្នក?

៩-សូមផ្តល់ឧទាហរណ៍អំពីរបៀបដែលអ្នកនឹងអនុវត្ត និងវាយតម្លៃប្រសិទ្ធភាពនៃក្របខណ្ឌសាលារៀនសុវត្ថិភាពរបស់អ្នក?

# មេរៀនទី៣៖ នីតិវិធីទូទៅ និងដំណើរការនៃការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន

## ១- វត្ថុបំណង

- ប្រាប់ពីនីតិវិធីទូទៅនិងដំណើរការនៃការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀននៅកម្រិតសាលារៀនតាមរយៈសំណួរបំផុស។
- អនុវត្តនីតិវិធីទូទៅនិងដំណើរការនៃការរៀបចំផែនការដើម្បីក្នុងការបញ្ចៀសគ្រោះមហន្តរាយនៅសាលារៀន
- មានគំនិតជាមូលដ្ឋានក្នុងការគាំទ្រនីតិវិធីទូទៅក្នុងសាលារៀនដើម្បីបន្តត្រៀមរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ តម្រូវឱ្យសិក្សាពីនីតិវិធីទូទៅនិងដំណើរការនៃការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀនមុនធ្វើផែនការ ត្រូវពិនិត្យស្ថានភាព និងប្រមូលព័ត៌មានលើ៖

ក- ការប៉ាន់ប្រមាណ មុខសញ្ញាគ្រោះថ្នាក់

- រៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់
- តារាងព័ត៌មានប្រវត្តិគ្រោះមហន្តរាយនិងតារាងប្រតិទិនរដូវកាល
- ការវិភាគមូលហេតុ និងផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ
- ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ (ភាពញឹកញាប់ ទំហំ និងផលប៉ះពាល់)

ខ- ការប៉ាន់ប្រមាណពីភាពងាយរងគ្រោះ នៅតាមសាលារៀន

- សិក្សាពីភូមិសាស្ត្រសាលារៀន និង ហេដ្ឋារចនាសម្ព័ន្ធ
- សិក្សាអំពីស្ថានភាពប្រជាសាស្ត្រ
- តារាងវិភាគអំពីភាពងាយរងគ្រោះតាមមុខសញ្ញាគ្រោះថ្នាក់នីមួយៗ
- តារាងវិភាគអំពីហានិភ័យទាំង ៥ នៅក្នុងសាលារៀន

ខ្លឹមសារខាងលើក្នុងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន កម្រិតសាលារៀនខាងលើគ្រាន់តែចំនុចនៃគម្រោងឆ្អឹងនៃទម្រង់ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នខាងលើតែប៉ុននោះ ខ្លឹមសារលម្អិត និងទម្រង់បានប្រើប្រាស់តាមសាលារៀន យើងនឹងសិក្សាលម្អិតនៅមេរៀនក្រោយៗទៀត។

### ២- ២ ពាក្យគន្លឹះ

- *ផែនការត្រៀមបម្រុង* គឺសំដៅដល់ការគ្រប់គ្រងដំណើរការដែលធ្វើការវិភាគលើការព្រឹត្តិការណ៍កើតឡើងឬស្ថានភាពអាចកើតឡើង ហើយអាចគម្រាមសង្គម ឬបរិស្ថាន និងការរៀបចំទុកដាក់

ដើម្បីចាត់ចែងពេលខាងមុខប្រកបដោយសមត្ថភាព និងទាន់ពេលទៅនឹងព្រឹត្តិការណ៍ភាពទាំងនោះ។

- ***ការឆ្លើយតប***គឺសំដៅដល់ការផ្តល់សេវាកម្មសង្គ្រោះបន្ទាន់ និងជំនួយសាធារណៈក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ ដើម្បីជួយសង្គ្រោះ កាត់បន្ថយផលប៉ះពាល់សុខភាព ជានាសុវត្ថិភាពសាធារណៈ និងដោះស្រាយសេចក្តីត្រូវការដើម្បីការចិញ្ចឹមជីវិតជាមូលដ្ឋានប្រជាជនដែលទទួលរងផលប៉ះពាល់។
- ***គ្រោះអាសន្ន***គឺសំដៅដល់ការគំរាមកំហែងដែលតម្រូវឱ្យមានសកម្មភាពបន្ទាន់ ប្រកបដោយប្រសិទ្ធភាពដែលអាចបញ្ចៀសនូវការរីកធំឡើងនៃព្រឹត្តិការណ៍ដែលឈានដល់គ្រោះមហន្តរាយ។
- ***នីតិវិធីទូទៅ និងដំណើរការ*** គឺសំដៅលើជំហាន ឬវិធីសាស្ត្រដែលបានរៀបចំទុកតាមផែនការនៅក្នុងគោលការណ៍កំណត់ទៅតាមយន្តការដំណាក់ការនីមួយៗ និងតាមតួនាទីភារកិច្ចរបស់បុគ្គល ។
- ***ការងារឆ្លើយតប*** គឺសំដៅលើវិស័យការងារសំខាន់ៗនិងចាំបាច់ដែលត្រូវអន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយ ដើម្បីបំពេញតម្រូវការជាមូលដ្ឋានរបស់អ្នករងគ្រោះ ដូចជា ស្បៀង ជម្រក ទឹកស្អាត និងអនាម័យ ការអប់រំ និងការការពារជាដើម។

### ២-៣ ខ្លឹមសារមេរៀន

សាលារៀនមានដំណើរការរៀបចំនៃផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀនត្រូវបង្កើតឡើង ដើម្បីត្រៀមជាមុនពេលមានគ្រោះមហន្តរាយកើតឡើង សំដៅការពារ កាត់បន្ថយ និងត្រៀមលក្ខណៈឆ្លើយតបនឹងគ្រោះមហន្តរាយក្នុងកម្រិតសាលារៀន។ ដូចនេះ ដើម្បីការរៀបចំនៃផែនការខាងលើនេះបាន គួរគប្បីដឹងពីនីតិវិធីទូទៅនិងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀននៅកម្រិតសាលា នូវនីតិវិធីនិងដំណើរការរៀបចំជាមុនជាបន្តបន្ទាប់ដូចខាងក្រោម ៖

#### ២-៣-១ ការប៉ាន់ប្រមាណ មុខសញ្ញាគ្រោះថ្នាក់

ជាដំបូងត្រូវសិក្សាអំពីបញ្ហាប្រឈម និង គ្រោះមហន្តរាយផ្សេងៗ ដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ កន្ត្រាក់ គ្រោះថ្នាក់ចរាចរណ៍ អគ្គីភ័យជាដើម ។ ជាញឹកញាប់ នៅរដូវវស្សាស្ថានភាពទឹកភ្លៀងលាយជាមួយខ្យល់កន្ត្រាក់ តែងតែបង្កការបារម្ភជាច្រើន និងញឹកញាប់ដល់តំបន់ទាំងឡាយ ដែលមានភូមិសាស្ត្រជាប់សាលារៀន ។ គេសង្កេតឃើញជារួមថា គ្រោះទឹកជំនន់ និង រាំងស្ងួតជាគ្រោះមហន្តរាយ ដែលបង្កជាហានិភ័យខ្លាំងដល់សាលា និងវិស័យអប់រំទាំងមូល ។ បន្ទាប់មក សាលារៀនត្រូវអនុវត្តនីតិវិធី និងឧទាហរណ៍មួយចំនួនដូចជា៖

ក- រៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់

ខ- តារាងព័ត៌មានប្រវត្តិគ្រោះមហន្តរាយនិងតារាងប្រតិទិនរដូវកាល

គ- ការវិភាគមូលហេតុ និងផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ

ឃ- ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ (ភាពញឹកញាប់ ទំហំ និងផលប៉ះពាល់)

**២-៣-២ ការប៉ាន់ប្រមាណពីភាពងាយរងគ្រោះ នៅតាមសាលារៀន**

**ក- សិក្សាពីភូមិសាស្ត្រសាលារៀន និង ហេដ្ឋារចនាសម្ព័ន្ធ**

ការសិក្សាពីភូមិសាស្ត្រសាលារៀន និង ហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន អ្នកសិក្សាឬ គណៈគ្រប់គ្រងសាលារៀនត្រូវធ្វើការងារជាមួយអាជ្ញាធរជាមួយគណកម្មការគ្រប់គ្រងសាលារៀន ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធអំពីស្ថានភាពទីតាំងភូមិសាស្ត្រ ស្ថិតិ និងទិន្នន័យព្រមទាំង សម្ភារៈ រូបវន និងធនធាន ដែលមានក្នុងភូមិទាំងក្នុងសាលារៀន។

**ខ- សិក្សាអំពីស្ថានភាពប្រជាសាស្ត្រ**

ការសិក្សាពីស្ថានភាពប្រជាសាស្ត្រ អ្នកសិក្សាឬ គណៈគ្រប់គ្រងសាលារៀនត្រូវធ្វើការងារជាមួយអាជ្ញាធរជាមួយគណកម្មការគ្រប់គ្រងសាលារៀន ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធអំពីស្ថិតិទិន្នន័យដោយផ្អែកលើស្ថិតិជំរឿនប្រជាសាស្ត្រ២០២៨ និងទិន្នន័យរបស់ភូមិនិងក្នុងសាលារៀនដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យជាក់ស្តែង ដែលមានក្នុងសាលារៀន។

**គ- តារាងវិភាគអំពីភាពងាយរងគ្រោះតាមមុខសញ្ញាគ្រោះថ្នាក់នីមួយៗ**

ដើម្បីវិភាគស្ថានភាពនៃភាពងាយរងគ្រោះតាមមុខសញ្ញាគ្រោះថ្នាក់ដោយផ្តោតលើបញ្ហានៃហានិភ័យមូលហេតុដែលអាចនឹងបណ្តាលឱ្យកើតបញ្ហាដែលយើងហៅថាភាពងាយរងគ្រោះ ព្រមទាំងសកម្មភាពដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យ។

**ឃ- តារាងវិភាគអំពីហានិភ័យទាំង ៥ នៅក្នុងសាលារៀន**

ក្នុងកាសិក្សាវិភាគអំពីហានិភ័យទាំង៥ក្នុងសាលារៀន យើងត្រូវផ្អែកលើភាពងាយរងគ្រោះដែលបានរកឃើញ រួចពិនិត្យឡើងវិញតាមប្រភេទហានិភ័យ (១)ហានិភ័យពីគ្រោងអគារ ឬរចនាសម្ព័ន្ធ (២)ហានិភ័យពីពីកត្តាផ្សេងៗ មិនមែនពីគ្រោងអាគារ ឬរចនាសម្ព័ន្ធ (៣)ហានិភ័យពីហេដ្ឋារចនាសម្ព័ន្ធ (៤)ហានិភ័យពីបរិស្ថាន និង(៥)ហានិភ័យលើសុវត្ថិភាពផ្ទាល់ខ្លួន។

**២-៣-៣ ការប៉ាន់ប្រមាណពីសមត្ថភាព នៅក្នុងសាលារៀន**

ជាគោលការណ៍មួយចំនួន ដើម្បីឱ្យការងារគ្រប់គ្រងគ្រោះមហន្តរាយមានប្រសិទ្ធភាព កត្តាសមត្ថភាព និង ធនធានទាំងខាងក្នុង និងខាងក្រៅគឺជាកត្តាចាំបាច់មួយទុកជាទុនវិនិយោគក្នុងការងារនេះ។ ដោយដំណើរការប្រព្រឹត្តរបស់សាលារៀនមានការពាក់ព័ន្ធជិតស្និទ្ធនិងសហគមន៍ វាជាការចាំបាច់ណាស់ដែលត្រូវវិភាគថា តើធនធានសហគមន៍អ្វីខ្លះដែលអាច កៀរគរមកប្រើប្រាស់បានសម្រាប់បម្រើការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងសាលារៀន ដោយផ្តោត

ក- ធនធានសម្ភារៈនិងឧបករណ៍ខាងក្នុងសាលារៀន

ខ- ធនធានសម្ភារៈ និងឧបករណ៍ខាងក្រៅសាលារៀន

គ- ការកំណត់ពីធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍?

ង- ការវិភាគស្ថាប័នដៃគូពាក់ព័ន្ធ

បន្ទាប់ដំណើរការប្រមូលព័ត៌មានមុនរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នខាងលើគឺត្រូវផ្អែកដំណើរការដូចខាងក្រោម៖




តាមការសង្កេតជាទូទៅ សាលារៀននៅតាមតំបន់ផ្សេងៗគ្នា ការកំណត់និងពិនិត្យប្រភេទហានិភ័យក៏ខុសគ្នាដែរ។ កន្លងមក បញ្ហាដែលបានបង្កការរងគ្រោះញឹកញាប់ បណ្តាលមកពីធម្មជាតិនិងមនុស្ស ហើយងាយផលប៉ះពាល់ដល់សាលារៀនរបស់ខ្លួនផ្ទាល់។ ដូចនេះ យើងត្រូវដឹងនិងកំណត់នូវសមត្ថភាពជាក់លាក់មួយ (បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាពផ្ទាល់ខ្លួន រចនាសម្ព័ន្ធអគារ និងមិនមែនរចនាសម្ព័ន្ធ) ដើម្បីធ្វើដំណើរការនៃការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន។ ម្យ៉ាងទៀត ដើម្បីកាត់បន្ថយហានិភ័យដែលមានការប៉ះពាល់ដល់សាលារៀន និងមនុស្ស ដូចជាគ្រូបង្រៀន នាយក សិស្សានុសិស្ស និងសហគមន៍ យើងត្រូវយល់ដឹងពីនីតិវិធីទូទៅ និងដំណើរការនៃការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នជាមុនមុននឹងរៀបចំផែនការនេះ ដើម្បីចូលរួម អនុវត្តបូករួមទាំងការដាក់បញ្ចូលពីហ្វឹកហាត់លំហាត់សមយុទ្ធនៅក្នុងកម្រិតសាលារៀន ព្រមទាំងមានគោលបំណង បញ្ជាក់ថាសាលារៀននិងសហគមន៍រួមគ្នាទប់ស្កាត់គ្រោះមហន្តរាយបានទាន់ពេលវេលា។

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

បន្ទាប់ពីបានសិក្សាមេរៀននេះចប់រួចរាល់ យើងបានយល់ដឹងពីនីតិវិធីទូទៅ និងដំណើរការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន ធម្មជាតិ និងគ្រោះថ្នាក់ សម្រាប់ការពារកុមារនៅក្នុងសាលារៀន ដើម្បីឱ្យកុមារនិងសាលារៀនជៀសផុតពីគ្រោះមហន្តរាយកម្រិតសាលារៀន។ យើងអាចធ្វើឱ្យសាលារៀនមានសុវត្ថភាព គុណភាព និងកាន់តែមានប្រសិទ្ធភាពតាមរយៈការសាងសង់ និងរៀបចំចំណុចសំខាន់ៗក្នុងការកែលម្អសាលារៀន។

បន្ទាប់ពីបានសិក្សាមេរៀននេះចប់រួចរាល់ យើងបានយល់ដឹងពីនីតិវិធីទូទៅ និងដំណើរការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន ធម្មជាតិ និងគ្រោះថ្នាក់ សម្រាប់ការពារកុមារនៅក្នុងសាលារៀន ដើម្បីឱ្យកុមារ និងសាលារៀនជៀសផុតពីគ្រោះមហន្តរាយកម្រិតសាលារៀន។ យើងអាចធ្វើឱ្យសាលារៀនមានសុវត្ថភាព គុណភាព និងកាន់តែមានប្រសិទ្ធភាពតាមរយៈការសាងសង់ និងរៀបចំចំណុចសំខាន់ៗក្នុងការកែលម្អសាលារៀន។

**២-៥ ឯកសារសិក្សាបន្ថែម**

- ឯកសារកម្មវិធីសាលាកុមារមេត្រី ឆ្នាំ២០១៦
- ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នកម្រិតសាលារៀន។

**២-៦ ការអនុវត្ត**

ចូរបង្ហាញចម្លើយ ស្តីពី ការអនុវត្តដំណើរការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នផ្សេងៗ របស់សាលារៀន លោកគ្រូ អ្នកគ្រូ តាមរយៈសំណួរខាងក្រោម៖

១- តើចូលរៀបរាប់ពីនិតីវិធីទូទៅ និងដំណើរការរៀបចំនៃផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀនមានអ្វីខ្លះ?

២- តើចូលរៀបរាប់ប្រវត្តិគ្រោះមហន្តរាយរបស់សាលារៀនរបស់លោកគ្រូ អ្នកគ្រូកន្លងមានអ្វីខ្លះ?

៣- តើនៅក្នុងសាលារៀន ឬ ភូមិ ឃុំ របស់អ្នក ធ្លាប់រងគ្រោះ ដោយសារគ្រោះមហន្តរាយអ្វីខ្លះ ក្នុងរយៈពេល ៥-១០ ឆ្នាំកន្លងមក?

៤- តើគ្រោះមហន្តរាយទាំងនោះកើតឡើងក្នុងឆ្នាំណា? ហើយបណ្តាលឱ្យមានផលប៉ះពាល់អ្វីខ្លះ?

៥- តើមានវិធានការអ្វីខ្លះដែលបានអនុវត្តដើម្បីឆ្លើយតបនឹងគ្រោះមហន្តរាយទាំងនោះ?

# មេរៀនទី៤៖ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន

## ១- វត្ថុបំណង

- ប្រាប់បានពីរបៀបរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀនច្បាស់លាស់
- រៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀនបានច្បាស់លាស់ ធានាផ្តល់ការអប់រំប្រកបដោយសុវត្ថិភាព ទោះបីមានគ្រោះមហន្តរាយកើតឡើងក៏ដោយនិងអនុវត្តផែនការដែលបានរៀបចំមុនជាស្រេចមុនគ្រោះមហន្តរាយកើតឡើង
- លើកកម្ពស់សុវត្ថិភាពនិងសុខុមាលភាពរបស់កុមារព្រមទាំងការពារទ្រព្យសម្បត្តិរបស់សាលា និងសម្រួលដល់ការសិក្សា របស់សិស្សប្រកបដោយជោគជ័យ។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះអ្នកនឹងសិក្សា អំពីការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀន ដោយផ្តោតលើ

ក- ស្ថានភាពផលប៉ះពាល់បម្រែបម្រួលអាកាសធាតុនៅកម្ពុជា

ខ- វិធីសាស្ត្រការឆ្លើយតប គ្រោះអាសន្នរបស់បុគ្គលិកសិក្សា

គ- តារាងចំណាត់ថ្នាក់មុខសញ្ញាគ្រោះថ្នាក់នៃផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដោយផ្តោតលើវិភាគលើមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ ធនធាន និងសមត្ថភាពរបស់សាលា។

### ២-២ ពាក្យគន្លឹះ

- ***ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន*** ជាផែនសកម្មភាព ដើម្បីអនុវត្តក្នុងអំឡុងពេលមានគ្រោះមហន្តរាយកើតឡើងភ្លាមៗនិងកម្ពស់សុវត្ថិភាព សុខុមាលភាពរបស់កុមារព្រមទាំងការពារទ្រព្យសម្បត្តិរបស់សាលា និងសម្រួលដល់ការសិក្សាបណ្តោះអាសន្នរបស់សិស្សនៅតែអាចបន្តដំណើរការបាន
- ***ការឆ្លើយតប គ្រោះអាសន្ន*** ជាសកម្មភាពដែលត្រូវបានអនុវត្តនៅក្នុងស្ថានភាពគ្រោះមហន្តរាយក្នុងគោលបំណងសង្គ្រោះ ជីវិត សម្រាលទុក្ខវេទនា និងកាត់បន្ថយការខាតបង់សេដ្ឋកិច្ច។
- ***ការត្រៀមបម្រុង*** គឺចំណេះដឹង និងសមត្ថភាពរៀបចំដោយរដ្ឋាភិបាលអង្គការដែលមានជំនាញក្នុងការឆ្លើយតប និងស្តារឡើងវិញសហគមន៍ និងបុគ្គលក្នុងព្យាករណ៍ឆ្លើយតប និងស្តារឡើងវិញយ៉ាងមានប្រសិទ្ធភាពពីផលប៉ះពាល់ ដែលអាចកើតមានដែលបម្រុងនឹងកើតឬព្រឹត្តិការណ៍ ឬលក្ខណៈគ្រោះមហន្តរាយបច្ចុប្បន្ន។

- ***ភាពងាយរងគ្រោះ*** សំដៅដល់លក្ខខណ្ឌ ដែលកំណត់ដោយកត្តារូបវន្ត សង្គម និងបរិស្ថាន ឬដំណើរការ ដែលបង្កើនភាព ចុះខ្សោយរបស់សហគមន៍ទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះ។

**២-៣ ខ្លឹមសារមេរៀន**

ក្នុងមេរៀននេះ គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលា គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយរបស់សាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស ។ ជាពិសេសគណៈកម្មាធិការប្រតិបត្តិ ក្រុមប្រឹក្សាកុមារ ដើម្បីធានាថាផែនការដែលបានបង្កើតឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

បច្ចុប្បន្ន ដោយសារការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យមានឧបសគ្គជាច្រើនដល់ការអភិវឌ្ឍលើវិស័យនានា ដូចជាវិស័យអប់រំ ក្នុងនោះ គ្រោះមហន្តរាយធម្មជាតិ ជាកត្តាសត្បានុម័តកំពុងគំរាមកំហែងយ៉ាងខ្លាំងលើពិភពលោក។ដោយឡែកនៅប្រទេសកម្ពុជា គ្រោះមហន្តរាយនានា ជាពិសេសគ្រោះទឹកជំនន់ ជំងឺរាតត្បាតសកល ដូចជាជំងឺកូវីដ ១៩។ល។ បានបង្អាក់ដំណើរការសិក្សារៀនសូត្រតាមសាលារៀន សាលារៀនត្រូវបិទ។ ដូចនេះ វាជាការចាំបាច់ដែលសាលារៀនត្រូវមានចំណេះដឹង និងសមត្ថភាព ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ទាំងមុនពេល(ការការពារ ការកាត់បន្ថយ ការត្រៀមលក្ខណៈឆ្លើយតប) អំឡុងពេល(ការឆ្លើយតប) និងក្រោយពេល (ការស្តារ និងកសាងឡើងវិញ) ។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយលើសិស្ស បុគ្គលិកសិក្សា និងសាលារៀនឱ្យនៅកម្រិតទាបបំផុត សាលារៀននីមួយៗ គប្បីបង្កើតរៀបចំផែនការត្រៀមបម្រុង ឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន។

ផែនការទាំងនេះ គួររៀបចំឡើងដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ រួមមាន គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលា គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយរបស់សាលារៀន គ្រូបង្រៀន និងសិស្សានុសិស្សនិងអ្នកពាក់ព័ន្ធជាច្រើនទៀត។ ជាពិសេសគណៈកម្មាធិការប្រតិបត្តិ ក្រុមប្រឹក្សាកុមារ ដើម្បីធានាថាផែនការដែលបាន បង្កើតឡើងឆ្លើយតបនឹងមុខសញ្ញាគ្រោះថ្នាក់ពិតប្រាកដរបស់សាលារៀន។ ការចូលរួមធ្វើផែនការពីគ្រប់អ្នកពាក់ព័ន្ធ គឺជាការបង្កើតនូវភាពជាម្ចាស់លើផែនការនោះ ដែលជាកត្តាជំរុញឱ្យមានការចូលរួមទទួលខុសត្រូវ ក្នុងការអនុវត្ត។ ផែនការទាំងនេះនឹងត្រូវបង្កើតឡើងនៅរៀងរាល់ដើមឆ្នាំសិក្សា ហើយបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ដើម្បីឱ្យសាលារៀនអាចកៀរគរធនធាននានាទាំងនៅក្នុងសាលារៀន ក៏ដូចជាក្នុងសហគមន៍យកមកអនុវត្តសកម្មភាពប្រកបដោយជោគជ័យ។ លើសពីនេះទៀត សាលារៀនត្រូវបន្តធ្វើបច្ចុប្បន្នកម្ម ផែនការខាងលើនេះជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការជាក់ស្តែង។

ហេតុអ្វីចាំបាច់ត្រូវផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន?

ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀនបង្កើតឡើង ដើម្បីអនុវត្តក្នុងអំឡុងពេលមានគ្រោះមហន្តរាយកើតឡើងភ្លាមៗសំដៅលើកកម្ពស់សុវត្ថិភាពនិងសុខុមាលភាពរបស់កុមារព្រម

ទាំងការពារទ្រព្យសម្បត្តិរបស់សាលា និងសម្រួលដល់ការសិក្សាបណ្ដោះអាសន្នរបស់សិស្សនៅតែអាចបន្តដំណើរការបាន។ ខាងក្រោមនេះគឺជាជំហានសំខាន់ៗនៃការបង្កើតផែនការត្រៀមបម្រុងឆ្លើយតបនឹងគ្រោះមហន្តរាយ។

*** ការគិតទុកជាមុនអំពីផលប៉ះពាល់ និងវិធានការឆ្លើយតប**

ដើម្បីបង្កើតផែនការខាងលើនេះគណៈគ្រប់គ្រងសាលាគណៈកម្មការគ្រប់គ្រងសាលា និងគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារ ធ្វើការពិនិត្យឡើងវិញនូវតារាងចំណាត់ថ្នាក់មុខសញ្ញាគ្រោះថ្នាក់ក្នុងផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ វិភាគលើមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ ធនធាន និងសមត្ថភាពរបស់សាលា ដើម្បីស្រង់យកមុខសញ្ញាគ្រោះថ្នាក់ដែលចាំបាច់ត្រូវត្រៀមបម្រុងឆ្លើយតបចំនួន ២-៣ ជាអាទិភាពនៅក្នុងសាលារៀន (ឧ- ខ្យល់ព្យុះ, ទឹក ជំនន់, អគ្គិភ័យ។ល។) ដាក់បញ្ចូលក្នុងតារាងខាងក្រោមរួចសួរសំណួរបំផុសដូចខាងក្រោម៖

1. តើអាចនឹងមានផលប៉ះពាល់អ្វីខ្លះដល់កុមារ និងសាលារៀនក្នុងអំឡុងពេលមានគ្រោះមហន្តរាយដែលបង្កដោយមុខសញ្ញាគ្រោះថ្នាក់នីមួយៗ?
2. ហេតុអ្វីបានជាមានហានិភ័យទាំងនេះ?
3. តើគួរមានវិធានការ ឬសកម្មភាព ធនធាន អ្វីខ្លះដើម្បីត្រៀមបម្រុងឆ្លើយតបក្នុងអំឡុងពេលមានគ្រោះមហន្តរាយដែលបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់នីមួយៗ?
4. តើសកកម្មភាពអ្វីខ្លះ ជាសកកម្មភាពអាទិភាពដែលត្រូវធ្វើ?
5. តើមុខសញ្ញាគ្រោះថ្នាក់នីមួយៗកើតឡើងពេលណា?
6. តើនរណាជាអ្នកដឹកនាំអនុវត្តសកម្មភាពទាំងនេះ?

ខាងក្រោមនេះ ជាគម្រោង/ប្លង់ សម្រាប់រៀបចំ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន

| ហានិភ័យ/ផលប៉ះពាល់ដែលអាចកើតមាន (ទាំងពេលខ្លីនិងវែង) | ភាពងាយរងគ្រោះ (ហេតុអ្វីបានជាមានហានិភ័យទាំងនេះ?) | សកម្មភាព ត្រូវធ្វើ | អាទិភាពសកម្មភាព | ធនធានសម្រាប់អនុវត្ត | ពេលវេលា | អ្នកដឹកនាំអនុវត្ត |
|---|---|---|---|---|---|---|
| ខ្យល់ព្យុះ (ខ្យល់កន្ត្រាក់) | | | | | | |
| | | | | | | |
| ទឹកជំនន់ទន្លេ | | | | | | |
| | | | | | | |

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ក្រោយពីសិក្សាមេរៀននេះចប់លោកគ្រូ អ្នកគ្រូ យល់ដឹងការប៉ាន់ប្រមាណ និងវិភាគលើមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព និងការរៀបចំផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាគ្រោះមហន្តរាយទាំងនានាដោយផ្អែកលើព័ត៌មាន ដែលប្រមូលបានពីការវិភាគ និងប៉ាន់ប្រមាណទាំងអស់ដែលបានធ្វើនៅផ្នែកខាងលើៗ ហើយនិយមន័យមួយចំនួនដូចជា ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀនជា ផែនការត្រៀមបម្រុង ការឆ្លើយតប គ្រោះអាសន្ន ការត្រៀមបម្រុង គ្រោះអាសន្ន ភាពងាយរងគ្រោះ។ការរៀបចំផែនការ មានប្រយោជន៍សម្រាប់សាលារៀន។

**២-៥ ឯកសារសិក្សាបន្ថែម**

- ឯកសារកម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ អំពី«*សាលារៀនសុវត្ថិភាព*» ផ្តោតលើការលើកកម្ពស់សុខភាព សុវត្ថិភាព និងការការពារកុមារនៅក្នុងសាលារៀន។

**២-៦ ការអនុវត្ត**

ផែនការនេះត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងគោលបំណងឱ្យការអនុវត្តការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការត្រៀមរៀបចំឆ្លើយតប បានប្រសិទ្ធភាពខ្ពស់ ឬក្នុងគោលបំណង ដើម្បីកៀរគរធនធានពីប្រភពផ្សេងៗបាន ។ ផែនការនេះគួរផ្សព្វផ្សាយដល់កុមារ ឪពុកម្តាយ ឬអាណាព្យាបាលកុមារ អាជ្ញាធរមូលដ្ឋាន គ្រូ នាយក និងអ្នកពាក់ព័ន្ធ ផ្សេងៗទៀតនៅក្នុងសហគមន៍ ប្រធាន/អនុប្រធាននិងមន្ត្រីការិយាល័យអប់រំស្រុកទាំងអស់ លេខាធិការដ្ឋាន និងតាមរយៈការធ្វើលំហាត់សមយុទ្ធជាដើម។

**សំណួរ**

១- តើត្រូវរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននេះយ៉ាងដូម្តេច? អ្នកណាខ្លះចូលរួម?

២- តើផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននេះបង្កើតឡើងដើម្បីអ្វី?

៣- តើផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននេះ អនុវត្តនៅពេលណា? អនុវត្តដូចម្តេច?

# ជំពូកទី២ យន្តការគណៈកម្មការ គ្រប់គ្រងគ្រោះមហន្តរាយសាលារៀន

**សេចក្តីណែនាំ**

ជំពូកនេះ យើងនឹងសិក្សាប្រធានបទអំពីយន្តការ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន។ នៅក្នុងជំពូកនេះ មានមេរៀនចំនួន៣ដែល បង្ហាញពី(១)ការរៀបចំឬពិនិត្យឡើងវិញនូវយន្តការ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន(២)តួនាទីក្រុមការងារសាលារៀនសុវត្ថិភាព(៣)ការពិនិត្យសមភាពយេនឌ័រ និងបរិយាបន្នក្នុងការងារកាត់បន្ថយ ហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ ។

# មេរៀនទី១៖ ការរៀបចំឬពិនិត្យឡើងវិញនូវយន្តការ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន

## ១- វត្ថុបំណង

- ប្រាប់ពីយន្តការឬរចនាសម្ព័ន្ធរបស់គណៈកម្មការគ្រប់គ្រងសាលារៀនស្របតាមក្របខណ្ឌសាលារៀនសុវត្ថិភាព
- រៀបចំឬពិនិត្យឡើងវិញនូវយន្តការឬរចនាសម្ព័ន្ធរបស់គណៈកម្មការគ្រប់គ្រងសាលារៀនដោយកំណត់បានពីតួនាទីនិងភារកិច្ចរបស់ក្រុមនីមួយៗបានច្បាស់លាស់
- យកចិត្តទុកដាក់បំពេញតួនាទី ភារកិច្ចទៅតាមក្រុមរៀងៗនៅមុនពេល កំឡុងពេលនិងក្រោយពេលមានគ្រោះមហន្តរាយកើតមានឡើង ក្នុងសាលារៀន។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះអ្នកនឹងសិក្សាអំពីការរៀបចំឬពិនិត្យឡើងវិញនូវយន្តការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន ដើម្បីត្រៀមបម្រុងនិងឆ្លើយតបគ្រោះអាសន្នដែលកើតឡើងនៅតាមសាលារៀនបានទាន់ពេលវេលា។ យន្តការឬរចនាសម្ព័ន្ធ គ្រប់គ្រងគ្រោះមហន្តរាយសាលារៀនមានសារៈសំខាន់បំផុត សម្រាប់ការងារឆ្លើយតបគ្រោះមហន្តរាយណាមួយដែលកើតឡើង។ ហេតុនេះ គណៈគ្រប់គ្រងសាលារៀន ចាំបាច់ត្រូវសិក្សាស្វែងយល់និងមានការពិនិត្យឬរៀបចំ យន្តការនេះ ដោយកំណត់នូវតួនាទីនិងភាកិច្ចរបស់សមាជិកក្នុងក្រុមនីមួយៗ ឱ្យបានច្បាស់លាស់ព្រមទាំងអនុវត្តតាមគោលការណ៍បានត្រឹមត្រូវ។ជាពិសេស ត្រូវមានកិច្ចសហការផងដែរពីសហគមន៍ អ្នកពាក់ព័ន្ធឬអង្គការដៃគូ។

### ២- ២ ពាក្យគន្លឹះ

- ***យន្តការ*** គឺជាដំណើរការរៀបចំក្រុមការងារត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយកម្រិតសាលារៀន តាមក្រុមនីមួយៗដែលមានតួនាទីនិងភារកិច្ចខុសៗគ្នា។
- ***ការគ្រប់គ្រងគ្រោះមហន្តរាយ*** គឺជាសកម្មភាពជាប្រព័ន្ធដើម្បីការពារឬកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយឱ្យនៅកម្រិតអប្បរមា។ សំដៅដល់សកម្មភាពមួយចំនួនមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយដើម្បីថែរក្សា ត្រួតពិនិត្យ តាមដានពីគ្រោះមហន្តរាយនិងផ្តល់ក្របខណ្ឌការងារសម្រាប់ជួយដល់មនុស្សដែលស្ថិតក្នុងហានិភ័យឬក្នុងសហគមន៍ណាមួយដើម្បីបញ្ចៀសកាត់បន្ថយជាអប្បរមាឬធ្វើឱ្យមានប្រក្រតីភាពឡើងវិញពីផលប៉ះពាល់នៃគ្រោះមហន្តរាយ។
- ***ការកាត់បន្ថយ*** គឺជាវិធានការដែលធ្វើឡើងនៅមុនពេល និងក្នុងពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើងសំដៅកាត់បន្ថយផលប៉ះពាល់អាយុជីវិតមនុស្ស សត្វ ហេដ្ឋារចនាសម្ព័ន្ធ ដំណើរការសង្គម បរិស្ថាននិងសង្គម។

- ***ការត្រៀមបម្រុងឆ្លើយតប*** គឺជាការធ្វើផែនការ ការត្រៀមឆ្លើយតបនិងវិធានការមុនពេលគ្រោះមហន្តរាយត្រូវបានធ្វើ និងត្រៀមរួចរាល់សម្រាប់គ្រោះមហន្តរាយ ដូចជាការសម្របសម្រួល ការគ្រប់គ្រង ការវិភាជន៍ ការបម្រុងថវិកា ធនធានផ្សេងៗទៀត ការកំណត់តួនាទី ការទទួលខុសត្រូវគ្រប់ទិដ្ឋភាពទាំងអស់នៃគ្រោះមហន្តរាយ។ ក្នុងចំណោមសកម្មភាពទាំងនេះការត្រៀមឆ្លើយតបគ្រោះមហន្តរាយគឺផ្តោតលើប្រតិបត្តិការក្នុងគ្រាអាសន្ន។

**២-៣ ខ្លឹមសារមេរៀន**

ឆ្លើយតបក្របខណ្ឌសាលារៀនសុវត្ថិភាព ដែលផ្តោតលើកម្មវិធីសាលាកុមារមេត្រីតម្រូវឱ្យសាលារៀនទាំងអស់ជាសាលារៀនសុវត្ថិភាព ចាំបាច់ត្រូវមាន យន្តការឬរចនាសម្ព័ន្ធសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ។ ដូច្នេះនាយកសាលារៀននីមួយៗត្រូវបង្កើតក្រុមត្រៀមបម្រុងឆ្លើយតប រចនាសម្ព័ន្ធ តួនាទីនិងភារកិច្ចច្បាស់លាស់។

នាយកសាលាត្រូវរៀបចំកិច្ចប្រជុំ ជាមួយគណៈកម្មការគ្រប់គ្រងសាលានិងគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារ ប្រធាន និងអនុប្រធាន នៅដើមឆ្នាំសិក្សា ដើម្បីពិភាក្សាគ្នាអំពីការបង្កើតក្រុមត្រៀមបម្រុងឆ្លើយតបនឹងគ្រាអាសន្នឬគ្រោះមហន្តរាយ។ ក្រុមនេះ បង្កើតឡើងដើម្បីសម្រួលដល់ការអនុវត្តសកម្មភាពឆ្លើយតបនឹងគ្រោះមហន្តរាយ ដែលអាចកើតមាននៅក្នុងសាលារៀន។ ក្រុមនេះ ត្រូវចែកចេញជា៥ ក្រុមតូចៗ គឺ ១- ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន ២- ក្រុមជម្លៀស ៣- ក្រុមរុករក និងសង្គ្រោះ ៤- ក្រុមសង្គ្រោះបឋម ៥- ក្រុមសន្តិសុខ។ នាយកសាលាគឺជាប្រធានយន្តការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន និងដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំដំណើរការរបស់ក្រុមនេះ។ ចំណែកឯគ្រូបង្រៀនគឺជាប្រធានក្រុមតូចៗ អនុប្រធានគឺជាសមាជិកគណៈកម្មការគ្រប់គ្រងសាលា និងសមាជិកក្រុមជាសមាជិកក្រុមប្រឹក្សាកុមារ។

ក្នុងការជ្រើសរើសសមាជិកគឺធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្ត ហើយដែលក្នុងនោះនាយកសាលានិងគ្រូបង្រៀនគួរពិចារណាលើសមាជិកក្រុមប្រឹក្សាកុមារ(ថ្នាក់ទី៤ ដល់ទី៦)ដែលមានឆន្ទៈខ្ពស់ កាយសម្បទាមាំមួន មានភាពប៊ិនប្រសប់និងទេពកោសល្យទាក់ទងទៅនឹងក្រុមតូចៗទាំង៥។

**ក- យន្តការ ឬរចនាសម្ព័ន្ធក្រុមការងារត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយនៅក្នុងសាលារៀន (គំរូ)**



## ខ- សមាសភាពក្រុមការងារត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយកម្រិតសាលារៀន

គណៈគ្រប់គ្រងសាលារៀន បន្ទាប់ពីរៀបចំយន្តការ ឬរចនាសម្ព័ន្ធក្រុមការងារត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយនៅក្នុងសាលារៀនរួច ត្រូវបន្តរៀបចំសមាសភាពនិងតួនាទី ភារកិច្ចក្រុមការងារត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយកម្រិតសាលារៀនឱ្យបានច្បាស់លាស់ផងដែរ។

ខាងក្រោមនេះ ជាគំរូតារាងសមាសភាព តួនាទី និងភារកិច្ចក្រុមការងារត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយកម្រិតសាលារៀនមួយ។

| ល-រ | គោត្តនាម និងនាម | ភេទ | តួនាទីក្រុមគ្រោះមហន្តរាយ | តួនាទីក្នុងការងារសង្គម | អាស័យដ្ឋាន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|
| ១- ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន | | | | | | |
| | | | | | | |
| ២- ក្រុមជម្លៀស | | | | | | |
| | | | | | | |
| ៣- ក្រុមរុករក និងសង្គ្រោះ | | | | | | |
| | | | | | | |
| ៤- ក្រុមសង្គ្រោះបឋម | | | | | | |
| | | | | | | |
| ៥- ក្រុមសន្តិសុខ | | | | | | |
| | | | | | | |

## គ- ផែនទីជម្លៀស សម្រាប់សាលារៀន

ក្រុមត្រៀមបម្រុងឆ្លើយតបត្រូវកំណត់ឱ្យបានរួចជាស្រេចនូវអគារថ្នាក់រៀនឬទីតាំងដទៃទៀតដែលមានភាពរឹងមាំនិងអាចធន់នឹងគ្រោះមហន្តរាយសម្រាប់ធ្វើជាកន្លែងជម្រកសម្រាប់ជម្លៀសសិស្សានុសិស្សនិងគ្រូបង្រៀន។ បន្ទាប់មក ក្រុមត្រូវគូសផែនទីសាលារៀននៅលើក្រដាសកាតុងដោយបង្ហាញ ពីគំនូសបំព្រួញនិងដៅកន្លែងដែលមានសុវត្ថិភាព ហើយក្រុមជម្លៀសដើរតួនាទីដើរតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយអំពីផែនទីជម្លៀសដល់សិស្សទាំងអស់នៅពេលគោរពទង់ជាតិនិងតាមថ្នាក់រៀន។ សូមមើលផែនទីជម្លៀសដូចឧទាហរណ៍ខាងក្រោម៖

### ផែនទីជម្លៀសរបស់សាលារៀន




### ឃ- តារាងព័ត៌មានទំនាក់ទំនងឪពុក ម្ដាយ និងស្ថាប័នពាក់ព័ន្ធ ក្នុងកំឡុងពេលគ្រោះមហន្តរាយ

បន្ទាប់ពីបង្កើតក្រុមត្រៀមបម្រុងឆ្លើយតបរួចមក សាលារៀនត្រូវស្រង់យកព័ត៌មានចាំបាច់មួយចំនួនពីសមាជិក ដូចជា ឈ្មោះ ភេទ តួនាទី អាសយដ្ឋាន និងលេខទូរស័ព្ទដើម្បីបញ្ចូលក្នុងតារាងដូចខាងក្រោម។ព័ត៌មាននេះ ត្រូវធ្វើការផ្សព្វផ្សាយឱ្យសិស្សានុសិស្សដទៃទៀតបានដឹងនិងអាចយកទៅបិទនៅតាមក្ដារខៀនព័ត៌មាននិងថ្នាក់រៀនផងដែរ។

-បញ្ជីទំនាក់ទំនងរបស់ក្រុមការងារឆ្លើយតបគ្រោះអាសន្នសាលារៀន។

### គំរូ តារាងព័ត៌មានទំនាក់ទំនងឪពុក ម្ដាយ និងស្ថាប័នពាក់ព័ន្ធក្នុងកំឡុងពេលគ្រោះមហន្តរាយ

| ស្ថាប័នពាក់ព័ន្ធ | ឈ្មោះ | ភេទ | តួនាទី | សមត្ថភាពជំនាញ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| អាជ្ញាធរមូលដ្ឋាន | | | | | |
| | | | | | |
| គណៈកម្មការទ្រទ្រង់សាលា | | | | | |
| | | | | | |
| មណ្ឌលសុខភាព | | | | | |
| | | | | | |
| ក្រុមសង្គ្រោះបឋម | | | | | |
| កម្លាំងយុវជន/អ្នកស្ម័គចិត្ត កាកបាទក្រហម | | | | | |
| អង្គការដៃគូពាក់ព័ន្ធ | | | | | |
| មន្ទីរអេយក- រាជធានី /ខេត្ត | | | | | |
| ការិ- អេយក- ខណ្ឌ/ក្រុង/ស្រុក- - - | | | | | |

| | | | | | |
|---|---|---|---|---|---|
| ក្រុមប្រឹក្សាកុមារ | | | | | |
| ឪពុកម្ដាយ/អាណាព្យាបាលសិស្ស | | | | | |

**សំណួរ**

១- ហេតុអីបានសាលារៀនត្រូវបង្កើតឱ្យមានរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ?

២- នៅពេលមានគ្រោះអាសន្នកើតឡើងនៅក្នុងសាលារៀនតើគណៈកម្មការតូចៗមានភារកិច្ចធ្វើអ្វីខ្លះ?

៣- ហេតុអ្វីចាំបាច់មានផែនទីជម្លៀស?

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

បន្ទាប់ពីសិក្សាមេរៀននេះចប់ គ្រូបានដឹងនិងអនុវត្តនូវខ្លឹមសារមួយចំនួនដូចជា

- គណៈគ្រប់គ្រងសាលារៀនត្រូវបង្កើតក្រុមត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយដែលមាន៥ក្រុម ១- ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន ២- ក្រុមជម្លៀស ៣- ក្រុមរុករក និងសង្គ្រោះ ៤- ក្រុមសង្គ្រោះបឋម ៥-ក្រុមសន្តិសុខនិងបិទផ្សាយនៅក្នុងសាលារៀន ឱ្យសមាជិកទាំងអស់បានយល់ដឹងគ្រប់គ្នា។នាយកសាលាគឺជាប្រធានយន្តការ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំសម្របសម្រួលដំណើរការរបស់ក្រុមនេះ ។ចំណែកឯគ្រូបង្រៀនគឺជាប្រធានក្រុមតូចៗ អនុប្រធានគឺជាសមាជិកគណៈកម្មការទ្រទ្រង់សាលា តំណាងមកពីមណ្ឌលសុខភាពជិតៗសាលាតំណាងមេភូមិតំណាងសន្តិសុខភូមិឬប្រជាការពារ - - - ដែលជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនដែលមានស្រាប់ និងសមាជិកក្រុមជាសិស្សមកពីក្រុមប្រឹក្សាកុមារ។
- តួនាទី ក្រុមទាំង៥ មានភារកិច្ចរៀងៗខ្លួនដែលត្រូវអនុវត្តនៅពេល អំឡុងពេលគ្រោះអាសន្នកើតមានឡើងនៅក្នុងសាលារៀន។
- ប្រធានយន្តការត្រូវមានផែនទីជម្លៀស ដើម្បីងាយក្នុងការអនុវត្តនៅពេលមានគ្រោះមហន្តរាយនិងប្រជុំណែនាំ សមាជិកក្នុងគណៈកម្មការឬក្រុមទាំង៥ សិស្សានុសិស្សទាំងអស់ក្នុងសាលារៀនឱ្យបានយល់ដឹង ស្គាល់ទីតាំងសុវត្ថិភាពក្នុងផែនទីជម្លៀសហើយត្រៀមអនុវត្តពេលមានគ្រោះមហន្តរាយកើតឡើង។
- ត្រូវមានតារាងព័ត៌មានទំនាក់ទំនងឪពុកម្ដាយ អ្នកអាណាព្យាបាលសិស្ស ឬសប្បុរសជន និងស្ថាប័នពាក់ព័ន្ធដើម្បីចូលរួមសហការ ឧបត្ថម្ភគាំទ្រ ក្នុងកំឡុងពេលគ្រោះមហន្តរាយកើតឡើង
- សមាជិកក្នុងយន្តការ ឬរចនាសម្ព័ន្ធនៃគណៈកម្មការឆ្លើយតបគ្រោះមហន្តរាយសាលារៀននីមួយៗត្រូវត្រៀមលក្ខណៈដើម្បីចូលរួមពេលមានគ្រោះអាសន្ន ដោយបំពេញតាមតួនាទីភារកិច្ចក្នុងក្រុមនីមួយៗឱ្យបានត្រឹមត្រូវ។

**២-៥ ឯកសារសិក្សាបន្ថែម**

- ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយ កម្រិតសាលារៀន ឆ្នាំ២០១៩ សាលាបឋមសិក្សាបឹងកាឆាង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

**២-៦ ការអនុវត្ត**

គណៈគ្រប់គ្រងសាលា ត្រូវរៀបចំយន្តការគ្រប់គ្រងគ្រោះមហន្តរាយតាមសាលារៀនឬពិនិត្យឡើងវិញ ដោយធ្វើបច្ចុប្បន្នកម្មយន្តការគ្រប់គ្រងគ្រោះមហន្តរាយតាមសាលារៀនដែលមានស្រាប់។ បន្ទាប់មក ត្រូវប្រជុំជាមួយសមាជិកទាំងអស់ក្នុងយន្តការនេះ ដើម្បីមានការគាំទ្រនិងឯកភាព។រួចប្រជុំផ្សព្វផ្សាយ និងណែនាំអនុវត្តតាមតួនាទីនៃក្រុមនីមួយៗ ឱ្យបានត្រឹមត្រូវ មុនពេលនិងនៅពេលមានគ្រោះមហន្តរាយកើតឡើង។

**សំណួរ**

១- តើយន្តការឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយកម្រិតសាលារៀនជាអ្វី?

២- តើសាលារៀនរបស់អ្នកមានយន្តការ ឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយឬនៅ? បើមិនទាន់មាន ចូរអ្នកបង្កើតឱ្យមានយន្តការឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀនរបស់អ្នកសម្រាប់អនុវត្ត។

៣- តើការបង្កើតយន្តការឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀន ត្រូវរៀបចំយ៉ាងដូចម្តេច?

៤- តើការរៀបចំយន្តការ ឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយសាលារៀនមានសារៈសំខាន់អ្វីខ្លះសម្រាប់សាលារៀនរបស់អ្នក?

# មេរៀនទី២៖ តួនាទីក្រុមការងារសាលារៀនសុវត្ថិភាព

## ១- វត្ថុបំណង

- ប្រាប់ពីតួនាទី និងភារកិច្ចរបស់ក្រុមនីមួយៗក្នុងយន្តការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន
- បង្ហាញបានពីតួនាទី និងភារកិច្ចរបស់ក្រុមនីមួយៗក្នុងយន្តការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន
- អនុវត្តតាមតួនាទីនិងភារកិច្ចរបស់ក្រុមនីមួយៗក្នុងយន្តការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

យើងបានសិក្សារួចមកហើយអំពីការរៀបចំយន្តការ ឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយតាមសាលារៀន។ យន្តការ ឬរចនាម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយសាលារៀនទាំង៥ នោះគឺ (១)ក្រុមផ្សព្វផ្សាយនិងប្រកាសព័ត៌មាន (២)ក្រុមជម្លៀស (៣)ក្រុមរុករក និងសង្គ្រោះ (៤)ក្រុមសង្គ្រោះបន្ទាន់ (៥)ក្រុមសន្តិសុខ។ ក្នុងមេរៀននេះយើងនឹងបន្តអំពី «តួនាទីក្រុមការងារសាលារៀនសុវត្ថិភាព»។

គោលបំណងសំខាន់នៃមេរៀននេះ គឺការកំណត់ និងបំពេញតួនាទីរបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន និងអ្នកពាក់ព័ន្ធផ្សេងៗ ព្រមទាំងជំរុញការការទទួលខុសត្រូវរបស់ក្រុមការងារទាំង៥ដែលបានបង្កើតឡើង។

### ២-២ ពាក្យគន្លឹះ

- ***តួនាទី*** ក្នុងបរិបទការងារគ្រប់គ្រងគ្រោះមហន្តរាយកម្រិតសាលារៀន សំដៅការណែនាំអនុវត្ត និងទទួលខុសត្រូវក្នុងក្រុមនីមួយៗឱ្យបានត្រឹមត្រូវ តាមការកំណត់នៅក្នុងយន្តការឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយនៅតាមសាលារៀននីមួយៗ
- ***ភារកិច្ច*** ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយកម្រិតសាលារៀន សំដៅដល់ការងារដែលត្រូវអនុវត្តតាមការចាត់តាំង តាមបង្គាប់ដែលបានកំណត់ទុក។

### ២- ៣ ខ្លឹមសារមេរៀន

បន្ទាប់ពីសាលារៀនមានយន្តការ ឬ រចនាសម្ព័ន្ធ សម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ ហើយគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយរបស់សាលារៀន ត្រូវកំណត់ពីតួនាទីរបស់រចនាសម្ព័ន្ធក្រុមការងារសាលារៀនសុវត្ថិភាព ព្រមទាំង ទទួលនាទីបន្ថែមដើម្បីតាមដានយន្តការការងារ។ យន្តការ ឬរចនាសម្ព័ន្ធសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយសាលារៀនទាំង៥ក្រុមនោះមាន៖

(១) ក្រុមផ្សព្វផ្សាយ និងប្រកាសព័ត៌មាន

(២) ក្រុមជម្លៀស

(៣) ក្រុមរុករក និងសង្គ្រោះ

(៤) ក្រុមសង្គ្រោះបន្ទាន់

(៥) ក្រុមសន្តិសុខ។

គណៈកម្មការនេះ មានតួនាទីសំខាន់ក្នុងការអនុវត្តកម្មវិធី កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និង ទទួលខុសត្រូវក្នុងការរៀបចំការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ សមត្ថភាព និង ធ្វើផែនការត្រៀមបម្រុង ឆ្លើយតបគ្រោះមហន្តរាយ សម្រាប់សាលារៀនអនុវត្ត និងមានការធ្វើបច្ចុប្បន្នភាព ជ្រើសរើស ក្នុង១ឆ្នាំម្តងព្រមទាំងមានការប្រជុំឆ្លុះបញ្ចាំងការ អនុវត្ត លើកឡើងចំណុចល្អ បញ្ហាប្រឈម ឬ ចំណុចខ្វះខាតដើម្បី ដោះស្រាយ ឬកែលម្អផែនការសម្រាប់អនុវត្តនៅឆ្នាំបន្តបន្ទាប់ឱ្យកាន់តែប្រសើរឡើង។ សមាសភាពចូលរួម ក្នុងគណៈកម្មការនេះ មានការចូលរួមពីក្រុមប្រឹក្សាកុមារ គ្រូបង្រៀន តំណាងគណៈកម្មកាគ្រប់គ្រងសាលារៀន មាតាបិតា តំណាងពីមណ្ឌលសុខភាព ប្រជាកាពារ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធក្នុងសហគមន៍។ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅសាលារៀន ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ ស្រុក ដើម្បីកៀរគរធនធាន និងការគាំទ្រលើការងារកាត់បន្ថយ ហានិភ័យនៅក្នុងសាលារៀន។

តួនាទី និងភារកិច្ចរបស់ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅសាលារៀន ត្រូវមានភាពបត់បែន ទៅតាមសមត្ថភាពរបស់សាលារៀន (ផ្អែកលើអាយុកុមារ ការយល់ដឹងពីការកាត់បន្ថយហានិភ័យនៃគ្រោះ មហន្តរាយ។ល។) និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ គ្រូបង្រៀនត្រូវមានតួនាទីចម្បង ក្នុងការដឹកនាំ ការឆ្លើយតប ការជម្លៀស ការរុករក និងជួយសង្គ្រោះបន្ទាន់តាមរយៈក្រុមទាំង៥។ ពិសេសការដឹកនាំសិស្ស ចូលរួមអនុវត្ត និងអនុវត្តការធ្វើលំហាត់សមយុទ្ធយ៉ាងតិចឱ្យបាន២ដងក្នុងមួយឆ្នាំ។ ការលើកកម្ពស់ការយល់ដឹង រៀបចំការតាំងពិព័ណ៌បង្ហាញ ប្រឡងប្រណាំងសរសេរអត្ថបទ ពិភាក្សាដេញដោល និងសម្តែងល្ខោនអប់រំ ទាក់ទងប្រធានបទសាលារៀនសុវត្ថិភាពជាដើម។

**តួនាទីរបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ កម្រិតសាលារៀននីមួយៗមានដូចខាងក្រោម ៖**

| ល-រ | ក្រុមត្រៀមបម្រុង ឆ្លើយតប | ការទទួលខុសត្រូវ | សម្ភារៈដែលត្រូវការ |
|---|---|---|---|
| ១ | ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន | **មុនពេល៖**<br>- តាមដាននិងដកស្រង់ព័ត៌មានថ្មីៗពីគ្រោះមហន្តរាយឱ្យបានទៀងទាត់តាមរយៈទូរទស្សន៍ វិទ្យុ និងប្រភពផ្សេងៗ<br>- ធ្វើការហ្វឹកហាត់ ឬសមយុទ្ធឱ្យបានទៀងទាត់<br>**អំឡុងពេល៖**<br>- ផ្តល់ព័ត៌មានឬប្រកាសអាសន្នអំពីស្ថានភាពគ្រោះថ្នាក់ដែលអាចនឹងកើតឡើងដល់គ្រូនិងសិស្សទាំងអស់<br>- ទាក់ទងជាមួយអាជ្ញាធរនិងអ្នកពាក់ព័ន្ធដើម្បីជួយអន្តរាគមន៍<br>**ក្រោយពេល៖**<br>- ផ្តល់ដំណឹងដល់មាតា បិតានិងអាណាព្យាបាលសិស្ស | - មេក្រូ ជួង កណ្តឹង កញ្ចែ ទូរស័ព្ទ<br>- ព័ត៌មានទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន |

| | | | |
|---|---|---|---|
| | | - រាយការណ៍ពីស្ថានភាពគ្រោះមហន្តរាយដល់ក្រុមដទៃទៀត | |
| ២ | ក្រុមជម្លៀស | **មុនពេល៖**<br>- ត្រួតពិនិត្យច្រក ឬផ្លូវដែលត្រូវជម្លៀសឱ្យបានទៀងទាត់<br>- កំណត់រកទីកន្លែងទូលាយសម្រាប់ប្រមូលផ្តុំគ្នា បន្ទាប់ពីធ្វើការជម្លៀស<br>- ត្រូវជានាថាគ្មានមុខសញ្ញាគ្រោះថ្នាក់ផ្សេងទៀតទេនៅច្រកចេញចូលកន្លែងប្រមូលផ្តុំ<br>- ត្រៀមឧបករណ៍ឬសម្ភារៈចាំបាច់ ក្នុងការចល័តសិស្សដែលមានលក្ខណៈទន់ខ្សោយ<br>- ធ្វើការហ្វឹកហាត់ឬសមយុទ្ធឱ្យបានទៀងទាត់<br>**អំឡុងពេល៖**<br>- ធ្វើការជម្លៀសឱ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ស្របតាមការហ្វឹកហាត់<br>- រាប់ចំនួនសមាជិកនៅតាមថ្នាក់រៀនឬកន្លែងប្រមូលផ្តុំ<br>**ក្រោយពេល៖**<br>- ផ្តល់ដំណឹងដល់ក្រុមរុករក និងសង្គ្រោះ ដើម្បីជួយស្វែងរកក្នុងករណីមានអ្នកបាត់ខ្លួន<br>- ទាក់ទងនិងរាការណ៍ដល់អ្នកពាក់ព័ន្ធ ដទៃទៀតក្នុងករណីត្រូវការជំនួយបន្ថែម | - មេក្រូ ជួង កណ្តឹង កញ្ចែ ទូរស័ព្ទ<br>- ផែនទីលម្អិតឬប្លង់សាលា<br>- ផែនទីជម្លៀស<br>-ព័ត៌មានអំពីចំនួនគ្រូនិងសិស្សនៅតាមថ្នាក់រៀន<br>-កូនសោ<br>-ផ្លាកសញ្ញាបង្ហាញកន្លែងសុវត្ថិភាព<br>-សម្ភារៈសម្រាប់ធ្វើការចល័តសិស្ស |
| ៣ | ក្រុមរុករកនិងសង្គ្រោះ | **មុនពេល៖**<br>- ដឹងពីវិធីរុករក និងជួយសង្គ្រោះកុមារដែលមានតម្រូវការពិសេស<br>- ត្រៀមសម្ភារៈដែលចាំបាច់រួចជាស្រេចដើម្បីធ្វើការរុករក<br>- ធ្វើការហ្វឹកហាត់ឬសមយុទ្ធឱ្យបានទៀងទាត់<br>**អំឡុងពេល៖**<br>- ធ្វើការរុករកនិងសង្គ្រោះអ្នកដែលបាត់ខ្លួន<br>- ផ្តល់ដំណឹងដល់ក្រុមសង្គ្រោះបឋមដើម្បីជួយជនរងគ្រោះ<br>**ក្រោយពេល៖**<br>ពិនិត្យមើលស្ថានភាពនៃការខូចខាតនៅក្នុងសាលានិងរាយការណ៍ដល់គណៈគ្រប់គ្រងសាលា | - ផែនទីលម្អិតឬប្លង់សាលារៀន<br>- ព័ត៌មានអំពីស្ថិតិរបស់សិស្សនិងចំនួនថ្នាក់រៀន<br>- ព័ត៌មានចំនួនបុគ្គលិកនិងគ្រូបង្រៀន<br>- ពិល ភ្លើងចន្លុះ(មានថ្មច្រើន)<br>- កូនសោមេ<br>- មួកការពារឬមួករឹង<br>- ហ្វ្រង់កា ខ្សែពួរ និងជណ្តើរ |
| ៤ | ក្រុមសង្គ្រោះបឋម | **មុនពេល៖**<br>- ត្រូវជានាថាសម្ភារៈសង្គ្រោះបឋមបានរៀបចំរួចជាស្រេច<br>- ត្រូវជានាថាសមាជិកក្រុម បានចូលរួមវគ្គបំប៉ន ស្តីពីជំនាញសង្គ្រោះបឋម | - ប្រអប់និងសម្ភារៈសង្គ្រោះបឋម |

| | | | |
|---|---|---|---|
| | | - ធ្វើការហ្វឹកហាត់ឬសមយុទ្ធឱ្យបានទៀងទាត់<br>**អំឡុងពេលៈ**<br>- ផ្តល់ការជួយសង្គ្រោះបឋម ដល់ជនរងគ្រោះ ឱ្យបានទាន់ពេលវេលា<br>- ក្នុងករណីធ្ងន់ធ្ងរត្រូវបញ្ជូនទៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែក<br>ក្រោយពេល<br>- ផ្តល់ព័ត៌មានដល់មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស | - លេខទូស័ព្ទឡានពេទ្យមណ្ឌលសុខភាព និងអ្នកអាណាព្យាបាលសិស្ស |
| ៥ | ក្រុមសន្តិសុខ | **អំឡុងពេល**<br>ថែរក្សាសណ្តាប់ធ្នាប់ និងការពារសន្តិសុខក្នុងពេលមានហេតុការណ៍កើតឡើង | - មេក្រូ កញ្ចែ<br>- ផែនទីលម្អិតឬប្លង់សាលារៀន<br>- ផែនការជម្លៀស<br>- កូនសោ |

ក្រៅពីនេះ យន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅសាលារៀន ក៏មានអ្នកពាក់ព័ន្ធសំខាន់ៗចូលរួមក្នុងការបំពេញតួនាទីជាមួយក្រុមទាំង៥ខាងលើដែរ។ អ្នកពាក់ព័ន្ធសំខាន់ៗ ទាំងនេះត្រូវមានតួនាទីបន្ថែមជំរុញសកម្មភាពដូចខាងក្រោមៈ

| **អ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងសលារៀន** | **តួនាទី និងការទទួលខុសត្រូវ** |
|---|---|
| **នាយកសាលា** | - -ដឹកនាំទូទៅក្នុងការបញ្ជ្រាបគំនិតផ្តួចផ្តើម ស្តីពីសាលារៀនសុវត្ថិភាព ក្នុងកម្មវិធីសិក្សាផ្លូវការក្នុងសហគមន៍និងស្ថាប័នពាក់ព័ន្ធព្រមទាំង ផ្សារភ្ជាប់និងប្រើប្រាស់ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធគ្រប់ផ្នែក។ ភ្ជាប់ និងប្រើប្រាស់ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធគ្រប់ផ្នែក។<br>- លើកទឹកចិត្តឱ្យមានការចូលរួមពីសិស្ស និងបុគ្គលិកសិក្សាទាំងអស់ ក្នុងកម្មវិធី កាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ និងឱកាសសិក្សារៀនសូត្រពីសហគមន៍។<br>- យល់ដឹងនិងអនុវត្តគោលនយោបាយពាក់ព័ន្ធស្តីពីសាលារៀនសុវត្ថិភាព និងកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ ដើម្បីគ្រប់គ្រង និងដំណើការសាលារៀន។<br>- ត្រួតពិនិត្យទូទៅ លើការរៀបចំទិវា កាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ ដើម្បីអប់រំសាលារៀន និងសហគមន៍ទាំងមូល ដោយធានាថា បទពិសោធន៍ នៃទិវានេះ មានទំនាក់ទំនងជាមួយការសិក្សារៀនសូត្រផ្លូវការ។<br>- ដឹកនាំសាលារៀន បង្កើត និងផ្សព្វផ្សាយពីទស្សនៈរួម ដើម្បីសិក្សារៀនសូត្រពី កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។<br>- បង្កើតវេទិកាពិភាក្សារវាងសាលារៀន និងសហគមន៍ស្តីពី កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីធានានូវឱកាសចូលរួមរបស់សិស្ស។ |

| | |
|---|---|
| | - កៀរគរធនធាន និងលើកកម្ពស់កិច្ចសហការរវាងសាលារៀន និងសហគមន៍មូលដ្ឋាន ដើម្បីសម្រេចបានគោលដៅកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ របស់សាលារៀន។<br>- ពិនិត្យតាមដានការសិក្សារៀនសូត្រ ពីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ នៅក្នុងសាលារៀន(របស់សិស្ស គ្រូបង្រៀន និងបុគ្គលិកការិយាល័យ)។<br>- ធ្វើឱ្យមានការយល់ដឹងក្នុងចំណោម PTA និងគណៈគ្រប់គ្រង សាលា/គណៈកម្មការទ្រទ្រង់សាលា/ក្រុមប្រឹក្សាភិបាលសាលាពីសារៈសំខាន់ នៃទំនាក់ទំនងរវាងការសិក្សារៀនសូត្រអំពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ជាផ្លូវការ ជាមួយនឹងអគារសិក្សាមានសុវត្ថិភាព ការគ្រប់គ្រងសាលារៀនសុវត្ថិភាព វប្បធម៌សាលារៀនមានសុវត្ថិភាព និងមានភាពធន់ទ្រាំ។<br>- ចូលរួម និងកសាងភាពជាដៃគូជាមួយអង្គការ ឬ ក្រុមនានា ក្នុងសហគមន៍ អាជ្ញាធរមូលដ្ឋាន ចាស់ព្រឹទ្ធាចារ្យ ដើម្បីគាំទ្រ ការសិក្សារៀនសូត្រពី ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ របស់សិស្ស។ |
| **គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលា /គណៈកម្មការគ្រប់គ្រងសាលារៀន/ ក្រុមប្រឹក្សាភិបាលសាលា** | - ធានានូវការបណ្តុះបណ្តាល ដល់គ្រូបង្រៀន និងសិស្សជាអ្នកដឹកនាំ (សមាជិកគណៈកម្មាធិការប្រតិបត្តិ ក្រុមប្រឹក្សាកុមារ និងគណៈ កម្មាធិការសាខា)? ពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការអនុវត្ត ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅក្នុង សាលារៀននិងសហគមន៍។<br>- ពិនិត្យតាមដាន និងធានានូវការវាយតម្លៃ ការអនុវត្តរួមរបស់ សាលារៀន ពីការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ ដោយផ្តោតលើអគារសិក្សា ការគ្រប់គ្រង និងកម្មវិធីសិក្សា ជាពិសេស គុណភាព និងទំនាក់ទំនងរវាងផ្នែកទាំងអស់។<br>- បង្កើតកម្មវិធីពិសេស ស្តីពីការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្ត- រាយដើម្បីគាំទ្រយ៉ាងសកម្ម និងលើកទឹកចិត្តសហគមន៍ សាលារៀន ទាំងមូល ធ្វើឱ្យសម្រេចនូវគោលដៅដែលបានគ្រោងទុក។<br>- ធានានូវការគ្រប់គ្រងធនធាននៅក្នុងសាលារៀនប្រកបដោយប្រសិទ្ធភាព និង ប្រសិទ្ធផល។<br>- ពិនិត្យមើលជាទូទៅ ក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងគ្រោះ មហន្តរាយ របស់សាលារៀន ដែលមានតំណាងសិស្សចូលរួម និងមានភារកិច្ចរៀបចំធ្វើបច្ចុប្បន្នភាពផែនការសាលារៀនសុវត្ថិភាព ដោយធានាថាផែនការមានគ្របដណ្តប់ផ្នែកនីមួយៗ នៃកម្មវិធីសិក្សា។ |
| **គ្រូបង្រៀន** | - ដឹងពីវិធីបញ្ជ្រាប ការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ ទៅក្នុងមេរៀន និងកម្មវិធីសិក្សាព្រមទាំងការផ្សព្វផ្សាយក្នុងសាលារៀន និងសហគមន៍<br>- ដឹងពីវិធីសាស្ត្រសម្របសម្រួលការសិក្សារៀនសូត្រ ពីការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយទាំងក្នុង និងក្រៅថ្នាក់រៀន។<br>- ធ្វើឱ្យការសិក្សារៀនសូត្រពីការកាត់បន្ថយហានិភ័យនៃគ្រោះ មហន្តរាយទាំងក្នុង និងក្រៅថ្នាក់រៀនឱ្យមានភាពរស់រវើក ដោយ ប្រើប្រាស់ នូវ វិធីសាស្ត្របង្រៀនចម្រុះ។<br>- បង្កើតបរិស្ថានគាំទ្រក្នុងការសិក្សារៀនសូត្រ ដែលធ្វើឱ្យអ្នករៀន មានអារម្មណ៍ល្អ និងជំរុញទឹកចិត្តក្នុងការចូលរួម និងចែករំលែក ចំណេះដឹង និងបទពិសោធន៍។ |

| | |
|---|---|
| | - រៀបចំកិច្ចប្រជុំទៀងទាត់ជាមួយមាតាបិតា ដើម្បីផ្លាស់ប្តូរទស្សនៈ ពីសមិទ្ធផលរបស់សិស្ស ទាក់ទងនឹងការសិក្សារៀនសូត្រ ការកាត់ បន្ថយ ហានិភ័យនៃគ្រោះមហន្តរាយ ទាំងក្នុង និង ក្រៅថ្នាក់រៀន។<br>- បន្តលើកកម្ពស់សមត្ថភាពបង្រៀនផ្ទាល់ខ្លួនតាមរយៈការឆ្លុះបញ្ចាំងការរៀនសូត្រ និងការបើក ទូលាយក្នុងការទទួលយក ចំណេះដឹងថ្មី។ |

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ក្នុងមេរៀននេះបង្ហាញអំពី «តួនាទីក្រុមការងារសាលារៀនសុវត្ថិភាព»។ ក្រុមការងារសាលារៀនសុវត្ថិភាព មានតួនាទីសំខាន់ក្នុងការអនុវត្តកម្មវិធី កាត់បន្ថយ ហានិភ័យនៃគ្រោះ មហន្តរាយ។ សមាសភាពចូលរួមក្នុង តួនាទីនិងភារកិច្ចនៃអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងសាលារៀនមានដូចជា នាយកសាលា គណៈគ្រប់គ្រងសាលា គណៈកម្មការទ្រទ្រង់សាលា ក្រុមប្រឹក្សាកុមារ និងគ្រូបង្រៀន។ គណៈកម្មការ គ្រប់គ្រងគ្រោះមហន្តរាយ នៅសាលារៀន ត្រូវសហការយ៉ាងជិតស្និទ្ធ ជាមួយគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយឃុំស្រុក ដើម្បីកៀរគរធនធាន និងការ គាំទ្រលើការងារកាត់បន្ថយហានិភ័យ នៅក្នុងសាលារៀន។

**២-៥ ឯកសារសិក្សាបន្ថែម**

- កម្មវិធីសាលាកុមារមេត្រី(ទំព័រទី៣៥ ដល់ទំព័រទី៣៧)

**២-៦ ការអនុវត្ត**

សាលារៀននីមួយៗ ត្រូវបង្កើតក្រុមការងារសាលារៀនសុវត្ថិភាពដូចក្រុមទាំង៥ខាងលើ (១)ក្រុមផ្សព្វផ្សាយ និងប្រកាសព័ត៌មាន (២)ក្រុមជម្លៀស (៣)ក្រុមរុករកនិងសង្គ្រោះ (៤)ក្រុមសង្គ្រោះបន្ទាន់ (៥) ក្រុមសន្តិសុខ ដោយកំណត់អំពីតួនាទីតាមក្រុមនីមួយៗត្រឹមត្រូវ រួចត្រូវមានការប្រជុំផ្សព្វផ្សាយពីតួនាទីក្នុងរចនាសម្ព័ន្ធនៃក្រុមការងារទាំង៥ និង ចូលរួមសកម្មភាពជំរុញកិច្ចការតាមតួនាទីបន្ថែម និងលើកសកម្មភាពដើម្បីអនុវត្តតាមផែនការសកម្មភាពដែលគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយបានរៀបចំ។

**សំណួរ**

១- តើក្រុមការងារសាលារៀនសុវត្ថិភាពមានអ្វីខ្លះ?

២- តើក្រុមនីមួយៗមានតួនាទីទទួលខុសត្រូវដូចម្តេចខ្លះ?

៣- ហេតុអ្វីបានជាត្រូវកំណត់តួនាទី និងភារកិច្ចរបស់ក្រុមនីមួយៗ ក្នុងយន្តការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន?

# មេរៀនទី៣៖ ការពិនិត្យសមភាពយេនឌ័រ និងបរិយាបន្ន ក្នុងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

## ១- វត្ថុបំណង

- ប្រាប់បានពីបញ្ញត្តិសមភាពយេនឌ័រនិងបរិយាបន្នសង្គមព្រមទាំងទស្សនាទានទាក់ទងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ តាមរយៈអនុសញ្ញាCEDAW ស្តីពីការផ្សារភ្ជាប់សមភាពយេនឌ័រទៅនឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនិងភាពធន់ អនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- បញ្ជ្រាបសមភាពយេនឌ័រ និងបរិយាបន្នក្នុងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ និងសកម្មភាពរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន កម្រិតសាលារៀន
- លើកកម្ពស់សិទ្ធិ និងកិច្ចការពារកុមារ សមភាពយេនឌ័រ និងបរិយាបន្ន ដោយគ្មានការរើសអើងពីអាយុ ឋានៈ ភេទ ជនជាតិ សាសនា ពណ៌សម្បុរ ជនមានពិការភាព និងការផាត់ចេញពីសង្គម។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

ក្នុងមេរៀននេះអ្នកសិក្សានឹងសិក្សាផ្តោតលើ សមភាពយេនឌ័រ និងបរិយាបន្នក្នុងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ ជាការងារចាំបាច់ ដែលធ្វើឡើងតាមរយៈគោលការណ៍ណែនាំ ការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ប្រកបដោយបរិយាបន្ន។ អនុសញ្ញា CEDAW ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាស្តីពីសិទ្ធិមនុស្ស ត្រូវបានដាក់បញ្ចូលទៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ ។

### ២-២ ពាក្យគន្លឹះ

- ***យេនឌ័រ*** សំដៅលើតួនាទី ឥរិយាបថ សកម្មភាពនិងគុណលក្ខណៈដែលសង្គមមួយ នៅពេលណាមួយ កំណត់ថាសមស្របសម្រាប់បុរស ស្ត្រី ។ ក្រៅពីគុណលក្ខណៈនិងឱកាសក្នុងសង្គមដែលពាក់ព័ន្ធនឹងភាពជាបុរស និងភាពជាស្ត្រីនិងទំនាក់ទំនងរវាងបុរស និងស្ត្រី ក្មេងប្រុសនិង ក្មេងស្រី យេនឌ័រ ក៏សំដៅលើទំនាក់ទំនងរវាងស្ត្រី និងទំនាក់ទំនងរវាងបុរសផងដែរ។ គុណលក្ខណៈ ឱកាស និងទំនាក់ទំនង ទាំងនេះ ត្រូវបានបង្កើតឡើងក្នុងសង្គម និងរៀនសូត្រ តាមរយៈដំណើរការសង្គមនីយកម្ម ។ គុណលក្ខណៈ ឱកាស និងទំនាក់ទំនងនេះ មានភាពជាក់លាក់តាមបរិបទ ពេលវេលា និងអាចកែប្រែបាន។ យេនឌ័រកំណត់ពីអ្វីដែលបានរំពឹងទុក អនុញ្ញាតនិងឱ្យតម្លៃលើស្ត្រីឬបុរសម្នាក់ក្នុងបរិបទមួយ។ ក្នុងសង្គមភាគច្រើន មានភាពខុសគ្នានិងវិសមភាពរវាងបុរសនិងស្ត្រី ក្នុងការទទួលខុសត្រូវ ដែលបានកំណត់សកម្មភាពដែលធ្វើឡើង ការទទួលបាន និងគ្រប់គ្រងធនធាន ក៏

ដូចជាឱកាសក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។យេនឌ័រគឺជាផ្នែកមួយនៃបរិបទសង្គម វប្បធម៌ ទូលំទូលាយ ដូចលក្ខណៈវិនិច្ឆ័យសំខាន់ៗផ្សេងៗទៀត សម្រាប់ការវិភាគសង្គមវប្បធម៌ ដែរ ដូចជាវណ្ណៈ ជាតិសាសន៍ កម្រិតភាពក្រីក្រ ក្រុមជាតិពន្ធុ ទំនោរផ្លូវភេទ អាយុ។ល។

- ***សមភាពយេនឌ័រ*** គឺជាសិទ្ធិ ការទទួលខុសត្រូវ និងឱកាសស្មើគ្នារវាងបុរស និងស្ត្រី និងរវាងក្មេងប្រុស ក្មេងស្រី សមភាពមិនមានន័យថា បុរស និងស្ត្រីនឹងមានលក្ខណៈដូចគ្នានោះទេ ប៉ុន្តែសំដៅថាលើសិទ្ធិ ការទទួលខុសត្រូវនិងឱកាសរបស់ស្ត្រីនិងបុរស នឹងមិនអាស្រ័យលើថាតើពួកគេកើតមកមានភេទ ប្រុស ឬស្រីនោះទេ។ សមភាពយេនឌ័រ មានន័យថា ផលប្រយោជន៍ តម្រូវការនិងអាទិភាពរបស់ស្ត្រីនិងបុរសត្រូវបានលើកមកពិចារណាដោយកត់សម្គាល់ ទោះបីលក្ខណៈចម្រុះនៃក្រុមស្ត្រីនិងក្រុមបុរស។ សមភាពយេនឌ័រ មិនមែនជាបញ្ហារបស់ស្ត្រីតែម្ខាងឡើយ ប៉ុន្តែបុរស និងស្ត្រីគួរពាក់ព័ន្ធនិងការចូលរួមឱ្យបានពេញលេញ។ សមភាពរវាងស្ត្រី និងបុរសត្រូវបានចាត់ទុកជាបញ្ហាសិទ្ធិមនុស្ស និងជាបុរេលក្ខខណ្ឌ និងសូចនាករសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលផ្តោតការយកចិត្តទុកដាក់លើមនុស្សផងដែរ។ សមភាពយេនឌ័ររួមបញ្ចូលទាំងសកម្មភាពផ្លូវការនិងសមភាពជាក់លាក់។
- ***ការបញ្ជ្រាបយេនឌ័រ*** ជាអភិក្រមដែលត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធ អង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ សម្រាប់ការសម្រេចបានវឌ្ឍនភាព នៃសិទ្ធិរបស់ស្ត្រី និងក្មេងស្រី ក្នុងនាមជាសំណុំរងនៃសិទ្ធិមនុស្ស ដែលអង្គការសហប្រជាជាតិប្តេជ្ញាសម្រេចឱ្យបាន។ការបញ្ជ្រាបយេនឌ័រ មិនមែនជាគោលដៅឬវត្ថុបំណងឡើយ ប៉ុន្តែជាយុទ្ធសាស្ត្រសម្រាប់ការអនុវត្តសមភាពកាន់តែប្រសើរសម្រាប់ស្ត្រីនិងក្មេងស្រី ធៀបនឹងបុរសនិងក្មេងប្រុស។ ការបញ្ជ្រាបទស្សនៈយេនឌ័រ ជាដំណើរការវាយតម្លៃ ផលវិបាកនៃសកម្មភាពដែលបានគ្រោងឡើងលើស្ត្រីនិងបុរស ដូចជាច្បាប់ គោលនយោបាយ ឬកម្មវិធីនៅគ្រប់ផ្នែក គ្រប់កម្រិត។ ការបញ្ជ្រាបយេនឌ័រ ជាវិធីមួយក្នុងការដាក់បញ្ចូលការព្រួយបារម្ភ និងបទពិសោធរបស់ស្ត្រី និងបុរស ជា-***សមធម៌យេនឌ័រ*** អង្គការសហប្រជាជាតិនិយមប្រើពាក្យ "សមភាពយេនឌ័រ" ជាង " សមធម៌យេនឌ័រ"។ " សមធម៌យេនឌ័រ" បញ្ជាក់ពីជាតុផ្សំមួយនៃការបកស្រាយយុត្តិធម៌សង្គមដែលជាទូទៅផ្អែកលើ ប្រពៃណី ទំនៀមទម្លាប់ សាសនាឬវប្បធម៌ ដែលជាញឹកញាប់បង្កអន្តរាយដល់ស្ត្រី។ ការប្រើប្រាស់សមធម៌ក្នុងការលើកកម្ពស់ស្ត្រី ត្រូវបានកំណត់ថា មិនអាចទទួលយកបាន។ សន្និសីទក្រុងប៉េកាំងឆ្នាំ១៩៩៥ បានសម្រេចប្រើប្រាស់ពាក្យ "សមភាព"។ ក្រោយមកទៀត ពាក្យ "សមភាព" ត្រូវបានអនុម័តដោយ គណៈកម្មាធិការ CEDAW ក្នុងអនុសាសន៍ទូទៅលេខ ២៨ ដែលលើកឡើងថា " រដ្ឋភាគីត្រូវបានអំពាវនាវ ឱ្យប្រើប្រាស់តែទស្សនាទាននៃសមភាព របស់ស្ត្រី និងបុរស ឬ សមភាពយេនឌ័រ តែប៉ុណ្ណោះនិងមិនត្រូវប្រើប្រាស់ទស្សនាទាននៃសមធម៌យេនឌ័រក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន

ក្រោមអនុសញ្ញានេះឡើយ។ទស្សនាទាននៃសមធម៌យេនឌ័រ ត្រូវបានប្រើប្រាស់ក្នុងយុត្តាធិការមួយចំនួនដើម្បីសំដៅលើការប្រព្រឹតដោយយុត្តិធម៌ ចំពោះស្ត្រីនិងបុរសទៅតាមតម្រូវការយុត្តធិការទាំងនោះ។ ពេលគឺអាចរួមមានការប្រព្រឹតដោយស្មើភាពឬផ្សេងពីនេះ តែត្រូវចាត់ទុកថា សមមូលពាក់ព័ន្ធនឹងសិទ្ធិ អត្ថប្រយោជន៍ កាតព្វកិច្ចនិងឱកាស។ ចំណុចស្នូលនៃការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ និងកម្មវិធី ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមទាំងអស់ ដើម្បីឱ្យស្ត្រីនិងបុរស ទទួលបានអត្ថប្រយោជន៍ស្មើគ្នា និងមិនជំរុញឱ្យមានវិសមភាព។ គោលដៅចុងក្រោយ នៃការបញ្ជ្រាបយេនឌ័រគឺការសម្រេចបានសមភាពយេនឌ័រ។

- ***បរិយាបន្នសង្គម*** ជាដំណើរការនៃការបង្កើនលក្ខខណ្ឌនៃការចូលរួមក្នុងសង្គមជាពិសេសសម្រាប់ជនដែលជួបការលំបាក តាមរយៈការបង្កើនឱកាស ការទទួលបានធនធាន សំឡេងនិងការគោរពសិទ្ធិ។ មានន័យថាសមាជិក និងបុគ្គលគ្រប់ផ្នែកទាំងអស់ក្នុងសង្គមទទួលបានសិទ្ធិ និងអត្ថប្រយោជន៍ស្មើគ្នាក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមដោយមិនមានការរើសអើង ដោយផ្អែកលើភេទ អាយុ ទីតាំងភូមិសាស្ត្រ ជាតិពន្ធុ ទីកន្លែងកំណើត សាវតារអប់រំ ស្ថានភាពសេដ្ឋកិច្ច វណ្ណៈ សាសនា ពិការភាព អត្តសញ្ញាផ្លូវភេទស្ថានភាពសុខភាពឬកត្តាផ្សេងទៀត។
- ***ការផាត់ចេញពីសង្គម*** ជាដំណើរដែលបុគ្គលឬក្រុមត្រូវបានផាត់ចេញទាំងស្រុងឬដោយផ្នែកមិនឱ្យមានការចូលរួមក្នុងសង្គមដែលពួកគេរស់នៅ (ប្រភព Kabeer 2005)។ ទស្សនាទាននៃការផាត់ចេញពីសង្គមមានដើមកំណើតនៅអឺរ៉ុបទស្សវត្សរ៍ទី៧០។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ២០៣០ «គ្មាននរណាម្នាក់ត្រូវបានផាត់ចេញពីសង្គមឡើយ»។ ក្របខណ្ឌការផាត់ចេញពីសង្គម ផ្តល់ជូននូវវិធីរួមបញ្ចូលគ្នានៃការពិនិត្យមើលលើទម្រង់ផ្សេងៗគ្នានៃគុណវិបត្តិដែលមានទំនោរ ត្រូវបានដោះស្រាយដោយឡែកពីគ្នាក្នុងការសិក្សាលើការអភិវឌ្ឍ និងចាប់យកបទពិសោធនៃក្រុមនិងប្រភេទមួយចំនួនត្រូវបាន «ទុកដោយឡែក» «បំបាត់ចោល» ឬ «ផាត់ចេញ» (ប្រភព UN DESA )
- ***ពិការភាព*** ជាទស្សនាទានដែលវិវត្តមិនឈប់ឈរ និងបណ្តាលមកពីអន្តរកម្ម រវាងជនមានកម្សោយ និងឧបសគ្គផ្នែកឥរិយាបថ និងបរិស្ថានដែលរារាំងមិនឱ្យពួកគេចូលរួមពេញលេញនិងប្រកបដោយប្រសិទ្ធភាពក្នុងសង្គមដោយស្មើភាពគ្នាជាមួយអ្នកដទៃ។
- ***ហានិភ័យគ្រោះមហន្តរាយ*** អានុភាពនៃការបាត់បង់ដោយគ្រោះមហន្តរាយ លើអាយុជីវិត សុខភាព ជីវភាពរស់នៅ ទ្រព្យសម្បត្តិ និងសេវាកម្មនានាដែលអាចកើតឡើងចំពោះសហគមន៍និងសង្គមនៅពេលមួយក្នុងពេលអនាគត។
- ***ភាពធន់*** ជាសមត្ថភាពរបស់ប្រព័ន្ធ សហគមន៍ឬសង្គមដែលប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ដើម្បីទប់ទល់ សម្របទៅតាមនិងស្តារពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ឱ្យបានទាន់ពេល និង

មានប្រសិទ្ធភាព តាមរយៈសកម្មភាពនានាដោយសិក្សាពីគ្រោះមហន្តរាយពីអតីតកាល ឱ្យមានការប្រុងប្រយ័ត្ន នាពេលអនាគតនិងចាត់វិធានការឱ្យបានប្រសើរឡើងនូវការកាត់បន្ថយហានិភ័យ។

- ***ហានិភ័យ*** ភាពដែលអាចកើតមានផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក ដែលបណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ឬមនុស្សទៅនឹងភាពងាយរងគ្រោះ
- ***CEDAW*** ( ស៊ី ដ ) ជាអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ CEDAW Convention on The Elimination of Descrimation Againt Women (យោងគោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ប្រកបដោយបរិយាបន្ន របស់ គ- ជ- គ- ម ២០២១)

## ២-៣ ខ្លឹមសារមេរៀន

មេរៀននេះ នឹងបង្ហាញ លោកអ្នកឱ្យយល់ដឹងខ្លឹមសារសំខាន់ៗថា តើការពិនិត្យលើសមភាពយេនឌ័រ និងបរិយាបន្ន ក្នុងការងារការបន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ មានអ្វីខ្លះ? តើមានបទដ្ឋានគតិយុត្តអ្វីខ្លះបង្ហាញពីសមភាពយេនឌ័រ និងបរិយាបន្ន ក្នុងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ?ហើយវាមានប្រយោជន៍អ្វី សម្រាប់សង្គមនិងសាលារៀនដែលត្រូវគិតគូរពីបញ្ហាប្រឈម ចំពោះស្ត្រីនិងក្មេងស្រីដែលជាជនងាយរងគ្រោះជាងបុរសនិងក្មេងប្រុស?

ក្នុងសេចក្តីផ្តើមស្តីពីអនុសញ្ញា ស៊ី-ដ (CEDAW )របស់ គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទបានចោទជាសំណួរថា តើពួកគេធ្លាប់បានឮពាក្យ "អនុសញ្ញា ស៊ី-ដ (CEDAW ) ឬគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទដែរឬទេ? ព្រមទាំងបានពន្យល់សង្ខេបអំពីអនុសញ្ញានេះនិងរបៀបដែលកម្ពុជាបានផ្តល់សច្ចាប័នដល់សន្ធិសញ្ញាអន្តរជាតិដែលចងកាតព្វកិច្ចជាផ្លូវច្បាប់។ ពិសេស បានគូសបញ្ជាក់ពីសេចក្តីសង្កេត របស់គណៈកម្មាធិការ CEDAW សម្រាប់ប្រទេសកម្ពុជា ដែលពាក់ព័ន្ធនឹងស្ត្រី និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងភាពធន់ ដូចជា ស្ត្រីនៅជនបទ ដូចការលើកឡើងក្នុងសេចក្តីសង្កេតសន្និដ្ឋានលើរបាយការណ៍តាមកាលកំណត់ទី ៦ របស់កម្ពុជា ស្តីពីអនុសញ្ញា CEDAW ឆ្នាំ ២០១៩។ ដូច្នេះក្នុងមេរៀននេះ យើងនឹងសិក្សាអំពី ការពិនិត្យទៅលើសមភាពយេនឌ័រ និងបរិយាបន្នក្នុងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ដែលមានខ្លឹមសារសំខាន់ៗ ចំនួន៥ ដូចខាងក្រោម៖

១- អនុសញ្ញាស៊ី ដ អនុសាសន៍ទូទៅលេខ៣៧ របស់គណៈកម្មាធិការ CEDAW ស្តីពីសមភាពយេនឌ័រ ក្នុងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

២- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

៣- ចក្ខុវិស័យ អាស៊ាន ២០២៥

៤- កម្មវិធីផែនការ ការងារ ADDMER ២០២១-២០២៥ ប្រទេសកម្ពុជា ។

(មានភ្ជាប់លម្អិតក្នុងឧបសម្ព័ន្ធ ក ដល់ឧបសម្ព័ន្ធ ង)

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ការបង្ហាញទំនាក់ទំនងរវាងទស្សនាទានយេនឌ័រ និងគ្រោះមហន្តរាយ ដោយប្រើទស្សនៈយល់ឃើញរបស់បុគ្គលស្ដីពីរបៀបដែលវិសមភាពបង្កជាភាពងាយរងគ្រោះ និងការយល់ឃើញថា គ្រោះមហន្តរាយអាចបង្កើនវិសមភាពទាំងនេះបន្ថែមទៀត។ នេះក៏បង្ហាញផងដែរថា ការដោះស្រាយហានិភ័យគ្រោះមហន្តរាយនឹងគ្មានប្រសិទ្ធភាពនោះទេប្រសិនបើគ្មានការបញ្ចូលតម្រូវការ និងទស្សនៈរបស់ជនរងគ្រោះបំផុត ទៅក្នុងដំណោះស្រាយ។

**២-៥ ឯកសារសិក្សាបន្ថែម**

- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- គោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាបន្ន (គ-ជ- គ- ម- )។
- អនុសញ្ញា CEDAW ការផ្សារភ្ជាប់សមភាពយេនឌ័រទៅនឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងភាពធន់
- អនុសញ្ញា CEDAW និងសិទ្ធិមនុស្ស

**២-៦ ការអនុវត្ត**

តាមរយៈការពិនិត្យលើបញ្ហាសមភាពយេនឌ័រ និងបរិយាបន្ន ទៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ សម្រាប់កម្ពុជាក្នុងមេរៀននេះ បានបង្ហាញច្បាស់ពីការឆ្លើយតបទៅនឹងបទដ្ឋានគតិយុត្ត និងផែនការជាច្រើន ទាក់ទងនឹង: អនុសញ្ញាស៊ី -ដ ច្បាប់ស្តីពីអំពើហិង្សាលើស្ត្រី និងកុមារ ផែនការមេស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៩-២០៣០)ដែលប៉ាន់ប្រមាណពីការដាក់បញ្ចូលក្នុងស្ថាប័ននូវការបញ្ជ្រាបយេនឌ័រ ក្នុងការវិនិយោគលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយផលប៉ះពាល់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់ការរួមចំណែកដល់ភាពធន់នឹងអាកាសធាតុប្រកបដោយសមធម៌ និងសង្គមប្រកបដោយនិរន្តរភាពនៅកម្ពុជា។ ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៩-២០២៣) ផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៣-២០២៣)ផែនការនារីរតនៈទី ៥ (២០១៩-២០២៣) ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣)ដែលផ្តោតលើការពង្រឹងយន្តការបញ្ជ្រាបយេនឌ័រនៃកម្មវិធីតាមវិស័យ និងកម្មវិធីជាតិ ដូចជាការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ។ ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (២០១៥) ដែលបានជំរុញការបញ្ជ្រាបក្នុងស្ថាប័ននូវហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ប្រព័ន្ធ ការអនុវត្ត និងផែនការដែលមានស្រាប់ ទៅក្នុងឧបករណ៍ចងកាតព្វកិច្ចផ្លូវច្បាប់។

មាត្រា ១៨ នៃច្បាប់នេះចែងថា «ក្នុងករណីដែលមានព្រឹត្តិការណ៍ ឬឧបទ្ទវហេតុកើតឡើង អាជ្ញាធរមានសមត្ថកិច្ចដែលមានទីតាំងនៅតំបន់កើតហេតុត្រូវយកចិត្តទុកដាក់ខ្ពស់លើតម្រូវការរបស់ស្ត្រី កុមារ ចាស់ជរា ជនពិការ និងជនបាត់បង់លទ្ធភាពពលកម្ម»។ ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០១៥ ក្នុងមាត្រា៣ ស្តីពីតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយចែងថា គណៈកម្មាធិការនេះនឹង «សម្របសម្រួលការអនុវត្តសកម្មភាពការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍប្រកបដោយចីរភាព យេនឌ័រ ដោយសារសហការជាមួយក្រសួងពាក់ព័ន្ធ អភិវឌ្ឍ និងពង្រឹងស្ថាប័ន យន្តការ និងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ជាន់ថ្នាក់ ជាពិសេសនៅថ្នាក់មូលដ្ឋានសហគមន៍ ធានាដល់ការឆ្លើយតបបានល្អប្រសើរពេលមានគ្រោះអាសន្ន»។ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨) ទទួលស្គាល់ថា ស្ត្រី និងក្មេងស្រីកាន់តែងាយប្រឈមនឹងហានិភ័យនៃអំពើហិង្សាផ្លូវភេទ ការកេងប្រវ័ញ្ច ការរំលោភបំពាន ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារក្នុងពេលកើតមានគ្រោះមហន្តរាយ។ ស្ត្រីដែលទទួលរងអំពើហិង្សាមុនពេលកើតមានគ្រោះមហន្តរាយ ច្រើនតែទទួលរងអំពើហិង្សាធ្ងន់ធ្ងរជាងមុន ក្រោយពេលកើតមានគ្រោះមហន្តរាយ ព្រោះពួកគេត្រូវបានកាត់ផ្តាច់ចេញពីប្រព័ន្ធគាំទ្រ និងប្រព័ន្ធការពាររបស់ពួកគេ។ ស្ត្រីដែលងាយប្រឈមនឹងហានិភ័យ ច្រើនតែប្រឈមនឹងអំពើហិង្សា និងមិនសូវទទួលបានយុត្តិធម៌ រួមចំណែកក្នុងការកាត់បន្ថយ ការរើសអើង ការផាត់ចេញពីសង្គម ។ ពិសេស ជំរុញនិងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាយេនឌ័រ និងបរិយាបន្នដែលត្រូវអនុវត្តនៅតាមសាលារៀន តាមរយៈការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកសធាតុ ជាដើម ។

**សំណួរ**

១- តើសេចក្តីផ្តើមស្តីពីអនុសាសន៍ទូទៅលេខ ២៧ របស់គណៈកម្មាធិការ CEDAW ) និងកថាខណ្ឌទី ៤ ស្តីពីសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ CEDAW កម្ពុជាលើរបាយការណ៍តាមកាលកំណត់ទី ៦ ឆ្នាំ ២០១៩ ខាងលើ បានបង្ហាញពីទស្សនៈយេនឌ័រ និងបរិយាបន្នក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ ដូចម្តេចខ្លះ ?

២- តើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានបង្ហាញគំនិតសំខាន់ៗអ្វីខ្លះ ទាក់ទងការពិនិត្យទៅលើសមភាពយេនឌ័រទៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ?

៣- តើចក្ខុវិស័យអាស៊ាន ២០២៥ បានគិតគូរអំពីបញ្ហាសមភាពយេនឌ័រ និងបរិយាបន្នក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយអ្វីខ្លះ ?

៤- នៅកម្ពុជា តើមានគោលនយោបាយ ផែនការយុទ្ធសាស្ត្រអ្វីខ្លះ សម្រាប់អនុវត្តការបញ្ជ្រាបយេនឌ័រ និងបរិយាបន្ន ? ចូរសង្ខេបចំណុចសំខាន់ៗ។

# ជំពូកទី៣ មុខសញ្ញាគ្រោះថ្នាក់ និង ហានិភ័យ

**សេចក្តីណែនាំ**

ជំពូកនេះ យើងនឹងសិក្សាប្រធានបទអំពីមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ។ នៅក្នុងជំពូកនេះ មានមេរៀនចំនួន៥ដែល បង្ហាញពី(១)មុខសញ្ញាគ្រោះថ្នាក់ (២)ប្រភេទហានិភ័យ (៣)វិភាគមុខសញ្ញាគ្រោះថ្នាក់ (៤)ផែនទីមុខសញ្ញាគ្រោះថ្នាក់និងទី(៥) វិភាគសមត្ថភាពនិងចំណុចខ្វះខាត។

# មេរៀនទី១៖ មុខសញ្ញាគ្រោះថ្នាក់

## ១- វត្ថុបំណង

- ប្រាប់ពីមុខសញ្ញាគ្រោះថ្នាក់នៅក្នុងសាលារៀន
- កំណត់មុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុងសាលារៀន
- បណ្តុះស្មារតីប្រុងប្រយ័ត្នចំពោះមុខសញ្ញាគ្រោះថ្នាក់និងផលប៉ះពាល់នៅក្នុងសាលារៀន។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ យើងនឹងសិក្សាប្រធានបទអំពីមុខសញ្ញាគ្រោះថ្នាក់។ នៅក្នុងមេរៀននេះ មានប្រភេទមុខសញ្ញាគ្រោះថ្នាក់ ចំនួន៧ ប្រភេទ ដែលបង្ហាញពីប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់នីមួយៗ មូលហេតុការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ ផលប៉ះពាល់ របស់មុខសញ្ញាគ្រោះថ្នាក់ដូចជា

1. ទឹកជំនន់
2. រាំងស្ងួត
3. ខ្យល់ព្យុះ ឬខ្យល់កន្ត្រាក់
4. រន្ទះបាញ់
5. ជំងឺឆ្លង
6. គ្រោះថ្នាក់ចរាចរណ៍
7. អគ្គិភ័យ

### ២-២ ពាក្យគន្លឹះ

**មុខសញ្ញាគ្រោះថ្នាក់** សំដៅចំនុច ឬទីតាំងនានាដែលអាចកើតមាន និងបង្កការគំរាមកំហែង ដល់មនុស្ស រងរបួស ឬមានការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត ដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សាលារៀន និងសហគមន៍។

### ២- ៣ ខ្លឹមសារមេរៀន

មុខសញ្ញាគ្រោះថ្នាក់ដែលតែងតែជួបប្រទះមានដូចជា ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ឬខ្យល់កន្ត្រាក់ រន្ទះបាញ់ ជំងឺឆ្លង  គ្រោះថ្នាក់ចរាចរណ៍ អគ្គិភ័យជាដើម។ ជាញឹកញាប់មុខសញ្ញាគ្រោះថ្នាក់នីមួយៗ តែងតែបង្កការបារម្ភជាច្រើន ដល់សាលារៀន និងតំបន់ទាំងឡាយ ដែលមានភូមិសាស្ត្រជាប់សាលារៀន។ គេសង្កេតឃើញជារួមថា គ្រោះទឹកជំនន់ និង រាំងស្ងួតជាគ្រោះមហន្តរាយ ដែលបង្កជាហានិភ័យខ្លាំងដល់សាលា និងវិស័យអប់រំទាំងមូល។ ទន្ទឹមនឹងនេះ គណៈគ្រប់គ្រង គ្រូ សិស្ស និងសហគមន៍ ត្រូវដឹងមូលហេតុ និងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយដើម្បីបញ្ចៀសមុខសញ្ញាគ្រោះថ្នាក់ដូចខាងក្រោម៖

## ១- ទឹកជំនន់

គ្រោះទឹកជំនន់កើតឡើងនៅពេលដែលកម្រិតទឹកឡើងលើសពីសភាពធម្មតា ដែលបណ្ដាលឱ្យ លិចលង់ផ្ទៃដី ឬតំបន់ដីស្ងួតនៅពេលធម្មតា។ ទឹកជំនន់គឺជាគ្រោះមហន្តរាយមួយប្រភេទ ដែលការខូចខាត និងផលប៉ះពាល់មានទំហំធំបំផុតក្នុងចំណោមមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗទៀត។ ទឹកជំនន់អាចបណ្ដាល មកពីការធ្លាក់ភ្លៀងច្រើនលើសពីធម្មតា ខ្យល់ព្យុះធំៗ ដែលនាំមកជាមួយនូវទឹករលកធំៗចូលភូមិដ្ឋាន ការបាក់ទំនប់ ការរលាយទឹកកកយ៉ាងឆាប់រហ័សជាដើម...។

ទោះជាយ៉ាងណាក្ដី ទឹកជំនន់បានផ្ដល់នូវផលប្រយោជន៍ផងដែរ បើមិនបានបង្កើតនូវគ្រោះមហន្តរាយ ព្រោះបានចូលរួមចំណែករក្សាលំនឹងធម្មជាតិក្នុងទន្លេ (ប្រព័ន្ធអេកូឡូជី)។ ទឹកជំនន់បានបំពេញឡើងវិញនូវជីជាតិក្នុងដី ផ្ដល់ទឹកស្រោចស្រពដំណាំនិងការនេសាទ ហើយក៏បានផ្គត់ផ្គង់ទឹក សម្រាប់ទ្រទ្រង់ដីដែលស្ងួតសោះកក្រោះផងដែរ។

### ក- ប្រភេទទឹកជំនន់

១- ១ ទឹកជំនន់ដែលកើតឡើងភ្លាមៗដោយសារទឹកភ្លៀង (Flash flood)

- តែងកើតមានឡើងនៅតាមដងទន្លេតូចៗ ឬតំបន់ភ្នំដែលមានផ្លូវទឹកតូចៗ
- ជាញឹកញាប់ វាកើតឡើងដោយសារតែ មានភ្លៀងធ្លាក់ជាប់ៗគ្នា ច្រើនថ្ងៃ នៅតាមតំបន់ដែលជាទីជម្រាល ដែលដើមឈើនិងរុក្ខជាតិត្រូវបានកាប់បំផ្លាញ ជាហេតុនាំឱ្យទឹកហូរលឿន ព្រោះមិនអាចស្រូបចូលក្នុងដីបាន
- កើតឡើងបន្ទាន់ភ្លាមៗ ហើយចរន្តទឹកហូរលឿន ដែលអាចប្រឈួយកនិងបោសសំអាតអ្វីៗទាំងអស់ដែលមាននៅតាមផ្លូវទឹកដែលវាហូរកាត់ចាប់ផ្ដើមកើតមានភ្លាមៗបន្ទាប់ពីមានភ្លៀងចាប់ផ្ដើមធ្លាក់យ៉ាងខ្លាំង ហើយពិបាកស្មានទុកជាមុនថាអាចនឹងកើតមាននៅទីណាណាស់
- អាចកើតមានផងដែរ នៅពេលអាងស្ដុកទឹកឬប្រព័ន្ធទំនប់ត្រូវបែកបាក់។

១- ២ ទឹកជំនន់នៅតាមទន្លេ (River flood)

- កើតមានឡើងនៅពេលដែលទឹកនៅក្នុងទន្លេហូរលឿន និងមានកម្ពស់ខុសពីធម្មតា
- ជាញឹកញាប់ គឺបណ្ដាលមកពីមានភ្លៀងធ្លាក់យ៉ាងខ្លាំងនៅផ្នែកខាងលើនៃដងទន្លេ
- អាចកើតឡើងសន្សឹមៗ (ដូចជានៅតាមដងទន្លេសាប) ឬយ៉ាងឆាប់រហ័សផងដែរ (ដូចនៅ
- តាមដងទន្លេនៅភាគកណ្ដាលនៃប្រទេសកម្ពុជា)។

១- ៣ ទឹកជំនន់នៅតាមតំបន់ឆ្នេរ (Coastal flood)

- កើតមានឡើងនៅពេលដែលព្យុះភ្លៀងខោលឡើង ឬពេលមានរលកសមុទ្រធំៗ បោកបក់មួយរំពេច គួបផ្សំនឹងជំនោរទឹកឡើងដែលនាំឱ្យបាក់ ឬមានទឹកហូរកាត់ទំនប់ការពារទឹក ស

មុទ្រ ហើយនាំឱ្យកើតមានទឹក ជំនន់ភ្លាមៗតែម្តង តែងកើតមានជារឿយៗ ជួនគ្នានឹងពេលដែលមានខ្យល់ព្យុះសម្ពាធទាប ឬព្យុះទីហ្វុង នៅជិតតំបន់ឆ្នេរ។

## ខ- មូលហេតុដែលបណ្តាលឱ្យមានគ្រោះទឹកជំនន់

- ភាគច្រើនទឹកជំនន់ បណ្តាលមកពីទឹកភ្លៀងច្រើនហួសប្រមាណ
- ការសាងសង់ផ្លូវថ្នល់ ផ្លូវដែក ប្រព័ន្ធធារាសាស្ត្រ អាចជាមូលហេតុបណ្តាលឱ្យកើតមានទឹកជំនន់ផងដែរ ព្រោះបានបិទផ្លូវទឹកហូរធម្មជាតិ (ដែលមានស្រាប់) ទៅកាន់សមុទ្រ ឬ ទន្លេ
- អាចកើតមានឡើងនៅពេលដែលទំនប់ការពារ ឬអាងស្តុកទឹកបាក់ស្រុត
- ខ្យល់ព្យុះធំៗបណ្តាលឱ្យទឹកសមុទ្រហូរហៀរលាតសន្ធឹងលើផ្ទៃដីធំធេង នាំឱ្យមានទឹកជំនន់ និងការជ្រាបចូលជាតិប្រៃក្នុងដីនោះ
- ការងារអភិវឌ្ឍន៍ដូចជាលប់បឹងត្រពាំង ឬចាក់បេតុងក្នុងក្រុងទាំងមូល ក៏ជាហេតុនាំឱ្យមានទឹកជំនន់ផងដែរព្រោះមិនមានកន្លែងស្តុកទឹកគ្រប់គ្រាន់និងទឹកមិនអាចជ្រាបចូលក្នុងដីបាន ការងារកសិកម្មដែលគ្មានបច្ចេកទេសត្រឹមត្រូវ នៅតាមទីជម្រាល ឬជើងភ្នំ នាំឱ្យបាក់ដីនិងហូរច្រោះដីចូលក្នុងទន្លេ ធ្វើឱ្យបាតទន្លេរាក់និងបណ្តាលឱ្យមានទឹកជំនន់




- ការកាប់បំផ្លាញព្រៃឈើ (ទាំងនៅតំបន់ភ្នំនិងទំនាប) នាំឱ្យមានគ្រោះទឹកជំនន់ព្រោះ មិនមានអ្វីស្រូបជាតិទឹក ម្យ៉ាងវិញទៀតក៏ជាហេតុនាំឱ្យមានការហូរច្រោះដីផងដែរ ទៅក្នុង ទន្លេ ព្រោះមិន មានស្លឹកឈើជួយបន្ថយកម្លាំងគ្រាប់ភ្លៀងដែលធ្លាក់មកដី។
  - ទីតាំងសាលារៀនទាប
  - គ្មានប្រឡាយរំដោះទឹក
  - ធ្វើផ្លូវមិនបានដាក់លូគ្រប់គ្រាន់
  - ភ្លៀងធ្លាក់ខ្លាំងនៅតំបន់ភ្នំ

## គ- ផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់

- បណ្តាលឱ្យមនុស្ស សត្វមានជំងឺ របួស ស្លាប់ និងគ្មានជម្រក

- បំផ្លាញផ្ទះសម្បែង សាលារៀន ទ្រព្យសម្បត្តិ និងរបស់របរសំខាន់ផ្សេងៗទៀតដូចជាក្មួយ មុង គ្រឿងសង្ហារឹម សម្ភារការិយាល័យ សៀវភៅសិក្សាគោល សៀវភៅរឿង ឯកសារផ្សេងៗ។ល។
- ប៉ះពាល់ដល់ជីវភាពរស់នៅរបស់មនុស្ស ព្រោះវាបានបំផ្លាញដំណាំសម្លាប់សត្វពាហនៈ បំផ្លាញស្រះចិញ្ចឹមត្រី បង្គារ ក្ដាម បង្កង ដែលជាហេតុនាំឱ្យមាន បញ្ហាកង្វះ ស្បៀងអាហារ
- ទឹកជំនន់ដែលមានរយៈពេលវែង នាំឱ្យរំខានដល់ការបង្កបង្កើនផលអាចបណ្ដាលឱ្យមានការហូរច្រោះដី ឬចាក់បំពេញដីខ្សាច់ ឬថ្មលើដីដាំដំណាំ ដែលនាំឱ្យថយបរិមាណដីបង្កើនផល
- អាចបំផ្លាញសំណង់ អគារ មានសាលារៀន មន្ទីរពេទ្យ គ្លីនិក ផ្លូវថ្នល់ ផ្លូវដែក ប្រព័ន្ធទូរស័ព្ទ និងបណ្ដាញអគ្គិសនី
- អាចរំខានដល់ការផ្គត់ផ្គង់ទឹកស្អាតនិងចម្លងមេរោគដល់ប្រភពទឹក ដែលនាំទៅរកជំងឺ
- ជួនកាលទឹកជំនន់ក៏ផ្ដល់ផលល្អផងដែរ ឧទាហរណ៍ បានជួយបំពេញឡើងវិញនូវជីវជាតិ ក្នុងដីដាំដំណាំ ជាតិទឹកក្រោមដី និងទឹកស្អាត
- សិស្សានុសិស្សមិនមករៀន
- សួនច្បារសាលាខូចខាត
- ខូចខាតសម្ភារបរិក្ខាសិក្សាតាមសាលា និង របស់កុមារ
- ការសិក្សាមិនបានចប់កម្មវិធី។

### ២- រាំងស្ងួត

គ្រោះរាំងស្ងួតកើតមានឡើងនៅពេលពុំមានភ្លៀងធ្លាក់រយៈពេលវែង ដែលនាំឱ្យប៉ះពាល់ដល់ ប្រភពទឹកទាំងនៅក្រោមដីនិងលើផ្ទៃដី។ គ្រោះរាំងស្ងួតគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ មនុស្ស ពិសេសនៅតាមតំបន់ដែលមានមនុស្សរស់នៅច្រើន។ក្នុងចំណោមគ្រោះមហន្តរាយដែលបណ្ដាលមកពីធម្មជាតិទាំងអស់ គ្រោះរាំងស្ងួតមានសក្ដានុពល ខ្លាំងជាងគេ និងប៉ះពាល់ទៅលើមនុស្សច្រើនបំផុត ព្រមទាំងទៅលើផលិតកម្មស្បៀង និងសេដ្ឋកិច្ចទាំងមូល។ តែទោះយ៉ាងណាក្ដី គ្រោះរាំងស្ងួតគឺខុសគ្នាពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិផ្សេងៗទៀត ដោយសារ តែវាកើតឡើងសន្សឹមៗ អូសបន្លាយពេលយូរ ហើយអាចបន្តជាច្រើនឆ្នាំផងដែរ។

ផលប៉ះពាល់របស់វាជាក់ស្ដែងគឺមិនសូវខ្លាំងក្លាដូចរយដី ឬខ្យល់ព្យុះ តែគ្រោះរាំងស្ងួតអាចគ្រប ដណ្ដប់លើតំបន់ភូមិសាស្ត្រយ៉ាងធំធេងជាងគ្រោះមហន្តរាយផ្សេងៗទៀត។ ដោយសារផលប៉ះពាល់រីក សាយយ៉ាងធំធេងរបស់វា ជាហេតុធ្វើឱ្យការប៉ាន់ប្រមាណពីផលប៉ះពាល់និងរៀបចំផែនការជំនួយសង្គ្រោះ បន្ទាន់មានការលំបាកជាងមុខសញ្ញាបង្កគ្រោះមហន្តរាយផ្សេងៗទៀត។ជួនកាលគ្រោះរាំងស្ងួតក៏អាចកើតមានឡើងផងដែរ ទោះបីជាមានភ្លៀងធ្លាក់ក៏ដោយ ឧទាហរណ៍ ប្រសិនបើព្រៃឈើត្រូវបានគេកាប់បំផ្លាញ ហើយដីមិន

អាចស្របយកទឹកភ្លៀងបាននោះ ទឹកនឹងហូរអស់។ ទន្ទឹមនេះប្រសិនបើមានភាពរាំងស្ងួតកើតឡើងនៅរដូវភ្លៀង ឬភ្លៀងធ្លាក់យឺតយ៉ាវនៅរដូវវស្សានោះគ្រោះ រាំងស្ងួតក៏អាចកើតមានឡើងផងដែរ។

**ក- ប្រភេទនៃភាពរាំងស្ងួត**

១- រាំងស្ងួតខាងឧត្តុនិយម ទាក់ទងទៅនឹងការថយចុះខ្លាំងនៃទឹកភ្លៀងជាងធម្មតា នៅក្នុង តំបន់មួយ និងកម្រិតអង្សាជាមូលដ្ឋានឡើងខ្ពស់ (បើប្រៀបធៀបនឹងកម្រិតអង្សាកម្តៅជាមធ្យម) និងមាន រយៈពេលក្តៅយូរ។ អត្ថន័យនៃគ្រោះរាំងស្ងួតខាងឧត្តុនិយមគឺជាការកំណត់ទៅតាមតំបន់ អាស្រ័យដោយ កម្រិតទឹកភ្លៀង និងរយៈពេលអូសបន្លាសនៃភ្លៀង។

២- រាំងស្ងួតខាងជលសាស្ត្រ គឺជារហួតនៅលើផ្ទៃទឹក (ទន្លេ បឹង ស្ទឹង និងស្រះ) ដែលគួរ ឱ្យ កត់សម្គាល់ និងសំដៅលើការមិនមាននីវ៉ូទឹកនៅក្រោមផ្ទៃដី។ ភាពកើតមានជារឿយៗ និងភាគច្រើន តែង កំណត់លើទីជម្រាល ឬកម្រិតដែនផ្ទៃទន្លេ។ ប្រសិនបើទឹកហូរជាក់លាក់នៅកំឡុងពេលណាមួយ ដែលយើងបានកំណត់មានការធ្លាក់ចុះនៅក្រោមកម្រិតអប្បបរមាមួយ នោះគ្រោះរាំងស្ងួតខាងជលសាស្ត្រពិត ជាកំពុងកើតមានឡើងហើយ។

៣- រាំងស្ងួតខាងកសិកម្ម កើតមានឡើងនៅពេលដែលដីគ្មានសំណើមគ្រប់គ្រាន់ និង ភ្លៀង ធ្លាក់មិនគ្រប់គ្រាន់សម្រាប់ដំណាំ។ វាបណ្តាលមកពីឥទ្ធិពលគ្រោះរាំងស្ងួតខាងឧត្តុនិយម និង ជលសាស្ត្រ ទៅ លើដំណាំដែលមិនមានសំណើមគ្រប់គ្រាន់ក្នុងការថែរក្សាទិន្នផល និងការលូតលាស់ជាមធ្យមនៃ ដំណាំ។ ឥទ្ធិពលគ្រោះរាំងស្ងួតខាងកសិកម្មមានការពិបាកក្នុងការវាស់វែង ព្រោះភាពសាំញ៉ាំ នៃការលូត លាស់របស់ដំណាំ និងការកើតមានឡើងនូវកត្តានានាដូចជា ដំណាំមានសត្វល្អិតចង្រៃ សម្បូររុក្ខជាតិគ្មាន ប្រយោជន៍ គុណភាពដីចុះអន់ថយ ... ។

**ខ- មូលហេតុដែលបណ្តាលឱ្យមានភាពរាំងស្ងួត**

- បាតុភូត អេលនីណូ/ឡានីណា (El Nino/La Nina)
- គ្មានភ្លៀងធ្លាក់យ៉ាងយូរ/ការកើនឡើងនូវកំដៅ
- បរិស្ថានធម្មជាតិត្រូវបានបំផ្លាញ ដីមិនអាចស្របយកទឹកដោយសារការកាប់បំផ្លាញព្រៃឈើ
- ការធ្វើអាជីវកម្មនិងការប្រើប្រាស់ទឹកដែលមិនត្រឹមត្រូវតាមបច្ចេកទេស
- រំហួតទឹកចេញពីបឹងហើយមិនមានទឹកភ្លៀងបំពេញវិញ
- ការបម្រែបម្រួលអាកាសធាតុ
- ការកើនឡើងនៃកាបូនឌីអុកស៊ីតនិងឧស្ម័នផ្ទាំងកញ្ចក់។

**គ- ផលប៉ះពាល់ដោយសាររាំងស្ងួត**

- ពិបាកស្វែងរកទឹកសម្រាប់ប្រើប្រាស់ដូចជា ទឹកផឹក ដាំស្ល សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ
- បង្កើនអត្រាជំងឺផ្សេងៗ ជាពិសេសចំពោះក្មេងនិងចាស់ជរា

- កាត់បន្ថយផលិតភាពដំណាំនិងរុក្ខជាតិនានាត្រូវងាប់ឬមិនអាចដាំឡើងវិញ ជាហេតុនាំឱ្យមានបញ្ហាខ្វះស្បៀងអាហារត្រី បង្គារ និងជីវចម្រុះផ្សេងៗទៀតនឹងស្លាប់ដោយសារទឹកស្រះត្រពាំងហួតហែង
- កសិដ្ឋានសត្វដូចជា ជ្រូក គោ ក្របីអាចនឹងត្រូវលក់ចេញ ឬប្រសិនបើរាំងស្ងួតអូសបន្លាយរយៈពេលវែងនោះ អាចនឹងឱ្យសត្វទាំងនោះងាប់ ដោយខ្វះទឹកផឹក ឬមានជំងឺ
- ដោយសារតែទន្លេលែងមានទឹកហូរ ធ្វើឱ្យតំបន់មួយចំនួនដែលនៅជិតសមុទ្រអាចនឹងត្រូវយាយីដោយសារទឹកប្រៃ
- ចំណាកស្រុកមានការកើនឡើង
- សាលាខ្វះទឹកប្រើប្រាស់ទាំងសម្រាប់ហូប និងសម្រាប់បង្គន់អនាម័យ
- ក្នុងបន្ទប់រៀនឡើងកំដៅពិបាកបង្រៀន និងរៀន
- ដំណើរការរៀនសូត្រ ត្រូវបានរំខាន ឬអាក់ខានមិនបានរៀនជាប់លាប់។

### ៣- ខ្យល់ព្យុះ និងខ្យល់កន្ត្រាក់ (ខ្យល់ព្យុះត្រូពិច ព្យុំទីហ្វុង ព្យុះស៊ីក្លូន ព្យុះសង្ឃរា)

ព្យុះត្រូពិច គឺជាពាក្យទូទៅមួយ ពិពណ៌នាអំពីសន្ទុះខ្យល់ព្យុះដ៏កំណាច រិលវល់ ដែលកើតឡើង នៅពេលទឹកសមុទ្រ នៅតំបន់ត្រូពិចមានកម្តៅក្តៅលើសពី២៦អង្សាសេ ហើយដែលស្ថិតនៅក្នុងចន្លោះ ខ្សែ រយៈទទឹង ទី៥ និងទី១៥។ ខ្យល់សម្ពាធទាបនឹងក្លាយទៅជាព្យុះត្រពិច កាលណាល្បឿនខ្យល់បក់ ហួសពី * កម្លាំងខ្យល់ខ្លាំង (សន្ទុះខ្យល់អប្បបរមា ១១៧គីឡូម៉ែត្រក្នុងមួយម៉ោង)។ នៅសមុទ្រចិនខាងត្បូងភាគពាយព្យ (ទិសខាងជើងឆៀងខាងលិច) នៃតំបន់ប៉ាស៊ីហ្វិច ខ្យល់ព្យុះរមែងកើតឡើងជារឿយៗ នៅអំឡុង ខែកក្កដា ដល់ខែវិច្ឆិកា ប៉ុន្តែគេក៏តែងដឹងថា វាមានកើតឡើងស្ទើរតែរៀងរាល់ខែនៃឆ្នាំផងដែរ។

គេអាចព្យាករណ៍ដំណើរវិវត្តនៃព្យុះត្រូពិចបាន ប៉ុន្តែលទ្ធភាពព្យាករណ៍សន្ទុះដែលវាធ្លាក់ដល់ដីគឺ អាចធ្វើបាន តែក្នុងប៉ុន្មានម៉ោងមុនប៉ុណ្ណោះ ហើយកម្រិតប្រែប្រួល ក្នុងពេលដែលវាកំពុងបោកបក់ ពិបាក នឹងទស្សន៍ទាយបានណាស់។

#### ក- មូលហេតុ

ហេតុដែលបណ្តាលឱ្យមានខ្យល់ព្យុះ និងឥទ្ធិពលសម្ពាធទាបត្រូពិចនេះ មានភាពស្មុគស្មាញ ណាស់។ មកដល់បច្ចុប្បន្ននេះ មានអ្នកវិទ្យាសាស្ត្រជាច្រើនមិនទាន់ស្រាវជ្រាវរកឃើញរាល់ បុព្វហេតុដែល បណ្តាលឱ្យមានខ្យល់ព្យុះ និងឥទ្ធិពលសម្ពាធទាបត្រូពិចនេះទេ។ តែទោះយ៉ាងណា គេអាចធ្វើសេចក្តីសន្និដ្ឋានបានថា ប្រភេទខ្យល់ទាំងនេះមកក្នុងទ្រង់ទ្រាយពីលើសមុទ្រត្រូពិច ជាពិសេសនៅក្នុងតំបន់ដែល មានសីតុណ្ហភាពពី៥ទៅ២០អង្សា នៅពេលដែលសីតុណ្ហភាពទឹក សមុទ្រខ្ពស់ជាង២៦អង្សា។

#### ខ- ផលប៉ះពាល់ដោយសារខ្យល់ព្យុះ

- ទូកឬកប៉ាល់នៅលើសមុទ្រអាចនឹងលិច

- កម្លាំងខ្យល់រុញច្រានទឹកសមុទ្រឱ្យហូរចូលទៅលើដីគោក ដែលបណ្តាលឱ្យមានទឹកប្រៃហូរ
- ចូល ធ្វើឱ្យខូចខាតដល់ដំណាំកសិកម្ម កសិដ្ឋានចិញ្ចឹមត្រី បង្គា និងក្តាម
- ទឹកបៃអាចធ្វើឱ្យទឹកអណ្តូង និងប្រភពទឹកស្អាតផ្សេងៗទៀតមិនស្អាត ផ្ទះនឹងទ្រព្យសម្បត្តិអាចទទួលរងផលប៉ះពាល់ ឬខូចខាតទាំងស្រុង
- សាលារៀន អាចទទួលរងផលប៉ះពាល់ឬខូចខាតទាំងស្រុង
- មនុស្សអាចមានរបួស ឬប៉ះពាល់ដល់អាយុជីវិត
- សត្វអាចស្លាប់បាន
- ធ្វើឱ្យដើមឈើធំរលំនិងធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើរ
- ប្រព័ន្ធអគ្គិសនីត្រូវបានកាត់បំផ្លាញ ហើយអាចបណ្តាលឱ្យមានអគ្គិភ័យឬគ្រោះថ្នាក់ដោយសារ
- ចរន្តអគ្គិសនីផងដែរ
- ប្រព័ន្ធទំនាក់ទំនងត្រូវបានកាត់ផ្តាច់
- ភ្លៀងធ្លាក់ខ្លាំងអាចបណ្តាលឱ្យមានទឹកជំនន់ និងបាក់ដី
- ប៉ះពាល់ទៅលើហេដ្ឋារចនាសម្ព័ន្ធ សម្ភារសិក្សា ម៉ោងសិក្សា និងសិស្សមិនអាចមករៀនបាន។

**៤- រន្ទះបាញ់**

ព្យុះផ្គររន្ទះហាក់ដូចជាកើតមានឡើង នៅពេលថ្ងៃ ក្តៅហើយសើម។ ព្យុះផ្គររន្ទះអាចជាគ្រោះថ្នាក់ ដ៏សម្បើម ជាពិសេសបើមនុស្ស សត្វ កំពុងស្ថិតនៅទីវាលលំហ ហើយមិនមានការការពារសមស្រប។ បើ សិនជាឮ ឬឃើញថាមានរន្ទះបាញ់ ត្រូវរួសរាន់ធ្វើការការពារភ្លាម។ នៅកន្លែងជាច្រើន រន្ទះរមែងបាញ់ នៅ ពេលរសៀល ក្នុងនិទាឃរដូវ (រដូវរំហើយ) និងរដូវក្តៅ។ ប៉ុន្តែរន្ទះក៏អាចបាញ់ប្រហាអ្នករាល់គ្នា នៅកន្លែង ផ្សេងទៀត និងនៅកន្លែងខុសៗគ្នាផងដែរ។ រន្ទះអាចបាញ់នៅកន្លែងដដែលៗច្រើនដង ច្រើនសារ។

រន្ទះបាញ់អាចបញ្ឈប់ចង្វាក់បេះដូង និងសម្លាប់អ្នក។ ប៉ុន្តែអ្នកក៏អាចទទួលការឆេះរលាក រលាក ខូចប្រព័ន្ធសរសៃប្រសាទ និងបញ្ហាសុខភាពផ្សេងៗទៀត។ អាការៈខ្លះអ្នកមិនអាចធ្វើការកត់សម្គាល់បានទេ រហូតអស់ពេលជាច្រើនខែ ក្រោយត្រូវរន្ទះបាញ់។

**ក- ផលប៉ះពាល់**

- ហេដ្ឋារចនាសម្ព័ន្ធ សម្ភារសិក្សា ម៉ោងសិក្សា និងសិស្សមិនអាចមករៀនបាន
- អាចធ្វើមនុស្សរបួស ឬពិការ និងស្លាប់
- ខូចខាតសម្ភារសិក្សា និងសម្ភារបរិក្ខារផ្សេងៗ
- ធ្វើសិស្សានុសិស្សមានភាពភ័យខ្លាច។

**៥- ជំងឺឆ្លងរាតត្បាតផ្សេងៗ**

ប្រទេសកម្ពុជាមានប្រវត្តិការកើតមានជម្ងឺ និងរោគរាតត្បាតមានដូចជា ជម្ងឺអាសន្នរោគ គ្រុនចាញ់ គ្រុនឈាម ហើយពេល ថ្មីៗនេះមានវីរុសគ្រុនផ្តាសាយបក្សី (H5N1) និងកូវីដ១៩/COVID-19ទៀតផង ។ ចាប់ពីឆ្នាំ២០២០ មកប្រទេសកម្ពុជាបានជួបប្រទេសកូវីដ១៩ / COVID-19 ជាខ្លាំង។ ជំងឺនេះបានជះឥទ្ធិពលជាអវិជ្ជមានយ៉ាងខ្លាំងលើបព័ន្ធអប់រំនៅទូទាំងពិភពលោក និងគ្រប់វិស័យទាំងអស់។

ជំងឺកូវីដ១៩ ជាជំងឺឆ្លងថ្មីមួយដលរាតត្បាតជាសាកល ហេតុនេះការយល់ដឹងពី របៀបចម្លងរោគ សញ្ញាសង្ស័យ និងវិធានការបង្ការដែលបានផ្សព្វផ្សាយដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក គឺជាការចាំបាច់សម្រាបើមនុស្សគ្រប់រូប ពិសេសបុគ្គលិកអប់រំ និងអ្នកសិក្សា។ អ្នកណាក៏អាចឆ្លងជំងឺកូវីដ ១៩បានដរ ហើយមនុស្សវ័យចំណាស់ និងអ្នកមានជំងឺរ៉ាំរ៉ៃដូចជា ជំងឺលើសសម្ពាធឈាម ជំងឺបេះដូង ជំងឺទឹកនោមផ្អមជំងឺមហារីក និងបញ្ហាសួតជាដើម ងាយនឹងវិវត្តទៅរកសភាពធ្ងន់ធ្ងរ។

**ក- តើអ្វីជាជំងឺកូវីដ ១៩?**

ជំងឺកូវីដ ១៩ (COVID-19) គឺជាជំងឺឆ្លងផ្លូវដង្ហើម ប៉ះពាល់សួតធ្ងន់ធ្ងរ បង្កឡើងដោយ វីរុសកូរ៉ូណា (Coronavirus)។ វីរុសកូរ៉ូណា ជាក្រុមគ្រួសារនៃវីរុសដ៏ធំមួយដែលបណ្តាល ឱ្យមានជំងឺផ្តាសាយធម្មតា និងជំងឺសួតធ្ងន់ធ្ងរជាច្រើនទៀតដូចជា ជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (Middle East Respiratory Syndrome = MERS) និងជំងឺសា (Server Actute Respiratory Syndrome = SARS) ជាដើម។ ជំងឺកូវីដ ១៩ ត្រូវបានរកឃើញដំបូងនៅទីក្រុងវូហាន(Wuhan) ខេត្តហ៊ុយប៉េ (Hubei) នៃសាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ហើយកម្ពុជាបានរកឃើញករណីដំបូងនៃជំងឺកូដ ១៩ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ អង្គការសុខភាពពិភពលោក (WHO) បានដាក់ឈ្មោះជំងឺបណ្តាលមកពីរុសកូរ៉ូណាប្រភេទថ្មី (2019-nCov) ជាផ្លូវការ ថា ជំងឺវីដ ១៩ (COVID-19) ដែលមកពីពាក្យកាត់ "CO" តំណាងឱ្យពាក្យ Corona (កូរ៉ូណា) "V" តំណាងឱ្យពាក្យ Virus (វីរុស) "D" តំណាងឱ្យពាក្យ Disease (ជំងឺ) និងលេខ១៩ តំណាងឱ្យឆ្នាំ២០១៩ ហើយបានកំណត់ថាជា ជំងឺរាតត្បាតសកល (Global Pandemic) ចាប់ពីថ្ងៃទី១១ ខែ មីនា ឆ្នាំ២០២០។

**ខ- តើជំងឺកូវីដ ១៩ឆ្លងដោយរបៀបណា?**

ជំងឺកូវីដ ១៩ បង្កឡើងដោយវីរុសកូរ៉ូណាថ្មី ឆ្លងពីមនុស្សម្នាក់ទៅមនុស្សដទៃទៀត តាមរយៈតំណក់ទឹកតូចៗដែលខ្ចាតចេញពីមាត់អ្នកមានវីរុសកូរ៉ូណា នៅពេល និយាយ ក្អក ឬកណ្តាស់ ហើយមេរោគទាំងនោះចូលទៅក្នុងខ្លួនមនុស្សតាមមាត់ ច្រមុះ ឬភ្នែក។ ម៉្យាងទៀតតំណក់ទឹកដែលមានមេរោគនេះនឹងធ្លាក់លើផ្ទៃនៃវត្ថុ ឬ សម្ភារៈប្រើប្រាស់ដែលនៅជុំវិញដូចជា តុ កៅអី ដៃទ្វារជាដើម ហើយវាអាចឆ្លង ទៅមនុស្សដទៃទៀតនៅពេលប៉ះពាល់ផ្ទាល់លើវត្ថុ ឬសម្ភារៈប្រើប្រាស់ទាំងនោះ និង បន្ទាប់មកបានយកដៃមកប៉ះពាល់មាត់ ច្រមុះ ឬ ភ្នែក។



## គ- តើជំងឺកូវីដ ១៩ មានរោគសញ្ញាអ្វីខ្លះ?

អ្នកឆ្លងវីរុសកូរ៉ូណាថ្មី អាចលេចចេញនូវរោគសញ្ញាក្នុងចន្លោះពី១ថ្ងៃ ទៅ១៤ថ្ងៃ ដោយអ្នកខ្លះគ្មានរោគសញ្ញាទាល់តែសោះ អ្នកខ្លះមានរោគសញ្ញាស្រាល និង អ្នកខ្លះទៀតមានរោគសញ្ញាធ្ងន់ធ្ងរ។ រោគសញ្ញានៃជំងឺកូវីដ ១៩ ដែលកើតមានញឹកញាប់រួមមាន គ្រុនក្តៅ ក្អកស្ងួត និងអស់កម្លាំង។ ក្រៅពីរោគសញ្ញាខាងលើ អាចមានរោគសញ្ញាផ្សេងទៀតដូចជា ឈឺខ្លួន ឈឺបំពង់ក ឈឺក្បាល តឹងច្រមុះ ភ្នែកក្រហម រាករូស បាត់បង់រសជាតិ បាត់បង់ក្លិន ស្បែកឡើងកន្ទួល ឬប្រែពណ៌ម្រាមដៃម្រាមជើង។



### ឃ- តើអ្នកអាចបង្ការជំងឺកូវីដ ១៩ដោយរបៀបណា?

ដើម្បីចៀសវាងហានិភ័យនៃការឆ្លងជំងឺកូវីដ ១៩ យើងគប្បីអនុវត្តវិធានការដូច ខាងក្រោម

- ត្រូវពាក់ម៉ាស់គ្របមាត់និងច្រមុះដើម្បីការពារតំណក់ទឹកតូចៗទៅអ្នកដទៃ និងពីអ្នកដទៃមកខ្លួនយើង
- រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្រឡើងទៅ និងគួរចៀសវាងការស្វាគមន៍គ្នា ដោយចាប់ដៃឬឱបដោយប្តូរមកជាការសំពះតាមទំនៀមទម្លាប់ខ្មែរ
- លាងសម្អាតដៃឱ្យបានញឹកញាប់ជាមួយទឹកស្អាតនិងសាប៊ូ (៤០វិនាទី) ឬ ទឹកអាល់កុល/អាល់កុលជែល (២០វិនាទី) បន្ទាប់ពីក្អកឬកណ្តាស់ មុនពេល អំឡុងពេល ឬបន្ទាប់ពីរៀបចំអាហារ មុនពេល ឬក្រោយពេលបរិភោគអាហារ ក្រោយចេញពីបន្ទោបង់ បន្ទាប់ពីប៉ះពាល់សត្វ និងនៅពេលដៃកខ្វក់។ល។
- ខ្ទប់មាត់និងច្រមុះនៅពេលក្អកឬកណ្តាស់ដោយប្រើគន្លាក់កែងដៃ ឬកន្សែងក្រមា ឬក្រដាស ហើយករណីប្រើកន្សែងឬក្រមាត្រូវបោកសម្អាតរាល់ថ្ងៃជា ប្រចាំ បើប្រើក្រដាសត្រូវបោះចោលទៅក្នុងធុងសំរាមដែលបិទជិត និងចៀសវាង យកដៃប៉ះពាល់ផ្ទៃមុខ ភ្នែក ច្រមុះ និងហាមប៉ះពាល់ជិតស្និទ្ធជាមួយអ្នក ដែលមានរោគសញ្ញាដូចជា គ្រុនក្តៅ ក្អក ឬផ្តាសាយ
- ប្រសិនបើអ្នកក្តៅខ្លួនខ្លាំងចាប់ពី៣៨,៥អង្សាសេ ក្អក ឬមានអារម្មណ៍ថាពិបាក ដកដង្ហើម អស់កម្លាំង ឈឺក្បាល ឈឺសាច់ដុំ រាក និងបាត់បង់រសជាតិ ឬក្លិន សូមទាក់ទង ១១៥។



### ង- តើអ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីជំងឺកូវីដ ១៩

ពីប្រភពណា? អ្នកអាចស្វែងរកព័ត៌មានថ្មីៗនិងទុកចិត្តបានអំពីជំងឺកូវីដ ១៩ តាមរយៈ គេហទំព័រដូចខាងក្រោម៖

១- នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង (CDC) នៃក្រសួងសុខាភិបាលកម្ពុជា

http://www- cdcmoh- gov- kh/

២- អង្គការសុខភាពពិភពលោក (WHO)

https://www- who- int/emergencies/diseases/novel-coronavirus2019/question-and-answers-hub-

https://www- who- int/emergencies/diseases/novel-coronavirus2019/advice-for-public/myth-busters-

### ៦- គ្រោះថ្នាក់ចរាចរណ៍

ប្រទេសកម្ពុជាមានអត្រាអ្នកស្លាប់ខ្ពស់បំផុតដោយសារគ្រោះថ្នាក់ចរាចរណ៍បើប្រៀបធៀបទៅនឹងបណ្តាប្រទេសនានានៅអាស៊ី។ដូច្នេះយើងទាំងអស់គ្នាត្រូវគោរព និងអនុវត្តច្បាប់ចរាចរណ៍ឱ្យបានគ្រប់ៗគ្នាទើបអាចទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ការពារជីវិតមនុស្ស សត្វ រក្សាសណ្តាប់ធ្នាប់ សុវត្ថិភាពក្នុងការធ្វើចរាចរណ៍នៅលើផ្លូវថ្នល់ ហើយទប់ស្កាត់ការប៉ះពាល់សុខ ភាពមនុស្ស ការខូចខាតទ្រព្យសម្បត្តិរដ្ឋ ឯកជន ជាពិសេសទប់ស្កាត់ការប្រព្រឹត្តបទល្មើសក្នុងការប្រើប្រាស់ផ្លូវថ្នល់ ។ករណីនេះ បានឆ្លុះបញ្ចាំងឲ្យឃើញថា គ្រោះថ្នាក់ចរាចរណ៍បានបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ ការងារអភិវឌ្ឍន៍ប្រទេសជាតិថែមទៀត ។ មនុស្សដែលកំពុងពេញពលកម្ម រួមមាន សិស្ស និស្សិត មន្ត្រី រាជការ បានរង របួសស្លាប់ ពិការ ដែលធ្វើឲ្យខាតបង់កម្លាំងសេដ្ឋកិច្ចសង្គមជាច្រើន។ បើសិនជាយើងមិនបានយកចិត្តទុកដាក់អំពី សុវត្ថិភាពចរាចរណ៍ផ្លូវថ្នល់ទេនោះ គ្រោះមហន្តរាយនឹងនៅតែអូសបន្លាយតទៅទៀត។ ហេតុដូច្នេះ វាមានសារៈសំខាន់ណាស់ សម្រាប់យើងទាំងអស់គ្នាចាំបាច់ត្រូវព្យាយាមធ្វើអ្វីដែលយើងអាចធ្វើឲ្យបានកាន់តែឆាប់កាន់តែល្អ ដើម្បីចូល រួម ទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលគម្រាមដល់អាយុជីវិតមនុស្ស និងបង្ហាញពីទិដ្ឋភាពដ៏គួរឲ្យខ្លាចនៅតាម ដងផ្លូវសាធារណៈ ។

មានសំណួរជាច្រើនដែលប្អូនសិស្សានុសិស្សបាន និងត្រូវយល់ដឹងពីគ្រោះថ្នាក់ចរាចរណ៍ ?តើអ្វីជាគ្រោះថ្នាក់ចរាចរណ៍ ?តើគ្រោះថ្នាក់ចរាចរណ៍បង្កឡើងដោយសារអ្វីខ្លះហើយផ្តល់ផលប៉ះពល់អ្វីខ្លះ ?

គ្រោះថ្នាក់ចរាចរណ៍ ជាព្រឹត្តិការណ៍នៃការបុកដែលពាក់ព័ន្ធយ៉ាងហោចណាស់ យានមួយគ្រឿង ដែលកំពុងមានចលនានៅលើ ផ្លូវសាធារណៈ ឬឯកជនមួយដែលយ៉ាងហោចណាស់បណ្តាលឱ្យមនុស្សម្នាក់រងរបួស ពិការ ឬស្លាប់ ។

### ក- មូលហេតុ

គ្រោះថ្នាក់ចរាចរណ៍បង្កឡើងដោយសារឥរិយាបថរបស់មនុស្សស្ថានភាពផ្លូវនិងអាកាសធាតុព្រមទាំងលក្ខណៈនៃយានជំនិះភាគរយនៃប្រជាជន រងគ្រោះភាគច្រើនបណ្តាលមកពីការធ្វេសប្រហែសនិងកំហុសឆ្គង

របស់មនុស្សដូចជាការសេពគ្រឿងស្រវឹង ការបើកបរលឿនមិនគោរពភ្លើងសញ្ញាចរាចរណ៍ឬការមិនគោរពច្បាប់ចរាចរណ៍ជាដើម

ហេតុនេះអ្នកធ្វើដំណើរចាំបាច់ត្រូវតែមានឥរិយាបថប្រុងប្រយ័ត្នគោរពនិងអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវដើម្បី បង្ការគ្រោះថ្នាក់។ខាងក្រោមនេះជាមូលហេតុដែលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ត្រូវបានបែងចែកជា ៤គឺ ៖

**១- កត្តាមនុស្ស គឺគ្រោះថ្នាក់ទាំងឡាយណា ដែលបង្កឡើងដោយកំហុសឆ្គងរបស់មនុស្សដូចជា**

- បើកបរមិនគោរពសិទ្ធិអាទិភាព
- បើកបរលើគន្លងផ្លូវដោយមិនប្រយ័ត្ន
- បើកបរជែង/វ៉ាក្នុងស្ថានភាពគ្រោះថ្នាក់
- បើកបរបញ្ច្រាសទិស
- បើកបរក្នុងស្ថានភាពស្រវឹង
- បើកបរលើសល្បឿនកំណត់
- ធ្វេសប្រហែស គ្មានការប្រុងប្រយ័ត្ន
- ព្រហើន
- គ្មានអារម្មណ៍នឹងនរ
- មិនគោរពច្បាប់ចរាចរណ៍ ឬ ស្លាកសញ្ញាចរាចរណ៍
- មិនពាក់មួកសុវត្ថភាព ឬ ដាក់ខ្សែក្រវ៉ាត់
- ដេកលក់ពេលកំពុងបើកបរ
- រំលោភគំនូសបែងចែកផ្លូវដែលត្រូវបើកបរ
- ខ្វះសុជីវធម៌ក្នុងការបើកបរ
- មានអារម្មណ៍មានះ ចចេស ច្រើន
- ប្រមាថអ្នកធ្វើចរាចរណ៍ដទៃទៀត
- ផ្ទុកហួសចំណុះ
- ស្លៀកពាក់សំពត់ខ្លី ខោខ្លី គូថខ្លី
- ស្បែកជើងកែងតូចហើយខ្ពស់
- មិនគោរពច្បាប់ចរាចរណ៍ (ជិះខុសស្តាំង ខុសឆ្វេង ភ្លើងសញ្ញាចរាចរណ៍)
- ផ្សេងៗ

<u>រូបភាពទី៤៣</u> ភាគរយនៃគ្រោះថ្នាក់ និងអ្នកស្លាប់ បង្កឡើងដោយកត្តាមនុស្ស – ២០១០




## ២- កត្តាផ្លូវគឺជាលក្ខខណ្ឌផ្លូវដែលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍

- ផ្លូវប្រហោងក្រហូង មានជង្ហុក
- ផ្លូវមានទឹកដក់
- ផ្លូវហ៊ុយ ខ្លាំងពេក (ផ្លូវបត់)
- ផ្លូវចោទពេក (ផ្លូវចំណោទ)
- ផ្លូវកោងខ្លាំងពេក (ផ្លូវបត់)
- ផ្លូវរអិល
- ផ្លូវគ្រប់ដណ្តប់ដោយអ័ព្ទ
- ផ្លូវគ្របដណ្តប់ដោយដំណក់ភ្លៀងខ្លាំង
- ផ្លូវគ្មានបិញ្ចើម
- ផ្លូវគ្មានស្លាកសញ្ញាចរាចរ គំនូរសញ្ញា ភ្លើងសញ្ញា
- ផ្លូវដី
- ផ្លូវសើម
- ផ្លូវចង្អៀត

## ៣- កត្តាអាកាសធាតុ អាកាសធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍

- ភ្លៀងលិចផ្លូវអ្នកបើកបរផ្សេងទៀតពិបាកមើលឃើញអ្នក
- ពិបាកមើលយានជំនិះផ្សេងទៀត
- ជង្ហុក
- សាចទឹក
- ផ្លូវរអិល

- ចុះអ័ព្ទខ្លាំងមើលផ្លូវមិនឃើញ

របភាពទី៤២ ភាគរយនៃគ្រោះថ្នាក់ តាមមូលហេតុនៃគ្រោះថ្នាក់ – ២០១០




### ៤- កត្តាយានជំនិះ

- យានយន្តខុសលក្ខណៈបច្ចេកទេស
- ផ្ទុះ ឬដាច់កង់
- យានយន្តមានកង់ស្អិត ចាស់ពេក
- ភ្លើងមិនភ្លឺ ខូចប្រព័ន្ធហ្វ្រាំង
- ខូចប្រព័ន្ធចង្កូត
- គ្មានភ្លើងសញ្ញាសម្រាប់បត់
- អស់ទឹកពីធុង (ធុងទឹក) អស់ប្រេងហ្វ្រាំង អស់ប្រេងចង្កូត
- អស់សាំង ពេលកំពុងបើកបរ
- គ្មានកញ្ចក់មើលក្រោយ
- គ្មានខ្សែក្រវ៉ាត់(រថយន្ត)
- ដាច់ក្រឡេ

### ខ- ទម្រង់បែបបទបំពេញគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក (សូមភ្ជាប់ជាឧបសម្ព័ន្ធ)

### ក- នគរបាលចរាចរណ៍ផ្លូវគោគ

ទម្រង់បែបបទគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកត្រូវបានប្រើប្រាស់ពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ទម្រង់នេះត្រូវបានកត់ត្រាដោយនគរបាលចរាចរណ៍ តាមរយៈការជួបជាមួយជនបង្កហេតុ និងជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍។

### ខ- ទម្រង់បែបបទប្រមូលទិន្នន័យក្រសួងសុខាភិបាល

ទម្រង់បែបបទប្រមូលទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់ផ្សេងៗ ត្រូវបានប្រើប្រាស់ពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ទម្រង់នេះត្រូវបានកត់ត្រាដោយនគរបាលចរាចរណ៍ តាមរយៈការជួបជាមួយជនបង្កហេតុ និងជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍។

*(មានភ្ជាប់ជូនទម្រង់ក្នុងឧបសម្ព័ន្ធ)*

## ៨- គ្រឿងញៀន

គ្រឿងញៀនបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខុមាលភាពនិងសេដ្ឋកិច្ចរបស់បុគ្គល គ្រួសារ សហគមន៍ ព្រមទាំងសន្តិសុខ សណ្តាប់ធ្នាប់ និងការអភិវឌ្ឍសង្គម។ ដើម្បីបង្កើននូវប្រសិទ្ធ ភាពក្នុងការជួយសង្គ្រោះជនរងគ្រោះក្រុមគ្រួសារ និងសហគមន៍ដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ ដែលបង្កឡើងដោយបញ្ហាគ្រឿងញៀន និងគាំទ្រដល់ការធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្ត ច្បាប់ពាក់ព័ន្ធការបង្ការ ការបង្ក្រាបរាល់បទល្មើស ការជាំជុះ ការរក្សាទុក ការលួចលាក់ផលិត ការ ចរាចរ និងការប្រើប្រាស់គ្រឿងញៀនចាំចាច់ត្រូវតែធ្វើយ៉ាងណាឱ្យប្រជាជនគ្រប់រូបបានយល់ដឹងពី បញ្ហានានាពាក់ព័ន្ធទៅនឹងបញ្ហាគ្រឿងញៀននេះ។

ផ្នែកនេះ នឹងជួយដល់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សាទាំងអស់ទទួលបាននូវវិជ្ជាសម្បទាពាក់ព័ន្ធនឹងគ្រឿងញៀន ព្រម ទាំងអាចបង្កើតបាននូវបំណិនចូលរួមប្រកបដោយការទទួលខុសត្រូវ បដិសេធ ឬឆ្លើយថាទេចំពោះ គ្រឿងញៀន។

គ្រឿងញៀន គឺជាអ្វី ?

គ្រឿងញៀន គឺជាសារធាតុគីមី ឬរុក្ខជាតិដែលមានឥទ្ធិពលធ្វើអោយមានរំញោចខ្លាំងទៅលើ អ្នកប្រើប្រាស់វាទាំងផ្នែកស្មារតី ចិត្តអារម្មណ៍ និងរូបកាយ ហើយពិបាកនឹងផ្តាច់ ឬបញ្ឈប់ការប្រើប្រាស់ណាស់។

គ្រឿងញៀន មានជាប្រភេទ លេប ថ្នាំគ្រាប់ ចាក់ ជក់ ហិត- - - ។

ឈ្មោះគ្រឿងញៀន មានដូចជា កញ្ឆា អាភៀន ម៉ាទឹកកក អំហ្វេតាមីន អ៊ិចស្តាសី អិលអេ សឌី គេតាមីន មេតំហ្វេតាមីន អេធីស៊ី ប្រភេទជំនួយកម្លាំង កាវ យ៉ាមា ឬ យ៉ាបា- - - ។

### ក- ផលប៉ះពាល់

ការប្រើប្រាស់គ្រឿងញៀនផ្តល់នូវផលប៉ះពាល់ដល់ ៣ ប្រភេទៈ

១- ផលប៉ះពាល់ទៅលើបុគ្គលអ្នកប្រើ មានដូចជាប៉ះពាល់ទៅលើសុខភាពផ្លូវកាយ ពោលគឺគ្រឿងញៀនបានជ្រាបចូល ក្នុងសរីរាង្គរបស់មនុស្សមានថ្លើម បេះដូង តម្រងនោម និងសួត ហើយបង្កឱ្យមានជំងឺដោយសារធាតុពុល និងជំងឺឆ្លងផ្សេងៗ រាងកាយ ស្គមស្គាំង ស្លេកស្លាំង មិនងងុយដេក មិនឃ្លានអាហារ និងកម្លាំងចុះថយ។ សម្រាប់ស្ត្រីមានផ្ទៃពោះ ប្រសិនបើប្រើគ្រឿងញៀនអាចមាន ឥទ្ធិពលផ្ទាល់ទៅលើទារកក្នុងផ្ទៃ ទាំងរាងកាយ និងខួរក្បាល។ ហើយប្រសិនបើប្រើម្ជុលសីរ៉ាំងរួមគ្នាអាចធ្វើឱ្យឆ្លងមេរោគអេដស៍ រលាកថ្លើម ប្រភេទ B C និងជំងឺបូសថ្លើម។ សម្រាប់សុខភាពផ្លូវចិត្ត វាផ្តល់នូវផលប៉ះពាល់ដូចជា សតិស្មារតីមិនប្រក្រតី គ្មានភាពច្បាស់

លាស់នូវការឃើញ ស្តាប់ ការចងចាំថយចុះ ឬបាត់បង់តែម្តងកាចសាហាវឡប់សតិ ឬឆ្កួតនៅពេលដែលប្រើវាយូរពេក ជាពិសេសនោះគឺ បាត់បង់ការសិក្សា និងការងារ។

២- ផលប៉ះពាល់ចំពោះគ្រួសារ ដូចជា បាត់បង់កិត្តិយស បំផ្លាញទ្រព្យសម្បត្តិគ្រួសារ បង្កការភ័យខ្លាច អំពើហិង្សាខាតបង់ថវិការនិងគ្រោះថ្នាក់ដល់គ្រួសារជាដើម។

៣- ផលប៉ះពាល់ចំពោះសង្គម មានដូចជា បង្កនូវអំពើអសីលធម៌ផ្សេងៗ បោះបង់ការសិក្សា (អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្លូវភេទ) គ្រោះថ្នាក់ចរាចរ ប្រព្រឹត្តអំពើធក់ប្លន់ និងបទឧក្រិដ្ឋផ្សេងៗ រួមទាំងបាត់បង់ធនធានមនុស្សទៀតផង។



ផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន

**៩- វិធានការ**

តើត្រូវធ្វើដូចម្តេចដើម្បីជម្នះខ្លួនពីការប្រើប្រាស់គ្រឿងញៀន?

ដើម្បីជម្នះឱ្យផុតពីការប្រើប្រាស់គ្រឿងញៀននោះ មនុស្សគ្រប់រូបជាពិសេសយុវវ័យត្រូវធ្វើការសម្រេចចិត្តឱ្យបានច្បាស់លាស់ និងប្រាកដថាឈប់ប្រើគ្រឿងញៀន ចៀសវាងឱ្យឆ្ងាយពីអ្នកប្រើបាស់គ្រឿងញៀន និងទៅជួបអ្នកផ្តល់ប្រឹក្សាដើម្បីពិភាក្សាអំពីរបៀបផ្តាច់ការញៀននៅមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលផ្តាច់គ្រឿងញៀន។ វិធីការពារខ្លួនកុំឱ្យប្រើប្រាស់គ្រឿងញៀនគឺ កុំសាកល្បងនឹងគ្រឿងញៀនសូម្បីតែម្តង ពីព្រោះគ្រឿងញៀនជាសន្ទួចស្ទូចអ្នកឱ្យញៀន កុំសេពគប់មិត្តភក្តិប្រើប្រាស់គ្រឿងញៀន និងចេះជំនាញចរចា បដិសេធនៅពេលមានមិត្តភក្តិអូសទាញឱ្យប្រើប្រាស់គ្រឿងញៀន។មនុស្សគ្រប់រូបត្រូវឆ្លើយថាទេចំពោះគ្រឿងញៀន!!!

**៧-អគ្គិភ័យ**

តើអគ្គិភ័យជាអ្វី?បង្កឡើងដោយសារអ្វី?ហើយប៉ះពាល់ទៅលើអ្វីខ្លះ?

អគ្គិភ័យ សំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិតទ្រព្យសម្បត្តិ និងបរិស្ថាន។

អគ្គិភ័យអាចកើតមាននៅលើ សាលារៀន ឃ្លាំង រោងចក្រ សិប្បកម្មស្ថានីយប្រេងឥន្ធនៈ មណ្ឌលកម្សាន្តម៉ាស៊ីនកិនស្រូវ តូបផ្សារ សំណង់មិនទាន់រៀបរយ។ដោយមូលហេតុការឆ្លងចរន្តនៃការធ្វើអាជីវកម្មនិងប្រើប្រាស់ប្រេងឥន្ធនៈនិងឧស្ម័នមិនសមស្របការចម្អិនអាហារអុជធូបទៀនចោលជាដើម ជាមួយនេះក៏មានភ្លើងឆេះព្រៃឆេះចម្ការស្រែដោយសារការធ្វេសប្រហែសរបស់ប្រជាជននៅពេលដែលចូលព្រៃរកជ័រក៏បោះកន្ទុយបារីរងើកភ្លើងនិងរួមផ្សំរដូវប្រាំងហួតហែងទៀតផង

**ក-មូលហេតុ**

អគ្គិភ័យអាចបណ្តាលមកពីមនុស្សដែលធ្វេសប្រហែសជាមួយនឹងសម្ភារងាយឆេះនានា ដូច ជា ប្រេងកាត ចំបើង អុស និងគ្រឿងបរិក្ខារអគ្គិសនីដែលមិនមានសុវត្ថិភាព។ វាកើតមានឡើង ច្រើនបំផុត នៅរដូវក្តៅ ឬអាកាសធាតុក្តៅ នៅរដូវរាំងស្ងួត ឬនៅក្នុងព្រៃ។ជាមួយនេះក៏មានភ្លើងឆេះព្រៃឆេះចម្ការស្រែដោយសារការធ្វេសប្រហែសរបស់ប្រជាជននៅពេលដែលចូលព្រៃរកជ័រក៏បោះកន្ទុយបារីរងើកភ្លើងនិងរួមផ្សំរដូវប្រាំងហួតហែងទៀតផង

**ខ-ផលប៉ះពាល់**

- អគ្គិភ័យបំផ្លាញផ្ទះសម្បែង អគារសិក្សា ដំណាំដាំដុះ រុក្ខជាតិ និងទ្រព្យសម្បត្តិ
- ភ្លើងឆេះអាចបណ្តាលឱ្យមនុស្សស្លាប់ ឬរលាកយ៉ាងធ្ងន់ធ្ងរ និងធ្វើឱ្យខូចទ្រង់ទ្រាយដើម
- ភ្លើងឆេះរបស់របរផ្សេងៗជាច្រើន និងបង្កើតនូវឧស្ម័នពុលទៅក្នុងអាកាស។ ឧស្ម័នទាំងនេះអាចធ្វើឱ្យមនុស្សថប់ស្លាប់
- អាក់ខាននៃការសិក្សារបស់កុមារ

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

បន្ទាប់ពីសិក្សាមេរៀននេះចប់ គ្រូត្រូវរៀបចំឬសរសេរមេរៀនសង្ខេបចំណុចសំខាន់តាមប្រភេទមុខសញ្ញាគ្រោះថ្នាក់ ដែលបង្ហាញពីប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់នីមួយៗ មូលហេតុការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ ផល់ប៉ះពាល់ របស់មុខសញ្ញាគ្រោះថ្នាក់ដូចជា

1. ទឹកជំនន់
2. រាំងស្ងួត
3. ខ្យល់ព្យុះ ឬខ្យល់កន្ត្រាក់
4. រន្ទះបាញ់
5. ជំងឺឆ្លង
6. គ្រោះថ្នាក់ចរាចរណ៍
7. អគ្គិភ័យ

ជាគោលការណ៍ ការងារគ្រប់គ្រងគ្រងគ្រោះមហន្តរាយ គឺពាក់ព័ន្ធដោយផ្ទាល់និងខានមិនបានដល់កត្តាមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព ។

មុខសញ្ញាគ្រោះថ្នាក់ សំដៅដល់ព្រឹត្តិការណ៍ ឬបាតុភូតមួយ ឬសកម្មភាពរបស់មនុស្សដែលសក្តានុពលអាចធ្វើឱ្យខូចខាតជារូបវន្ត រួមមានការបាត់បង់អាយុ ជីវិត រងរបួស ខូចខាត និងបាត់បង់ទ្រព្យសម្បត្តិ រាំងស្ទះដល់សង្គម និងសេដ្ឋកិច្ច ឬខូចខាតបរិស្ថាន។

នៅពេលដែលសាលារៀន គ្រូ សិស្ស និងសហគមន៍ ស្ថិតក្នុងកម្រិតនៃភាពរងគ្រោះខុសៗគ្នា។ នោះសាលារៀនក៏មានសមត្ថភាពឬលទ្ធភាពផ្សេងៗ ដើម្បីទប់ទល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ផងដែរ។ ក្នុងស្ថានការណ៍គ្រោះមហន្តរាយបន្ទាន់ សាលា ត្រូវតែមានសមត្ថភាពអាចជួយខ្លួនឯងបាន យ៉ាងហោចណាស់ក៏មានវិធានការដែលអាចធ្វើការឆ្លើយតប និងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយកើតឡើងបានខ្លះៗដែរ។

**២- ៥ ឯកសារសិក្សាបន្ថែម**

- រូបភាពបង្ហាញពីមុខសញ្ញាគ្រោះថ្នាក់នៅក្នុងសាលារៀន
- មុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុងសាលារៀនដែលបានកំណត់។

**២- ៦ ការអនុវត្ត**

គណៈគ្រប់គ្រងសាលា រួមជាមួយនឹងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវដឹកនាំ សម្របសម្រួលគ្រូ សិស្ស និងអ្នកពាក់ព័ន្ធ ចូលរួមផ្សព្វផ្សាយពីប្រភេទ ផលប៉ះពាល់ និងវិធានការទប់ស្កាត់តាមប្រភេទមុខសញ្ញាទាំង៧ ដោយបាន ជាពិសេសដោយផ្តោតបន្ថែមអំពីគ្រឿងញៀនក្នុងសាលារៀននីមួយៗឱ្យបានច្បាស់លាស់។ រៀបចំផ្លាកសញ្ញាតាមប្រភេទមុខសញ្ញាគ្រោះថ្នាក់ក្នុងសាលារៀន និងក្នុងសហគមន៍សិស្ស ដោយមានបង្ហាញពីចំគួរធ្វើ និងមិនគួរធ្វើ ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដោយប្រការណាមួយ តាមស្ថានភាពមុខសញ្ញាគ្រោះថ្នាក់។

# មេរៀនទី២៖ ប្រភេទហានិភ័យ

## ១- វត្ថុបំណង

- ប្រាប់ពីប្រភេទហានិភ័យនៅក្នុងសាលារៀន
- កំណត់ប្រភេទហានិភ័យសំខាន់ៗ បញ្ហាដែលអាចកើតមាននៅក្នុងសាលារៀន កំណត់សកម្មភាពជាអាទិភាព និងដំណោះស្រាយ
- មានការរៀបចំជាមុន ដើម្បីគេចផុតពីហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងសាលារៀន។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ យើងនឹងសិក្សាប្រធានបទអំពីហានិភ័យ ដោយផ្តោតសំខាន់លើ ប្រភេទហានិភ័យទាំង៥ ក្នុងសាលារៀន ប្រភេទហានិភ័យនីមួយៗនឹងអាចកើតចេញមុខសញ្ញាគ្រោះថ្នាក់ មានអន្តរកម្មជាមួយភាពងាយរងគ្រោះ ប្រភេទហានិភ័យទាំង ៥ នោះរួមមាន៖

1. ហានិភ័យពីគ្រោងអគារ ឬរចនាសម្ព័ន្ធ
2. ហានិភ័យពីពីកត្តាផ្សេងៗ មិនមែនពីគ្រោងអគារ ឬរចនាសម្ព័ន្ធ
3. ហានិភ័យពីហេដ្ឋារចនាសម្ព័ន្ធ
4. ហានិភ័យពីបរិស្ថាន
5. ហានិភ័យលើសុវត្ថិភាពផ្ទាល់ខ្លួន

### ២- ២ ពាក្យគន្លឹះ

*ហានិភ័យ* សំដៅដល់ភាពដែលអាចកើតមាននូវផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក (ស្លាប់ របួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ចត្រូវបានរំខាន ឬបរិស្ថានត្រូវបានខូចខាត) ដែលបណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ទៅនឹងភាពងាយរងគ្រោះ។

### ២-៣ ខ្លឹមសារមេរៀន

តើអ្វីទៅជាហានិភ័យ?

ហានិភ័យសំដៅដល់ភាពដែលអាចកើតមាននូវផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក (ស្លាប់ របួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ចត្រូវបានរំខាន ឬបរិស្ថានត្រូវបានខូចខាត) ដែល បណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ ទៅនឹងភាពងាយរងគ្រោះ។ ភាពងាយរងគ្រោះ និងមុខសញ្ញាគ្រោះថ្នាក់ស្ថិតនៅដាច់ដោយឡែកពីគ្នា គឺពុំមានគ្រោះថ្នាក់អ្វីទេ ក៏ប៉ុន្តែបើពួកគេស្ថិតនៅជាមួយគ្នានឹងក្លាយជាហានិភ័យ ឬអាចនឹងមានគ្រោះមហន្តរាយកើតឡើង នាពេលខាងមុខ។




ប្រភេទហានិភ័យដែលអាចកើតមាននៅតាមសាលារៀន ត្រូវបានចែកចេញជា៥ប្រភេទ

1. **ហានិភ័យពីគ្រោងអគារ ឬរចនាសម្ព័ន្ធ** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីគ្រោងអគារ មានដូចជាដំបូលបាក់ ពុកផុយ ពិដាន បង្អួច ទ្វា បេតុង រួមទាំងគ្រោងអគារទាំងមូល ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
2. **ហានិភ័យពីពីកត្តាផ្សេងៗ មិនមែនពីគ្រោងអគារ ឬរចនាសម្ព័ន្ធ** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីមិនមែនគ្រោងអគារ មានដូចជាគ្រឿងសង្ហារឹមក្នុងអគារ តុ កៅអីគ្រូ ទូរ សម្ភារៈរៀន និងបង្រៀន ក្តារខៀន សម្ភារៈអនាម័យក្នុងថ្នាក់រៀន ឧបករណ៍បាញ់សម្លាប់មេរោគ គ្រឿង និងសម្ភារៈប្រើប្រាស់ក្នុងថ្នាក់រៀន ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
3. **ហានិភ័យពីហេដ្ឋារចនាសម្ព័ន្ធ**សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីហេដ្ឋារចនាសម្ព័ន្ធ មានដូចជា បណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បេតុង លូរំដោះទឹក របងសាលា រូបសំណាក់ផ្សេងៗ កន្លែងរៀនក្រៅថ្នាក់ បង្គន់អនាម័យ កន្លែងលាងដៃ រួមទាំងគ្រោងអគារទាំងមូល ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
4. **ហានិភ័យពីបរិស្ថាន** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីបរិស្ថានក្នុងសាលារៀន មានដូចជា សួនច្បារ ដើមឈើ កន្លែងសិស្សលេង សួនជីវចំរុះ សួនបំណិនជីវិត ធុងសំរាម ស្រះ ឬអណ្តូង កន្លែងដុតសំរាម រួមទាំងគ្រោងអគារទាំងមូល ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
5. **ហានិភ័យលើសុវត្ថិភាពផ្ទាល់ខ្លួន** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីការបង្កឡើងដោយមនុស្សជាអ្នកប្រព្រឹត្តខ្លួនឯង ក្នុងសាលារៀន មានដូចជា ការធ្វើចរាចរណ៍ សុវត្ថិភាពចំណីអាហារ ទឹក និងប្រភពទឹក អំពើហិង្សា ការរើសអើងភេទ យេនឌ័រ វប្បធម៌ សាសនា ពិការភាព ដែលអាចនឹងបង្កហានិភ័យដល់សុវត្ថិភាពក្នុងការរស់នៅ សិទ្ធទាំង៤ របស់សិស្ស និងសីលធម៌សង្គម ។

ដូចក្នុងតារាងលម្អិតអំពីបញ្ហាអាចកើតឡើង ដែលអាចកើតឡើង សកម្មភាពដោះស្រាយ និងចាត់អាទិភាពនៃការដោះស្រាយ ដោយផ្តោតតាមហានិភ័យទាំង៥ របស់សាលារៀន ៖

| ល-រ | ហានិភ័យ | បញ្ហាដែលអាចកើតមាន | សកម្មភាពដោះស្រាយ | អាទិភាពសកម្មភាពដោះស្រាយ |
|---|---|---|---|---|
| 1 | **ហានិភ័យពីគ្រោងអគារ ឬរចនាសម្ព័ន្ធ** | 1.អគារទ្រុឌទ្រោម បាក់រលំលើសិស្ស និងគ្រូ<br>2.ដំបូល និងបង្អួចខូចអាចធ្លាក់បាក់សង្កត់សិស្ស-គ្រូ<br>3.ជញ្ជាំងពុកផុយងាយនឹងរលំ | 1.ជួសជុលអគារឡើងវិញ<br>2.ជួសជុលដំបូលអគារ និងបង្អួច<br>3.ជួសជុលជញ្ជាំង | 2.ជួសជុលដំបូលអគារ |
| 2 | **ហានិភ័យពីពីកត្តាផ្សេងៗ មិនមែនពីគ្រោងអគារ ឬរចនាសម្ព័ន្ធ** | 1.កង្ហារ ធ្លាក់លើ<br>2.ខ្សែភ្លើង ឆក់<br>3.ទូកញ្ចក់ ដួលរលំ | 1.ចងកង្ហារឱ្យបានជាប់ល្អ<br>2.រៀបចំប្រព័ន្ធខ្សែភ្លើងឱ្យបានត្រឹមត្រូវ<br>3.រៀបចំដាក់ទូកញ្ចក់ឱ្យបានត្រឹមត្រូវ<br>4.ត្រូវមានវិធានការការពារ និងផ្សព្វផ្សាយ | 1.ចងកង្ហារឱ្យបានជាប់ល្អ<br>2.រៀបចំប្រព័ន្ធខ្សែភ្លើងឱ្យ បានត្រឹមត្រូវ |
| 3 | **ហានិភ័យពីហេដ្ឋារចនាសម្ព័ន្ធ** | 1. ជណ្តើរ បង្ការរអិល<br>2.របង សិស្សឡើងរបងអាចធ្លាក់ | 1.សម្អាតជណ្តើរជាប្រចាំ<br>2.ដាក់ផ្លាកសញ្ញាគ្រោះថ្នាក់ ឬផ្សព្វផ្សាយ<br>3.ផ្សព្វផ្សាយអប់រំកុំសម្គារៈសិស្សឡើងរបង | 1.សម្អាតជណ្តើរជាប្រចាំ<br>2.ដាក់ផ្លាកសញ្ញាគ្រោះថ្នាក់ និងផ្សព្វផ្សាយ |
| 4 | **ហានិភ័យពីបរិស្ថាន** | 1.ទីធ្លាសាលាមានសំរាមច្រើន<br>2.គ្មានធុងសម្រាប់ដាក់សម្ភារៈ<br>3.មូសខាំគ្រុនឈាម និងបង្កជំងឺផ្សេងៗ | 1.ដាក់សំរាមក្នុងធុង<br>2.រៀបចំឱ្យមានធុងសំរាម<br>3.រៀបចំឡដុតសំរាម<br>4.សម្អាតព្រៃស៊ុបទ្រុបនៅក្នុងបរិវេណ និងជុំវិញសាលារៀន | 3.រៀបចំឡដុតសំរាម |
| 5 | **ហានិភ័យលើសុវត្ថិភាពផ្ទាល់ខ្លួន** | 1.សម្ភារៈសង្គ្រោះបឋម គ្មានគ្រប់គ្រាន់<br>2.សម្ភារៈការពារខ្លួន អនាម័យខ្លួនប្រាណ ដូចជាសាប៊ូលាងដៃ កន្លែងលាងដៃមិនមាន។ | 1.ទិញសម្ភារៈសង្គ្រោះបឋមបន្ថែម<br>2.ផ្សព្វផ្សាយអំពីអនាម័យខ្លួនប្រាណ<br>3.ទិញសាប៊ូលាងដៃ<br>4.រៀបចំឱ្យមានកន្លែងលាងដៃ | 1.ទិញសម្ភារៈសង្គ្រោះបឋមបន្ថែម<br>2.រៀបចំឱ្យមានកន្លែងលាងដៃ |

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ក្នុងមេរៀននេះ អ្នកសិក្សាត្រូវច្បាស់លាស់អំពីពាក្យគន្លឹះ នៃពាក្យហានិភ័យ ព្រមទាំង ការរៀបរាប់ពីចំនុចសំខាន់ៗក្នុងប្រភព ប្រភេទហានិភ័យទាំង៥ ដែលអាចកើតមាននៅតាមសាលារៀន៖

1. **ហានិភ័យពីគ្រោងអគារ ឬរចនាសម្ព័ន្ធ** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីគ្រោងអគារ មានដូចជាជំបូលបាក់ ពុកផុយ ពិដាន បង្អួច ទ្វា បេតុង រួមទាំងគ្រោងអគារទាំងមូល ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
2. **ហានិភ័យពីពីកត្តាផ្សេងៗ មិនមែនពីគ្រោងអគារ ឬរចនាសម្ព័ន្ធ** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីមិនមែនគ្រោងអគារ មានដូចជាគ្រឿងសង្ហារឹមក្នុងអគារ តុ កៅអីគ្រូ ទូរ សម្ភារៈរៀន និងបង្រៀន ក្តារខៀន សម្ភារៈអនាម័យក្នុងថ្នាក់រៀន ឧបករណ៍បាញ់សម្លាប់មេរោគ គ្រឿង និងសម្ភារៈប្រើប្រាស់ក្នុងថ្នាក់រៀន ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
3. **ហានិភ័យពីហេដ្ឋារចនាសម្ព័ន្ធ**សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីហេដ្ឋារចនាសម្ព័ន្ធ មានដូចជា បណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បេតុង លូរំដោះទឹក របងសាលា រូបសំណាក់ផ្សេងៗ កន្លែងរៀនក្រៅថ្នាក់ បង្គន់អនាម័យ កន្លែងលាងដៃ រួមទាំងគ្រោងអគារទាំងមូល ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
4. **ហានិភ័យពីបរិស្ថាន** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីបរិស្ថានក្នុងសាលារៀន មានដូចជា សួនច្បារ ដើមឈើ កន្លែងសិស្សលេង សួនជីវចំរុះ សួនបំណិនជីវិត ធុងសំរាម ស្រះ ឬអណ្តូង កន្លែងដុតសំរាម រួមទាំងគ្រោងអគារទាំងមូល ដែលអាចនឹងបង្កហានិភ័យដល់មនុស្ស។
5. **ហានិភ័យលើសុវត្ថិភាពផ្ទាល់ខ្លួន** សំដៅ មុខសញ្ញាគ្រោះថ្នាក់ដែលកើតចេញពីការបង្កឡើងដោយមនុស្សជាអ្នកប្រព្រឹត្តខ្លួនឯង ក្នុងសាលារៀន មានដូចជា ការធ្វើចរាចរណ៍ សុវត្ថិភាពចំណីអាហារ ទឹក និងប្រភពទឹក ការរើសអើងភេទ យេនឌ័រ វប្បធម៌ សាសនា ពិការភាព រួមទាំងគ្រោងអគារទាំងមូល ដែលអាចនឹងបង្កហានិភ័យ។

**២- ៥ ឯកសារសិក្សាបន្ថែម**

- ក្រសួងអប់រំ យុវជន និងកីឡា (2023) កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារៈ *ក្របខណ្ឌសាលារៀនសុវត្ថិភាព ។*

**២-៦ ការអនុវត្ត**

មេរៀននេះមានសារៈសំខាន់ណាស់សម្រាប់ គណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការកំណាត់ប្រភេទហានិភ័យ ដែលជាមុខសញ្ញាគ្រោះថ្នាក់ ឬរំខានដល់ការសិក្សាដល់សិស្ស។

គណៈគ្រប់គ្រងសាលា ត្រូវដឹកនាំ សម្របសម្រួល គ្រូ សិស្ស និងអ្នកពាក់ព័ន្ធ ចូលរួមអនុវត្តជាក់ស្តែងរកប្រភេទហានិភ័យក្នុងសាលារៀននីមួយៗឱ្យបានច្បាស់លាស់។

តើហានិភ័យនៅសាលារៀនរបស់អ្នកមានអ្វីខ្លះ? ចូរធ្វើតារាងចំណាត់ថ្នាក់ប្រភេទហានិភ័យទាំងនោះ?

សាលារៀនទាំងអស់ ត្រូវតែជាសាលារៀនសុវត្ថិភាព ដែលកាត់បន្ថយហានិភ័យកម្រិតអប្បបរមា ពីគ្រប់ប្រភពទាំងអស់។គណៈគ្រប់គ្រងសាលា គណៈកម្មការគ្រប់គ្រងសាលា ឬ គណៈកម្មការគ្រប់គ្រងគ្រោះ

មហន្តរាយរបស់ សាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស ជាពិសេសគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារត្រូវជួបប្រជុំគ្នា ដើម្បីពិភាក្សា ស្វែងរក ប្រភេទហានិភ័យនៅសាលា ដើម្បីកំណត់និងធានាថាព័ត៌មានដែលទទួលបានមកគឺមានភាពជាក់លាក់ អាចយកទៅប្រើប្រាស់បាន និងផ្សព្វផ្សាយយល់ដឹងទាំងអស់គ្នា។

**សំណួរ**

ហេតុអ្វីបានជាត្រូវសិក្សាពីប្រភេទហានិភ័យទាំង៥ក្នុងសាលារៀន ?តើមានសារៈប្រយោជន៍អ្វីខ្លះ ? ហើយត្រូវដោះ ស្រាយយ៉ាងដូចម្តេច ?

# មេរៀនទី៣៖ ការវិភាគមុខសញ្ញាគ្រោះថ្នាក់

## ១- វត្ថុបំណង

- ប្រាប់មុខសញ្ញាគ្រោះថ្នាក់ ប្រវត្តិ អាទិភាព និងប្រតិទិនរដូវកាលនៃមុខសញ្ញាគ្រោះថ្នាក់ នៅក្នុងសាលារៀន
- កំណត់និងវិភាគមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុងសាលារៀន
- មានការរៀបចំជាមុន ដើម្បីគេចផុតពីមុខសញ្ញាគ្រោះថ្នាក់នៅក្នុងសាលារៀននិងសហគមន៍។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

ក្នុងមេរៀននេះអ្នកសិក្សានឹងសិក្សាផ្តោតលើខ្លឹមសារសំខាន់ៗ (១)ផែនទីមុខសញ្ញាគ្រោះថ្នាក់សាលារៀន (២) ប្រវត្តិគ្រោះមហន្តរាយ (៣)ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ និង (៤) ប្រតិទិនតាមរដូវកាល ដើម្បីបានជាព័ត៌មានបឋមសម្រាប់បន្តទៅ ជំហានខាងមុខទៀតក្នុងការវិភាគមុខសញ្ញាគ្រោះថ្នាក់។

### ២- ២ ពាក្យគន្លឹះ

*ការវិភាគមុខសញ្ញាគ្រោះថ្នាក់* គឺធ្វើឡើង ដើម្បីកំណត់ពីលក្ខណៈ ទំហំ និងឥទ្ធិពលនៃមុខសញ្ញាគ្រោះថ្នាក់នានាដែលអាចកើតមាន និងបង្កការគំរាមកំហែងដល់សាលារៀន និងសហគមន៍។

*ភាពងាយរងគ្រោះ* គឺធ្វើឡើង

*ព័ត៌មាន* គឺសំដៅលើព្រឹត្តិការណ៍ ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន បច្ចុប្បន្នកាល ។

*អាទិភាព* គឺភាពនាំមុខ។

*វិភាគ* គឺ ការចែក ការបែង ការញែកធាតុ ញែកចំណែក គឺសំដៅលើការការបែងចែកយ៉ាងល្អិតល្អន់ដោយផ្អែកលើព័ត៌មាន និងទិន្នន័យដែលប្រមូលបាន។

*ហានិភ័យ* គឺ សំដៅដល់ភាពដែលអាចកើតមាននូវផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក (ស្លាប់ របួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ចត្រូវបានរំខាន ឬបរិស្ថានត្រូវបានខូចខាត)ដែល បណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ ទៅនឹងភាពងាយរងគ្រោះ

*គ្រោះមហន្តរាយ* គឺសំដៅលើបាតុភូត និងសកម្មភាពបង្កដោយធម្មជាតិ ឬមនុស្ស ដែលអាចបង្កគ្រោះថ្នាក់ដល់មនុស្ស មានការបង្កឱ្យមនុស្សស្លាប់ រងរបួស ខូចខាតទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធរបស់បុគ្គល និងសង្គម។

### ២- ៣ ខ្លឹមសារមេរៀន

តើយើងចាំបាច់វិភាគមុខសញ្ញាគ្រោះថ្នាក់ ដើម្បីអ្វី?

*ការវិភាគមុខសញ្ញាគ្រោះថ្នាក់* គឺធ្វើឡើង ដើម្បីកំណត់ពីលក្ខណៈ ទំហំ និងឥទ្ធិពលនៃមុខសញ្ញាគ្រោះថ្នាក់នានាដែលអាចកើតមាន និងបង្កការគំរាមកំហែងដល់សាលារៀន និងសហគមន៍។

ការវិភាគមុខសញ្ញាគ្រោះថ្នាក់អាចធ្វើតាមមធ្យោបាយខុសៗគ្នាទៅតាមទិន្នន័យដែលមានស្រាប់ និងតំបន់។សាលារៀន និងសហគមន៍តែងតែជួបគ្រោះមហន្តរាយផ្សេងៗដូចជា គ្រោះទឹកជំនន់ពីស្ទឹង គ្រោះរាំងស្ងួត ខ្យល់កន្ត្រាក់ គ្រោះថ្នាក់ចរាចរណ៍ អគ្គីភ័យជាដើម ។

ការវិភាគមុខសញ្ញាគ្រោះថ្នាក់ ត្រូវធ្វើឡើងអាស្រ័យលើចំណុចសំខាន់ៗ

ក- ផែនទីមុខសញ្ញាគ្រោះថ្នាក់សាលារៀន

ខ- ការប្រមូលព័ត៌មានប្រវត្តិគ្រោះមហន្តរាយ

គ- ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ (ភាពញឹកញាប់ ទំហំ និងផលប៉ះពាល់)

ឃ- តារាងប្រតិទិនរដូវកាល

ង- តារាងវិភាគភាពងាយរងគ្រោះ

ច- តារាងវិភាគហានិភ័យទាំង៥

ខាងក្រោមនេះជាឧទាហរណ៍ដែលបង្ហាញនិងទាក់ទងការវិភាគមុខសញ្ញាគ្រោះ

**ក- ផែនទីមុខសញ្ញាគ្រោះថ្នាក់សាលារៀន**

ការគូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ជាការធ្វើលំហាត់មើលឃើញមួយ ដែលត្រូវបានធ្វើឡើងជាក្រុមដោយអ្នក ចូលរួមដើម្បី កំណត់រកឲ្យឃើញនូវរូបភាព ដែលបង្ហាញពី រចនាសម្ព័ន្ធសង្គមដែលទទួលការប៉ះពាល់ គ្រោះមហន័រាយ ដែល័កើតមាននៅក្នុងសាលារៀន ឬសហគមន៏។ ផែនទីដែល យើងនឹង គូរនេះគឺជាផែនទីសាលារៀន និង ភូមិសាស្ត្រទូទៅ។

**ខ- តារាងព័ត៌មានប្រវត្តិគ្រោះមហន្តរាយ**

តើអ្វីជាប្រវត្តិនៃគ្រោះមហន្តរាយ ?តើត្រូវធ្វើដូចម្តេច ?

ជាការរៀបរាប់ ឬចងក្រងព័ត៌មានអំពីព្រឹត្តិការណ៍ និងសកម្មភាពនានាដែលបានកើតឡើងនៅអតីតកាល ទាកទងនឹងមុខសញ្ញាគ្រោះថ្នាក់ដែលអាច ឬបានបង្កជាគ្រោះមហន្តរាយ ភាពងាយរងគ្រោះនៃសហគមន៍ សាលារៀន និងធានធានដែលជាសមត្ថភាព សម្រាប់ទប់ទល់កាត់បន្ថយគ្រោះមហន្តរាយ និងវិធានការនានា ដែលបានកំណត់យក ក្នុងការដោះស្រាយវិបត្តិទាំងនោះ ជាតារាងគំរូ។

| ល-រ | គ្រោះមហន្តរាយ | ឆ្នាំ | ផលប៉ះពាល់ | វិធានការណ៍ដែលអនុវត្តកន្លងមក |
|---|---|---|---|---|
| 1 | ខ្យល់ព្យុះ | | | |
| 2 | ផ្ទុះមីន | | | |
| 3 | សង្គ្រាមទល់ដែន ជាមួយថៃ | | | |
| 4 | គ្រោះថ្នាក់ចរាចរណ៍ | | | |
| 5 | ភ្លើងឆេះផ្ទះ | | | |
| 6 | ភ្លើងឆេះព្រៃ | | | |

| | | | | |
|---|---|---|---|---|
| 7 | ចោរប្លន់ | | | |
| 8 | គ្រឿងញៀន | | | |
| 9 | ខ្យល់ព្យុះ | | | |

### គ- ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ (ភាពញឹកញាប់ ទំហំ និងផលប៉ះពាល់)

ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ គឺជាវិធីកំណត់នូវមុខសញ្ញាគ្រោះថ្នាក់ណា ដែលអាចនឹងកើតមុនគេ និងប៉ះពាល់ខ្លាំងជាងគេតាមរយៈការប៉ាន់ស្មានដោយផ្អែកលើការមើលដោយផ្ទាល់នៅ នឹងកន្លែងដែលបានកើតឡើងកន្លងមក ឬកំពុងកើត។ ខាងក្រោមនេះឧទាហរណ៍វិធីសាស្ត្រ ចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ (តារាងចំណាត់ថ្នាក់ជាគំរូ)

| មុខសញ្ញាគ្រោះថ្នាក់ | ទឹកជំនន់ | រាំងស្ងួត | ខ្យល់ព្យុះ | រន្ទះបាញ់ | គ-ចរាចរណ៍ | ជំងឺឆ្លង | ពិន្ទុ | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ទឹកជំនន់ | | | | | | | | |
| រាំងស្ងួត | | | | | | | | |
| ខ្យល់ព្យុះ | | | | | | | | |
| រន្ទះបាញ់ | | | | | | | | |
| គ-ចរាចរណ៍ | | | | | | | | |
| ជំងឺឆ្លង | | | | | | | | |

### ឃ- តារាងប្រតិទិនរដូវកាល

តើអ្វីជាប្រតិទិនរដូវកាល? តើត្រូវធ្វើដូចម្តេច? តើគ្រោះមហន្តរាយទាំងនេះកើតឡើងក្នុងអំឡុងខែណាខ្លះ? ប្រតិទិនរដូវកាលជាគំនូសតាំងដែលបង្ហាញឲ្យឃើញពីសកម្មភាពហេតុការណ៍ ឬព្រឹត្តិការណ៍ដែលបានកើត ឡើងជាទម្លាប់ឬយ៉ាងទៀងទាត់ញឿក្នុងសប៉ាគមន៏មួយ ឬសាលារៀន ពីមួយខែទៅមួយខែ សម្រាប់រយៈពេលពេញមួយឆ្នាំ។ ឌីយ៉ាក្រាមតាមរដូវកាលី អាចមានទម្រង់ជាតារាងឺជាអ័ក្ស វែង ឬជាក្រាហ្វិក។បន្ទាប់ពីបានលទ្ធផល ចូលគូx ,xx, xxx នៅខែដែលគ្រោះមហន្តរាយកើតឡើងដូចគំរូតារាងខាងក្រោម៖

| ល-រ | ប្រភេទមុខសញ្ញាគ្រោះថ្នាក់ | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | ខ្យល់ព្យុះ | | | | | | | | | | | | | |
| ២ | ទឹកជំនន់ | | | | | | | | | | | | | |
| ៣ | រន្ទះបាញ់ | | | | | | | | | | | | | |
| ៤ | ផ្ទុះមីន | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥ | គ្រោះថ្នាក់ចរាចរណ៍ | | | | | | | | | | | | | |
| ៦ | ភ្លើងឆេះផ្ទះ | | | | | | | | | | | | | |
| ៧ | ភ្លើងឆេះព្រៃ | | | | | | | | | | | | | |
| ៨ | គ្រឿងញៀន | | | | | | | | | | | | | |
| ៩ | ជំងឺឆ្លង | | | | | | | | | | | | | |

**សម្គាល់** សញ្ញា x x x ជាពិន្ទុខ្ពស់ចង្អុលបង្ហាញនូវកំរិតភាពធ្ងន់ធ្ងរ ខ្លាំង ញឹកញាប់ ឬវិសាលភាពនៃឥទ្ធិពលព្រឹត្តិការណ៍នោះ និង x x កម្រិតមធ្យម ហើយ x ជាកម្រិតស្រាល តិចតួច មិនញឹកញាប់។

### ង- តារាងវិភាគអំពីភាពងាយរងគ្រោះតាមមុខសញ្ញាគ្រោះថ្នាក់នីមួយៗ

| ល-រ | បញ្ហា (ហានិភ័យ) | ហេតុអ្វីបានជាមានបញ្ហាទាំងនេះ? (ភាពងាយរងគ្រោះ) | សកម្មភាពដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យ (បញ្ហា)ដែលធ្វើកន្លងមក និងត្រូវធ្វើបន្ត |
|---|---|---|---|
| ១ | **ខ្យល់ព្យុះ** | | |
| | | | |
| ២ | **ទឹកជំនន់ និងជំនោរកក្កិក** | | |
| | | | |
| ៣ | **គ្រោះរាំងស្ងួត** | | |
| | | | |
| | | | |
| | | | |
| ៤ | **គ្រោះថ្នាក់ចរាចរណ៍** | | |
| | | | |
| ៥ | **គ្រឿងញៀន** | | |
| | | | |

### ច- តារាងវិភាគអំពីហានិភ័យទាំង ៥ នៅក្នុងសាលារៀន

| ល-រ | ហានិភ័យ | បញ្ហាដែលអាចកើតមាន | សកម្មភាពដោះស្រាយ | អាទិភាពសកម្មភាពដោះស្រាយ |
|---|---|---|---|---|
| ១ | ហានិភ័យពីគ្រោងអគារ ឬចនាសម្ព័ន្ធ | | | |
| ២ | ហានិភ័យពីពីកត្តាផ្សេងៗ មិនមែនពីគ្រោងអាគារ ឬចនាសម្ព័ន្ធ | | | |

| | | | | |
|---|---|---|---|---|
| ៣ | ហានិភ័យពីហេដ្ឋារចនាសម្ព័ន្ធ | | | |
| ៤ | ហានិភ័យពីបរិស្ថាន | | | |
| ៥ | ហានិភ័យលើសុវត្ថិភាពផ្ទាល់ខ្លួន | | | |

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

បន្ទាប់ពីបានសិក្សារួចខ្លឹមសារខាងលើរួច អ្នកសិក្សាត្រូវចងចាំអំពីកិច្ចការមួយចំនួនរបស់ គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលា/គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយរបស់សាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស ជាពិសេសគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារត្រូវជួបប្រជុំគ្នា ដើម្បីពិភាក្សា និងរៀបចំ អំពីផែនទីមុខសញ្ញាគ្រោះថ្នាក់សាលារៀន ប្រវត្តិគ្រោះមហន្តរាយ ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ និងប្រតិទិនតាមរដូវកាលដើម្បីបានជាព័ត៌មានបឋមសម្រាប់បន្តទៅ ជំហានខាងមុខទៀតក្នុងការវិភាគមុខសញ្ញាគ្រោះថ្នាក់ ជាពិសេសត្រូវផ្តោតសិក្សាបន្ថែមពីរបៀបបំពេញតារាងក្នុងឧបសម្ព័ន្ធជាគំរូសម្រាប់ជាគំរូក្នុងការអនុវត្តបន្តនៅសាលារៀនរបស់ខ្លួន។

**២- ៥ ឯកសារសិក្សាបន្ថែម**

- ក្រសួងអប់រំ យុវជន និងកីឡា (2023) កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារៈ *ក្របខណ្ឌសាលារៀនសុវត្ថិភាព ។*

**២-៦ ភាពអនុវត្ត**

គណៈគ្រប់គ្រងសាលា ត្រូវដឹកនាំ សម្របសម្រួល គ្រូ សិស្ស និងអ្នកពាក់ព័ន្ធ ចូលរួមអនុវត្តជាក់ស្តែងដោយវិភាគមុខសញ្ញាគ្រោះថ្នាក់ដូចលំនាំតារាងចំណុច ក ខ គ និងឃ តាមសាលារៀននីមួយៗឱ្យបានច្បាស់លាស់ ដែលចំនុចទាំងអស់នោះមានៈ

ក- ផែនទីមុខសញ្ញាគ្រោះថ្នាក់សាលារៀន

ខ- ការប្រមូលព័ត៌មានប្រវត្តិគ្រោះមហន្តរាយ

គ- ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ (ភាពញឹកញាប់ ទំហំ និងផលប៉ះពាល់)

ឃ- តារាងប្រតិទិនរដូវកាល

បន្ទាប់ពីសិក្សាមេរៀននេះចប់ យើងនឹងបន្តចូលសិក្សាលម្អិតអំពីរបៀបរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់សាលារៀននៃមេរៀនបន្ទាប់។

**សំណួរ**

១- តើការវិភាគមុខសញ្ញាគ្រោះថ្នាក់នៅតាមសាលារៀននីមួយៗផ្អែកលើចំណុចសំខាន់ៗអ្វីខ្លះ? ចូរធ្វើតារាងការវិភាគមុខសញ្ញាគ្រោះថ្នាក់នៅតាមសាលារបស់អ្នកឱ្យបានត្រឹមត្រូវ?

២- តើនៅក្នុងសាលារៀន ឬ ភូមិ ឃុំ របស់អ្នកធ្លាប់រងគ្រោះដោយសារគ្រោះមហន្តរាយអ្វីខ្លះក្នុងរយៈពេល ៥-១០ ឆ្នាំកន្លងមក?

៣- តើគ្រោះមហន្តរាយទាំងនោះកើតឡើងក្នុងឆ្នាំណា? ហើយបណ្តាលឲ្យមានផលប៉ះពាល់អ្វីខ្លះ?

៤- តើមានវិធានការអ្វីខ្លះដែលបានអនុវត្តដើម្បីឆ្លើយតបនឹងគ្រោះមហន្តរាយទាំងនោះ?

៥- អ្នកដឹកនាំការពិភាក្សាត្រូវកត់ត្រាចម្លើយ ឬលទ្ធផលរបស់ក្រុមដើម្បីបញ្ចូលទៅក្នុងតារាងវិភាគមុខសញ្ញាគ្រោះថ្នាក់។

# មេរៀនទី៤៖ ផែនទីមុខសញ្ញាគ្រោះថ្នាក់

## ១- វត្ថុបំណង

- កំណត់មុខសញ្ញាគ្រោះថ្នាក់និងសារៈសំខាន់ក្នុងផែនទីមុខសញ្ញាគ្រោះថ្នាក់នៅសាលារៀន
- គូរនិងប្រើប្រាស់ផែនទីមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុងសាលារៀន ដើម្បីដាក់បញ្ចូលទៅក្នុងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន (ផែនការកាត់បន្ថយហានិភ័យ) សម្រាប់សាលារៀនអនុវត្ត
- បណ្ដុះស្មារតីប្រុងប្រយ័ត្នក្នុងការបញ្ចៀសមុខសញ្ញាគ្រោះ និងផលប៉ះពាល់ថ្នាក់ក្នុងសាលារៀន។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្ដីណែនាំ

ក្នុងមេរៀនមុនអ្នកបានយល់ច្បាស់ហើយថាដើម្បីវិភាគមុខសញ្ញាគ្រោះថ្នាក់ ចាំបាច់អ្នកសិក្សាត្រូវរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ នៅក្នុងមេរៀននេះអ្នកនឹងសិក្សាអំពីការរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ដោយផ្ដោតយ៉ាងលម្អិតដូចខាងក្រោម៖

- ការណែនាំទូទៅពីផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
- សិក្សាអំពីរបៀបគូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
- ដំណើរការដឹកនាំរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
  - កំណត់ហានិភ័យទាំង៥ ដែលនឹងអាចកើតឡើង
  - កំណត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ដែលត្រូវលុបបំបាត់ និងដាក់ផ្លាកទប់ស្កាត់។

ដូច្នេះការកំណត់និងធ្វើចំណាត់ថ្នាក់ជាអាទិភាពទៅលើមុខសញ្ញាគ្រោះថ្នាក់ ដើម្បីរៀបចំ ដាក់បញ្ចូលទៅក្នុងផែនទីមុខសញ្ញាគ្រោះថ្នាក់និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលា ហើយពិតជាមានប្រយោជន៍បំផុតសម្រាប់សាលារៀនទាំងអស់យកទៅប្រើប្រាស់។

### ២- ២ ពាក្យគន្លឹះ

- ***មុខសញ្ញាគ្រោះថ្នាក់*** សំដៅដល់ព្រឹត្តិការណ៍ បាតុភូត ឬសកម្មភាពរបស់មនុស្សដែលសក្ដានុពលរបស់វាអាចធ្វើឱ្យខូចខាតជារូបវន្ត រួមមាន ការបាត់បង់អាយុជីវិត ការរងរបួស ខូចខាតនិងបាត់បង់ទ្រព្យសម្បត្តិ រាំងស្ទះដល់សង្គមនិងសេដ្ឋកិច្ចឬខូចខាតបរិស្ថាន ។
- ***ផែនទីមុខសញ្ញាមុខសញ្ញាគ្រោះ*** គឺជាគំនូសចង្អុលបង្ហាញពីទីតាំងដែលអាចនឹងបង្កហានិភ័យដែលមនុស្សដែលអាស្រ័យក្នុងទៅតាំង ឬតំបន់នោះ។

### ២- ៣ ខ្លឹមសារមេរៀន

មេរៀននេះ លោកគ្រូ អ្នកគ្រូ ត្រូវធ្វើការកំណត់ឱ្យបានជាមុនអំពីនូវមុខសញ្ញាគ្រោះថ្នាក់សំខាន់ៗនៅក្នុងសាលារៀនដែលបានរកឃើញ ដោយផ្តោតលើៈ

- ការណែនាំទូទៅពីផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
- សិក្សាអំពីរបៀបគូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
- ដំណើរការដឹកនាំរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
  - កំណត់ហានិភ័យទាំង៥ ដែលនឹងអាចកើតឡើង
  - កំណត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ដែលត្រូវលុបបំបាត់ និងដាក់ផ្លាកទប់ស្កាត់។

**ក.ការណែនាំទូទៅពីផែនទីមុខសញ្ញាគ្រោះថ្នាក់នៅក្នុងសាលារៀន**

ឧទាហរណ៍ មុខសញ្ញាគ្រោះថ្នាក់មានដូចជា អគារសិក្សា បន្ទប់រៀនដែលមានភាពចាស់ទ្រុឌទ្រោម អណ្តូងទឹកគ្មានគម្របហើយនៅប្របនឹងផ្ទៃដី សាលារៀននៅជាប់ស្រះ ត្រពាំង ព្រែក ស្ទឹង ទន្លេ មានដើមឈើធំៗមានមែកចាស់ៗពុកផុយ របងសាលារុំបន្លា ទោងជិះចាស់មានគន្លឹះមិនរឹងមាំ... អាចបង្កគ្រោះថ្នាក់ដល់សិស្សពេលទៅជិះលេង ពេលទៅលេងជិត ពេលមានខ្យល់ខ្លាំងបាក់ឬធ្លាក់រលំលើ បង្កឱ្យមានការរងរបួស ប៉ះពាល់ដល់អាយុជីវិត ឬខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធឬបរិស្ថានសាលារៀនជាដើម។

លើសពីនេះទៀត គំនិតជាមូលដ្ឋានលើការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុនិងភាពធន់ ផ្តោតសំខាន់គឺការតម្រូវឱ្យសាលារៀននីមួយៗត្រូវរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលារៀនអនុវត្ត។ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននេះ សំដៅលើគ្រប់គ្រងដំណើរការដែលធ្វើការវិភាគព្រឹត្តិការណ៍កើតឡើង ឬស្ថានភាពដែលអាចកើតឡើងហើយអាចគំរាមកំហែងដល់សង្គម បរិស្ថាននិងការរៀបចំទុកដាក់ដើម្បីចាត់ចែងនៅពេលខាងមុខប្រកបដោយសមត្ថភាពនិងទាន់ពេលវេលាទៅនឹងព្រឹត្តិការណ៍និងស្ថានភាពទាំងនោះ។ ដូច្នេះទើបសាលារៀននីមួយៗត្រូវកំណត់មុខសញ្ញាគ្រោះថ្នាក់ ធ្វើចំណាត់ថ្នាក់អាទិភាពនិងគូសផែនទីរដ្ឋបាលឬផែនទីសិក្សា បន្ទាប់មក ទើបគូសផែនទីមុខសញ្ញាគ្រោះថ្នាក់ដែលគ្រាន់តែបន្ថែមមុខសញ្ញាគ្រោះថ្នាក់ដាក់បញ្ចូលបន្ថែមជាការស្រេច។

ខាងក្រោមនេះ ជាឧទាហរណ៍ផែនទីរដ្ឋបាល ឬផែនទីសិក្សាក្នុងសាលា។

**<u>ផែនទីរដ្ឋបាល ឬផែនទីសិក្សាក្នុងសាលារៀន</u>**




## ខ.ការសិក្សារៀបគូរផែនទីមុខសញ្ញាគ្រោះថ្នាក់នៅក្នុងសាលារៀន

### ខ-១ ការណែនាំទូទៅ

គណៈគ្រប់គ្រងសាលារៀននីមួយៗ គប្បីចូលរួមកៀងគរដឹកនាំសម្របសម្រួលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស គណៈកម្មការទ្រទ្រង់សាលានិងអ្នកពាក់ព័ន្ធនានា។ល។ឱ្យចូលរួមរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ រួមគ្នាហើយឯកភាពគ្នាក្នុងការដៅចំណុចគោលធំៗក្នុងសាលាមួយចំនួនដូចជាទីតាំងផ្លូវចូលខ្លោងទ្វារ និងផ្លាកសាលា អគារសិក្សា បន្ទប់រៀន ទីចាត់ការ បណ្ណាល័យ ដងទង់ជាតិ សួនច្បារ សួនជីវៈចម្រុះ ដើមឈើធំ តូច បង្គន់អនាម័យ អណ្តូងទឹក ធុងទឹកធំៗសម្រាប់បង្ហូរទឹកស្អាតហូប ប្រើប្រាស់ ដែលសាលារៀនមាន។ល។ ពិសេស ការដាក់បញ្ចូលចំណុចដៅ មុខសញ្ញាគ្រោះថ្នាក់ដែលក្រុមការងារសាលាបានកំណត់និងធ្វើចំណាត់ថ្នាក់អាទិភាពរួចហើយជាចំណុចក្រហមសម្គាល់និងដៅចំណុចសម្គាល់ផ្សេងៗក្នុងផែនទីគ្រប់ចំណុចសំខាន់ៗដែលមានដោយដាក់ជាតារាងតូចល្មម នៅជ្រុងម្ខាងនៃផែនទីព្រមទាំងកំណត់ទិស( លិច កើត ជើង ត្បូង )សម្គាល់ផងដែរ។

### ខ-២ របៀបគូរផែនទីមុខសញ្ញាគ្រោះថ្នាក់

### ១-ការរៀបចំ

- សម្ភារៈ ក្រដាសផ្ទាំងធំ ក្រដាសរ៉ាម ក្រដាសរ៉ាមពណ៌ ហ្វឺត បន្ទាត់ កន្ត្រៃ ប៊ិក ខ្មៅដៃ ខ្មៅដៃពណ៌ ឬកូល័រ
- អ្នកចូលរួម អ្នកមានបំណិននិងស្ម័គ្រចិត្តគូរផែនទី និងអ្នកចូលរួមគ្រប់ភាគីពាក់ព័ន្ធ ផ្តល់គំនិតយោបល់ក្នុងការគូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ។

### ២-របៀបគូរ

- យកក្រដាសផ្ទាំងធំ ឬក្រដាសកាតុងធំ១សន្លឹក មកគូសព្រាងជារាងបួនជ្រុងជុំវិញបរិវេណក្រដាសតាមទំហំកំណត់មួយជារួមដោយរក្សាទុកជាយខាងក្រៅក្រដាសតូចល្មម ដោយប្រើខ្មៅដៃព្រាងសិន មុនកែសម្រេចចុងក្រោយ

- ដៅចំណុចសំខាន់ៗទាំងចំណុចគោលនិងមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ ទៅតាមសាលានីមួយៗ ដែលមានជាក់ស្តែង និងដូចបានរៀបរាប់ជាតួយ៉ាងក្នុងលំណែនាំទូទៅខាងលើ តាមបរិបទសាលារៀននីមួយៗ
- គូរ រចនា តុបតែង ចំណុចដៅទាំងអស់ដែលបានដៅនៅលើផែនទី។ បន្ទាប់មក នាំគ្នាពិនិត្យ កែលម្អឱ្យបានល្អ ដោយផាត់ពណ៌លម្អ ឬកាត់ក្រដាសរ៉ាមពណ៌បិតតាមតម្រូវការ ឱ្យបានស្អាត ល្អដូចជាសញ្ញាគ្រោះថ្នាក់ ពណ៌ក្រហម ដើមឈើពណ៌បៃតង - - -
- សរសេរព្រាងចំណុចសម្គាល់សំខាន់ៗក្នុងផែនទី ដាក់ក្នុងប្រអប់ដែលតាងដោយនិមិត្តសញ្ញាផ្សេងៗឱ្យច្បាស់លាស់។

  ឧទាហរណ៍ សញ្ញា=អណ្តូងទឹក សញ្ញា=បង្គន់
- ពិនិត្យនិងកែលម្អ រូបផែនទី ឡើងវិញ ជាការសម្រេចចុងក្រោយ។

## គ. ដំណើរការដឹកនាំរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន

ការរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់នឹងអាចជួយក្នុងការកំណត់បាននូវទីតាំង មុខសញ្ញាគ្រោះថ្នាក់ហានិភ័យដែលអាចកើតមាននៅក្នុងសាលារៀន និងសហគមន៍និងក៏អាចកំណត់បានផងដែរនូវភាពងាយរងគ្រោះនិងធនធានផ្សេងៗដែលមាន។ក្នុងការគូរផែនទីត្រូវបង្ហាញពីទីតាំងអគារសិក្សា បង្គន់អនាម័យ សួនកុមារ ដងទង់ជាតិ ដើមឈើ ស្រះទឹក អណ្តូង ឬសម្ភារៈរូបវន្តនានាដែលមាននៅក្នុងសាលារៀន។ ដើម្បីងាយស្រួលក្នុងការគូរផែនទីនេះ អ្នកដឹកនាំការពិភាក្សាឱ្យសមាជិក អង្គប្រជុំចេញទៅខាងក្រៅថ្នាក់រៀន ដើម្បីពិនិត្យមើលក្នុងបរិវេណ និងទីជិតជុំវិញរបងសាលា។

### គ.១ កំណត់ហានិភ័យទាំង៥ដែលនឹងអាចកើតឡើង តាមកម្រងសំណួរពិភាក្សា

បន្ទាប់មក ឱ្យពួកគាត់ចាប់ផ្តើមគូរផែនទីសាលារៀនដោយសួរសំណួរបំផុសដូចខាងក្រោម ៖

1. តើមានសម្ភារៈរូបវន្ត (ស្រះ អគារសិក្សា បង្គន់អនាម័យ សួនកុមារ ដងទង់ជាតិ អណ្តូង) និងដើមឈើអ្វីខ្លះនៅក្នុងសាលារៀន? មានទីតាំងនៅកន្លែងណាខ្លះ?
2. តើសម្ភារៈរូបវន្ត ឬ ទីកន្លែង ណាខ្លះអាចបង្កគ្រោះថ្នាក់ដល់កុមារ?
   - តើមានមុខសញ្ញាគ្រោះថ្នាក់ដែលបង្កដោយធម្មជាតិអ្វីខ្លះទៀត (ក្រៅពីសម្ភារៈរូបវន្ត ឬ ទីកន្លែងដែលបង្កគ្រោះថ្នាក់ខាងលើ) ដែលបង្កផលប៉ះពាល់ដល់សាលារៀន?
     - ក្នុងករណីសមាជិក អង្គប្រជុំរកមុខសញ្ញាគ្រោះថ្នាក់មិនទាន់អស់ អ្នកដឹកនាំការពិភាក្សាអាចលើកបន្ថែមនូវមុខសញ្ញាគ្រោះថ្នាក់ដែលខ្លួនមើលឃើញ។
     - កត់ត្រាចម្លើយនៅក្រដាសផ្ទាំងធំ ឬក្តារខៀន។ បន្ទាប់មក ឱ្យសមាជិកអង្គប្រជុំយកក្រដាសផ្ទាំងធំបិទលើក្តារខៀនរួចគូរផែនទីសាលារៀនហើយកំណត់ទីតាំងមុខសញ្ញាគ្រោះថ្នាក់នានាដែលបានរកឃើញដាក់នៅក្នុងផែនទី។

- បន្ទាប់ពីកំណត់បានទីតាំងមុខសញ្ញាគ្រោះថ្នាក់នៅក្នុងផែនទីខាងលើរួចមក អ្នកដឹកនាំការពិភាក្សាឱ្យសមាជិកអង្គប្រជុំកំណត់រកបន្តទៀតនូវ ភាពងាយរងគ្រោះ ដោយសួរសំណួរបំផុសដូចខាងក្រោម

3. តើមានកន្លែងណា ឬ ក្រុមណាដែលងាយរងគ្រោះទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដែលបានរកឃើញនៅក្នុងផែនទី ?
   - អ្នកដឹកនាំការពិភាក្សាឱ្យសមាជិកអង្គប្រជុំដាក់សញ្ញាសម្គាល់នៅត្រង់កន្លែងនោះ។ ចំពោះភាពងាយរងគ្រោះណាដែលមិនអាចដាក់សញ្ញាសម្គាល់បាន។ ឧទាហរណ៍ ដូចជាកុមារខ្វះចំណេះដឹង គ្មានក្រុមសម្រួលចរាចរណ៍ អាចសរសេរជាអក្សរត្រង់ចន្លោះ ដែលទំនេរនៅក្នុងផែនទី។
   - អ្នកដឹកនាំការពិភាក្សា ឱ្យសមាជិកអង្គប្រជុំកំណត់រកធនធាន ឬសមត្ថភាពមួយចំណុចទៀតដោយសួរសំណួរបំផុស

4. តើមានធនធាន សម្ភារៈឧបករណ៍ ទីកន្លែង ឬក្រុមណាខ្លះ ដែលមានលទ្ធភាពទប់ទល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដែលបានរកឃើញក្នុងផែនទី ?
   - អ្នកដឹកនាំការពិភាក្សា ឱ្យសមាជិកអង្គប្រជុំដាក់សញ្ញាសម្គាល់នៅត្រង់កន្លែងនោះ។ ធនធាន ឬសមត្ថភាពដែលមិនអាចដាក់សញ្ញាសម្គាល់ ឧទាហរណ៍ដូចជា មានក្រុមសង្គ្រោះបន្ទាន់ រចនាសម្ព័ន្ធគ្រប់គ្រងសាលា ឬក្រុមផ្សេងៗដែលមានទាំងក្នុង និងក្រៅសាលា យើងអាចសរសេរជាអក្សរត្រង់ចន្លោះណាដែលទំនេរ នៅក្នុងផែនទី។

### គ.២ ដំណើរការគូរ ផ្អែកលើមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះដែលបានរកឃើញ

- **គូរព្រាងផែនទីមុខសញ្ញាគ្រោះថ្នាក់**

ដើម្បីគូរផែនទីមុខសញ្ញាគ្រោះថ្នាក់ឱ្យមានសោភ័ណ្ឌ ចាំបាច់ត្រូវគូរព្រាងសិន ដោយកំណត់សញ្ញាសម្គាល់សម្ភារៈរូបវន្តគួរប្រើប្រាស់ហ្វឺតពណ៌ខ្មៅ មុខសញ្ញាគ្រោះថ្នាក់គួរប្រើហ្វឺតពណ៌ក្រហម ធនធាន ឬសមត្ថភាពគួរប្រើហ្វឺតពណ៌បៃតង ភាពងាយរងគ្រោះប្រើហ្វឺតពណ៌ខៀវ។

**ខាងក្រោមជាគំរូឧទាហរណ៍៖ ផែនទីមុខសញ្ញាគ្រោះថ្នាក់ព្រាង**



❖ គូរសម្រេចផែនទីមុខសញ្ញាគ្រោះថ្នាក់

ដើម្បីគូរផែនទីមុខសញ្ញាគ្រោះថ្នាក់សម្រេចចុងក្រោយ យើងគាប់បីត្រូវចំលងចេញពីផ្ទាំងគំនូរផែនទីមុខសញ្ញាគ្រោះថ្នាក់ព្រាងក្នុងជំហានមុន។

ខាងក្រោមជាគំរូឧទាហរណ៍៖ ផែនទីមុខសញ្ញាគ្រោះថ្នាក់សម្រេច



❖ ស្រង់សកម្មភាពលុបបំបាត់ និងផ្លាកសញ្ញាទប់ស្កាត់ ពីផែនទីមុខសញ្ញាគ្រោះថ្នាក់ ដាក់ចូលក្នុងផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ កម្រិតសាលារៀន

ជំហានបន្ទាប់ ដើម្បីរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ យើងត្រូវចាត់ថ្នាក់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ជាមុនសិន ថាតើមុខសញ្ញាគ្រោះថ្នាក់ណាដែលត្រូវដោះស្រាយឬឆ្លើយតបមុនគេ។

➢ ការរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ

ជំហានចុងក្រោយគឺការរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ ដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់នៃគ្រោះមហន្តរាយ សាលារៀនត្រូវបង្កើតផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយឡើង។

តើយើងត្រូវធ្វើផែនការដូចម្តេច?

ដើម្បីធ្វើផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយបាន យើងត្រូវយកព័ត៌មានទាំងអស់ដែលបានរកឃើញតាំងពីជំហានទី១ មកបិទនៅជុំវិញកន្លែងធ្វើផែនការ។ បន្ទាប់មក ស្រង់ព័ត៌មានពីតារាងការវិភាគមូលហេតុ ផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ។ ជាពិសេស លើចំណុច សកម្មភាព និងវិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយដាក់ក្នុងកូឡោន ឬ ជួរបញ្ឈរទីមួយនៃតារាងផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ រួចបន្តសួរសំណួរ ដូចខាងក្រោមដើម្បីយកព័ត៌មានមកបំពេញ ក្នុងតារាងផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនេះ

1. តើយើងចង់អនុវត្តសកម្មភាពនេះនៅពេលណា និងបញ្ចប់នៅពេលណា?
2. តើអ្នកណាជាអ្នកទទួលខុសត្រូវអនុវត្ត?
3. តើយើងមានធនធានអ្វីខ្លះហើយ និងត្រូវការធនធានអ្វីបន្ថែមទៀតដើម្បីអនុវត្តសកម្មភាពនេះ?
4. តើអ្នកណាអាចជួយអ្នកក្នុងការអនុវត្តសកម្មភាពនេះ?

❖ ជាគំរូតារាងស្រង់សកម្មភាពក្រោយពេលរៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់

| សកម្មភាព/វិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (យកពីតារាងការវិភាគមូលហេតុ និងផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ) | ពេលណា? | អ្នកទទួលខុសត្រូវ | ធនធានមានស្រាប់(យកពីផែនទីកំណត់ធនធាន ឬសមត្ថភាព) | ធនធានត្រូវការ (សម្ភារៈឬបច្ចេកទេស) | ភ្នាក់ងារគាំទ្រ | |
|---|---|---|---|---|---|---|
| | | | | | ថវិកា | បច្ចេកទេស |
| - ដាក់សញ្ញាសម្គាល់អណ្តូងមានជាតិអាសេនិក | | | - | - | - | - |
| - ផ្សព្វផ្សាយហាមប្រើប្រាស់ទឹកអណ្តូងសម្រាប់ហូប | | - | - | - | - | - |
| - ជីកអណ្តូងថ្មី | | | - | | - | - |
| - ជីកស្រះបន្ថែម | | | - | - | - | - |

| | | | | | | |
|---|---|---|---|---|---|---|
| - ដាំដើមឈើបន្ថែមធ្វើជារបាំងទប់ខ្យល់ | | | - | - | - | - |

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

មុខសញ្ញាគ្រោះថ្នាក់មានដូចជា អគារសិក្សា បន្ទប់រៀនដែលមានភាពចាស់ទ្រុឌទ្រោម អណ្តូងទឹកគ្មានគម្របហើយនៅប្រឡបនឹងផ្ទៃដី សាលារៀននៅជាប់ស្រះ ត្រពាំង ព្រែក ស្ទឹង ទន្លេ មានដើមឈើធំៗមានមែកចាស់ៗពុកផុយ របងសាលារុំបន្លា ទោងជិះចាស់មានគន្លឹះមិនរឹងមាំ... អាចបង្កគ្រោះថ្នាក់ដល់សិស្សពេលទៅជិះលេង ពេលទៅលេងជិត ពេលមានខ្យល់ខ្លាំងបាក់ឬធ្លាក់រលំលើ បង្កឱ្យមានការរងរបួស ប៉ះពាល់ដល់អាយុជីវិត ឬខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធ ឬបរិស្ថានសាលារៀនជាដើម បន្ទាប់មកយើងត្រូវច្បាស់លាស់ពីៈ

- របៀបគូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
- ដំណើរគូរ ផែនទីមុខសញ្ញាគ្រោះថ្នាក់ ក្នុងសាលារៀន
  - សិក្សាស្ថានភាពមុខសញ្ញាគ្រោះថ្នាក់តាមមុខសញ្ញា តាមរយៈការកំណត់ហានិភ័យទាំង៥ដែលនឹងអាចកើតឡើង
  - កំណត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ដែលត្រូវលុបបំបាត់ និងដាក់ផ្លាកទប់ស្កាត់។
- កំណត់សកម្មភាពដែលត្រូវលើកដាក់ចូលផែនការកាត់បន្ថយហានិភ័យក្នុងសាលារៀន

ដូច្នេះការកំណត់និងធ្វើចំណាត់ថ្នាក់ជាអាទិភាពទៅលើមុខសញ្ញាគ្រោះថ្នាក់ ដើម្បីរៀបចំ ដាក់បញ្ចូលទៅក្នុងផែនទីមុខសញ្ញាគ្រោះថ្នាក់និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សម្រាប់សាលា ហើយពិតជាមានប្រយោជន៍បំផុតសម្រាប់សាលារៀនទាំងអស់យកទៅប្រើប្រាស់។

**២-៥ ឯកសារសិក្សាបន្ថែម**

- ឯកសារណែនាំពីកម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣

**២-៦ ការអនុវត្ត**

គណៈគ្រប់គ្រងសាលា ត្រូវដឹកនាំ សម្របសម្រួល គ្រូ សិស្ស និងអ្នកពាក់ព័ន្ធ ចូលរួមអនុវត្តជាក់ស្តែងដោយវិភាគមុខសញ្ញាគ្រោះថ្នាក់ដូចលំនាំតារាងចំណុច ក ខ គ និងឃ តាមសាលារៀននីមួយៗឱ្យបានច្បាស់លាស់ ។

ក- ផែនទីមុខសញ្ញាគ្រោះថ្នាក់សាលារៀន

ខ- ការប្រមូលព័ត៌មានប្រវត្តិគ្រោះមហន្តរាយ

គ- ការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ (ភាពញឹកញាប់ ទំហំ និងផលប៉ះពាល់)

ឃ- តារាងប្រតិទិនរដូវកាល

**សំណួរ**

1. តើគួរជ្រើសរើសមុខសញ្ញាគ្រោះថ្នាក់ណាខ្លះដើម្បីកំណត់អាទិភាពពីកម្រិតនៃផលប៉ះពាល់របស់មុខសញ្ញាសំខាន់ៗទាំងនោះ ទៅក្នុងផែនទីមុខសញ្ញាគ្រោះថ្នាក់របស់សាលារៀន?

2. តើមុខសញ្ញាគ្រោះថ្នាក់សំខាន់ណាខ្លះដែលត្រូវដាក់បញ្ចូលទៅក្នុងផែនទីមុខសញ្ញាគ្រោះថ្នាក់និងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលាប្រើប្រាស់ ?
3. តើសាលាត្រូវគូរផែនទីមុខសញ្ញាគ្រោះថ្នាក់របស់សាលារៀនយ៉ាងដូចម្ដេច ?
4. ដូច្នេះ លោកគ្រូ អ្នកគ្រូ ត្រូវចាប់ផ្ដើមពិភាក្សាគ្នាជាដំបូងថាតើអ្វីជា "មុខសញ្ញាគ្រោះថ្នាក់" ហើយគូរវារបៀបណា ?

# មេរៀនទី៥៖ វិភាគសមត្ថភាព និងចំនុចខ្វះខាត

## ១- វត្ថុបំណង

- ប្រាប់ពីសម្ភារៈ និងធនធាន ដើម្បីកំណត់សមត្ថភាពក្នុងការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀននៅកម្រិតសាលារៀន។
- វិភាគ និងកំណត់បានធនធានមនុស្ស និងសម្ភារៈ ក្នុងការជួយការគាំទ្រសាលារៀន និងសហគមន៍ ដើម្បីបន្តត្រៀមរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន។
- បណ្តុះបណ្តាលនូវផ្នត់គំនិតការចូលរួមលះបង់ ធនធាន និងសម្ភារៈដើម្បីចូលរួមសម្ភារៈ កំលាំងកាយចិត្ត និងធនធាន ក្នុងសកម្មភាពកាត់បន្ថយការបម្រែប្រួលអាកាសធាតុ និងត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន កម្រិតសាលារៀន និងក្នុងសហគមន៍។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ តម្រូវឱ្យសិក្សាពីសមត្ថភាព និងចំនុចខ្វះខាត លើការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន មុននឹងឈានដល់ការធ្វើផែនការ ដោយផ្តោតលើ៖

ក- ធនធានសម្ភារៈនិងឧបករណ៍ខាងក្នុងសាលារៀន

ខ- ធនធានសម្ភារៈ និងឧបករណ៍ខាងក្រៅសាលារៀន

គ- ការកំណត់ពីធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍ ?

ឃ- ការវិភាគស្ថាប័នដៃគូពាក់ព័ន្ធ

### ២- ២ ពាក្យគន្លឹះ

- *ប៉ាន់ស្មាន* គឺសំដៅការបែងចែក កាលៃមើល។
- *សមត្ថភាព* គឺសំដៅសេចក្តីអាចហាន សេចក្តីមោះមុត ដំណើរអាចធ្វើកើតដោយផ្អែកលើធនធាន ចំណេះដឹង ជំនាញ បច្ចេកទេស ដែលមាន។
- *ធនធាន* គឺសំដៅទ្រព្យរបស់ដែលគង់នៅ។
- *ឧបករណ៍* គឺសំដៅគ្រឿងប្រដាប់ ជួយទំនុកបម្រុង ការជួយទប់ទល់គ្នា។
- *សាលារៀន* គឺសំដៅ សាលាជំនុំរៀន និងកន្លែងជំនុំរៀន ។
- *សហគមន៍* គឺសំដៅ ការប្រមូលផ្តុំចូលគ្នា ដំណើរជាមួយគ្នា ការប្រជុំគ្នាជាភូមិឬតំបន់ ប្រកបមុខរបររស់នៅ ផ្តុំគ្នា។

### ២- ៣ ខ្លឹមសារមេរៀន

សាលារៀនមានដំណើរការប្រកបដោយសុខសុវត្ថិភាព អ្នកត្រូវរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន ដើម្បីត្រៀមជាមុនពេលមានគ្រោះមហន្តរាយកើតឡើង សំដៅការពារ កាត់បន្ថយ និងត្រៀមលក្ខណៈឆ្លើយតបនឹងគ្រោះមហន្តរាយក្នុងកម្រិតសាលារៀន។ ដូចនេះ ដើម្បីការរៀបចំនៃផែនការខាងលើនេះបាន គួរគប្បីដឹងអំពីសមត្ថភាពរបស់អ្នក និងអង្គភាពរបស់អ្នក ព្រមទាំងសហគមន៍របស់អ្នកតាមរយៈការកំណត់ធនធានសម្ភារៈ និងធនធានមនុស្សដែលអ្នកកំពុងមាន ក្នុងមេរៀននេះអ្នកនឹងយល់ច្បាស់អំពី អ្វីជាគោលការណ៍មួយចំនួន ដើម្បីឱ្យការងារគ្រប់គ្រងគ្រោះមហន្តរាយមានប្រសិទ្ធភាព កត្តាសមត្ថភាព និង ធនធានទាំងខាងក្នុង និងខាងក្រៅគឺជាកត្តាចាំបាច់មួយទុកជាទុនវិនិយោគក្នុងការងារនេះ។ ដោយដំណើរការប្រព្រឹត្តរបស់សាលារៀនមានការពាក់ព័ន្ធជិតស្និទ្ធនិងសហគមន៍ វាជាការចាំបាច់ណាស់ដែលត្រូវវិភាគថា តើធនធានសហគមន៍អ្វីខ្លះដែលអាច កៀរគរមកប្រើប្រាស់បានសម្រាប់បម្រើការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងសាលារៀន ដោយត្រូវសិក្សាផ្តោតលើៈ

ក- ធនធានសម្ភារៈ និងឧបករណ៍ខាងក្នុងសាលារៀន

ខ- ធនធានសម្ភារៈ និងឧបករណ៍ខាងក្រៅសាលារៀន

គ- ការកំណត់ពីធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍

ឃ- ការវិភាគស្ថាប័នដៃគូពាក់ព័ន្ធ

**គំរូតារាង ក ធនធានសម្ភារៈ និងឧបករណ៍ខាងក្នុងសាលារៀន**

| សម្ភារៈ/ធនធានសំខាន់ៗ | លំអិតអំពីសម្ភារៈ/ធនធាន | ឈ្មោះ និងតួនាទីមនុស្សសំខាន់ៗសំរាប់ទាក់ទង | លេខទូរស័ព្ទ |
|---|---|---|---|
| ស៊ីទែនទឹក | | | |
| បង្គន់អនាម័យ | | | |
| ពេងអាហារ | | | |
| សួនដើមកោងកាង និងព្រៃកោងកាង | | | |
| ព្យ៉ាណូ | | | |

**គំរូតារាង ខ ធនធានសម្ភារៈ និងឧបករណ៍ខាងក្រៅសាលារៀន**

| សំភារៈ/ធនធានសំខាន់ៗ | លំអិតអំពីសំភារៈ/ធនធាន | ចំងាយពីទីតាំងសាលារៀន | ឈ្មោះ និងតួនាទីមនុស្សសំខាន់ៗសំរាប់ទាក់ទង | លេខទូរស័ព្ទ |
|---|---|---|---|---|
| ទីស្នាក់ការសហគមន៍ | | | | |
| ទូកឬ អូបំរ | | | | |
| សាលាឃុំ | | | | |
| សាលាស្រុក | | | | |

| | | | | |
|---|---|---|---|---|
| មណ្ឌលសុខភាព | | | | |
| ប៉ុស្តិ៍រដ្ឋបាល | | | | |
| កំព្យូទ័រ កាមេរ៉ា ម៉ាស៊ីនព្រីន ម៉ាស៊ីនថតចំលង និងម៉ាស៊ីនបញ្ចាំងស្លាយ | | | | |
| ធុងបាស និងមេក្រូ | | | | |
| ហិបសង្គ្រោះបឋម | | | | |
| ហិបសង្គមសង្គ្រោះ | | | | |
| ក្រុមសន្សំប្រាក់ | | | | |
| ក្ដារខៀនព័ត៌មានសហគមន៍ | | | | |
| ទូកដឹកស៊ីទែនទឹក | | | | |
| ម៉ាស៊ីនភ្លើង | | | | |

## គំរូតារាង គ ការកំណត់ពីធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍

| ស្ថាប័នពាក់ព័ន្ធ | ឈ្មោះ | ភេទ | តួនាទី | សមត្ថភាពជំនាញ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| អាជ្ញាធរមូលដ្ឋាន | | | | | |
| គណៈកម្មការទ្រទ្រង់សាលា | | | | | |
| មណ្ឌលសុខភាព | | | | | |
| ក្រុមសង្គ្រោះបឋម | | | | | |
| កម្លាំងយុវជន ឬ អ្នកស្ម័គ្រចិត្ត កាកបាទក្រហម | | | | | |
| ក្រុមប្រឹក្សាកុមារ | | | | | |

## គំរូតារាង ឃ ការវិភាគស្ថាប័នដៃគូពាក់ព័ន្ធ

| ឈ្មោះស្ថាប័នពាក់ព័ន្ធ | បទអន្តរាគមន៍ ឬសកម្មភាព ឬវិស័យការងារ | កម្រិតនៃការចូលរួម/ពាក់ព័ន្ធ (១ តិច,២ មធ្យម, ៣ ច្រើន) | ឈ្មោះ តួនាទី និងលេខទូរស័ព្ទទាក់ទង |
|---|---|---|---|
| អាជ្ញាធរភូមិ | | | |
| សប្បុរសជន | | | |
| មន្ទីរបរិស្ថាន | | | |
| មន្ត្រីបរិស្ថានុរក្ស | | | |
| អង្គការ Save the Children | | | |
| មន្ទីរអប់រំ/ការិយាល័យស្រុក | | | |
| សាលាស្រុក/ឃុំ | | | |

| | | | |
|---|---|---|---|
| ប្រករបៀងអភិរក្សជីវៈចម្រុះមហាអនុតំបន់មេគង្គ | | | |
| មន្ទីរជលផល | | | |

*(មានភ្ជាប់ការបំពេញគំរូជាឧទាហរណ៍តារាងក្នុងឧបសម្ព័ន្ធ)*

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

បន្ទាប់ពីបានសិក្សាមេរៀននេះចប់រួចរាល់ យើងបានយល់ដឹងពីកម្រិតសមត្ថភាព និងចំនុចខ្វះខាតរបស់អ្នកដើម្បីរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន ធម្មជាតិ និងគ្រោះថ្នាក់ សម្រាប់ការពារកុមារនៅក្នុងសាលារៀន ដើម្បីឱ្យកុមារនិងសាលារៀនជៀសផុតពីគ្រោះមហន្តរាយកម្រិតសាលារៀន។ យើងអាចធ្វើឱ្យសាលារៀនមានសុវត្ថិភាព គុណភាព និងកាន់តែមានប្រសិទ្ធភាពតាមរយៈការសាងសង់ និងរៀបចំចំណុចសំខាន់ៗក្នុងការកែលម្អសាលារៀន។

ចំនុចដែលត្រូវចងចាំក្នុងមេរៀននេះគឺៈ

- អត្ថន័យពាក្យគន្លឹះក្នុងមេរៀន
- កំណត់ធនធានសម្ភារៈនិងឧបករណ៍ខាងក្នុងសាលារៀន
- កណត់ធនធានសម្ភារៈ និងឧបករណ៍ខាងក្រៅសាលារៀន
- ការកំណត់ពីធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍
- ការវិភាគស្ថាប័នដៃគូពាក់ព័ន្ធ។

**២- ៥ ឯកសារសិក្សាបន្ថែម**

- ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នកម្រិតសាលារៀន។

**២-៦ ការអនុវត្ត**

បន្ទាប់ពីសិក្សាខ្លឹមសារមេរៀននេះរួច គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀនដឹកនាំប្រជុំជាមួយ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ ដើម្បីកំណត់ធនធានសម្ភារៈនិងឧបករណ៍ខាងក្នុងសាលារៀន កំណត់ធនធានសម្ភារៈ និងឧបករណ៍ខាងក្រៅសាលារៀន កំណត់ពីធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍ និងការវិភាគស្ថាប័នដៃគូពាក់ព័ន្ធ ដើម្បីវិភាគសមត្ថភាព និងចំនុចខ្វះខាត ក្នុងការរៀបចំសាលារៀនរបស់ខ្លួនសាលារៀនរបស់ខ្លួនឱ្យមានធនធានប្រើប្រាស់គ្រប់គ្រាន់ តាមរយៈការប្រជុំកៀងគរធនធានបន្ថែម ក្នុងការចូលរួមសកម្មភាពកាត់បន្ថយបម្រែបម្រួលអាកាសធាតុ និងសកម្មភាពឆ្លើយតបគ្រោះអាសន្នក្នុងសាលារៀន។

ក្រោយពីការកំណត់ធនធានមនុស្ស និងធនធានសម្ភារៈ គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវរៀបចំតារាងទាំង៤ បិទតាមសាលារៀន និងសហគមន៍ដើម្បីផ្សព្វផ្សាយ នឹងទាក់ទាញការចូលរួមអ្នកមានធនធាន និងលទ្ធភាពដែលមានក្នុងការចូលរួម ដើម្បីឆ្លើយតបគ្រោះអាសន្ន កម្រិតសាលារៀន។

# ជំពូកទី៤ ផែនការកាត់បន្ថយហានិភ័យ

**សេចក្តីណែនាំ**

ជំពូកនេះ យើងនឹងសិក្សាប្រធានបទអំពីផែនការកាត់បន្ថយហានិភ័យ។ នៅក្នុងជំពូកនេះ មានមេរៀនចំនួន២ ដែល បង្ហាញពី(១)ការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២)សុវត្ថិភាពអគារសិក្សា និងការរៀបចំអគារសិក្សាធន់នឹងការប្រែប្រួលអាកាសធាតុ។

# មេរៀនទី១៖ ការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់សាលារៀន

## ១- វត្ថុបំណង

- ប្រាប់បានពីរបៀបរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ សម្រាប់សាលារៀនច្បាស់លាស់
- រៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀន ដើម្បីការកាត់បន្ថយ ឬដោះស្រាយនូវរាល់ផលប៉ះពាល់នានាដែលកើតមានពីគ្រោះមហន្តរាយនៅក្នុងសាលារៀន
- លើកកម្ពស់សុវត្ថិភាព សុខុមាលភាពព្រមទាំងការពារទ្រព្យសម្បត្តិរបស់សាលារៀន និងសម្រួលដល់ការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។

## ២- ខ្លឹមសារណែនាំ/មេរៀន

### ២-១ សេចក្តីណែនាំ

ក្នុងមេរៀននេះ អ្នកសិក្សានឹងសិក្សាអំពី ផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀន មានសារៈសំខាន់បំផុតសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយតាមសាលានីមួយៗ។ ការរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀនដែលត្រូវបានបង្កើតឡើង ត្រូវបានដាក់ក្នុងផែនការអភិវឌ្ឍសាលារៀន ស្តង់ដាសាលាគំរូ មេរៀននេះអ្នកនឹងសិក្សាផ្តោតសំខាន់លើ៖

- ទម្រង់ផែនការកាត់បន្ថយហានិភ័យគ្រោះអាសន្ន កម្រិតសាលារៀន
    1. រំឭកប្រវត្តិគ្រោះមហន្តរាយ និងប្រតិទិនតាមរដូវកាល
    2. គូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងធនធាន
    3. ធ្វើចំណាត់ថ្នាក់អាទិភាពនៃមុខសញ្ញាគ្រោះថ្នាក់
    4. វិភាគមូលហេតុ ផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ
    5. ការវិភាគសកម្មភាពកាត់បន្ថយហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់
    6. ការវិភាគសកម្មភាពកាត់បន្ថយហានិភ័យនៃប្រភេទហានិភ័យទាំង៥របស់សាលា
- ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ តាមគោលការណ៍សាលាកុមារមេត្រី (ទម្រង់ចាស់)
- ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ តាមស្តង់ដាសាលាគំរូ (ទម្រង់ថ្មី)។

### ២- ២ ពាក្យគន្លឹះ

- *ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ* សំដៅដល់ទស្សនាទាន និងការអនុវត្តការកាត់ បន្ថយហានិភ័យនៃគ្រោះមហន្តរាយ តាមរយៈកិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធដើម្បីវិភាគ និងគ្រប់គ្រង កត្តាដែលបណ្តាលឱ្យមានគ្រោះមហន្តរាយ រួមទាំងតាមការកាត់បន្ថយកម្រិតគ្រោះថ្នាក់ នៃមុខសញ្ញា

គ្រោះថ្នាក់ធ្វើឱ្យតិចនូវភាពងាយរងគ្រោះរបស់មនុស្ស និងទ្រព្យសម្បត្តិរបៀបគ្រប់គ្រងដីធ្លី បរិស្ថាន និងពង្រឹងការត្រៀមរៀបចំសម្រាប់ព្រឹត្តិការណ៍អាក្រក់នានា។

- *សកម្មភាព* សំដៅភាពប្រកបដោយសកម្ម ដំណើរដែលមានកិច្ចការប្រព្រឹត្តទៅជានិច្ច ការកម្រើករវើកឥតឈប់ឈរ និងការបមបេញមុខងារការងារផ្សេងៗ។

**២- ៣ ខ្លឹមសារមេរៀន**

ក្នុងមេរៀននេះ អ្នកសិក្សានឹងសិក្សាអំពី ផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀន មានសារៈសំខាន់បំផុតសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយតាមសាលានីមួយៗ។ ការរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀនដែលត្រូវបានបង្កើតឡើង ដើម្បីអនុវត្តមុនពេលមានគ្រោះមហន្តរាយ កើតឡើងសំដៅការពារ កាត់បន្ថយ និងត្រៀមលក្ខណៈឆ្លើយតបនឹងគ្រោះមហន្តរាយ។ សកម្មភាពភាពទាំងអស់នេះ នឹងត្រូវបានលើកក្រោយពេលពេលអ្នកបានសិក្សាអំពីការវិភាគហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យទាំង៥ក្នុងសាលារៀន។ ផែនការកាត់បន្ថយនេះ ធ្វើឡើងយ៉ាងលម្អិតដើម្បីភ្ជាប់ជាឧបសម្ព័ន្ធឱ្យផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន។ ហើយសកម្មភាពដែលបានលើកក្នុងផែនការនេះនឹងត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍសាលារៀន ស្តង់ដាសាលាគំរូ ។

ផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀនត្រូវរៀបចំឡើងដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់នៃគ្រោះមហន្តរាយ និងធានាថាផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយដែលបានបង្កើតឡើងនេះ ត្រូវមានប្រសិទ្ធភាព។

ដូច្នេះ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយលើសិស្ស បុគ្គលិកសិក្សា និងសាលារៀនឱ្យនៅកម្រិតទាប សាលារៀននីមួយៗ គប្បីមានផែនការនេះសម្រាប់អនុវត្ត។

តើយើងត្រូវធ្វើផែនការនេះដូចម្តេច?

ដើម្បីធ្វើផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយបាន យើងត្រូវយកព័ត៌មានទាំងអស់ដែលបានសិក្សាក្នុងមេរៀនមុនដូចជា៖

1. រំឭកប្រវត្តិគ្រោះមហន្តរាយ និងប្រតិទិនតាមរដូវកាល
2. គូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងធនធាន
3. ធ្វើចំណាត់ថ្នាក់អាទិភាពនៃមុខសញ្ញាគ្រោះថ្នាក់
4. វិភាគមូលហេតុ ផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ
5. ការវិភាគសកម្មភាពកាត់បន្ថយហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់
6. ការវិភាគសកម្មភាពកាត់បន្ថយហានិភ័យនៃប្រភេទហានិភ័យទាំង៥របស់សាលា

បន្ទាប់មកស្រង់ព័ត៌មានពីតារាងការវិភាគ មូលហេតុ ផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ ជាពិសេសលើចំណុច សកម្មភាព និងវិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្ត

រាយដាក់ក្នុងកូឡោន ឬជួរបញ្ឈរទីមួយនៃតារាងផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ រួចបន្តសួរសំណួរដូចខាងក្រោម ដើម្បីយកព័ត៌មានមកបំពេញក្នុងតារាង ផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនេះ តែមុនបំពេញចូលក្នុងតារាងយើងត្រូវឆ្លើយសំណួរ ៤ ខាងក្រោម៖

1. តើយើងចង់អនុវត្តសកម្មភាពនេះនៅពេលណា និងបញ្ចប់នៅពេលណា?
2. តើអ្នកណាជាអ្នកទទួលខុសត្រូវអនុវត្ត?
3. តើយើងមានធនធានអ្វីខ្លះហើយ និងត្រូវការធនធានអ្វីបន្ថែមទៀតដើម្បីអនុវត្តសកម្មភាពនេះ?
4. តើអ្នកណាអាចជួយអ្នកក្នុងអនុវត្តសកម្មភាពនេះ?

ខាងក្រោមនេះ ជាតារាងគំរូផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ៖

| សកម្មភាព/វិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ(យកពីតារាងការវិភាគមូលហេតុ និងផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ) | ពេលណា? | អ្នកទទួលខុសត្រូវ | ធនធានមានស្រាប់(យកពីផែនទីកំណត់ធនធាន ឬសមត្ថភាព) | ធនធានត្រូវការ(សម្ភារះឬបច្ចេកទេស) | ភ្នាក់ងារគាំទ្រ | |
|---|---|---|---|---|---|---|
| | | | | | ថវិកា | បច្ចេកទេស |
| - ………………………………. | - | - | - | - | - | - |
| - ………………………………. | - | - | - | - | - | - |
| - ………………………………. | - | - | - | - | - | - |
| - ………………………………. | - | - | - | - | - | - |
| - ………………………………. | - | - | - | - | - | - |

*(មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ក)*

ដើម្បីធានាថាសកម្មភាពទាំងអស់ដែលបានលើកមានប្រសិទ្ធភាព និងមានការអនុវត្តសកម្មភាពកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយនៅក្នុងសាលារៀន យើងត្រូវដាក់បញ្ចូលសកម្មភាពដែលបានលើកក្នុងផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយដែលបានរៀបចំខាងលើនេះ ដាក់ទៅក្នុងទម្រង់ដែលធ្លាប់អនុវត្តក្នុងការធ្វើទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៤ ដូចមានបង្ហាញគំរូប្លង់ពីរ បានភ្ជាប់ជូនដើម្បីធ្វើស្វ័យសិក្សា។

- ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ តាមគោលការណ៍សាលាកុមារមេត្រី (ទម្រង់ចាស់)
- ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ តាមស្តង់ដាសាលាគំរូ (ទម្រង់ថ្មី)។

*(មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ខ និងគ)*

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀន មានសារៈសំខាន់ណាស់សម្រាប់សាលារៀននីមួយៗ ដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់នៃគ្រោះមហន្តរាយនានា ដែលអាចកើត

មានឡើងនៅតាមសាលារៀន។ ជាពិសេស ផ្តោតលើការដឹកនាំ សម្របសម្រួលរបស់គណៈគ្រប់គ្រងគ្រោះមហន្តរាយប្រចាំសាលារៀន ដែលចលនាធនធានក្នុងការចូលរួម រៀបចំ និងការអនុវត្តផែនការគ្រប់ភាគីពាក់ព័ន្ធ ដោយមានការទទួលខុសត្រូវក្នុងសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅតាមសាលារៀនដែលអាចកើតមានឡើង។ លើសពីនេះទៀត ផែនការនេះត្រូវផ្សារភ្ជាប់ជាមួយផែនការអភិវឌ្ឍន៍សាលាផងដែរ ដោយអ្នកសិក្សាត្រូវផ្តោត និងចងចាំយ៉ាងលម្អិតនូវចំនុចសំខាន់ៗដូចខាងក្រោម៖

- ទម្រង់ផែនការកាត់បន្ថយហានិភ័យគ្រោះអាសន្ន កម្រិតសាលារៀន
  1. រំឮកប្រវត្តិគ្រោះមហន្តរាយ និងប្រតិទិនតាមរដូវកាល
  2. គូរផែនទីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងធនធាន
  3. ធ្វើចំណាត់ថ្នាក់អាទិភាពនៃមុខសញ្ញាគ្រោះថ្នាក់
  4. វិភាគមូលហេតុ ផលប៉ះពាល់ និងការកំណត់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ
  5. ការវិភាគសកម្មភាពកាត់បន្ថយហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់
  6. ការវិភាគសកម្មភាពកាត់បន្ថយហានិភ័យនៃប្រភេទហានិភ័យទាំង៥របស់សាលា
- ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ តាមគោលការណ៍សាលាកុមារមេត្រី (ទម្រង់ចាស់)
  1. កុមារទាំងអស់បានចូលរៀន
  2. ការសិក្សាប្រកបដោយប្រសិទ្ធភាព
  3. សុខភាព សុវត្ថិភាព និងការការពារកុមារ
  4. ការឆ្លើយតបទៅនឹងយេនឌ័រ
  5. ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ក្នុងដំណើរការសាលារៀនតាមមូលដ្ឋាន
  6. ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ
- ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំ តាមស្តង់ដាសាលាគំរូ (ទម្រង់ថ្មី) តាមស្តង់ដា និងសូចនាករដូចខាងក្រោម៖

  ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស

  សូចនាករទី១ ការប្រមូលកុមារចូលរៀន

  សូចនាករទី២ កុមាររៀនបានគង់វង្សក្នុងសាលារៀន

  សូចនាករទី៤ ស្ថានភាពអាហារូបត្ថម្ភ

  ស្តង់ដាទី២៖ ការបង្រៀននិងរៀន

  សូចនាករទី៧ ការអនុវត្តកម្មវិធីសិក្សា និងផែនការបង្រៀន

  សូចនាករទី៨ សម្ភារបង្រៀន និងរៀន

  សូចនាករទី១៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្អាត

សូចនាករទី១៤ ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោង

សូចនាករទី១៥ ការអនុវត្តការអប់រំសីលធម៌ និងចរិយាធម៌

ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍

សូចនាករទី១៦ ការបង្កើត និងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងថ្នាក់រៀន

សូចនាករទី១៧ ការចូលរួមរបស់សហគមន៍

សូចនាករទី១៨ ការគាំទ្ររបស់សហគមន៍

ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

សូចនាករទី២០ ការរៀបចំផែនការអភិវឌ្ឍសាលារៀន

ស្តង់ដាទី៥៖ គណនេយ្យភាព

សូចនាករទី២៥ វេទិកាសាធារណៈ

សូចនាករទី២៦ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

សូចនាករទី២៧ ការទទួលបានការគាំទ្រពីថ្នាក់ជាតិ។

**២- ៥ ឯកសារសិក្សាបន្ថែម**

- រាជរដ្ឋាភិបាលកម្ពុជា (២០១៥) ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងអប់រំ យុវជន និងកីឡា (2023) កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារៈ ក្របខណ្ឌសាលារៀនសុវត្ថិភាព
- សេចក្តីណែនាំលេខ ៦១ អយក.សណន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ។

**២- ៦ ការអនុវត្ត**

សាលារៀននីមួយៗ ក្រោយពីរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយរួចមក គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយតាមសាលារៀននីមួយៗ ប្រជុំផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សិស្សានុសិស្ស ឪពុកម្តាយ ឬអាណាព្យាបាលកុមារ អាជ្ញាធរមូលដ្ឋាន គ្រូបង្រៀន នាយក និងអ្នកពាក់ព័ន្ធ ផ្សេងៗទៀតនៅក្នុងសហគមន៍ ដើម្បីចូលរួមនិងកៀរគរធនធាន សម្ភារៈ ថវិកា បច្ចេកទេស និងបំពេញការងារតាមតួនាទី និងការទទួលខុសត្រូវក្នុងផែនការដែលបានកំណត់ប្រកបដោយប្រសិទ្ធភាព។

**សំណួរ**

១- តើត្រូវរៀបចំផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយយ៉ាងដូម្តេច? អ្នកណាខ្លះចូលរួម?

២- តើផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនេះបង្កើតឡើងដើម្បីអ្វី?

៣- តើផែនការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនេះ អនុវត្តនៅពេលណា? អនុវត្តដូចម្តេច?

# មេរៀនទី២៖ សុវត្ថិភាពអគារសិក្សា និងការរៀបចំអគារសិក្សាធន់នឹងការប្រែប្រួលអាកាសធាតុ

## ១- វត្ថុបំណង

- ពន្យល់បានពីលក្ខណៈនិងគោលការណ៍នៃការសាងសង់សាលារៀនថ្មី ប្រកបដោយសុវត្ថិភាព និង មានភាពធនទៅនឹងគ្រោះមហន្តរាយ ឬ ការប្រែប្រួលអាកាសធាតុ
- ប្រាប់បានពីភាពចាំបាច់ក្នុងការជួសជុល និង កែលម្អអគារសាលារៀនដែលមានស្រាប់ ដើម្បីឱ្យមាន សុវត្ថិភាព និងធន់ទៅនឹងគ្រោះមហន្តរាយ ឬ ការប្រែប្រួលអាកាសធាតុ
- អនុវត្តគោលការណ៍នៃការសាងសង់សាលារៀនថ្មី និងការជួសជុល ឬ កែលម្អអគារសាលារៀនដែល មានស្រាប់ប្រកបដោយសុវត្ថិភាព និងមានភាពធនទៅនឹងគ្រោះមហន្តរាយ ឬ ការប្រែប្រួលអាកាស ធាតុដោយកំណត់បាននូវសញ្ញាណគ្រោះថ្នាក់ វិធីកាត់បន្ថយហានិភ័យ រួមបញ្ចូលហេដ្ឋារចនាសម្ព័ន្ធ បៃតង ដើម្បីធានាបាននូវភាពរឹងមាំនៃរចនាសម្ព័ន្ធ និងនិរន្តរភាពបរិស្ថាននៃអគារសិក្សា។
- មានស្មារតី និង អាកប្បកិរិយាជំរុញការអនុវត្តការសាងសង់សាលារៀនសាលារៀនថ្មី និងការជួសជុល និងសាលារៀនដែលមានស្រាប់ ឱ្យមានសុវត្ថិភាព និងមានភាពធនទៅនឹងគ្រោះមហន្តរាយ ឬ ការប្រែ ប្រួលអាកាសធាតុ។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

នៅក្នុងមេរៀននេះខ្លឹមសារដែលត្រូវសិក្សារួមមាន (១) ការសង់សាលារៀនថ្មីគួរតែមានភាពធន់ទៅ នឹងគ្រោះមហន្តរាយ (២) ការជួសជុលនិង កែលម្អឡើងវិញអគារសាលារៀនដែលមានស្រាប់ និង (៣) ការ រៀបចំសាលារៀនទាំងអស់ជា សាលារៀនសុវត្ថិភាព ដែលកាត់បន្ថយហានិភ័យឱ្យនៅកម្រិតទាបបំផុត។

### ២- ២ ពាក្យគន្លឹះ

- *ការប្រែប្រួលអាកាសធាតុ* គឺសំដៅលើការផ្លាស់ប្តូររយៈពេលវែងនៃសីតុណ្ហភាព និងលំនាំអាកាស ធាតុ។ ការផ្លាស់ប្តូរបែបនេះអាចជាធម្មជាតិ ដោយសារតែការផ្លាស់ប្តូរសកម្មភាពរបស់ព្រះអាទិត្យ ឬការផ្ទុះភ្នំភ្លើងដ៏ធំ។ ប៉ុន្តែចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៨០០ មកសកម្មភាពរបស់មនុស្សគឺជាកត្តា ជំរុញដ៏សំខាន់នៃការប្រែប្រួលអាកាសធាតុ ដែលភាគច្រើនដោយសារតែការដុតឥន្ធនៈហ្វូស៊ីលដូច ជា ធ្យូងថ្ម ប្រេង និងឧស្ម័ន (យោងតាមឯកសារអង្គការសហប្រជាជាតិ)។ ម៉្យាងវិញទៀត យោង តាមសទ្ទានុក្រមនៃក្រមបរិស្ថាននិងធនធានធម្មជាតិរបស់ក្រសួងបរិស្ថាន *ការប្រែប្រួលអាកាស ធាតុ* គឺសំដៅដល់ការប្រែប្រួលស្ថានភាពអាកាសធាតុដែលអាចកំណត់អត្តសញ្ញាណបាន (តាមរ យៈការវិភាគស្ថិតិ) តាមរយៈការប្រែប្រួលតួលេខ មធ្យមនិងតួលេខថេរនៃអាកាសធាតុ ហើយការ ប្រែប្រួលនោះបន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទស្សវត្សរ៍ ឬយូរជាងនេះ។

- ***អគារសិក្សាដែលធន់នឹងអាកាសធាតុ*** គឺជាអគារដែលត្រូវបានរចនាប្លង់ សាងសង់ និងថែទាំដើម្បីទប់ទល់ និងសម្របខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងធានាបាននូវសុវត្ថិភាព និងសុខុមាលភាពរបស់សិស្សានុសិស្ស និងបុគ្គលិកអប់រំ។
- ***អគារសិក្សាដែលមានសុវត្ថិភាព*** គឺជាអគាររឹងមាំដែលប្រកាន់ខ្ជាប់នូវស្តង់ដាសុវត្ថិភាព អាចចូលប្រើបានសម្រាប់ទាំងអស់គ្នា និងមានការអនុវត្តវិធានការសុវត្ថិភាព ដូចជាប្រព័ន្ធជូនដំណឹងអគ្គីភ័យ និងមានការរៀបចំ និងអនុវត្តផែនការត្រៀមសង្គ្រោះបន្ទាន់ ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់សិស្ស បុគ្គលិកអប់រំ។

**២- ៣- ខ្លឹមសារមេរៀន**

**២-៣-១ ការសង់សាលារៀនថ្មីគួរតែមានភាពធន់ទៅនឹងគ្រោះមហន្តរាយ**

**តើការសង់សាលារៀនថ្មីគួររៀបចំដូចម្តេចដើម្បីឱ្យមានភាពធន់ទៅនឹងគ្រោះមហន្តរាយ?**

គ្រប់សាលារៀនសាងសង់អគារសិក្សាថ្មីទាំងអស់ត្រូវតែជាអគារសិក្សាមានសុវត្ថិភាព។ ការសាងសង់ និងការថែទាំអគារសិក្សា ត្រូវផ្អែកលើប្លង់សមស្រប និងគិតគូរពីបញ្ហាសុវត្ថិភាពដោយផ្អែកលើហានិភ័យដែលបានកំណត់តាមបញ្ហាជាក់ស្តែងរបស់សាលារៀននីមួយៗ និងប្រើប្រាស់បទដ្ឋានសំណង់ ដែលផ្តល់ការណែនាំក្នុងការរៀបចំប្លង់សាងសង់មានភាពធន់នឹងគ្រោះមហន្តរាយ។ ការកែសម្រួលប្លង់សាងសង់សាលារៀនឱ្យធន់ទៅនឹងទឹកជំនន់ ត្រូវរួមបញ្ចូលទាំងការរៀបចំផ្លូវដែលអាចចេញចូលបានដោយសុវត្ថិភាពសម្រាប់ជនពិការផងដែរ។ ក្នុងករណីសាលារៀនត្រូវបានរៀបចំជាជម្រកបណ្តោះអាសន្នសម្រាប់សហគមន៍ សាលារៀនត្រូវសាងសង់ដើម្បីឆ្លើយតបតាមបទដ្ឋានទាំងនោះ។ ការសាងសង់ និងកែលម្អសាលារៀនដែលមានសុវត្ថិភាពត្រូវមានការចូលរួមពីសហគមន៍ ដើម្បីបញ្ចូលចំណេះដឹងថ្មីៗពីពួកគាត់។ រីឯពួកគាត់ក៏ទទួលបានជំនាញក្នុងការការពារពីគ្រោះមហន្តរាយ ដែលជាគំរូមួយអាចអនុវត្តក្នុងការសាងសង់ផ្ទះ មណ្ឌលសុខភាពសហគមន៍ និងអគារសាធារណៈផ្សេងៗទៀតឱ្យមានសុវត្ថិភាពផងដែរ។

**ក- ការជ្រើសរើសទីតាំងមានសុវត្ថិភាព**

ដំណើរការប្រកបដោយការចូលរួមនៅក្នុងការសាងសង់សាលារៀន ចាប់ផ្តើមដោយការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន។ កិច្ចការដំបូងរបស់គណៈកម្មការនេះ គឺធ្វើការប៉ាន់ប្រមាណ និងកំណត់ទំហំដីសមស្របដើម្បីសាងសង់សាលារៀន ក៏ដូចជាប៉ាន់ស្មានពីតម្រូវការអប់រំនៅក្នុងសហគមន៍ ប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ចម្បងៗ ព្រមទាំងប្រមើលមើលថាតើអគារដែលនឹងសាងសង់នោះអាចរួមចំណែកកាត់បន្ថយហានិភ័យយ៉ាងដូចម្តេច។

លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសទីតាំងសាលារៀនថ្មីរួមមាន៖

១- ទីតាំង

២- ស្ថានភាពដី និងសណ្ឋានដី

៣- ទិដ្ឋភាពសង្គម

៤- ទិដ្ឋភាពស្ថាប័ន និងផ្លូវច្បាប់

៥- ទិដ្ឋភាពបច្ចេទេស

៦- ទិដ្ឋភាពសេដ្ឋកិច្ច

៧- ទិដ្ឋភាពបរិស្ថាន

៨- ទិដ្ឋភាពសុវត្ថិភាព។

ចំពោះទិដ្ឋភាពសុវត្ថិភាពចំណុចដែលត្រូវពិចារណារួមមានៈ

- កំណត់ទីតាំងផ្លូវក្នុងការជម្លៀស និងផ្លូវផ្តល់សេវាសង្គ្រោះបន្ទាន់តាមរយៈកិច្ចសហការជាមួយមណ្ឌលសុខភាពនៅជិតសាលារៀន។
- គិតគូរពីអគារដែលស្ថិតនៅជិតៗក្នុងតំបន់ជុំវិញសាលារៀន ដែលអាចប្រើជាជម្រកនៅពេលមានការជម្លៀសក្នុងគ្រាអាសន្ន។
- កំណត់ឱ្យបានច្បាស់លាស់ថាតើទីតាំងនោះនឹងស្ថិតនៅក្នុងគម្រោងអភិវឌ្ឍន៍ ឬ អាចជាតំបន់ហាមឃាត់ការសាងសង់ដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះមហន្តរាយធម្មជាតិ។
- ក្នុងករណីតំបន់មានហានិភ័យខ្ពស់ ត្រូវពិចារណាក្នុងការផ្លាស់ប្តូរទៅទីតាំងដែលមានហានិភ័យទាប។ ការងារនេះត្រូវកំណត់ដោយអាជ្ញាធរមូលដ្ឋាន ផ្អែកលើទីតាំងដីដែលមាន និងលក្ខខណ្ឌសេដ្ឋកិច្ច។
- ក្នុងតំបន់កំពុងមានជម្លោះ និងក្រោយពីមានជម្លោះ ត្រូវជៀសវាងទីតាំងដែលមានគ្រាប់មីន ឬ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ត្រូវស្វែងរកជំនួយពីស្ថាប័នជំនាញ ក្នុងករណីអ្នកសង្ស័យថា មានគ្រាប់មីន ឬ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងតំបន់នោះ។
- ប៉ាន់ប្រមាណពីហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់បង្កដោយធម្មជាតិ (ដូចជា ទឹកជំនន់ រន្ទះបាញ់ ខ្យល់ខ្លាំង អគ្គីភ័យ។ល។) ហើយប្រសិនបើអាចគួរជៀសវាងសាងសង់សាលារៀនក្នុងតំបន់ដែលមានមុខសញ្ញាគ្រោះថ្នាក់នោះ។ ត្រូវពិចារណាផងដែរពីការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ដែលបានធ្វើពីមុនមក។
- ការខូចខាតដែលអាចកើតមានពីខ្យល់ព្យុះអាចត្រូវបានកាត់បន្ថយ ដោយការជ្រើសរើសទីតាំងដែលមាន រនាំងការពារខ្យល់ធម្មជាតិ។
- ករណីមានគ្រោះទឹកជំនន់ ការជ្រើសរើសទីតាំងខ្ពស់ អាចកាត់បន្ថយគ្រោះថ្នាក់ និងការខាតបង់ពីគ្រោះមហន្តរាយ។ ករណីមិនមានទីខ្ពស់ អាចធ្វើការកែសម្រួលទីតាំងដូចជាលើកដី (ចាក់ដីឱ្យខ្ពស់) ឬកសាងរបាំងទឹកជំនន់ ឬប្រព័ន្ធបង្ហូរទឹក។ ករណីទីតាំងនោះស្ថិតក្នុងតំបន់ងាយរងគ្រោះពីទឹកជំនន់ ត្រូវពិចារណាចំណុចដូចខាងក្រោមៈ

- ទីតាំងសាលារៀនត្រូវលើកឱ្យផុតពីកម្រិតទឹកជំនន់ (កម្រិតអតិបរមាលើសពីកម្រិតទឹកជំនន់) ដោយពិចារណាពីបញ្ហាខ្យល់ព្យុះផងដែរ។ ករណីមិនមានទីតាំងខ្ពស់ អគារសាលារៀនត្រូវធ្វើទម្រឱ្យខ្ពស់។
- ពិចារណាចាក់ដី បើចាំបាច់ដើម្បីសាងសង់អគារសាលារៀនថ្មីឱ្យខ្ពស់ផុតពីកម្រិតទឹកជំនន់ កំណត់ពីជម្រៅទឹកដក់ក្នុងដី។ នេះជាព័ត៌មានសំខាន់សម្រាប់ការរៀបចំជម្រៅគ្រឹះសំណង់ ក៏ដូចជាការកំណត់ជម្រៅ និងចម្ងាយរវាងប្រព័ន្ធឬអាង បង្គន់អនាម័យ និងធុងស្តុកទឹក។
- ប្រសិនបើអាច គួរជៀសវាងសាងសង់អគារសាលារៀនលើដីមានទឹកដក់ព្រោះមានទឹក ជ្រាបធ្វើឱ្យដីទន់ ដែលនាំឱ្យគ្រឹះមិនអាចទ្រអគារបានយូរអង្វែង។
- សាលារៀនត្រូវសង់លើទីតាំងដែលអាចការពារពីការហូរច្រោះដីដោយសារទឹកជំនន់ដូចជាមានដើមឈើ និងគម្របដី(ស្មៅ ស្បូវ គ្រៃង។ល។)
- ត្រូវប៉ាន់ប្រមាណពីប្រព័ន្ធទឹក ហើយទីតាំងសាលារៀនត្រូវស្ថិតនៅលើទីតាំងដែលអាចរៀបចំប្រព័ន្ធបង្ហូរទឹក ដើម្បីការពារកុំឱ្យរងទឹកជំនន់ក្នុងរយៈពេលយូរ។
- ដើម្បីកាត់បន្ថយហានិភ័យ ជៀសវាងសាងសង់សាលារៀនលើទីជម្រាលមិនមានសុវត្ថិភាព និងនៅជាប់ស្ទឹង ទន្លេ។ល។



**ខ- ប្លង់សំណង់មានភាពធន់ទៅនឹងគ្រោះមហន្តរាយ** (ចំពោះមុខសញ្ញាគ្រោះថ្នាក់ដែលបានដឹង)

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យគុណភាពនៃការសាងសង់សាលារៀន ហើយស្តង់ដាទាំងនេះគួរត្រូវបានយកមកប្រើប្រាស់ស្របជាមួយសេចក្តីព្រាងលម្អិតនៃគោលការណ៍ណែនាំស្តីពីការសាងសង់សាលារៀន ឬស្តង់ដាអន្តរជាតិក្នុងការសាងសង់ និងរៀបចំប្លង់សាលារៀន។ គោលការណ៍ណែនាំនេះកំណត់នូវការរចនាអគារ និងសម្ភារៈសំណង់សមស្រប ដើម្បីទប់ទល់នឹង

លក្ខខណ្ឌអាកាសធាតុនៅមូលដ្ឋាន មុខសញ្ញាគ្រោះថ្នាក់ដែលបានដឹង ឬរំពឹងទុក នៅក្នុងបរិបទសាលារៀន ហើយត្រូវបានសង្ខេបដូចខាងក្រោម៖

❖ *ប្លង់សំណង់អគារ*

- ប្លង់សំណង់អគារ សាលារៀនត្រូវមានលក្ខណៈអចិន្ត្រៃយ៍ ការរចនា និងសាងសង់ ដើម្បីឱ្យមានអាយុកាល ៥០ឆ្នាំ ឬលើសពីនេះ។
- អគារសាលារៀនត្រូវមានភាពធន់ទ្រាំនឹងគ្រោះរញ្ជួយដី ប៉ុន្តែចំពោះសាលារៀននៅទីតាំងខ្ពស់ត្រូវមានវិធានការការពារខ្យល់ព្យុះ ហើយពុំចាំបាច់សាងសង់ឱ្យធន់ទ្រាំនឹងការរញ្ជួយដីនោះទេ។
- ប្រព័ន្ធសំណង់ត្រូវមានវិធាននានា ដើម្បីការការពារកុំឱ្យស្រុត ឬប្រេះស្រាំ និងការខូចខាតនានា ដូចជាការត្រួតពិនិត្យទៅលើមុខតំណនានា។ លើសពីនេះ អគារសាលារៀនត្រូវមានសមត្ថភាពធន់ទ្រាំនឹងផលប៉ះពាល់ពីបរិស្ថានធ្ងន់ធ្ងរ ដោយគ្មានការខូចខាត ឬការសឹករេចរឹលដែលនឹងកាត់បន្ថយអាយុកាលអគារ។
- អ្នករៀបចំប្លង់អគារត្រូវយល់ពីទំហំនៃការធន់ទ្រាំរបស់អគារនឹងទម្ងន់ដែលអាចទ្រាំទ្របាន។ ត្រូវពិនិត្យមើលពីសមាសធាតុសំណង់ដែលអាចទ្រទ្រង់អគារទាំងមូល។ ត្រូវគិតគូរទម្ងន់នៅផ្នែកដំបូល និងគ្រឹះសំណង់។
- សុចរិតភាពសំណង់ អាចធ្វើឡើងដោយការរៀបចំសមាសធាតុសំណង់ ដើម្បីធានាបាននូវទម្ងន់ដោយប្រៀបធៀបនៅមូលដ្ឋាន និងក្នុងតំបន់
- គម្រោងអគារត្រូវមានលក្ខណៈសាមញ្ញ និងជាប្រព័ន្ធ។ រូបរាងសំណង់អគារដែលផ្ទុកទម្ងន់លើសលប់អាចនាំឱ្យមានការខូចខាតទ្រង់ទ្រាយធំជាងសំណង់អគារធម្មតា។ សំណង់អគាររាងអក្សរ T L U ឬ រាងឈើឆ្កាង គឺជាការរចនាសំណង់អគារមិនមានភាពប្រក្រតី។ ជាទូទៅ ការតភ្ជាប់សំណង់អគារពីស្លាបអគារផ្សេងៗ ធ្វើឡើងក្នុងគោលបំណងឱ្យស្លាបនីមួយៗបំពេញមុខងាររៀងៗខ្លួនប៉ុណ្ណោះ។ ការជ្រើសរើស ត្រូវពិចារណាពីតម្រូវការសេដ្ឋកិច្ច មុខងារ និងភាពអាចជឿជាក់បាន។ ការសាងសង់អគារក្នុងរូបរាងសាមញ្ញគឺត្រូវបានលើកទឹកចិត្ត ជាពិសេសក្នុងតំបន់ងាយរងគ្រោះពីមុខសញ្ញាគ្រោះថ្នាក់។ ក្នុងករណីមិនអាចសាងសង់ក្នុងរូបរាងសាមញ្ញបាន អ្នកគូសប្លង់ត្រូវទទួលស្គាល់ពីផលប៉ះពាល់នៃភាពមិនប្រក្រតីជាពិសេសណាមួយលើសំណង់ និងត្រូវខិតខំធានាថាការរចនាប្លង់ឆ្លើយតបទៅនឹងទម្ងន់ និងលក្ខខណ្ឌអាចប្រើប្រាស់បាន។
- អាស្រ័យទៅតាមតំបន់ដែលប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ វិធានការខាងក្រោមនេះត្រូវបានណែនាំឱ្យអនុវត្តក្នុងការរៀបចំប្លង់សាងសង់

❖ ***សំណង់អគារធន់នឹងទឹកជំនន់***

- ចាក់ដីបំពេញបន្ថែម និងបង្ហាប់ដើម្បីធ្វើឱ្យទីតាំងខ្ពស់ផុតពីកម្រិតទឹកជំនន់
- ក្នុងករណីទីតាំងមិនអាចលើកដីឱ្យខ្ពស់បាន សម្រាប់តំបន់ដែលមានទឹកជំនន់មាន កម្រិតខ្ពស់ជាង ៣០ សង់ទីម៉ែត្រពីដី ត្រូវបានណែនាំឱ្យសង់អគារមានសសរខ្ពស់ បើកម្រិតមិនខ្ពស់ជាង ៣០ សង់ទីម៉ែត្រពីដីទេ ត្រូវសង់អគារនៅលើជើងតាង ដែលមានកម្ពស់ត្រឹម ៦០ សង់ទីម៉ែត្រ (៣ ទៅ៤ កាំជណ្ដើរ)។
- ក្នុងករណីទីតាំងស្ថិតក្នុងដីភក់ និងងាយរងគ្រោះដោយទឹកជំនន់ សំណង់អគារត្រូវមានកម្ពស់យ៉ាងហោចណាស់ ៣០ សង់ទីម៉ែត្រលើសពីកម្រិតកម្ពស់ទឹកជំនន់ជាអតិបរមា
- ដាំដើមឈើដែលមានឫសវែងៗដើម្បីការពារកុំឱ្យទឹកហូរច្រោះដី
- កសាងនាំងទប់ទឹកដូចជាទំនប់ច្រាំងទន្លេ ស្នឹង និងអាងស្តុកទឹកដើម្បីការពារការហៀរហូរទឹក
- កសាងរចនាសម្ព័ន្ធដែលអាចកាត់បន្ថយទឹកជំនន់ដូចជាលូ ស្ពាន ព្រែក ប្រឡាយ រំដោះទឹកដើម្បីគ្រប់គ្រងទឹកជំនន់រដូវវស្សា
- ក្នុងការសាងសង់នាំងទប់ទឹក ជាការចាំបាច់ត្រូវរៀបចំប្រព័ន្ធរំដោះទឹក ក្នុងករណីទឹកជំនន់ហូរជន់លើនាំងទឹកទាំងនោះ
- សាលារៀនត្រូវសាងសង់ស្របតាមបណ្ដោយទិសទឹកហូរ ដើម្បីកាត់បន្ថយការខូចខាតនានាពីការ ហូរបាក់ដី ឬកាកសំណល់ដែលហូរធ្លាក់
- ក្នុងដំណាក់កាលរៀបចំសំណង់អគារត្រូវដាក់បញ្ចូលនូវលទ្ធភាពនៃការសាងសង់ច្រកបង្ហូរទឹកកុំឱ្យទឹកដក់ក្នុងអគារ ដែលនាំឱ្យមានការខូចខាតអគារ។



❖ ***សំណង់អគារអាចការពារពីអគ្គីភ័យ***

- សាងសង់អគារដាច់ពីគ្នា ជៀសវាងអគារជាប់គ្នារដឹក ដើម្បីការពារការរាលដាលនៅពេលមានអគ្គីភ័យ
- ផ្នែកដំបូលលយចេញត្រូវបំពាក់ឧបករណ៍ការពារអគ្គីភ័យ ដែលអាចការពារ រងើកភ្លើងដែលហើរចេញនៅខាងក្រោមផ្ទោងដំបូល

- ដំបូលត្រូវមានកន្លែងបិទបើក ដូចជា រន្ធខ្យល់ រន្ធបញ្ចេញផ្សែង ឬបំពង់ផ្សែង ដែលគួរសាងសង់ពីសម្ភារៈ ដែលអាចទប់ទល់នឹងភ្លើង ហើយត្រូវមានគម្របប្រវែង ១ សង់ទីម៉ែត្រ មានសំណាញ់ដើម្បីការពាររងើកភ្លើងហើរចូល។




## គ- លទ្ធកម្មសម្ភារៈមានគុណភាព ការត្រួតពិនិត្យការសាងសង់ និងសវនកម្មហិរញ្ញវត្ថុ

- គុណភាពនៃសម្ភារៈសំណង់អាចកំណត់ថា អគារសំណង់អាចរួចផុតពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់។ ការធ្វើតេស្ត និងការត្រួតពិនិត្យគឺមានភាពចាំបាច់ដើម្បីធានាថាសំណង់អគារឆ្លើយតបនឹងបទដ្ឋានសំណង់អគារ។ អគារ សាលារៀនដែលស្របតាមស្តង់ដា ជាធម្មតាធ្វើពីបេតុង និងដែក ជញ្ជាំងសង់ពីឥដ្ឋបូកបាយអ ជាទូទៅ ដំបូលសង់ពីក្បឿង និងផ្ទោងធ្វើពីបេតុង ទ្វារ និងបង្អួចធ្វើពីឈើ។
- នៅក្នុងតំបន់ដាច់ស្រយាល សំណង់សាលារៀនដែលធ្វើពីឈើអាចទទួលយកបាន ប៉ុន្តែសំណង់អគារ ទាំងនោះ ត្រូវឆ្លើយតបនឹងស្តង់ដាសុវត្ថិភាព និងគុណភាព។ ប្រើសម្ភារៈដែលអាចរកបាននៅក្នុងមូលដ្ឋាន ដើម្បីកាត់បន្ថយការចំណាយ និងសម្រួលដល់ការសាងសង់។ សំណង់សាលារៀនប្រើប្រាស់សម្ភារៈដែលមានគុណភាព ទាប បេតុងខ្វះគុណភាព ដែកមិនគ្រប់ស្តង់ដានិងឈើមិនសូវមានគុណភាពតែងតែងាយខូចខាតដោយទឹកជំនន់ ឬខ្យល់ព្យុះ។ អ្នកត្រួតពិនិត្យការដ្ឋានសំណង់ត្រូវយកចិត្តទុកដាក់ក្នុងការប្រើ សម្ភារៈសំណង់មានគុណភាពខ្ពស់ ដោយព្យាយាមធ្វើតេស្តជាទៀងទាត់ពីការលាយខ្សាច់ ថ្ម ទឹក និងស៊ីម៉ងត៍។ ដើម្បីធានាសុខភាពកុមារៈ មិនត្រូវប្រើសម្ភារៈមានជាតិពុល មិនត្រូវប្រើសម្ភារៈមានជាតិក្លរ៉ូហ្វ្លរ៉ូកាបោន (CFC) ដូចមាននៅក្នុងទូទឹកកក ឬម៉ាស៊ីនត្រជាក់ មិនត្រូវប្រើរូបធាតុដែលមិនឆេះ និងមិនត្រូវប្រើដែកមានសំណប៉ាហាំងក្នុងតំបន់ងាយរងគ្រោះពីខ្យល់ព្យុះ។

### ឃ- សេចក្តីណែនាំពីការថែទាំសាលារៀននៅពេលប្រគល់ និងទទួលយក

- សាលារៀនសុវត្ថិភាពមិនមែនស្ថិតលើការរៀបចំប្លង់សំណង់ និងការសាងសង់ប៉ុណ្ណោះទេ។ នៅពេល អគារសាលារៀនត្រូវបានដាក់ឱ្យប្រើប្រាស់ ការត្រួតពិនិត្យ ការថែទាំ និងការជួសជុលជាទៀងទាត់ដើម្បីរក្សាអគារ គ្រឿងសង្ហារិម និងឧបករណ៍អាចប្រើប្រាស់បានយូរ គឺជាការទទួលខុសត្រូវរបស់សាលារៀន និងសហគមន៍។ យន្តការតាមដាន និងថែទាំ ដោយមានតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ មានថវិកាគ្រប់គ្រាន់ និងវគ្គបណ្តុះបណ្តាល គឺជាកត្តាសំខាន់សម្រាប់ជួយសម្រួលដល់ការងារថែទាំសាលារៀន។ ឧទាហរណ៍ កត្តាមួយសំខាន់ដែលធ្វើឱ្យខូចខាតដល់អគារនោះគឺសំណើម។ ដូច្នេះការរក្សាការពារសំណង់អគារពីសំណើមគឺជាអាទិភាពសំខាន់។ កម្មវិធីថែទាំសាលារៀនត្រូវធានាថា សំណង់អគារសាលារៀនអាច ដំណើរការតាមការគ្រោងទុកគ្រប់ពេលវេលា ដំណើរការតាមអាយុកាលនៃសំណង់អគារទប់ទល់នឹងផលប៉ះពាល់ពីគ្រោះធម្មជាតិធ្ងន់ធ្ងរដូចជា ខ្យល់ព្យុះ ទឹកជំនន់ និងរញ្ជួយដី ដរាបណា ការរៀបចំប្លង់ ការសាងសង់ និងសម្ភារៈសំណង់អគារស្របតាមលក្ខខណ្ឌសំណង់។
- សាលារៀនទាំងអស់គួរបង្កើតគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលាដែលមានសមាជិកពីសហគមន៍ និងអ្នកពាក់ព័ន្ធ និងទទួលបានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មការនេះទទួលខុសត្រូវថែទាំសាលារៀន រៀបចំកម្មវិធី ថែទាំសមស្រប រួមទាំងការកំណត់កាលវិភាគ រៀបចំថវិកា និង រៀបចំបញ្ជីសារពើភណ្ឌ សម្ភារៈ គ្រឿងសង្ហារិម និងឧបករណ៍ដែលត្រូវថែទាំ និងកែលម្អនូវចំណុចខ្វះខាតមួយចំនួន។

### ង- ការសាងសង់សាលារៀនគឺជាឱកាសនៃការសិក្សារៀនសូត្រសម្រាប់កុមារ និងសហគមន៍

សាលារៀនក៏បានផ្តល់ឱកាសសិក្សារៀនសូត្រផងដែរដល់សហគមន៍។ កុមារអាចសិក្សារៀនសូត្រពីគំនិតថ្មីៗបានយ៉ាងឆាប់រហ័ស បញ្ជ្រាបចំណេះដឹងទៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងផ្សព្វផ្សាយសារទាំងអស់នោះទៅសមាជិកគ្រួសារ និងសហគមន៍ទាំងមូល។ ការបង្រៀនពីការបង្ការគ្រោះមហន្តរាយនៅក្នុងសាលារៀនគឺជាចំណុចចាប់ផ្តើមសំខាន់មួយក្នុងការកសាង នូវភាពធន់ទៅនឹងគ្រោះមហន្តរាយរបស់សហគមន៍ទាំងមូល។ បច្ចេកទេសសាងសង់អគារថ្មីៗអាចត្រូវបានបង្រៀននៅក្នុងសាលារៀន ជាផ្នែកមួយនៃកម្មវិធីសាងសង់ និងជួសជុលសាលារៀនឱ្យមានសុវត្ថិភាពដែលអាចធ្វើជាគំរូដល់ការសាងសង់ និងជួសជុលផ្ទះ មណ្ឌលសុខភាពសហគមន៍ អគារសាធារណៈ និងឯកជនផ្សេងៗទៀត។

### ២-៣-២ ការជួសជុល និង កែលម្អអគារសាលារៀនដែលមានស្រាប់ឡើងវិញ

**តើការជួសជុល និង កែលម្អអគារសាលារៀនដែលមានស្រាប់គួររៀបចំដូចម្តេចដើម្បីឱ្យមានសុវត្ថិភាព និងធន់ទៅនឹងគ្រោះមហន្តរាយ?**

ស្តង់ដាក្នុងការសាងសង់អគារសាលារៀនខាងលើអាចប្រើប្រាស់ជាមគ្គុទ្ទេសក៍ក្នុងការកែលម្អ ឬជួសជុលសំណង់អគារសាលារៀនដែលមានស្រាប់។ ការជួសជុលសំណង់អគារសាលារៀនគឺជាការធ្វើឱ្យប្រសើរឡើងនូវសំណង់អគារសាលារៀនដែលមានស្រាប់ មុនឬក្រោយពេលរងផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ដើម្បីធ្វើឱ្យធន់ទ្រាំនឹងការខូចខាត។ ជាលក្ខខណ្ឌតម្រូវ ត្រូវធ្វើការប៉ាន់ប្រមាណពីភាពងាយរងគ្រោះរបស់អគារពីមុខសញ្ញាគ្រោះថ្នាក់ ដើម្បីកំណត់ពីភាពចាំបាច់ក្នុងការកែលម្អនិងជួសជុលឡើងវិញ។ មុនពេលជួសជុលអគារឡើងវិញ ត្រូវអនុវត្តនូវជំហាន ៣សំខាន់ដូចខាងក្រោម៖

១- កំណត់ភាពងាយរងគ្រោះរបស់អគារពីមុខសញ្ញាគ្រោះថ្នាក់ក្នុងមូលដ្ឋាន

២- សម្រេចថា តើត្រូវកែលម្អឬសាងសង់អគារជាថ្មីឡើងវិញ

៣- លើកឡើងនូវយុទ្ធសាស្ត្រសមស្រប សម្រាប់ការជួសជុលឡើងវិញ ដើម្បីបង្កើនភាពធន់ទៅនឹងគ្រោះមហន្តរាយ។

សេចក្តីណែនាំលម្អិតមាននៅក្នុងសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពី «ការសាងសង់សាលារៀន» របស់ក្រសួងអប់រំ យុវជន និងកីឡា ខែមីនា ឆ្នាំ២០១០។ ខាងក្រោមគឺជាសេចក្តីសង្ខេបបញ្ជីប៉ាន់ប្រមាណពីសាលារៀនមានសុវត្ថិភាព៖

- គ្រឿងដំបូលត្រូវប្រក់ឱ្យជាប់បានត្រឹមត្រូវ
- ដំបូលមិនត្រូវជ្រាបទឹក
- ចំពោះផ្នែកនៃសំណង់ដែលធ្វើពីឈើ រួមទាំង គ្រោងឆ្អឹងដំបូល ត្រូវមានវិធានការថែទាំឱ្យបានល្អ កុំឱ្យពុកផុយឬសត្វល្អិតបំផ្លាញ
- ឈើសំណង់ត្រូវប្រើឈើស្ងួត មិនប្រេះ និងមិនបោរ
- ពិដានត្រូវភ្ជាប់ឱ្យបានមាំជាមួយនឹងធ្នឹមដំបូល
- សសរកន្លោងត្រូវមាំ មិនមានបែក
- ត្រូវរៀបរបងសាលារៀនតាមព្រំដីកំណត់
- រៀបចំកន្លែងមានសុវត្ថិភាពពេលមានខ្យល់
- ទឹកមានពណ៌ ប្រផេះ»និង«ខ្មៅ ត្រូវបង្ហូរចេញនិងគ្រប់គ្រងឱ្យបានត្រឹមត្រូវ
- ជញ្ជាំងត្រូវភ្ជាប់ជាមួយសសរកន្លោងឱ្យបានត្រឹមត្រូវ មិនអាចឱ្យធ្លាក់ក្នុងរណ្តៅឬអណ្តូងដែលមិនប្រើប្រាស់ត្រូវលុបឱ្យជិត

ត្រូវកំណត់ និងផ្តល់អាទិភាពដល់សាលារៀនដែលមានតម្រូវការចាំបាច់ក្នុងការជួសជុល កែលម្អនិងសាងសង់ថ្មីឡើងវិញ។ តាមរយៈដំណើរការប៉ាន់ប្រមាណពី មុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព។ ក្រោយពីមានគ្រោះមហន្តរាយធ្ងន់ធ្ងរណាមួយកើតឡើង ត្រូវបង្កើតឱ្យមានប្រព័ន្ធ ១- កំណត់ពីសាលារៀនដែលទទួលរងគ្រោះធ្ងន់ធ្ងរ និង ២- ឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។

**២-៣-៣ ការរៀបចំសាលារៀនទាំងអស់ជា សាលារៀនសុវត្ថិភាព ដែលកាត់បន្ថយហានិភ័យឱ្យនៅកម្រិតទាបបំផុត**

សាលារៀនទាំងអស់ត្រូវតែជា «**សាលារៀនសុវត្ថិភាព**» ដែលកាត់បន្ថយហានិភ័យឱ្យនៅកម្រិតអប្បបរមាពី គ្រប់ប្រភេទទាំងអស់ដោយមានផែនការសុវត្ថិភាពសាលារៀន។ ផែនការសុវត្ថិភាពសាលារៀនរួមមានទាំងការរចនាការបំពាក់គ្រឿងសង្ហារិមក្នុងបន្ទប់រៀន សម្រាប់សម្រួលដល់ការជម្លៀសនិងការពារអាយុជីវិត។ អគារទាំងអស់និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត ដូចជា ទីធ្លាលេងកំសាន្ត ត្រូវតែមានសុវត្ថិភាពពីគ្រោះមហន្តរាយធម្មជាតិ និងពី គ្រោះថ្នាក់នានា។ ក្នុងនោះរួមបញ្ចូលទាំងការរៀបចំរបងការពារកុមារពីប្រភពទឹកស្រះវិធានការការពារសាលារៀនពីទឹកជំនន់មកលើអគារនិងទីធ្លាសាលារៀន។ ត្រពាំង។ល។ ប្រព័ន្ធបង្ហូរទឹកពិសេស ត្រូវគិតគូរពីហានិភ័យដែលបណ្ដាលមកពីចរន្តអគ្គិសនី មុខសញ្ញាគ្រោះថ្នាក់អគ្គិភ័យ និងរបងសាលារៀនរួមទាំងដើមឈើ ជាងដូង ជាងត្នោត មែកឈើងាប់ជាដើម ដែលអាចបង្កការខូចខាតឬគ្រោះថ្នាក់នៅពេលមានខ្យល់ខ្លាំង។

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

- អគារសិក្សាមានសុវត្ថិភាព និងធន់នឹងការប្រែប្រួលអាកាសធាតុ ត្រូវសាងសង់ឡើងដោយការជ្រើសរើសទីតាំងមានសុវត្ថិភាព ប្លង់សំណង់ និងការសាងសង់មានលក្ខណៈ និងគោរពតាមបទដ្ឋានបច្ចេកទេសសំណង់តាមស្តង់ដាត្រឹមត្រូវ ដោយមានភាពធន់ទៅនឹងគ្រោះមហន្តរាយដូចជាការរញ្ជួយដី ខ្យល់ព្យុះ ទឹកជំនន់ និងមានខ្យល់ចេញចូល ពន្លឺគ្រប់គ្រាន់ ព្រមទាំងបញ្ចូលគោលការណ៍បរិយាបន្ន។
- លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសទីតាំងសាលារៀនថ្មីដែលមានសុវត្ថិភាព រួមមានការពិនិត្យអំពីទីតាំង ស្ថានភាពដី និងសណ្ឋានដី ទិដ្ឋភាពសង្គម ទិដ្ឋភាពស្ថាប័ន និងផ្លូវច្បាប់ ទិដ្ឋភាពបច្ចេទេស ទិដ្ឋភាពសេដ្ឋកិច្ច ទិដ្ឋភាពបរិស្ថាន និងទិដ្ឋភាពសុវត្ថិភាព។
- ការរចនាប្លង់សំណង់អគារសិក្សាប្រកបដោយសុវត្ថិភាព និងមានភាពធន់ទៅនឹងគ្រោះមហន្តរាយគឺផ្តល់អាទិភាពដល់សុវត្ថិភាព និងសុខុមាលភាពរបស់សិស្ស និងបុគ្គលិកសិក្សា។ ក្នុងនោះរចនាសម្ព័ន្ធអគារ ធានាបានការប្រើប្រាស់យូរអង្វែង(មានអាយុកាល ៥០ឆ្នាំ ឬលើសពីនេះ) មានភាពធន់ទៅនឹងគ្រោះមហន្តរាយដូចជាការរញ្ជួយដី ខ្យល់ព្យុះ ទឹកជំនន់ និងមានខ្យល់ចេញចូល ពន្លឺគ្រប់គ្រាន់ ព្រមទាំងបញ្ចូលគោលការណ៍បរិយាបន្ន។
- ការធ្វើលទ្ធកម្មសម្ភារៈដែលមានគុណភាព ការត្រួតពិនិត្យការសាងសង់ជាប្រចាំ និងសវនកម្មហិរញ្ញនៃសំណង់ គឺចាំបាច់ដើម្បីធានាថាសំណង់អគារមានគុណភាពស្របនឹងបទដ្ឋានសំណង់។

- ដើម្បីជានាសុខភាពកុមារ មិនត្រូវប្រើសម្ភារៈមានជាតិពុល មិនត្រូវប្រើសម្ភារៈមានជាតិក្លរ៉ូហ្លួរកាបោន (CFC) ដូចមាននៅក្នុងទូទឹកកក ឬម៉ាស៊ីនត្រជាក់ មិនត្រូវប្រើរូបធាតុដែលមិនឆេះ មិនត្រូវប្រើដែកមានសំណប៉ាហាំងក្នុងតំបន់ងាយរងគ្រោះពីខ្យល់ព្យុះ។
- ការថែទាំអគារសិក្សា រួមមានការត្រួតពិនិត្យ និងជួសជុលជាប្រចាំ ដោយមានការទទួលខុសត្រូវរួមគ្នារវាងសាលា និងសហគមន៍ តាមរយៈការបង្កើតយន្តការថែទាំអគារសិក្សាច្បាស់លាស់ ដែលមានការកំណត់តួនាទី ការស្វែងរកថវិកា និងការផ្តល់ការបណ្តុះបណ្តាលត្រឹមត្រូវសម្រាប់អ្នកទទួលខុសត្រូវថែទាំអគារសិក្សា។

**២-៥ ឯកសារសិក្សាបន្ថែម**

- ក្រសួងអប់រំ យុវជន និងកីឡា (2023) កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារៈ *ក្របខណ្ឌសាលារៀនសុវត្ថិភាព ។*

**២-៦ ភាររអនុវត្ត**

បន្ទាប់ពីរៀនមេរៀននេះរួច សូមអ្នកឆ្លើយសំណួរ និងអនុវត្តដូចខាងក្រោមៈ

១- ចូរអ្នករៀបរាប់ចំណុចសំខាន់ៗដែលអ្នករៀនបានពីមេរៀននេះ?

២- តើអ្នកចែករំលែកចំណេះដឹងពីមេរៀននេះដល់អ្នកពាក់ព័ន្ធក្នុងសាលារៀន(ដូចជាគណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន)ឬស្ថាប័នអប់រំដទៃទៀតតាមវិធីណា?

៣- តើអ្វីជាលក្ខណៈសំខាន់ៗនៃអគារសិក្សាមានសុវត្ថិភាព និងធន់នឹងការប្រែប្រួលអាកាសធាតុ?

៤- ហេតុអ្វីបានជាវាសំខាន់សម្រាប់សាលារៀនដើម្បីឱ្យមានហេដ្ឋារចនាសម្ព័ន្ធរួមទាំងអគារសិក្សា ធន់នឹងគ្រោះមហន្តរាយ?

៥- តើមានបទពិសោធន៍ល្អៗអ្វីខ្លះ សម្រាប់ការរចនាប្លង់ និងសាងសង់អគារសិក្សាមានសុវត្ថិភាព?

៦- តើហានិភ័យ និងគ្រោះថ្នាក់ដែលអាចប៉ះពាល់ដល់អគារសិក្សាមានអ្វីខ្លះ? តើហានិភ័យ និងគ្រោះថ្នាក់ទាំងនោះអាចកាត់បន្ថយបានដោយរបៀបណា?

៧- តើមានវិធីអ្វីខ្លះដែលសាលារៀនអាចអនុវត្ត ដើម្បីថែទាំអគារសិក្សាឱ្យប្រើប្រាស់ជាប់បានយូរអង្វែង?

៨- តើសាលារៀនធ្វើដូចម្តេចដើម្បីឱ្យចូលរួមសហគមន៍ក្នុងការរៀបចំផែនការ និងការអនុវត្តសាលារៀន មានសុវត្ថិភាព និងធន់នឹងការប្រែប្រួលអាកាសធាតុ?

៩- តើធនធានអ្វីខ្លះដែលសាលារៀនអាចរកបានដើម្បីគាំទ្រកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀនរួមទាំងអគារសិក្សា ឱ្យមានសុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុ និងបៃតងជាងមុន?

# ជំពូកទី៥ ការរៀបចំនីតិវិធីប្រតិបត្តិបទដ្ឋានស្តង់ដា (SOP) និងលំហាត់សមយុទ្ធ

**សេចក្តីណែនាំ**

ជំពូកនេះ យើងនឹងសិក្សាប្រធានបទអំពីការរៀបចំនីតិវិធីប្រតិបត្តិ បទដ្ឋាន ស្តង់ដា(SOP) និងលំហាត់សមយុទ្ធ។ នៅក្នុងជំពូកនេះ មានមេរៀនចំនួន៣ដែល បង្ហាញពី(១)ការរៀបចំផែនការបន្តការសិក្សាក្នុងគ្រាមានអាសន្ន (២)ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាSOP និងណែនាំលំហាត់សមយុទ្ធ (៣)លំហាត់សមយុទ្ធ។

# មេរៀនទី១៖ ការរៀបចំផែនការបន្តការសិក្សាក្នុងគ្រាមានអាសន្ន

## ១- វត្ថុបំណង

- ប្រាប់បានផែនការបន្ត ដើម្បីធានាសុវត្ថិភាពសិក្សាកំឡុងមានគ្រោះមហន្តរាយកើតឡើង
- រៀបចំផែនការបន្ត ដើម្បីធានាថាមិនមានការបាត់បង់ពេលវេលាសិក្សា នៅតាមសាលារៀននិង ដោះស្រាយបញ្ហាខកខាន ក្នុងការសិក្សារបស់សិស្ស
- ធានានិរន្តរភាពក្នុងការសិក្សារបស់សិស្សក្នុងកំឡុងមានគ្រោះមហន្តរាយកើតឡើង។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្ដីណែនាំ

ការរៀបចំផែនការបន្តសំដៅដល់ការរៀបចំសកម្មភាព ដើម្បីធានានិរន្តរភាពនៃការសិក្សារបស់សិស្ស កំឡុងពេលមានគ្រោះអាសន្ន។ ផែនការសកម្មភាពនេះ មានដូចជា៖

- គោលការណ៍ណែនាំសម្រាប់បង្កើតផែនការបន្តក្នុងការឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន ផែនការបម្រុងទុកសម្រាប់ ឱ្យសិស្សអាចបន្តការសិក្សាក្នុងពេលគ្រោះមហន្តរាយ
- គោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការសាលារៀនក្នុងបរិបទកូវីដ-១៩ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- ទម្រង់ផែនការបន្តក្នុងការឆ្លើយតបគ្រោះអាសន្នសាលារៀន។

### ២- ២ ពាក្យគន្លឹះ

- ***ផែនការបន្ត*** សំដៅដល់ការរៀបចំគ្រប់គ្រងដំណើរការបន្តការសិក្សារបស់សិស្សប្រកបដោយនិរន្តរភាពក្នុងកំឡុងពេលមានគ្រោះអាសន្ន រីកធំឡើងនៃព្រឹត្តិការណ៍ដែលឈានដល់គ្រោះមហន្តរាយ។
- *គ្រា* សំដៅពេលមួយ គ្រានេះ គ្រានោះ គ្រាក្រោយ គ្រាអំណត់ និងគ្រាក្រ។
- ***អាសន្ន*** សំដៅហេតុឬដំណើរ ការធុរៈដែលមានទីជិត ប្រថុចប្រថំ បន្ទាន់ ប្រញ៉ីកខ្លាំង មមាញឹក និង ទាន់ហន់។
- ***ការសិក្សា*** សំដៅការហ្វឹកហាត់ ការរៀនសូត្រ។

### ២-៣ ខ្លឹមសារមេរៀន

#### ក- គោលការណ៍ណែនាំបង្កើតផែនការបន្តក្នុងការឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន

កម្រិតឋានានុក្រមការឆ្លើយតបគ្រោះមហន្តរាយកម្រិតសាលារៀនក្នុងគ្រាមានអាសន្ន គណៈកម្មការគ្រប់គ្រងគ្រោះហន្តរាយក្នុងសាលារៀន អាចធ្វើការសម្រេចចិត្តក្នុងការឆ្លើយតបគ្រោះអាសន្ននៅក្នុងសាលារៀន ទៅតាមស្ថានភាពចាំបាច់ ដោយសហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដូចជា គណៈកម្មការគ្រប់គ្រងគ្រោះហន្តរាយថ្នាក់ឃុំ-សង្កាត់ ការិយាល័យអយក- ខណ្ឌ ស្រុក ក្រុង និងស្ថាប័នដៃគូពាក់ព័ន្ធ នៅពេល

- ទទួលបានព័ត៌មានប្រកាសអាសន្ន ស្តីពីគ្រោះមហន្តរាយ ចេញពីអាជ្ញាធរ

- មានការកើនឡើងពីកម្រិតហានិភ័យនៃគ្រោះមហន្តរាយក្នុងកម្រិតតំបន់។

**ខ- ផែនការបម្រុងទុកសម្រាប់ឱ្យសិស្សអាចបន្តការសិក្សាក្នុងពេលគ្រោះមហន្តរាយ**

ក្នុងពេលមានគ្រោះមហន្តរាយ ជាពិសេស ទឹកជំនន់ ការកើនកំដៅ គ្រោះរាំងស្ងួត និងជំងឺឆ្លង(កូវីដ១៩)សាលារៀនជាច្រើននៅតាមតំបន់មួយចំនួនស្ទើរទៀងរាល់ឆ្នាំ បានផ្អាកដំណើរការសិក្សារៀនសូត្រ។ ដូច្នេះ ដើម្បីធានានូវនិរន្តរភាព និងសុវត្ថិភាពនៃដំណើរការឆ្នាំសិក្សាបន្តបន្ទាប់ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំលេខ២៧ អយក- សណន ស្តីពី ការអប់រំក្នុងកម្មវិធីសង្គ្រោះបន្ទាន់ដោយផ្តោតលើការរៀបចំទីកន្លែងរៀន ថ្នាក់រៀនមានសុវត្ថិភាពក្នុងពេលមានគ្រោះទឹកជំនន់ ការកើនកំដៅ គ្រោះរាំងស្ងួត និងជំងឺឆ្លង។ សេចក្តីណែនាំនេះ គឺតម្រូវឱ្យគ្រប់សាលារៀនទាំងអស់ដែលរងគ្រោះ បង្កើតគណៈកម្មការ និងអនុគណៈកម្មការសម្រាប់គ្រប់គ្រង និងជួយដោះស្រាយផលប៉ះពាល់ដែលបណ្តាលពីគ្រោះមហន្តរាយ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដោយប្រើប្រាស់សមត្ថភាពក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ គណៈកម្មការទ្រទ្រង់សាលារៀន ក្រុមបណ្តាញ និងអាជ្ញាធរមូលដ្ឋានដើម្បីរៀបចំកន្លែងរៀនបណ្តោះអាសន្ន ដោយកំណត់អំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចច្បាស់លាស់។

**គ- ផែនការបន្តការសិក្សាក្នុងកំឡុងបរិបទកូវីដ-១៩**

នៅពេលសាលារៀនស្ថិតនៅក្នុងគ្រោះអាសន្ន ជាពិសេស ជំងឺឆ្លង កូវីដ-១៩ ថ្នាក់ដឹកនាំសាលារៀន និងគ្រូបង្រៀនទាំងអស់ ត្រូវអនុវត្តផែនការបន្តការសិក្សាដល់សិស្ស ដើម្បីធានាថា មិនមានការបាត់បង់ពេលវេលាសិក្សា។ ការដោះស្រាយបញ្ហាខកខានក្នុងការសិក្សារបស់សិស្ស គណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំផែនការបន្តការសិក្សារបស់សិស្សតាមលិខិត ឬសេចក្តីណែនាំ អនុវត្តមួយចំនួនដូចខាងក្រោម៖

- ការបែងចែក និងកែសន្លឹកកិច្ចការ

**ឃ- ទម្រង់ផែនការបន្តការសិក្សាក្នុងបរិបទគ្រោះអាសន្ន**

តើផែនការបន្តក្នុងការឆ្លើយតបគ្រោះអាសន្នសាលារៀនជាអ្វី?

ផែនការបន្តក្នុងការឆ្លើយតបគ្រោះអាសន្នសាលារៀន ជាការរៀបចំសកម្មភាពឆ្លើយតបគ្រោះអាសន្នកំឡុងពេលកើតមានហានិភ័យគ្រោះមហន្តរាយ។

| សកម្មភាព | អ្នកទទួលខុសត្រូវដឹកនាំ | ផែនការបន្តការសិក្សា | អ្នកពាក់ព័ន្ធ |
|---|---|---|---|
| **ជំងឺឆ្លង / ជំងឺកូវីដ-១៩** | | | |
| ការរៀនពីចម្ងាយ | នាយកសាលា<br>គ្រូបង្រៀន | កាលបរិច្ឆេទ | សិស្ស<br>មាតាបិតា<br>អ្នកអាណាព្យាបាល<br>អាជ្ញាធរមូលដ្ឋាន |
| ការរៀនតាមបណ្តុំ (សហគមន៍ ផ្ទះមេភូមិ សាលាឆទាន) | | | |
| ការរៀនតាមវេន | | | |
| ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក | | | |
| ការរៀនតាមផ្ទះ | | | |
| ការរៀនបន្តនៅថ្នាក់បណ្តោះអាសន្ន | | | |

| | | | |
|---|---|---|---|
| ការបង្រៀនពីចម្ងាយ | | | |
| ការបង្រៀនតាមបណ្តុំ | | | |
| ការថត និងបង្រៀនតាមវីដេអូ | | | |
| ការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក Zoom... | | | |
| ការបែងចែក និងកែសន្លឹកកិច្ចការ | | | |

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ផែនការបន្តសម្រាប់ការសិក្សាក្នុងគ្រោះអាសន្ន ជាការងារឆ្លើយតបដ៏សំខាន់ដែលគ្រប់អ្នកផ្តល់សេវាអប់រំដល់សាលារៀនទាំងអស់ត្រូវរៀបចំបានទាន់ពេលវេលា ហើយសិស្សនៅតែបន្តការសិក្សាបាន។ ដូចជាបញ្ហាជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានចាត់វិធានការជាបន្ទាន់ក្នុងការផ្តល់សេវាអប់រំដល់គ្រឹះស្ថានសាធារណៈគ្រប់កម្រិតថ្នាក់ តាមរយៈសេចក្តីណែនាំអនុវត្តការរៀន និងបង្រៀន មួយចំនួន ដូចជាការបង្រៀន និងរៀនពីចម្ងាយ ការបង្រៀនតាមបណ្តុំ ការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក ការចែកសន្លឹកកិច្ចការឱ្យសិស្សធ្វើនៅផ្ទះរួចផ្ញើមកគ្រូកែដាក់ពិន្ទុ និងបង្រៀនតាមវីដេអូឃ្លីបជាដើម។ ឯគ្រូបង្រៀនក៏បានរួមចំណែកយ៉ាងសកម្មក្នុងការបង្រៀនតាមគន្លងបរិបទថ្មីនេះផងដែរ។

ដូច្នេះ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ មាតាបិតាឬអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធត្រូវយល់ដឹង និងត្រៀមលក្ខណៈទុកជាមុនក្នុងការរៀបចំផែនការបន្តសម្រាប់ឱ្យសិស្សនៅតែបន្តការសិក្សាបាន ទោះបីមានគ្រោះអាសន្នកើតឡើងក៏ដោយ។

**២- ៥ ឯកសារសិក្សាបន្ថែម**

ក្រសួងអប់រំ យុវជន និងកីឡា (2023) កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារៈ *ក្របខណ្ឌសាលារៀនសុវត្ថិភាព ។*

**២-៦ ការអនុវត្ត**

បន្ទាប់ពីសិក្សាខ្លឹមសារ «ការរៀបចំផែនការបន្តសម្រាប់ការសិក្សាក្នុងគ្រោះអាសន្ន» រួច តើលោកអ្នកគិតថា ការរៀបចំផែនការបន្តការសិក្សា ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ននៃគ្រោះមហន្តរាយមានសារៈសំខាន់យ៉ាងណាខ្លះ? តើលោកអ្នកបានត្រៀមរួចហើយឬនៅដើម្បីការអនុវត្តផែនការបន្តការសិក្សាក្នុងការឆ្លើយតបហានិភ័យនៃគ្រោះមហន្តរាយផ្សេងៗនៅសាលារៀនរបស់លោកអ្នក?

**សំណួរ**

១- ដើម្បីធានាថា មិនមានការបាត់បង់ពេលវេលាសិក្សានៅពេលមានគ្រោះអាសន្ននៃគ្រោះមហន្តរាយនៅតាមសាលារៀន តើលោកអ្នកត្រូវធ្វើអ្វី?

២- ចូរសាកល្បងបង្កើតផែនការបន្តសម្រាប់សាលារៀនរបស់អ្នកដែលកំពុងស្ថិតនៅគ្រាមានអាសន្ន?

៣- តើសកម្មភាពអ្វីខ្លះ ដែលសំខាន់សម្រាប់ការងារឆ្លើយតបគ្រោះអាសន្នសម្រាប់ឱ្យសិស្សអាចបន្តការសិក្សា?

# មេរៀនទី២៖ ការតាមដានហានិភ័យ

## ១- វត្ថុបំណង

- ប្រាប់បានពីយន្តការ ពង្រឹងការតាមដានការវាយតម្លៃ ការអនុវត្តសកម្មភាពការងារសាលារៀនសុវត្ថិភាពនៅតាមសាលារៀនឱ្យកាន់តែមានភាពប្រសើរឡើង
- បង្កើនការអនុវត្តប្រព័ន្ធប្រកាសឱ្យដឹងមុន និងផ្សព្វផ្សាយពីហានិភ័យដល់អ្នកពាក់ព័ន្ធផ្សេងៗ
- ត្រៀមលក្ខណៈ និងដំណើរការដែលអាចឱ្យបុគ្គល សហគមន៍ សាលារៀន និងអ្នកដទៃចាត់វិធានការទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយជាមុនៗព្រឹត្តិការណ៍គ្រោះថ្នាក់ដែលកើតឡើង និងឆ្លើយតបប្រកបដោយប្រសិទ្ធភាព។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ សិក្សាអំពីការតាមដានហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សាលារៀនដែលត្រូវបានអនុវត្តមុនពេល កំឡុងពេល ក្រោយពេលមានគ្រោះមហន្តរាយ ។ ជាពិសេស ពង្រឹង ប្រព័ន្ធប្រកាសឱ្យដឹងមុន សមត្ថភាពត្រៀម កាត់បន្ថយ ការស្តារឡើងវិញ និងការឆ្លើយតប ចំពោះហានិភ័យគ្រោះមហន្តរាយនានាដែលកើតមានឡើង។ ដោយមេរៀនអ្នកនឹងផ្តោតលើខ្លឹមសារមេរៀនដូចខាងក្រោម៖

- សេណារីយ៉ូ មុខសញ្ញាគ្រោះថ្នាក់
- ការតាមដានហានិភ័យគ្រោះមហន្តរាយ
- ប្រព័ន្ធព័ត៌មានឱ្យដឹងមុន
  - ប្រព័ន្ធព័ត៌មានឱ្យដឹងជាមុន១២៩៤ សម្រាប់ថ្នាក់ខេត្ត
  - ប្រព័ន្ធប្រកាសព័ត៌មានជាមុន សម្រាប់សាលារៀន។

### ២- ២ ពាក្យគន្លឹះ

- ***ប្រព័ន្ធប្រកាសឱ្យ ដឹងមុន*** សំដៅដល់សមត្ថភាព ដែលតម្រូវឱ្យមានការបង្កើនសម្រាប់ប្រមូល និងផ្សព្វផ្សាយទាន់ពេលវេលា និង ប្រកកាសព័ត៌មានដែលមានន័យគ្រប់គ្រាន់ ទៅដល់ក្រុមមនុស្ស សហគមន៍ និងស្ថាប័នដែលគំរាម កំហែងដោយមុខសញ្ញាគ្រោះថ្នាក់ ដើម្បីត្រៀមធ្វើឱ្យសមស្រប និងទាន់ពេលវេលា ពីការកាត់បន្ថយ លទ្ធភាពនៃការអន្តរាយ ឬបាត់បង់។
- ***ហានិភ័យ*** សំដៅដល់ភាពដែលអាចកើតមាននូវផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក ( ស្លាប់ របួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ចត្រូវបាន រំខាន ឬបរិស្ថានត្រូវបានខូចខាត) ដែលបណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញ គ្រោះថ្នាក់ធម្មជាតិ ឬមនុស្ស ទៅនឹងភាពងាយរងគ្រោះ

- *សេណារីយ៉ូ* (Scenario) ជាដំណើរសាច់រឿង ឬស្ថានភាពនៃរឿងអ្វីមួយ។ ឧទាហរណ៍ ការឆ្លើយតបនឹងគ្រោះអាសន្នណាមួយ។ ចំពោះការថតភាពយន្ត ត្រូវគោរពតាមសេណារីយ៉ូ ដែលបានរៀបចំរួចហើយ។

**២- ៣ ខ្លឹមសារមេរៀន**

នៅមេរៀនមុនៗ យើងបានសិក្សារួចហើយអំពី ខ្លឹមសារមេរៀនក្នុងជំពូកទី១ ដល់ជំពូកទី៤ ដែលបង្ហាញពី (១)- ច្បាប់ បទដ្ឋានគតិយុត្តនិងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀននិងក្របខណ្ឌសាលារៀនសុវត្ថិភាព (២)- យន្តការ/គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន (៣)- មុខសញ្ញាគ្រោះថ្នាក់និងហានិភ័យ (៤)- ផែនការកាត់បន្ថយហានិភ័យ និងបន្ត(៥)- ការរៀបចំនីតិវិធីប្រតិបត្តិ/បទដ្ឋាន/ស្តង់ដា(SOP)និងលំហាត់សមយុទ្ធ។

ឥឡូវនេះ យើងនឹងសិក្សាការតាមដានហានិភ័យគ្រោះមហន្តរាយសាលារៀន គឺជាដំណើរការត្រួតពិនិត្យ ប្រព័ន្ធព័ត៌មានមុនពេល កំឡុងពេល និងក្រោយពេលមានគ្រោះមហន្តរាយកើតឡើង ដើម្បីពង្រឹងសមត្ថភាពត្រៀម កាត់បន្ថយ ការស្តារឡើងវិញ និងការឆ្លើយតបទាន់ពេលវេលា។

ការតាមដានហានិភ័យនេះ មានសារៈសំខាន់ជាពិសេសដើម្បីធានាថាកុមារត្រូវបានការពារពីហានិភ័យនៃគ្រោះមហន្តរាយ និងអាចបន្តការសិក្សានៅពេលដែលមានគ្រោះថ្នាក់កើតឡើង។

ដូច្នេះ មុនការតាមដានហានិភ័យប្រកបដោយប្រសិទ្ធភាព គណៈគ្រប់គ្រងត្រូវគិតថា

- តើការតាមដានហានិភ័យគ្រោះមហន្តរាយគឺជាអ្វី?
- ហេតុអ្វីត្រូវការតាមដានហានិភ័យគ្រោះមហន្តរាយ?
- តើត្រូវសិក្សាអ្វីខ្លះ ដើម្បីតាមដានហានិភ័យគ្រោះមហន្តរាយ?
- តើប្រព័ន្ធប្រកាសឱ្យដឹងជាមុនជាអ្វី និង ដំណើរការដូចម្តេច?
- អ្វីជាសេណារីយ៉ូមុខសញ្ញាគ្រោះថ្នាក់?

**១- សេណារីយ៉ូ មុខសញ្ញាគ្រោះថ្នាក់**

យោងតាមប្រវត្តិគ្រោះមហន្តរាយនៅកម្ពុជាដែលកើតមានជាញឹកញាប់ គឺគ្រោះទឹកជំនន់ ខ្យល់ព្យុះ (ខ្យល់កន្ត្រាក់) និងគ្រោះរាំងស្ងួត។ ដូចនេះ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ គួរផ្តោតលើមុខសញ្ញាគ្រោះថ្នាក់ខាងលើ ដើម្បីពង្រឹងសមត្ថភាពត្រៀមបម្រុង និងឆ្លើយតប។ នៅក្នុងផ្នែកនេះ បង្ហាញពីការប៉ាន់ប្រមាណហានិភ័យ និងផលប៉ះពាល់ក្នុងវិស័យអប់រំ ទាំងផ្នែកអប់រំកុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ ទន្ទឹមនឹងនេះ ក៏នៅមានគ្រោះមហន្តរាយផ្សេងៗទៀត ដូចជាបញ្ហាសង្គម ជំងឺរាតត្បាត និងបញ្ហាចំណាកស្រុកទ្រង់ទ្រាយធំ ដែលអាចកើតមានឡើង ហើយគួរតែឆ្លើយតបតាមគោលការណ៍ និងយុទ្ធសាស្ត្រ ដែលបានបង្ហាញក្នុងផែនការនេះ។

**កម្រិតសេណារីយ៉ូ**

ក្នុងសិក្ខាសាលាធ្វើចំណាត់ថ្នាក់កម្រិតហានិភ័យគ្រោះមហន្តរាយ នៅខែកក្កដា ឆ្នាំ២០១៨ ដែលមានការចូលរួមពីក្រុមការងារ លេខាធិការដ្ឋាន និងក្រុមការងារពីយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្រសួង មន្ទីរអប់រំខេត្ត និង អង្គការដៃគូ គ្រោះទឹកជំនន់ ត្រូវបានធ្វើចំណាត់ថ្នាក់ខ្ពស់ ដែលទាមទារឱ្យក្រសួងអប់រំយុវជន និងកីឡា ក៏ដូចជាសាលារៀន ត្រូវធ្វើផែនការលម្អិតទៅលើមុខសញ្ញាគ្រោះមហន្តរាយ ដើម្បីដឹងពីមុខសញ្ញាគ្រោះថ្នាក់ កម្រិតមុខសញ្ញាគ្រោះថ្នាក់ កម្រិតផលប៉ះពាល់ និងកម្រិតសេណារីយ៉ូ។
ខាងក្រោមគឺជាចំណាត់ថ្នាក់មុខសញ្ញាគ្រោះមហន្តរាយ។




ចំណាត់ថ្នាក់ហានិភ័យនេះ ត្រូវពិនិត្យឡើងវិញរៀងរាល់ ៦ខែម្តង ដើម្បីធានាការត្រៀមរៀបចំមុនគ្រោះមហន្តរាយមានប្រសិទ្ធភាពខ្ពស់។ ក្នុងឆ្នាំ២០១៩ ហានិភ័យគ្រោះមហន្តរាយ បានឱ្យចំណាត់ថ្នាក់ខ្ពស់ទៅលើគ្រោះរាំងស្ងួត ដែលបង្កដោយបាតុភូត El Nino ដែលនឹងមានការកើនកំដៅខ្ពស់នៅតាមបណ្តាខេត្តមួយចំនួន។

**២- ការតាមដានហានិភ័យគ្រោះមហន្តរាយ**

ដើម្បីតាមដានការកើនឡើងនូវហានិភ័យគ្រោះមហន្តរាយ ប្រភពព័ត៌មានខាងក្រោមត្រូវបានកំណត់ឡើងសម្រាប់ធ្វើជាយន្តការក្នុងការតាមដានហានិភ័យគ្រោះមហន្តរាយ។

| ហានិភ័យ | ប្រភព/សូចនាករព័ត៌មាន | អ្នកទទួលខុសត្រូវ | កក្តាប្រឈម | |
|---|---|---|---|---|
| | | | ប្រឈម | ដំណោះស្រាយ |
| **ទឹកជំនន់** | • ឧតុនិយម (www-cambodiameteo - com) | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ | • មិនទាន់មានទំនាក់ទំនងជា | • ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ១២៩៤ |

| | | | | |
|---|---|---|---|---|
| | • ពេលវេលារដូវកាល(ខែ៧ ទៅខែ១០)<br>• តាមទម្លាប់ចំណាំទៅសត្វនិងរុក្ខជាតិ<br>• តាមរយៈទូរសព្ទ័អ្នកនៅផ្នែកខាងលើប្រភពទឹក<br>• ប្រពន្ធ័១២៩៤<br>• តាមការប្រកាសកម្ពស់ទឹក<br>• ព័ត៌មានពីមជ្ឈដ្ឋានជុំវិញ<br>• វិទ្យុ ទូរទស្សន៍ និងសារព័ត៌មាន បណ្ដាញសង្គម<br>• ឧបករណ៍វាស់កម្ពស់ទឹក<br>• គេហទំព័រគណៈកម្មការទន្លេមេគង្គ ffw-mrcmekong-org **<br>• ការព្យាករណ៍ពីកម្រិតទឹកភ្លៀងនៅប្រទេសឡាវនិងវៀតណាម | លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ<br>• មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអេយក (មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹក និងឧតុនិយម | មួយមន្ត្រីឧត្តុនិយមខេត្ត<br>• ខ្វះប្រព័ន្ធ១២៩៤<br>• ខ្វះខាតការផ្សព្វផ្សាយទូទៅ<br>• ខ្វះខាតឧបករណ៍បច្ចេកទេស<br>• ខ្វះខាតមន្ត្រីជំនាញ<br>• ស្ថានភាពភូមិសាស្ត្រតាមតំបន់<br>• គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់មិនទាន់បានបំពេញភារកិច្ចបានគ្រប់ជ្រុងជ្រោយ<br>• ថវិកាត្រៀមនិងឆ្លើយតបមិនទាន់មានគ្រប់គ្រាន់<br>• ការយល់ដឹងនិងការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត | • រៀបចំផែនការត្រៀមបម្រុង<br>• រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតបឱ្យច្បាស់លាស់ |

| | | | | |
|---|---|---|---|---|
| **ខ្យល់ព្យុះ** | • ឧតុនិយម (www-cambodiameteo - com)<br>• មេឃដុំពពកខ្មៅច្រើន<br>• សីតុណ្ហភាពក្តៅខ្លាំងខុសពីថ្ងៃធម្មតា<br>• ល្បឿនខ្យល់<br>• ការប្រកាសព័ត៌មាន<br>• វាស់កម្រិតទឹកភ្លៀង | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ<br>• មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអេយក (មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹក និងឧត្តុនិយម | • ខូចខាតអគារសិក្សា | • រៀបចំផែនការត្រៀមបម្រុង<br>• ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ១២៩៤<br>• រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតបឱ្យច្បាស់លាស់ |
| **រាំងស្ងួត** | • ឧតុនិយម (www-cambodiameteo - com)<br>• ពេលវេលារដូវកាល (ខែ២ ដល់ខែ៥)<br>• អាកាសធាតុការប្រកាសព័ត៌មាន<br>• កម្រិតទឹកក្នុងអណ្តូង/ទឹកក្រោមដី/ទឹកស្រះ/ទន្លេ<br>• សាលារៀនគ្មានទឹកប្រើប្រាស់<br>• ចំនួនកុមារអវត្តមានដោយជំងឺលើសពី៣០%ទូទាំងប្រទេស | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ<br>• មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអេយក- (មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹក និងឧតុតនិយម | • ខ្វះទឹកប្រើប្រាស់<br>• ប៉ះពាល់ម៉ោងសិក្សារបស់សិស្ស | • មានអាងស្តុកទឹកតាមសាលា<br>• មានធុងស្តុកទឹកតាមថ្នាក់<br>• រៀបប្រព័ន្ធទឹក(ជីកអណ្តូង)<br>• រៀបចំផែនការត្រៀមបម្រុង<br>• ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ១២៩៤<br>• រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតបឱ្យច្បាស់លាស់ |
| **រន្ទះបាញ់** | • កម្រិតទឹកភ្លៀង<br>• ឧតុនិយម<br>• មេឃដុំពពកខ្មៅច្រើន | • គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ជាតិនិងក្រោមជាតិ | • មិនអាចព្យាករណ៍បានច្បាស់លាស់ | • រៀបចំផែនការត្រៀមបម្រុង<br>• ត្រូវមានទំនាក់ទំនងជាមួយមន្ត្រីឧតុនិយម<br>• ពង្រីកបន្ថែមប្រព័ន្ធ១២៩៤<br>• រៀបចំផែនការត្រៀមបម្រុង |

| | | | | |
|---|---|---|---|---|
| | | • មន្ត្រីអប់រំស្រុករហូតដល់មន្ទីរអេយក- (មន្ត្រីបង្គោល)<br>• ក្រសួងធនធានទឹក និងឧតុនិយម | | • រៀបចំនិងតែងតាំងមន្ត្រីបង្គោលឱ្យច្បាស់លាស់<br>• កំណត់និងស្វែងដៃគូអភិវឌ្ឍន៍<br>• រៀបចំឱ្យមានថវិកាជាតិសម្រាប់ត្រៀមបម្រុងនិងឆ្លើយតបឱ្យច្បាស់លាស់ |

** ចំពោះកម្រិតនៃ ការប្រកាសគ្រោះអាសន្នសម្រាប់ទឹកជំនន់ ទិន្នន័យកម្ពស់ទឹកត្រូវបានព្យាករណ៍ទៅតាមស្ថានីយជលសាស្ត្រ ចំនួន ៧ ដែលស្ថិតនៅតាមដងទន្លេមេគង្គ និងទន្លេសាប។

| ឈ្មោះស្ថានីយជលសាស្ត្រ | **កម្រិតប្រកាសអាសន្ន** (វាស់កំពស់ទឹកគិតជាម៉ែត្រ) | | | | |
|---|---|---|---|---|---|
| | កម្រិតមិនមានភាពអាសន្ន និង និមិត្តសញ្ញា | កម្រិតប្រកាសភាពអាសន្ន និង និមិត្តសញ្ញា | | **កម្រិតទឹកជំនន់ និង និមិត្តសញ្ញា** | |
| ទន្លេមេគង្គ ស្ទឹងត្រែង | ⇩ ⇧ | ១០.៧០ | ⇩ ⇧ | ១២.០០ | ⇩ ⇧ |
| ទន្លេមេគង្គ ក្រចេះ | | ២២.០០ | | ២៣.០០ | |
| ទន្លេមេគង្គ កំពង់ចាម | | ១៥.២០ | | ១៦.២០ | |
| ទន្លេចតុមុខ ភ្នំពេញ | | ១០.៥០ | | ១២.០០ | |
| ទន្លេសាប កំពង់ផែភ្នំពេញ | | ៩.៥០ | | ១១.០០ | |
| ទន្លេបាសាក់ កោះខែល | | ៧.២០ | | ៧.៩០ | |
| ទន្លេមេគង្គ អ្នកលឿង | | ៧.៥០ | | ៨.០០ | |
| ទន្លេសាប ព្រែកក្តាម | | ៩.៥០ | | ១០.០០ | |

**៣- ប្រព័ន្ធព័ត៌មានឱ្យដឹងមុន**

ប្រព័ន្ធព័ត៌មានឱ្យដឹងជាមុន មានសារៈសំខាន់ណាស់ឱ្យយើងដឹងពីប្រតិបត្តិការដែលកើតឡើង និងត្រៀមលក្ខណៈបានគ្រប់គ្រាន់ រួមទាំងពេលវេលានិងធនធាន និងវិធានការនានាក្នុងការឆ្លើយតបក្នុងការមានគ្រាអាសន្ន ឬគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ដែលបានកើតមានឡើងនៅកម្រិតអប្បបរមាបំផុត។ ការផ្តល់ដឹងជាមុន គឺរួមមាន ក្តារខៀនព័ត៌មាន ជួងសញ្ញា និងទូរស័ព្ទ ។ ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន ដើរតួយ៉ាងសំខាន់ក្នុងការតាមដាននូវព័ត៌មាននានា ទាក់ទងនិងការព្យាករណ៍ ឧតុនិយម និងអាកាសធាតុតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដូចជាទូរទស្សន៍ វិទ្យុ កាសែត ប្រព័ន្ធទូរស័ព្ទ ដើម្បីដឹងពីព័ត៌មាន ទឹកជំនន់ ខ្យល់ព្យុះ កម្រិតទឹកភ្លៀង និងការប្រែប្រួលអាកាសធាតុផ្សេងៗ ។

ក្នុងមេរៀននេះលោកគ្រូ អ្នកគ្រូនឹងយល់ច្បាស់ពីប្រព័ន្ធព័ត៌មានឱ្យដឹងជាមុនសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសសាលារៀនដូចខាងក្រោម៖

**ក- ប្រព័ន្ធព័ត៌មានឱ្យដឹងជាមុន១២៩៤ សម្រាប់ថ្នាក់ខេត្ត**

ដើម្បីដឹងព័ត៌មានស្តីពីគ្រោះមហន្តរាយ យើងត្រូវតាមដានតាមដានដោយប្រើទូរស័ព្ទដៃចុចលេខ ១២៩៤ ដើម្បីចូលក្នុងប្រព័ន្ធប្រកាសឱ្យដឹងជាមុន។ ជំហានសំខាន់ៗនៃការចូលក្នុងប្រព័ន្ធប្រកាសឱ្យដឹងជាមុន យើងត្រូវធ្វើតាមជំហាននីមួយៗដូចខាងក្រោម

១- ទូរស័ព្ទមកកាន់លេខ១២៩៤

២- ស្តាប់ការណែនាំតាមទូរស័ព្ទ

៣- ធ្វើការជ្រើសខេត្ត(មាន១១ខេត្ត)

៤- ជ្រើសរើសស្រុក

៥- ជ្រើសរើសឃុំ

៦- ចុះឈ្មោះបានសម្រេច

**ជំហានទាំង៦នៃការចុះឈ្មោះ**







ជំហានទាំងនេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីផ្សព្វផ្សាយអំពីសារៈសំខាន់របស់ប្រព័ន្ធប្រកាសឱ្យដឹងមុន១២៩៤ និងតួនាទីរបស់ប្រព័ន្ធដល់ប្រជាពលរដ្ឋក្នុងភូមិ និងបង្កើតឱកាសឱ្យប្រជាពលរដ្ឋចុះឈ្មោះ)។ រាល់ព័ត៌មានស្តីពីផលប៉ះពាល់ គ្រោះអាសន្ន ឬការប្រកាសព័ត៌មានឱ្យដឹងមុន ត្រូវធ្វើបច្ចុប្បន្នភាពតាមរយៈ Telegram ឈ្មោះ «មន្ត្រីបង្គោលគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី ខេត្ត» និងរាយការណ៍ទៅកាន់មន្ត្រីបង្គោលរបស់យន្តការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ជាន់ថ្នាក់។

ម្យ៉ាងវិញទៀតព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤ ត្រូវបានរចនាឡើង ដោយយកគំរូតាមបញ្ជីត្រួតពិនិត្យនៃប្រព័ន្ធហានិភ័យអាកាសធាតុ និងប្រព័ន្ធផ្តល់សញ្ញាព្រមានជាមុន (CREWS) ដែលកំណត់ដោយធនាគារ

ពិភពលោក អង្គការសហប្រជាជាតិ និងអង្គការឧតុនិយម ពិភពលោក។ ក្របខណ្ឌនេះ បង្កើតបានជាសមាស ជាតុចំនួន ៤ ដែលចាំបាច់ដើម្បីឱ្យ ប្រព័ន្ធប្រកាសឱ្យដឹងមុន (EWS) មានប្រសិទ្ធភាព ដោយមានការយល់ដឹងអំពី៖

- ចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ
- ការពិនិត្យតាមដានគ្រោះថ្នាក់
- ការផ្សាយសារប្រកាសព្រមាន
- ការត្រៀមបម្រុង និងការឆ្លើយតប

**ខ- ប្រព័ន្ធប្រកាសព័ត៌មានជាមុន សម្រាប់សាលារៀន**

ប្រព័ន្ធប្រកាសព័ត៌មានជាមុននៅសាលារៀនកំពង់ក្តលនេះរួមមានដូចជា ជួង ទូរស័ព្ទ ។ ប្រព័ន្ធប្រកាសព័ត៌មានជាមុននេះ មានសារៈសំខាន់ណាស់សម្រាប់សិស្សានិសិស្សដឹងពីព្រឹត្តិការណ៍ដែលនឹងកើតឡើង និងអាច ត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់រួមទាំងពេលវេលា ធនធាន និងវិធានការនានាក្នុងការឆ្លើយតបនៅពេលមាន អាសន្ន ឬគ្រោះមហន្តរាយសំដៅកាត់បន្ថយនូវផលប៉ះពាល់ឱ្យនៅកម្រិតអប្បបរមាបំផុត។ ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការតាមដាននូវព័ត៌មាននានាទាក់ទងនឹងការព្យាករណ៍ឧតុនិយម និងអាកាសធាតុតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាដូចជាទូរទស្សន៍ វិទ្យុ ការសែត ជាប្រចាំ ដើម្បីដឹងពីព័ត៌មានទឹកជំនន់ កម្រិតទឹកភ្លៀង និងព័ត៌មានសំខាន់ៗដទៃទៀត។ បន្ទាប់មក ត្រូវផ្សព្វផ្សាយព័ត៌មានទាំងនេះ នៅពេលគោរពទង់ជាតិ តាមថ្នាក់រៀន ដើម្បីឱ្យសិស្សានុសិស្ស និងអ្នកពាក់ព័ន្ធដទៃទៀតបានដឹង និងត្រៀមខ្លួនរួចជាស្រេច។

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ការតាមដានហានិភ័យគ្រោះមហន្តរាយទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេសតាមសាលារៀន ប្រព័ន្ធប្រកាសឱ្យដឹងមុន និងប្រព័ន្ធព័ត៌មានផ្សេងៗមានសារៈសំខាន់បំផុតសម្រាប់ការតាមដានហានិភ័យដែលកើតឡើង និងប្រសិទ្ធភាពក្នុងការឆ្លើយតបទាន់ពេលវេលា។ ជាពិសេស ធានាបានថាកុមារត្រូវបានការពារពីហានិភ័យនៃគ្រោះមហន្តរាយ និងអាចបន្តការសិក្សានៅពេលដែលមានគ្រោះថ្នាក់កើតឡើង។

ប្រព័ន្ធប្រកាសព័ត៌មានជាមុននេះ មានសារៈសំខាន់ណាស់សម្រាប់សិស្សានុសិស្សដឹងពីព្រឹត្តិការណ៍ដែលនឹងកើតឡើង និងអាច ត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់រួមទាំងពេលវេលា ធនធាន និងវិធានការនានាក្នុងការឆ្លើយតបនៅពេលមានគ- អាសន្ន ឬគ្រោះមហន្តរាយសំដៅកាត់បន្ថយនូវផលប៉ះពាល់ឱ្យនៅកម្រិតអប្បបរមាបំផុត។ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការតាមដាននូវព័ត៌មាននានាទាក់ទងនឹងការព្យាករណ៍ឧតុនិយម និងអាកាសធាតុតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាដូចជាទូរទស្សន៍ វិទ្យុ ការសែត ជាប្រចាំ ដើម្បីដឹងពីព័ត៌មានទឹកជំនន់ កម្រិតទឹកភ្លៀង និងព័ត៌មានសំខាន់ៗដទៃទៀ

ត។ បន្ទាប់មក ត្រូវផ្សព្វផ្សាយព័ត៌មានទាំងនេះ នៅពេលគោរពទង់ជាតិ តាមថ្នាក់រៀន ដើម្បីឱ្យសិស្សានុសិស្ស និងអ្នកពាក់ព័ន្ធដទៃទៀតបានដឹង និងត្រៀមខ្លួនរួចជាស្រេច។

**២- ៥ ឯកសារសិក្សាបន្ថែម**

- សៀវភៅផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់វិស័យអប់រំ ២០១៩ ( ទំព័រទី១៨ ដល់ទំព័រទី២៤ និងទំព័រទី៦១ )
- សៀវភៅណែនាំស្ដីពីអំពីលក្ខណៈបច្ចេកទេស និងការថែទាំឧបករណ៍វាស់កម្ពស់ទឹកនៃប្រព័ន្ធប្រកាសឱ្យដឹងមុន១២៩៤( ទំព័រទី៧ )
- ឯកសារផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយសម្រាប់វិស័យអប់រំកម្រិតសាលារៀន របស់សាលាបឋមសិក្សាកំពង់ក្ដុល
- គោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាប័ន្នឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

**២-៦ ភាពអនុវត្ត**

គណៈគ្រប់គ្រងត្រូវអនុវត្តនិង ផ្សព្វផ្សាយ ប្រព័ន្ធប្រកាសព័ត៌មានជាមុន និងប្រព័ន្ធឱ្យព័ត៌មានផ្សេងៗ ដល់សិស្សានុសិស្ស ឪពុកម្ដាយ ឬអាណាព្យាបាលកុមារ អាជ្ញាធរមូលដ្ឋាន គ្រូ នាយក និងអ្នកពាក់ព័ន្ធ ផ្សេងៗទៀតនៅក្នុងសហគមន៍ ។ ជាពិសេសត្រូវបិទផ្សាយនៅក្ដារខៀនព័ត៌មានសាលារៀន។

**កម្រងសំណួរ**

១- តើការតាមដានហានិភ័យគ្រោះមហន្តរាយគឺជាអ្វី ?

៣- ហេតុអ្វីបានជាសាលារៀននីមួយៗ ត្រូវការតាមដានហានិភ័យគ្រោះមហន្តរាយ ?

៤- តើសាលារៀននីមួយៗត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីតាមដានហានិភ័យគ្រោះមហន្តរាយ ?

៥- តើសាលារៀននីមួយៗ ត្រូវធ្វើដូចម្ដេច ដើម្បីថាមុខសញ្ញាគ្រោះថ្នាក់ណាមួយដែលរងផលប៉ះពាល់ខ្លាំង និងត្រូវធ្វើអាទិភាពចំណាត់ក្នុងធ្វើផែនការព្រមទាំងរៀបចំសេណារីយ៉ូឆ្លើយតប ?

៦- អ្វីជាសេណារីយ៉ូមុខសញ្ញាគ្រោះថ្នាក់ ?

# មេរៀនទី៣៖ ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដា SOP និងណែនាំលំហាត់សមយុទ្ធ

## ១- វត្ថុបំណង

- ប្រាប់បានបញ្ញត្តិសំខាន់ៗ និងនីតិវិធីប្រតិបត្តិស្តង់ដាSOPសម្រាប់ត្រៀម និងណែនាំអនុវត្តលំហាត់សមយុទ្ធឆ្លើយតបគ្រោះអាសន្នកម្រិតសាលារៀន
- កំណត់នីតិវិធីប្រតិបត្តិស្តង់ដាSOPនិងគោលការណ៍សាលារៀនសុវត្ថិភាព ព្រមទាំងរបៀបបង្កើតសេណារីយ៉ូដើម្បីឆ្លើយតបគ្រោះអាសន្នកម្រិតសាលារៀន
- ជំរុញ និងលើកទឹកចិត្តលើការលើកកម្ពស់ការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាSOP និងលំហាត់សមយុទ្ធឆ្លើយតបគ្រោះអាសន្ន កម្រិតសាលារៀន ដើម្បីធានាសុវត្ថិភាពរបស់សិស្សក្នុងការសិក្សាទាំងក្នុងសាលារៀន និងការរស់នៅក្នុងសហគមន៍ជាក់ស្តែង។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ បង្ហាញពី ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដា SOP ឆ្លើយតបគ្រោះអាសន្ននៅក្នុងសាលារៀន ដូចជាខ្យល់ខ្លាំង ទឹកជំនន់ អគ្គីភ័យជាដើម។ ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដា SOP នេះ មានចំណុចសំខាន់ៗមួយចំនួនដូចជា ការណែនាំអំពីនីតិវិធីប្រតិបត្តិស្តង់ដា SOP ឆ្លើយតបគ្រោះអាសន្ន ការណែនាំពីដំណើរការធ្វើលំហាត់សមយុទ្ធ ការសរសេរសេណារីយ៉ូសម្រាប់អនុវត្តលំហាត់សមយុទ្ធ ការអនុវត្តលំហាត់សមយុទ្ធតាមសាលារៀន និងវិធីឆ្លុះបញ្ចាំងការអនុវត្តលំហាត់សមយុទ្ធ។

### ២- ២ ពាក្យគន្លឹះ

- ***សេណារីយ៉ូ*** សំដៅដល់សេចក្តីអធិប្បាយដ៏សាមញ្ញ និងដែលគួរឱ្យជឿជាក់បានថា តើនាពេលអនាគតប្រហែលវានឹងកើតឡើងយ៉ាងដូចម្តេច ដោយផ្អែកលើភាពប្រទាក់គ្នា និងសង្គតិភាពផ្ទៃក្នុងនៃការសន្មតពីកម្លាំងជំរុញ និងទំនាក់ទំនងសំខាន់ៗ។ (ការប្រែប្រួលអាកាសធាតុទុតិយភូមិ)
- ***ស្តង់ដា*** សំដៅអ្វីដែលធ្វើទៅតាមលក្ខណៈ ក្បួនខ្នាតបច្ចេកទេសត្រឹមត្រូវមានការទទួលស្គាល់ដឹងឮជាសកល(វចនានុក្រមអ៊ីនធើណេត) ពាក្យនេះគឺកម្ចីមកពីភាសាបារាំង Standard មានន័យថា និយាមឬបទដ្ឋាន។ ឧទាហរណ៍ ការសិក្សានេះគ្មានស្តង់ដា។ មានន័យថា ការសិក្សានេះមិនស្របតាមនិយាម ឬក្បួនខ្នាតទូទៅនៃប្រទេសជាច្រើន។ អាចថាគុណភាពអន់ជាងគេ របៀបបង្រៀនមិនច្បាស់លាស់។ល។ ការដឹកនាំគ្មានស្តង់ដា មានន័យថាការដឹកនាំដោយគ្មានគោរពតាមក្បួនខ្នាតអ្វីទាំងអស់ ឬអាចនិយាយបែបផ្សេងថា ដឹកនាំគ្មានរបៀប រញ៉េរញ៉ៃឬតាមបែបអារម្មណ៍។ (វចនានុក្រមសម្តេចសង្ឃរាជ)

- ***នីតិវិធីប្រតិបត្តិស្តង់ដាSOP*** សំដៅជាគោលការណ៍ណែនាំអន្តរជាតិ ក្នុងការអនុវត្តលំហាត់សមយុទ្ធ ដើម្បីត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន។ ជាសំណុំនៃការណែនាំ ជាលាយលក្ខណ៍អក្សរ ដែលពិពណ៌នាអំពីដំណើរការមួយជំហានម្តងដែលត្រូវតែធ្វើឡើងដើម្បីអនុវត្តសកម្មភាពប្រចាំថ្ងៃឱ្យបានត្រឹមត្រូវ។
- ***ខ្យល់ខ្លាំង*** សំដៅលើខ្យល់បក់ខ្លាំងគឺជាកម្លាំងនៃការបំផ្លិចបំផ្លាញដោយការបោកបក់ដែលទាក់ទងនឹងភ្លៀងផ្គររន្ទះ ឬព្យុះសង្ឃរា។

**២- ៣ ខ្លឹមសារមេរៀន**

តើនីតិវិធីប្រតិបត្តិស្តង់ដា SOP ជាអ្វី?

នីតិវិធីប្រតិបត្តិស្តង់ដា SOP ជាសំណុំនៃការណែនាំ ជាលាយលក្ខណ៍អក្សរ ដែលពិពណ៌នាអំពីដំណើរការមួយជំហានម្តងដែលត្រូវតែធ្វើឡើងដើម្បីអនុវត្តសកម្មភាពប្រចាំថ្ងៃឱ្យបានត្រឹមត្រូវ។ នីតិវិធីប្រតិបត្តិស្តង់ដា (SOP) គួរតែត្រូវបានអនុវត្តតាមវិធីដូចគ្នាយ៉ាងពិតប្រាកដហើយរាល់ពេល ដើម្បីធានាថា រាល់សកម្មភាពទាំងអស់ស្របនឹងអនុលោមតាមបទបញ្ញត្តិសាលារៀនសុវត្ថិភាព។ លើសពីនេះទៀត វាផ្តល់នៅគោលនយោបាយ ដំណើរការនិងស្តង់ដាចាំបាច់ សម្រាប់សាលារៀនមានសុវត្ថិភាព និងផ្តល់អត្ថប្រយោជន៍ដល់សាលារៀនក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមសាលារៀននីមួយៗ។ ដូច្នេះ នីតិវិធីប្រតិបត្តិស្តង់ដា SOP ត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម

ក- ការណែនាំពីនីតិវិធីប្រតិបត្តិស្តង់ដា (SOP)

ខ- ការណែនាំពីដំណើរការធ្វើលំហាត់សមយុទ្ធតាមសាលារៀន

គ- ការសរសេរសេណារីយូសម្រាប់អនុវត្តលំហាត់សមយុទ្ធសាកល្បង

ឃ- ការអនុវត្តលំហាត់សមយុទ្ធតាមសាលារៀន និង

ង-ការឆ្លុះបញ្ចាំងពីការអនុវត្តក្រោយពេលអនុវត្តលំហាត់សមយុទ្ធ។

**ក- ការណែនាំពីនីតិវិធីប្រតិបត្តិស្តង់ដា (SOP)**

ការណែនាំពីនីតិវិធីប្រតិបត្តិស្តង់ដា (SOP) សំដៅដល់ការណែនាំ ដែលជាការកំណត់នីតិវិធីសម្រាប់អនុវត្តក្នុងពេលធ្វើសមយុទ្ធ។ នីតិវិធីដែលត្រូវអនុវត្តនៅពេលធ្វើលំហាត់សមយុទ្ធ មាននីតិវិធីប្រតិបត្តិស្តង់ដា ៦ ចំណុចដូចខាងក្រោម៖

**១- នីតិវិធីប្រតិបត្តិស្តង់ដាទី១ ការជម្លៀសចេញពីអគារ**

នីតិវិធីប្រតិបត្តិស្តង់ដាទី១ ការជម្លៀសចេញពីអគារ គឺធ្វើឡើងដើម្បីការពារសិស្ស មន្ត្រីអប់រំក្នុងករណីមាន គ្រោះមហន្តរាយដូចជាអគ្គីភ័យ ឬមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុងអគារ។ ការជម្លៀសចេញពីអគារប្រព្រឹត្តទៅតាមសូរសំឡេងសញ្ញាអាសន្ន ឬសំឡេងអគ្គីភ័យប្រកាសអាសន្នឱ្យជម្លៀស។ ករណីសំឡេងប្រកាសអាសន្ននេះកើតឡើង យើងត្រូវចាប់ផ្តើមដំណើរការប្រព័ន្ធឆ្លើយតបគ្រោះអាសន្នតាមការចាំបាច់ មានដូចជា៖

លោកគ្រូ អ្នកគ្រូត្រូវ៖

- រំឭកសិស្សនូវគោលការណ៍ជម្លៀស កុំរត់ កុំនិយាយ កុំរុញ កុំត្រឡប់ក្រោយ
- បិទទ្វារ និងបង្អួច
- ឈរនៅខាងមុខជួរសិស្សមួយនាក់ និងមួយនាក់ទៀតឈរនៅខាងក្រោយជួរសិស្ស
- យកប្រអប់សុវត្ថិភាពឬសង្គ្រោះ
- ពិនិត្យមើលសុវត្ថិភាពនៅលើផ្លូវជម្លៀស
- នាំសិស្សទៅរកកន្លែងជួបជុំនៅក្រៅអគារ
- នាំសិស្សត្រឡប់មកវិញនៅពេលមានសុវត្ថិភាពដោយអនុវត្តគោលការណ៍ជម្លៀសដូចខាងលើ។

សិស្សត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍៖

- កុំរត់ កុំប៉ះពាល់គ្នាបង្កការរបួស ឬបង្កការឈឺផ្សេងៗ
- កុំនិយាយ
- កុំរុញគ្នា
- កុំត្រឡប់ក្រោយ
- កំណត់ផ្លូវកំពុងជម្លៀសរបស់អ្នកឱ្យបានច្បាស់លាស់ និងប្រាកដថាមិនមានការផ្លាស់ប្តូរអ្វីផ្សេង។

**២- នីតិវិធីប្រតិបត្តិស្តង់ដាទី២ ការជួបជុំ និងជ្រកខាងក្រៅបន្ទប់ ឬអគារ**

នីតិវិធីប្រតិបត្តិស្តង់ដាទី២ ការជួបជុំ និងជ្រកខាងក្រៅបន្ទប់ឬអគារ គឺជាការការពារសិស្ស មន្ត្រីអប់រំ ដើម្បីធានាសុវត្ថិភាព ហើយគ្រប់គ្នាអាចជួបជុំគ្រួសារវិញបាន។ នីតិវិធីនេះជាដំណើរការឆ្លើយតបរបស់សាលារៀនក្រោយពេលជួបជុំនិងជ្រកកន្លែងមានសុវត្ថិភាពរួចហើយ។ តួនាទីអ្នកប្រតិបត្តិការរុករកនិងសង្គ្រោះបឋម គឺមើលការខុសត្រូវសិស្ស ធានានូវសុវត្ថិភាព ដោយមាន ទឹក អាហារ ជម្រក និងអនាម័យនៅកន្លែងជួបជុំ។ នីតិវិធីនេះ ចាំបាច់ឱ្យមានការចូលរួមពីយុវជនស្ម័គ្រចិត្ត និងសិស្សដែលមានសមត្ថភាព ហើយត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម

លោកគ្រូអ្នកគ្រូត្រូវ ៖

- រំឭកសិស្សពីគោលការណ៍ជម្លៀសសុវត្ថិភាព កុំរត់ កុំនិយាយ កុំរុញ កុំត្រឡប់ក្រោយ (សិស្សគួរជម្លៀសជាគូ)
- ពិនិត្យមើលថា តើមានតម្រូវការពិសេសអ្វីខ្លះដែរឬទេ?
- យកសម្ភារៈ ឬព័ត៌មាននៅក្នុងបន្ទប់ ដូចជា ប្រអប់សង្គ្រោះបឋម ផែនទីផ្លូវជម្លៀស សោបន្ទប់ កញ្ចែ ទូរស័ព្ទ លេខទូរស័ព្ទទាក់ទងសំខាន់ បញ្ជីគណៈកម្មការ

- រៀបចំគ្រូ ឬមនុស្សធំមួយនាក់នៅខាងមុខ ដើម្បីមើលថាផ្លូវជម្លៀសមានសុវត្ថិភាពឬទេ ហើយត្រូវមានគ្រូឬសិស្សមានសមត្ថភាពមួយនាក់ទៀតនៅខាងក្រោយក្រុមសិស្សជម្លៀសនោះ ដើម្បីពិនិត្យមើលថាសិស្សទាំងអស់ជុំគ្នា( អាចធ្វើជាពីរថ្នាក់ចូលគ្នាបាន)
- ដឹកនាំសិស្សទៅរកកន្លែងជួបជុំពេលមានអាសន្ននិងហៅឈ្មោះសិស្សម្តងម្នាក់
- ក្រើនរំឭកដល់សិស្សអំពីនីតិវិធីក្នុងការអនុញ្ញាតឱ្យសិស្សចេញទៅបាន ដើម្បីធានាសុវត្ថិភាព
- រៀបចំសិស្សនៅជុំគ្នាតាមថ្នាក់នីមួយៗគ្រប់ពេល។

សិស្សត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍

- អង្គុយតាមកន្លែងដែលបានកំណត់ទុក ដោយរក្សាភាពស្ងាត់ស្ងៀម
- ជួយរៀបចំទឹក ម្ហូប ជម្រក និងអនាម័យផ្សេងៗនៅពេលគ្រូស្នើឱ្យជួយ
- ជួបជុំនៅកន្លែងដែលបានកំណត់ និងបានដឹងជាមុន
- សិស្សគ្រប់គ្នាដឹងកន្លែងជួបជុំតាមក្រុមថ្នាក់របស់ពួកគេ។

**៣- នីតិវិធីប្រតិបត្តិស្តង់ដារទី៣ ការជម្លៀសទៅកន្លែងសុវត្ថិភាព**

នីតិវិធីប្រតិបត្តិស្តង់ដារទី៣ ការជម្លៀសទៅកន្លែងសុវត្ថិភាព គឺជាការការពារសិស្ស មន្ត្រីអប់រំ ក្នុងករណីអគ្គីភ័យឬមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុងបរិស្ថានសាលារៀននោះ។ ចំពោះសាលារៀនទាំងឡាយណាដែលប្រឈមនឹងអគ្គីភ័យ ទឹកជំនន់ បាក់ដី ការហូរល្បាប់ដី ឬសាលារៀនដែលគ្មានកន្លែងជួបជុំ គួរតែរៀបចំកន្លែងនេះនៅកន្លែងផ្សេងទៀត និងរៀបចំឱ្យមានផ្លូវជម្លៀសឱ្យបានមុនពេលអនុវត្ត។ អ្នកដឹកនាំត្រូវប្រាប់ដល់ឪពុកម្តាយនិងអាណាព្យាបាលសិស្សឱ្យបានដឹងពីទីកន្លែងជួបជុំនោះ។ បើជម្លៀស ត្រូវជម្លៀសទៅរកទីតាំងជួបជុំណាដែលបានកំណត់ពីមុនរួចហើយ។ នីតិវិធីនេះ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម

លោកគ្រូអ្នកគ្រូត្រូវៈ

- រំឭកសិស្សពីគោលការណ៍ជម្លៀសសុវត្ថិភាព កុំរត់ កុំនិយាយ កុំរុញ កុំត្រឡប់ក្រោយ(សិស្សគួរជម្លៀសជាគូ)
- រៀបចំឱ្យមានមនុស្សធំមួយនាក់នៅខាងមុខ ដើម្បីមើលថា ផ្លូវជម្លៀសមានសុវត្ថិភាពឬទេ ហើយត្រូវមានគ្រូឬសិស្សមានសមត្ថភាពមួយនាក់ទៀតនៅខាងក្រោយក្រុមសិស្សជម្លៀសនោះ ដើម្បីពិនិត្យមើលថាសិស្សទាំងអស់ជុំគ្នា។ (អាចធ្វើជាពីរថ្នាក់ចូលគ្នាបាន)។
- យកសម្ភារៈ ឬព័ត៌មាននៅក្នុងបន្ទប់ មានដូចជា ប្រអប់សង្គ្រោះបឋម ផែនទីផ្លូវជម្លៀស សោបន្ទប់កញ្ចែ ទូរស័ព្ទ លេខទូរស័ព្ទទាក់ទងសំខាន់ បញ្ជីគណៈកម្មការ។
- ដឹកនាំសិស្សទៅរកកន្លែងជួបជុំពេលមានអាសន្ននិងហៅឈ្មោះសិស្សម្តងម្នាក់
- មើលថា នៅពេលមានសុវត្ថិភាពហើយ ត្រូវនាំសិស្សត្រឡប់មកវិញ ដោយអនុវត្តគោលការណ៍ជម្លៀសដូចខាងលើ។

សិស្សត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍៖

- ត្រូវអង្គុយតាមក្រុមបម្លាស់ទីឱ្យបានលឿននិងស្ងាត់ស្ងៀម
- នៅកន្លែងជួបជុំ និងជ្រកខាងក្រៅបន្ទប់អគារ គឺត្រូវអង្គុយតាមកន្លែងស្ងាត់ស្ងៀម
- ត្រូវជួយរៀបចំទឹក ម្ហូប ជម្រក និងអនាម័យផ្សេងៗនៅពេលគ្រូស្នើឱ្យជួយ។

**៤- នីតិវិធីប្រតិបត្តិស្តង់ដាទី៤ ការជួបជុំ និងជ្រកខាងក្នុងអគារ ឬបន្ទប់**

នីតិវិធីប្រតិបត្តិស្តង់ដាទី៤ ការជួបជុំនិងជ្រកខាងក្នុងអគារឬបន្ទប់ គឺធ្វើឡើងដើម្បីការពារសិស្ស មន្ត្រីអប់រំ ក្នុងករណីអគ្គីភ័យឬមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្រៅបន្ទប់ ដូចជា ទឹកជំនន់ អគ្គីភ័យ អាកាសធាតុអាក្រក់ដើម្បីធានាសុវត្ថិភាពរបស់ពួកគេរហូតអាចត្រឡប់ទៅជួបជុំគ្រួសាររបស់ពួកគេវិញ។ ការជួបជុំ និងជ្រកខាងក្នុងអគារ ឬបន្ទប់ត្រូវបានអនុវត្តនៅពេលណាដែលការជម្លៀសមិនចាំបាច់ ឬមិនទាន់ដល់ពេលត្រូវជម្លៀស។ ករណីនេះ ធ្វើឡើងដោយប្រកាសឱ្យនៅក្នុងបន្ទប់អគារ ឬឱ្យត្រឡប់ចូលក្នុងអគារ។ ត្រូវមើលរាល់ការទាក់ទងទាំងអស់ និងផ្តល់ការណែនាំផ្សេងៗតាមចាំបាច់។ នីតិវិធីនេះត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

លោកគ្រូអ្នកគ្រូត្រូវ៖

- រំឮកសិស្សពីគោលការណ៍ជម្លៀសសុវត្ថិភាព កុំរត់ កុំនិយាយ កុំរុញ កុំត្រឡប់ក្រោយ (សិស្សគួរជម្លៀសជាគូ)
- បិទទ្វារ និងបង្អួចបើចាំបាច់
- កត់ត្រាវត្តមានសិស្ស
- ត្រួតពិនិត្យមើលស្ថានការណ៍ និងផ្តល់ព័ត៌មានផ្សេងៗនៅពេលមានបញ្ហា។ ត្រូវនៅឱ្យជាប់ទូរស័ព្ទដើម្បីទាក់ទងផ្សេងៗ
- មើលថែទាំសិស្សក្នុងថ្នាក់ ដោយឱ្យសិស្សរៀន លេងខ្លះ ហូប សម្រាក ដើម្បីកុំឱ្យពួកគេមានអារម្មណ៍តក់ស្លុត (បត់បែនជាក់ស្តែង)
- រៀបចំកន្លែងបត់ជើង បត់ជើងបណ្តោះអាសន្ន (ដូចជាប្រើថង់ឬធុង)។
- សិស្សត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍
- ចូលរួមនិងជួយការងារផ្សេងៗតាមដែលអាចជួយបាន
- បត់បែនសកម្មភាពតាមការកំណត់របស់សាលារៀន។

**៥- នីតិវិធីប្រតិបត្តិស្តង់ដាទី៥ ការឃាំងឬហាមការចូលដោយហិង្សា**

នីតិវិធីប្រតិបត្តិស្តង់ដាទី៥ការឃាំងឬហាមការចូលដោយហិង្សា គឺធ្វើឡើងដើម្បីការពារសិស្ស មន្ត្រីអប់រំ ពីការរំលោភបំពាន ឬការគំរាមកំហែងនៃអំពើហឹង្សា។ នីតិវិធីនេះ អនុវត្តតាមការប្រកាសអាសន្នចាប់ផ្តើមដូចជាមានការឃោឃាំង ឬមិនអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ច ឬតួនាទីក្នុងការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាSOP ចូលក្នុងបរិវេណហាមឃាត់ មានន័យថា ជាការមិនឱ្យចូលក្នុងអគារដោយហិង្សា។ យើងត្រូវត្រួតពិនិត្យមើល

ស្ថានការណ៍ និងវាយតម្លៃឡើងវិញពីស្ថានភាពនោះ។ ត្រូវត្រៀមខ្លួនរួចជាស្រេចក្នុងការទាក់ទងទៅប៉ូលីស និងអាជ្ញាធរពាក់ព័ន្ធ។ ក្រោយពីព្រឹត្តិការណ៍នេះ រួចហើយ ត្រូវជូនដំណឹងដល់សិស្ស និងអាណាព្យាបាល ក្នុងការឆ្លុះបញ្ចាំងនិងពិភាក្សា។ នីតិវិធីនេះ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម

លោកគ្រូអ្នកគ្រូត្រូវ៖

- ប្រាប់ដល់សិស្សផ្សេងៗទៀតឱ្យរកកន្លែងជ្រក
- ប្រមូលសិស្សឱ្យស្ថិតនៅកន្លែងសុវត្ថិភាពឆ្ងាយពីការគំរាមកំហែង
- បិទ និងចាក់សោទ្វារ ហើយរុញគ្រឿងសង្ហារិមផ្សេងៗទប់ទល់នឹងការគម្រាមកំហែងនោះ
- ឱ្យសិស្សគ្រប់គ្នាឱនចុះនិងយកដៃគ្របក្បាលនៅពីក្រោមគ្រឿងសង្ហារិមទាំងនោះ ហើយធ្វើខ្លួនឱ្យបានតូចតាមដែលអាចធ្វើបាន
- បិទភ្លើង បិទសំឡេងវិទ្យុ និងសំឡេងទូរស័ព្ទពេទ៍
- នៅឱ្យបានឆ្ងាយពីការមើលឃើញតាមបង្អួច និងទ្វារ
- ប្រាប់សិស្សគ្រប់គ្នាត្រូវនៅឱ្យស្ងៀមស្ងាត់។

សិស្សត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍៖

- នៅស្ងៀមស្ងាត់ និងស្ដាប់ការណែនាំរបស់គ្រូ
- ពិនិត្យមើលការប្រែប្រួលរបស់សាលារៀន។

**៦- នីតិវិធីប្រតិបត្តិស្តង់ដាទី៦ ការវិលទៅជួបក្រុមគ្រួសារវិញដោយសុវត្ថិភាព**

នីតិវិធីប្រតិបត្តិស្តង់ដាទី៦ ការវិលទៅជួបក្រុមគ្រួសារវិញដោយសុវត្ថិភាព គឺធ្វើឡើងដើម្បីការពារសិស្ស មន្ត្រីអប់រំហើយធានាថាក្រុមគ្រួសារពួកគេជួបគ្នាវិញដោយសុវត្ថិភាព។ កុមារមានអាយុក្រោម១៦ឆ្នាំ ប្រសិនមិនមានការអនុញ្ញាតពីអាណាព្យាបាល គឺមិនឱ្យចេញទៅផ្ទះដោយខ្លួនឯងឡើយ។ ក្នុងការមកទទួលយកសិស្សចេញពីសាលានៅពេលមានអាសន្ន អាណាព្យាបាលត្រូវផ្តល់ព័ត៌មាន ឬទំនាក់ទំនងដល់សាលារៀន។ នៅពេលមានអាសន្ន សិស្សនឹងត្រូវអនុញ្ញាតឱ្យចេញទៅជាមួយបុគ្គលណាដែលអាណាព្យាបាលអនុញ្ញាត ហើយមានឈ្មោះក្នុងបញ្ជីតែប៉ុណ្ណោះ។ នីតិវិធីនេះត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

លោកគ្រូអ្នកគ្រូត្រូវ

- ត្រូវធានាថា សិស្ស និងអាណាព្យាបាលបានស្គាល់គ្នាត្រឹមត្រូវ
- ផ្ទៀងផ្ទាត់ប័ណ្ណសម្គាល់ និងធានាថាបុគ្គលនោះមានក្នុងបញ្ជីអនុញ្ញាតពីអាណាព្យាបាលឱ្យមកយកសិស្សបាន
- ធ្វើកំណត់ត្រាផ្សេងៗ
- សិស្សត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍
- ត្រូវស្គាល់អាណាព្យាបាលឱ្យច្បាស់

- អនុវត្តនីតិវិធីជួបជុំគ្រួសារ។

**សម្គាល់ បញ្ជីត្រួតពិនិត្យមើលការខារត្រៀមបម្រុងទុកនៅពេលមានអាសន្ន ៖**

ការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា SOP ត្រូវមានបញ្ជីត្រៀមបម្រុងទុកនៅពេលមានអាសន្ន ដូចជា

- ប្រអប់សម្រាប់ទុកសម្ភារៈនៅការិយាល័យរដ្ឋបាលរបស់សាលា (តារាង)
- ប្រអប់ឬកេសសម្រាប់ទុកសម្ភារៈសង្គ្រោះបឋម (តារាង)
- ប្រអប់ឬកញ្ចប់សម្ភារៈប្រចាំថ្នាក់ ឬកញ្ចប់សម្រាប់ប្រើនៅពេលមិនមានការជម្លៀសទីខាងក្រៅបន្ទប់សម្រាប់ថ្នាក់នីមួយៗ (តារាង)
- ការគៀបក្រដាសសរសេរ ឬសៀវភៅកត់ត្រាប្រចាំថ្នាក់ពេលមានអាសន្ន (តារាង)
- កាបូបផាសុកភាពរបស់សិស្ស (ផ្គត់ផ្គង់ដោយគ្រួសារ) (តារាង)។

**ខ- ការណែនាំពីដំណើរការធ្វើលំហាត់សមយុទ្ធតាមសាលារៀន**

មុនពេលធ្វើលំហាត់សមយុទ្ធតើត្រូវមានការណែនាំឱ្យប្រព្រឹត្តទៅដូចម្តេចខ្លះ?

ការណែនាំពីដំណើរការធ្វើលំហាត់សមយុទ្ធតាមសាលារៀន ត្រូវប្រព្រឹត្តដូចខាងក្រោម ៖

១- ប្រជុំក្រុមការងាររៀបចំនិងបែងចែកភារកិច្ចការងារ

២- កំណត់សញ្ញាជូនដំណឹងជាមុន ឬប្រកាសអាសន្ន

៣- ការឆ្លើយតប ឬជម្លៀសចេញពីកន្លែងគ្រោះថ្នាក់

៤- ការជួបជុំនៅកន្លែងដែលបានកំណត់ទុក

៥- រាប់ចំនួនសិស្ស និងផ្ទៀងផ្ទាត់

៦- រៀនសូត្រ និងឆ្លុះបញ្ចាំង។

**គ- ការសរសេរសេណារីយ៉ូសម្រាប់អនុវត្តលំហាត់សមយុទ្ធ**

យោងតាមប្រវត្តិគ្រោះមហន្តរាយនៅកម្ពុជាដែលកើតមានជាញឹកញាប់ គឺគ្រោះទឹកជំនន់ ខ្យល់ខ្លាំង និងគ្រោះរាំងស្ងួត។ ដូចនេះ ការសរសេរសេណារីយ៉ូ សម្រាប់អនុវត្តលំហាត់សមយុទ្ធកម្រិតសាលារៀន ត្រូវបង្កើតឡើង ដោយផ្អែកទៅលើសកម្មភាព ត្រៀមរៀបចំជាមុន និងមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ ក្រោមការដឹកនាំសម្របសម្រួលពីគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន។ អ្នកពាក់ព័ន្ធទាំងនេះ រួមមានក្រុមការងារសាលារៀនសុវត្ថិភាពដែលបង្កើតឡើងនៅក្នុងយន្តការគ្រប់គ្រងគ្រោះមហន្តរាយកម្រិតសាលារៀនទាំង៥ក្រុម ដូចមានបង្ហាញក្នុងមេរៀនមុន រួមអ្នកពាក់ព័ន្ធដ៏ទៃទៀត ដូចជា តំណាងអាជ្ញាធរដែនដី តំណាងសហគមន៍ និងអង្គការដៃគូ។

ដំណើរការនៃការសរសេរ សេណារីយ៉ូ សម្រាប់អនុវត្តលំហាត់សមយុទ្ធ ជាទូទៅរួមមាន៖

- ប្រជុំគណៈកម្មការរៀបចំធ្វើលំហាត់សមយុទ្ធយ៉ាងហោចណាស់២ដងក្នុងមួយឆ្នាំ(ដើមឆ្នាំ និងចុងឆ្នាំសិក្សា)

- កំណត់យកប្រធានបទមួយដែលសាលាជួបប្រទះញឹកញាប់ ដូចជា «ខ្យល់ខ្លាំង ទឹកជំនន់ អគ្គីភ័យ» ធ្វើលំហាត់សមយុទ្ធ
- ប្រើប្រាស់ផែនទីមុខសញ្ញាគ្រោះថ្នាក់នៅពេលជម្លៀស(ដែលបានសិក្សាមេរៀនមុនរួច)
- កំណត់ទីតាំង ផែនទីជម្លៀសដែលបានសិក្សាក្នុងមេរៀនមុន(ក្នុងថ្នាក់ ក្រៅថ្នាក់ ក្នុងសហគមន៍)
- ប្រើប្រាស់គណៈកម្មការទទួលបន្ទុកភារកិច្ចការងារសាលារៀនសុវត្ថិភាពទាំង៥ក្រុម ក្នុងយន្តការមានស្រាប់គឺ៖
  - ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន
  - ក្រុមជម្លៀស (សម្រាប់អនុវត្ត ជាមួយសិស្សថ្នាក់ទី៣ដល់ថ្នាក់ទី៦)
  - ក្រុមរុករក និងសង្គ្រោះ
  - ក្រុមសង្គ្រោះបឋម
  - ក្រុមសន្តិសុខ
- កំណត់សកម្មភាពនៃសេណារីយ៉ូ សម្រាប់អនុវត្ត

  ឧទាហរណ៍ សេណារីយ៉ូអំពី «ខ្យល់ខ្លាំង»
  - ម៉ោង៨:៣០នាទីសិស្សក្រុមជម្លៀស កំពុងចេញលេងពេញធ្លាសាលារៀន(សិស្សខ្លះនៅបន្ទប់ទឹក ខ្លះនៅក្រោមដើមឈើ ខ្លះទៀតលេងរត់ លេងលោតកៅស៊ូ ខ្លះញុំានំ)
  - ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន មានកុមារ៣នាក់(ស្រី១ ប្រុស២) ឈរជុំគ្នាក្បែរជួង កុមារាវាយជួងរោទិ៍រន្ទើនញាប់ខ្លាំងចំនួន៣ដង។ បន្ទាប់មកកុមារី ដៃកាន់មេក្រូ ស្រែកប្រកាសថា « មិត្តភក្តិទាំងអស់គ្នា ចូរប្រុងប្រយ័ត្ន ព្រោះយើងបានទទួលដំណឹងតាមទូស័ព្ទមកថា ភូមិយើង សាលាយើងនឹងត្រូវប្រឈមមុខខ្យល់ខ្លាំង។ ពេលនេះ អ្នកទាំងអស់គ្នាត្រូវចូលទីសុវត្ថិភាពតាមទីកន្លែងដែលបានកំណត់សុវត្ថិភាពពីខ្យល់ខ្លាំង។» ពួកគេទាំង៣នាក់រត់ជុំវិញបរិវេណអគារសាលាបណ្តើរ ស្រែកបណ្តើរដោយផ្លាស់វេនគ្នាស្រែកប្រកាស ចំនួន៣ជុំ។
  - សិស្សជម្លៀស នាំគ្នាដើរលឿនដោយដៃលើកបាំងក្បាលហើយតម្រង់ចូលទៅថ្នាក់រៀនដែលជាអគារធន់នឹងខ្យល់ខ្លាំងនិងបានកំណត់ទុកក្នុងផែនទីជម្លៀស
    - ក្នុងថ្នាក់នីមួយៗមានគ្រូប្រចាំ និងសិស្សក្រុមជម្លៀសដែលទទួលបន្ទុកតាមថ្នាក់(ទី៣ ទី៤ ទី៥ ទី៦)និងមានទឹកស្អាតសម្រាប់បង្ការសិស្សស្រេក
    - សិស្សជម្លៀសគ្រប់គ្នាចូលអង្គុយក្រោមតុ ដៃលើកបាំងក្បាល ទឹកមុខភ័យខ្លាច រីឯគ្រូនិងសិស្សទទួលបន្ទុកដើរបិទបង្អួច ទ្វារថ្នាក់ឱ្យបានលឿនរហ័ស។ បន្ទាប់មកគ្រូ ឬសិស្សច្បងទទួលបន្ទុកថ្នាក់ រាប់ចំនួនសិស្សវត្តមាន និងអវត្តមាន។

- ក្រុមសន្តិសុខ លើកម្ជុកសុវត្ថិភាពពាក់ រួចដើរសំដៅថ្នាក់ជម្លៀស ហើយសាកសួរអវត្តមានតាមថ្នាក់នីមួយៗដោយរហ័សនិងប្រុងប្រយ័ត្ន
- អ្នកទទួលបន្ទុកតាមថ្នាក់ជម្លៀស បានប្រាប់ថា
  - បន្ទប់ទី១ បាត់កុមារា១នាក់
  - បន្ទប់ទី៣ បាត់កុមារី១នាក់
- ក្រុមសន្តិសុខ យកព័ត៌មានបាត់សិស្ស មកប្រាប់ក្រុមសង្គ្រោះនិងរុករកជាបន្ទាន់នៅទីចាត់ការ។
- ក្រុមរុករក និងសង្គ្រោះ មានកុមារា ៤នាក់ ឈរនៅមុខទីចាត់ការសាលា។ ពេលទទួលបានដំណឹងថាមានបាត់សិស្ស ពួកគេលើកម្ជុកសុវត្ថិភាពពាក់។ កុមារ២នាក់ដៃកាន់ប្រង់ការឬសម្ភារៈសែងអ្នករបួស ដើរយ៉ាងលឿនតម្រង់បន្ទប់ទឹក។ ឯកុមារ២នាក់ទៀតដើរលឿនទៅពិនិត្យក្រោមដើមឈើក្រោយសាលា។ ពួកគេបានរកឃើញ៖
  - កុមារាមួយនាក់ដួលគ្រេចជើងជិតគល់ស្វាយ ហើយក៏បានលើកគ្រាដាក់លើប្រង់ការដើរសំដៅមកបន្ទប់សង្គ្រោះបឋម។
  - កុមារីមួយនាក់ទៀតដួលដើបមិនរួចនៅជិតបន្ទប់ទឹកព្រោះភ័យ ហើយបានលើកនាងដាក់លើប្រង់ការរួចសែងដើរលឿនសំដៅមកបន្ទប់សង្គ្រោះបឋមដែរ។
- ក្រុមសង្គ្រោះបឋម នៅក្នុងបន្ទប់មួយមានសុវត្ថិភាព មានគ្រែសម្រាប់ទទួលកុមារជួបគ្រោះថ្នាក់មានសម្ភារៈសង្គ្រោះបឋម ពួកគេអនុវត្តការសង្គ្រោះកុមារ ដោយ
  - ធ្វើចលនាសង្គ្រោះអ្នកភ័យដួល តាមជំនាញសង្គ្រោះបឋម ដើម្បីឱ្យដកដង្ហើមបានស្រួល
  - និងលាបប្រេងខ្យល់ រួចរុំរបួសឱ្យជើងគ្រេច។
  - ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន ចាប់ផ្ដើមប្រកាសម្ដងទៀតថា « មិត្តភក្តិទាំងអស់គ្នា នៅខាងក្រៅខ្យល់បានស្ងប់ហើយ យើងមានសុវត្ថិភាពហើយ មិត្តទាំងអស់គ្នាអាចចេញមកក្រៅបាន»
  - ក្រុមជម្លៀស បើកទ្វារបន្ទប់និងបង្អួច រួចដើរចេញមកបរិវេណសាលារៀន

សម្គាល់ អនុញ្ញាតឱ្យសិស្សអ្នកចូលរួមទាំងអស់សម្រាក(ញ៉ាំ ផឹក) រួចឱ្យទៅផ្ទះដោយអនុវត្តតាមនីតិវិធីប្រតិបត្តិស្តង់ដាទី៦ ការវិលទៅជួបក្រុមគ្រួសារវិញដោយសុវត្ថិភាព និងត្រូវប្រាកដថា ទៅផ្ទះប្រកបដោយសុវត្ថិភាព (មានអ្នកមកទទួល)។

**ឃ- ការអនុវត្តលំហាត់សមយុទ្ធតាមសាលារៀន**

ការអនុវត្តលំហាត់សមយុទ្ធតាមសាលារៀន គឺជាកិច្ចការដែលត្រៀមរៀបចំតាមលំដាប់សកម្មភាពការងារដូចជា ពេលអនុវត្តលំហាត់ត្រូវមាន ការប្រជុំក្រុមការងាររៀបចំលំហាត់សមយុទ្ធនិងបែងចែកភារកិច្ចការងារ ដោយមាន៖

- កំណត់សញ្ញាជូនដំណឹង ពេលប្រកាសអាសន្ន
- ក្រុមឆ្លើយតប ឬជម្លៀសចេញពីកន្លែងគ្រោះថ្នាក់
- ការរៀបចំជួបជុំក្រុមជម្លៀសទៅកន្លែងសុវត្ថិភាព និងរាប់ចំនួនសិស្ស ផ្ទៀងផ្ទាត់វត្តមានសិស្ស
- ក្រុមរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរក្សាសុខភាព។

**ខ- ការឆ្លុះបញ្ចាំងពីការអនុវត្តក្រោយពេលអនុវត្តលំហាត់សមយុទ្ធ**

បន្ទាប់ពីលំហាត់សមយុទ្ធ នាយកសាលាត្រូវប្រជុំឆ្លុះបញ្ចាំង ជាមួយគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន ដើម្បីកំណត់ពីបញ្ហាក្នុងពេលអនុវត្ត ក្នុងការកែលម្អ ហើយវាគួរតែរៀបចំរៀងរាល់ត្រីមាស។

- ជួបប្រជុំអ្នកចូលរួម(អ្នកទទួលបន្ទុកក្នុងគណៈកម្មការទាំង៦និងអ្នកតាមដានត្រួតពិនិត្យ)
- នាយកសាលា ឬអ្នកទទួលបន្ទុកដឹកនាំសមយុទ្ធ ជាប្រធានអង្គប្រជុំ តាមរយៈសំណួរ

  ១- តើក្រុមទាំង៥ ដែលបានអនុវត្តលំហាត់សមយុទ្ធ មានគុណសម្បត្តិអ្វីខ្លះ ?

  ២- តើការអនុវត្តលំហាត់សមយុទ្ធ មានចំណុចខ្វះខាតអ្វីខ្លះ ?

  ៣- តើយើងគួរកែលម្អសកម្មភាពលំហាត់សមយុទ្ធដូចម្តេចបន្តទៀត ?

សម្គាល់ មុនពេលលំហាត់សមយុទ្ធ យើងក៏គួរប្រាប់ពីការរៀបចំនេះដល់សហគមន៍ក្បែរៗឱ្យដឹង ដើម្បីកុំឱ្យមានភាពចលាចលផ្សេងៗដែលមិនរំពឹងទុក។

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាSOPឆ្លើយតបគ្រោះអាសន្ននៅក្នុងសាលារៀន ដូចជាខ្យល់ខ្លាំង និងទឹកជំនន់មានសារៈសំខាន់បំផុត ចំពោះសាលារៀន ដែលប្រឈមនឹងគ្រោះអាសន្នញឹកញាប់។ ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដាSOPនេះបង្ហាញពី ការលើកកម្ពស់សុវត្ថិភាព និងការការពារកុមារចៀសផុតពីគ្រោះមហន្តរាយ ដែលអាចកើតមានឡើងក្នុងសាលារៀន។ ពិសេស ការណែនាំពីដំណើរការនីតិវិធីប្រតិបត្តិស្តង់ដាSOP ដើម្បីឆ្លើយតបមុខសញ្ញាគ្រោះថ្នាក់នានា ការរៀបចំសេណារីយ៉ូសម្រាប់អនុវត្ត និងការឆ្លុះបញ្ចាំង និងបទពិសោធពីការអនុវត្តលំហាត់សមយុទ្ធ។

ដើម្បីធានាថា រាល់សកម្មភាពទាំងអស់ស្របនឹងអនុលោមតាមបទបញ្ញត្តិសាលារៀនសុវត្ថិភាព សាលារៀនទាំងអស់ ត្រូវអនុវត្តតាមគោលការណ៍ប្រតិបត្តិស្តង់ដា SOP ជាចម្បង។

**២- ៥ ឯកសារសិក្សាបន្ថែម**

- ក្រសួងអប់រំ យុវជន និងកីឡា (2023) កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារៈ *ក្របខណ្ឌសាលារៀនសុវត្ថិភាព។*

**២-៦ ការអនុវត្ត**

ចូរសរសេរសេណារីយ៉ូ ដែលត្រូវអនុវត្តលំហាត់សមយុទ្ធនៅសាលារៀនរបស់អ្នក។

**សំណួរ**

១- តើSOPជាអ្វី? ហើយប្រព្រឹត្តទៅដូចម្តេច?

២- តើសាលារៀនរបស់លោកអ្នក អាចធ្វើលំហាត់សមយុទ្ធមួយឆ្នាំប៉ុន្មានដង?

៣- ចូរជ្រើសរើសមុខសញ្ញាគ្រោះថ្នាក់ចំនួនមួយ( ទឹកជំនន់ ខ្យល់ខ្លាំង ឬអគ្គីភ័យ )និងបង្កើតសេណារីយ៉ូសម្រាប់អនុវត្តលំហាត់សមយុទ្ធនៅតាមសាលារៀននីមួយៗ។

៤- តើការអនុវត្តលំហាត់សមយុទ្ធ មានសារៈសំខាន់អ្វីខ្លះចំពោះសាលារៀន?

# មេរៀនទី៤៖ លំហាត់សមយុទ្ធ

## ១- វត្ថុបំណង

- ប្រាប់បានពីការណែនាំនីតិវិធីប្រតិបត្តិស្តង់ដា (SOP) និងគោលការណ៍សាលារៀនសុវត្ថិភាពនៃជំហានសំខាន់ៗសម្រាប់ត្រៀម និងការណែនាំអនុវត្តលំហាត់សមយុទ្ធ ឆ្លើយតបគ្រោះអាសន្នកម្រិតសាលារៀន
- ហ្វឹកហាត់និងអនុវត្តជាក់ស្តែងលំហាត់សមយុទ្ធ តាមសេណារីយ៉ូ ដែលបានរៀបចំរួច ដើម្បីឆ្លើយតបគ្រោះអាសន្ន ដោយបានត្រៀមទុកជាមុនៗគ្រោះមហន្តរាយមកដល់និងឆ្លុះបញ្ចាំងដើម្បីដកស្រង់បទពិសោធនៃការអនុវត្តលំហាត់សមយុទ្ធ
- បណ្តុះទម្លាប់ឱ្យមានការហ្វឹកហាត់និងធ្វើលំហាត់សមយុទ្ធជាប្រចាំនៅតាមសាលារៀន និងបង្កើនស្មារតីប្រុងប្រយ័ត្ន ក្នុងការការពារខ្លួន ចៀសវាសគ្រោះថ្នាក់ បង្កដោយគ្រោះមហន្តរាយផ្សេងៗ ដើម្បីធានាសុវត្ថិភាព ទាំងក្នុងសាលារៀន និងការរស់នៅក្នុងជីវភាពជាក់ស្តែង ក្នុងសហគមន៍បានកាន់តែប្រសើរឡើង។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

មេរៀននេះ មានគោលបំណងសំខាន់ ចង់ឱ្យសាលារៀននីមួយៗ ពិសេស ក្រុមការងារសាលារៀនសុវត្ថិភាព និងអ្នកពាក់ព័ន្ធដែលមានក្នុងរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ តាមសាលាដែលប្រឈមនឹងគ្រោះមហន្តរាយ មានការដឹកនាំសិស្ស ហ្វឹកហាត់និងអនុវត្ត លំហាត់សមយុទ្ធ ឱ្យបានទៀងទាត់ យ៉ាងហោចណាស់១ឆ្នាំ២ដង ដើម្បីបណ្តុះទម្លាប់សិស្សឱ្យមានបំណិន និងត្រៀមខ្លួនជាស្រេចមុនគ្រោះមហន្តរាយកើតឡើង។

នៅមេរៀនមុនបានបង្ហាញរួចមកហើយ អំពីការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដា SOP ឆ្លើយតបគ្រោះអាសន្ន នៅក្នុងសាលារៀន ដូចជាខ្យល់ព្យុះ និងទឹកជំនន់ជាដើម។ ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដា SOP នេះ មានចំណុចសំខាន់ៗមួយចំនួនដូចជា ការណែនាំអំពីនីតិវិធីប្រតិបត្តិស្តង់ដា SOP ឆ្លើយតបគ្រោះអាសន្ន ការណែនាំពីដំណើរការធ្វើលំហាត់សមយុទ្ធ ការរៀបចំសេណារីយូ សម្រាប់អនុវត្តលំហាត់សមយុទ្ធ ណែនាំធ្វើលំហាត់អនុវត្ត និងវិធីឆ្លុះបញ្ចាំងការអនុវត្តលំហាត់សមយុទ្ធ ក្រោយធ្វើសមយុទ្ធរួច។

ក្នុងមេរៀននេះនឹងសិក្សាបន្តអំពីលំណែនាំ និងដំណើរការធ្វើលំហាត់សមយុទ្ធ និងលំហាត់សមយុទ្ធ ។ ដូច្នេះ លោកគ្រូ អ្នកគ្រូ ត្រូវពិនិត្យឡើងវិញទៅលើមានតួនាទីសំខាន់ក្នុងយន្តការឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយតាមសាលានីមួយៗដែលបានរៀបចំរួច ដើម្បីធ្វើការណែនាំ សម្របសម្រួលសិស្សក្នុងការហ្វឹកហាត់ ព្រមទាំងការធ្វើលំហាត់សមយុទ្ធអនុវត្តជាក់ស្តែង ដោយប្រើប្រាស់យន្តការឬរចនាសម្ព័ន្ធក្រុមការងារ

ឆ្លើយតបគ្រោះមហន្តរាយទាំង៥ក្រុម និងផែនទីជម្លៀស ដែលបានសិក្សានិងរៀបចំនៅតាមសាលារៀននីមួយៗ ព្រមទាំងគោរពតាមតួនាទីក្រុមបានត្រឹមត្រូវ ដើម្បីបណ្តុះទម្លាប់សិស្សឱ្យមានបំណិនការពារខ្លួនជាប្រចាំ ហើយពេលជួបគ្រោះអាសន្ន សិស្សអាចការពារសុវត្ថិភាពផ្ទាល់ខ្លួនបានដោយសុវត្ថិភាព។

**២- ២ ពាក្យគន្លឹះ**

- ***សេណារីយ៉ូ*** គឺជាការរៀបចំនិងណែនាំអំពីរបៀបឬដំណើរការនៃការអនុវត្តធ្វីមួយ ឧទាហរណ៍ «លំហាត់សមយុទ្ធ» ទៅតាមនីតិវិធីប្រតិបត្តិស្តង់ដា (SOP) និងគោលការណ៍សាលារៀនសុវត្ថិភាព ជាជំហានៗច្បាស់លាស់។

**២- ៣ ខ្លឹមសារមេរៀន**

***ក- ការណែនាំពីការធ្វើសមយុទ្ធឆ្លើយតបគ្រោះមហន្តរាយ***

ការធ្វើសមយុទ្ធឆ្លើយតបគ្រោះមហន្តរាយ តម្រូវឱ្យក្រុមនីមួយៗត្រូវស្វែងយល់អំពីតួនាទីនិងភារកិច្ចរបស់ខ្លួននិងត្រៀមរៀបចំសម្ភារៈរួចជាស្រេច ដើម្បីប្រើប្រាស់ក្នុងករណីចាំបាច់ មួយចំនួន ដូចជា មេក្រូ កញ្ចែ ស៊ីរ៉ែន មួកសុវត្ថិភាព ប្រង់កាឬកំណាត់ធ្វើប្រង់កា ឈើស្នែង ផែនទីជម្លៀស ។ល។សម្រាប់ដំណើរការ នៅពេលមានគ្រាអាសន្នកើតឡើង។ គ្រូបង្រៀនដែលជាប្រធានក្រុមតូចៗ ក្នុងយន្តការឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយទាំង៥ក្រុម នៅតាមសាលារៀននីមួយៗ ត្រូវពង្រឹងសមត្ថភាពសមាជិករបស់ខ្លួន និងហ្វឹកហាត់ឱ្យបានទៀងទាត់ មុនពេលធ្វើសមយុទ្ធជាក់ស្តែង។ បន្ទាប់មក ក្រុមត្រៀមបម្រុងឆ្លើយតប ត្រូវធ្វើការផ្សព្វផ្សាយអំពីរបៀបឬដំណើរការនៃការធ្វើសមយុទ្ធដល់សិស្សានិសិស្សនិងអ្នកពាក់ព័ន្ធទាំងអស់ឱ្យបានដឹងមុននិងចូលរួមអនុវត្តទាំងអស់គ្នា។

ដូច្នេះ ដើម្បីយល់កាន់តែច្បាស់អំពីការធ្វើសមយុទ្ធ មេរៀននេះ នឹងបង្ហាញអំពីដំណើរការធ្វើសមយុទ្ធឆ្លើយតបនឹងខ្យល់ព្យុះជាឧទាហរណ៍ ដែលមានការចូលរួមអនុវត្ត ដោយក្រុមត្រៀមបម្រុងឆ្លើយតប ដូចខាងក្រោម៖

១- នៅពេលដែលមានមេឃងងឹតនិងខ្យល់ខ្លាំងបម្រុងនឹងភ្លៀង ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន(ក្រុមទី១) ត្រូវធ្វើការផ្សព្វផ្សាយឬប្រកាសអាសន្នឱ្យសិស្សានុសិស្សដែលនៅខាងក្នុងថ្នាក់ដឹងអំពីព័ត៌មាននេះនិងឱ្យពួកគាត់រត់រកកន្លែងដែលមានសុវត្ថិភាពដែលបានកំណត់ទុកជាស្រេច

២- ក្នុងពេលប្រកាសអាសន្ននេះដែរ ក្រុមជម្លៀស(ក្រុមទី២) ត្រូវចេញ ប្រតិបត្តិការ ការងាររបស់គេដោយធ្វើការណែនាំប្រាប់និងប្រមូលសិស្សានុសិស្សដែលមានក្នុងថ្នាក់សរុបនិងអ្នកដែលបាត់ខ្លួនដើម្បីរាយការណ៍ដល់ក្រុមប្រកាសអាសន្ននិងផ្សព្វផ្សាយព័ត៌មាន

៣- ក្រុមផ្សព្វផ្សាយព័ត៌មាន ត្រូវបន្តផ្តល់ដំណឹង ដល់ក្រុមរុករកនិងសង្គ្រោះ(ក្រុមទី៣) ដើម្បីធ្វើការស្វែងរកអ្នកដែលបាត់ខ្លួនឬរងរបួស តាមរយៈការត្រួតពិនិត្យមើលសិស្សដែលបាត់ខ្លួននៅក្នុងបរិវេណសាលារៀន ហើយបញ្ជូនអ្នកដែលបាត់ខ្លួនឬរបួសនោះមកកន្លែងសុវត្ថិភាពដោយប្រើប្រាស់មធ្យោបាយ ផ្សេងៗ ដូចជា ការសែង អៀវ ឬបីជាដើម ឱ្យស្របតាមស្ថានភាពជាក់ស្តែងរបស់អ្នករបួស

៤- បន្ទាប់មក ក្រុមសង្គ្រោះបឋម(ក្រុមទី៤) ត្រូវត្រៀមសម្ភារៈឱ្យបានរួចជាស្រេច ដើម្បីផ្តល់ការជួយសង្គ្រោះ បឋមដល់អ្នករងរបួសស្រាលៗនិងទាក់ទងរថយន្តពេទ្យ ឬបញ្ជូនអ្នករងរបួសទៅមណ្ឌលសុខភាព ហើយផ្តល់ដំណឹងដល់មាតាបិតាអាណាព្យាបាលរបស់សិស្សដែលរងរបួសឱ្យបានដឹង

៥- ចំណែកក្រុមសន្តិសុខ(ក្រុមទី៥) ត្រូវរក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់ ក្នុងអំឡុងពេលមានគ្រោះអាសន្ននិងគ្រោះមហន្តរាយ ដើម្បីការពារកុំឱ្យ មានអ្នកក្រៅចូលក្នុងបរិវេណសាលា មានការបាត់បង់ទ្រព្យសម្បត្តិឬសម្ភារៈផ្សេងៗដែលបណ្តាលមកពីជនឆ្លៀតឱកាសជាដើម។

**ខ- ការជូនដំណឹងដល់ឪពុកម្តាយនិងស្ថាប័នពាក់ព័ន្ធក្នុងអំឡុងពេលគ្រោះមហន្តរាយ**

សាលារៀន ត្រូវរៀបចំបង្កើតជាទិន្នន័យសិស្សដោយមានព័ត៌មានសំខាន់ៗ ដូចជា អាសយដ្ឋានទំនាក់ទំនងនិងលេខទូរស័ព្ទ ហើយរក្សាទុកឱ្យបានត្រឹមត្រូវនៅពេលចាប់ផ្តើមដំណើរការឆ្នាំសិក្សាថ្មី។ លើសពីនេះទៀត ព័ត៌មានពីអាជ្ញាធរមូលដ្ឋាន មណ្ឌលសុខភាព រថយន្តពន្លត់អគ្គីភ័យ។ល។ក៏ត្រូវប្រមូលនិងរក្សាទុកឱ្យបានត្រឹមត្រូវហើយព័ត៌មានទាំងនេះ ក៏ត្រូវបិទផ្សាយនៅតាមក្តារខៀនព័ត៌មាន ថ្នាក់រៀន និងកន្លែងចាំបាច់ដទៃទៀត សម្រាប់ប្រើប្រាស់ក្នុងពេលមានគ្រោះមហន្តរាយផ្សេងៗកើតឡើងផងដែរ។

ខាងក្រោមនេះ ជាគំរូតារាង សម្រាប់ស្រង់ព័ត៌មានទំនាក់ទំនងឪពុកម្តាយនិងស្ថាប័នពាក់ព័ន្ធក្នុងអំឡុងពេលគ្រោះមហន្តរាយ។

| ស្ថាប័នពាក់ព័ន្ធ | នាម និងគោត្តនាម | ភេទ | តួនាទី | អាសយដ្ឋាន និងទូរស័ព្ទ |
|---|---|---|---|---|
| អាជ្ញាធរមូលដ្ឋាន | | | | |
| គណៈកម្មការទ្រទ្រង់សាលា | | | | |
| មណ្ឌលសុខភាព | | | | |
| ភ្នាក់ងារពន្លត់អគ្គីភ័យ | | | | |

អំពី "មុខសញ្ញាគ្រោះថ្នាក់ខ្យល់ខ្លាំង" ដែលយើងគ្រប់គ្នា គួរសិក្សាយល់ដឹង

១- តើអ្វីទៅជាខ្យល់ខ្លាំង?

ខ្យល់បក់ខ្លាំងគឺជាកម្លាំងនៃការបំផ្លិចបំផ្លាញ ដោយការបោកបក់ដែលមានទាក់ទងទៅនឹងទឹកភ្លៀង ផ្គរ រន្ទះ ឬព្យុះសង្ឃរា

២- តើវាកើតឡើងនៅពេលណា?

ខ្យល់បក់ខ្លាំង តែងតែកើតឡើង នៅមុនពេល និងក្រោយពេលដែលមានភ្លៀង។ពេលខ្លះវាក៏លើកឡើងនៅពេលដែលមេឃកំពុងភ្លៀងផងដែរ។

៣- តើវាប៉ះពាល់ដល់អ្វីខ្លះ?

ខ្យល់បក់ខ្លាំងបានបណ្តាលឱ្យមានការបាក់ ដួល រលំ ឬខូចខាតដល់ដំបូល សាលារៀន ផ្ទះសម្បែង អគារសិក្សា ដើមឈើឬរុក្ខជាតិ តូចធំជាដើម។ ពេលខ្លះ វាបានធ្វើឱ្យរបួសដល់មនុស្សនិងសត្វ- - - ផងដែរ។

៤- តើយើងអាចដឹងសញ្ញាខ្យល់ខ្លាំងយ៉ាងដូចម្តេច?

សញ្ញាខ្យល់ខ្លាំង អាចឱ្យយើងដឹងបានតាមរយៈ (១)- អារម្មណ៍ៈ ថាមានខ្យល់ត្រជាក់ ឬខ្យល់ខ្លាំងខុសពីធម្មតាកំពុងបោកបក់។ (២)- មើលឃើញខ្យល់ៈ មើលឃើញផ្ទៃមេឃនិងពពកក្រាស់ ផ្លេកបន្ទោរ ស្លឹកនិងដើមឈើត្រូវខ្យល់បោកបក់ខ្លាំង សំរាមនិងធូលី ងោះហើរលើលំហ ។(៣)- ស្តាប់ឮសំឡេងៈ គឺឮសំឡេងខ្លាំងៗលើភ្នំដែលចាស់ៗ ជឿថានឹងមានខ្យល់ខ្លាំងកើតឡើង ឬស្តាប់ឮសំលេងផ្គរ រន្ទះ សំឡេងបោកបក់ខ្លាំង។ល។ ដូច្នេះ យើងត្រូវ (៣)- រត់រកកន្លែងសុវត្ថិភាពៈ ត្រូវប្រញាប់ប្រញាល់រត់រកកន្លែងសុវត្ថិភាពដែលបានកំណត់ទុកជាមុន ដូចជាបន្ទប់រៀន ឬកន្លែងជួបជុំដែលមានការណែនាំពីលោកគ្រូ អ្នកគ្រូ។



**គ- ការកំណត់សកម្មភាពនៃសេណារីយ៉ូសម្រាប់ដំណើរការអនុវត្តលំហាត់សមយុទ្ធ**

ជាទូទៅ មុនចាប់ផ្តើមដំណើរការអនុវត្តលំហាត់សមយុទ្ធ សាលារៀននីមួយៗ គប្បីៈ

១- ប្រជុំគណៈកម្មការរៀបចំធ្វើលំហាត់សមយុទ្ធយ៉ាងហោចណាស់ ២ដងក្នុងមួយឆ្នាំ

២- កំណត់ប្រធានបទមួយដែលសាលាជួបប្រទះញឹកញាប់ ដូចជា «ខ្យល់ខ្លាំង ទឹកជំនន់ អគ្គីភ័យ» ដើម្បីហ្វឹកហាត់ និងធ្វើលំហាត់សមយុទ្ធ

៣- ប្រើប្រាស់ផែនទីមុខសញ្ញាគ្រោះថ្នាក់នៅពេលជម្លៀសឬផែនទីជម្លៀស

៤- កំណត់ទីតាំង /ផែនទីជម្លៀស (ក្នុងថ្នាក់/បន្ទប់រៀន/ ក្រៅថ្នាក់ ឬក្នុងសហគមន៍មានសុវត្ថិភាព) ប្រើប្រាស់គណៈកម្មការទទួលបន្ទុកភារកិច្ចការងារសាលារៀនសុវត្ថិភាពទាំង៥ក្រុម ដែលមានក្នុងយន្តការមានស្រាប់និងអ្នកពាក់ព័ន្ធសំខាន់ៗ ដូចដែលបានសិក្សាហើយក្នុងមេរៀនមុនដូចជា ១- ក្រុមប្រកាសអាសន្ននិងផ្សព្វផ្សាយព័ត៌មាន ២- ក្រុមជម្លៀស (សម្រាប់អនុវត្ត ជាមួយសិស្សថ្នាក់ទី៣ដល់ថ្នាក់ទី៦)៣- ក្រុមរុករកនិងសង្គ្រោះ ៤- ក្រុមសង្គ្រោះបឋម និង ៥- ក្រុមសន្តិសុខ

៥- កំណត់សកម្មភាពនៃសេណារីយ៉ូ សម្រាប់អនុវត្ត

ឧទាហរណ៍ ការកំណត់សកម្មភាពនៃសេណារីយ៉ូអំពី «ខ្យល់ខ្លាំង»

- សិស្ស កំពុងចេញលេងនៅទីធ្លាសាលារៀន
- សិស្សខ្លះនៅបន្ទប់ទឹក ខ្លះនៅក្រោមដើមឈើ ខ្លះទៀតលេងរត់ លេងលោតកៅស៊ូ ខ្លះញុំានំ

ពេលនោះ មានសូរសញ្ញាជួងរោទិ៍រន្ទើនញាប់ខ្លាំងចំនួន៣ដង។ បន្ទាប់មក មានសំឡេងស្រែកប្រកាស៣ដងទៀត របស់កុមារ៣នាក់(ស្រី១ ប្រុស២)ពីក្រុមប្រកាសអាសន្ននិងផ្សព្វផ្សាយព័ត៌មាន ដែលកាន់មេក្រូនិងរត់ជុំវិញបរិវេណសាលា ហើយប្រាប់សិស្សានុសិស្សទាំងអស់ថា « មិត្តភក្តិទាំងអស់គ្នា ចូរប្រុងប្រយ័ត្ន ព្រោះយើងបានទទួលដំណឹងតាមទូរស័ព្ទមកថា ភូមិយើង សាលាយើងនឹងត្រូវប្រឈមមុខខ្យល់កន្ត្រាក់។ ពេលនេះអ្នកទាំងអស់គ្នាត្រូវចូលទីសុវត្ថិភាពតាមទីកន្លែងដែលបានកំណត់សុវត្ថិភាពពីខ្យល់កន្ត្រាក់។»

- សិស្សទាំងអស់ រត់ឱនពីកន្លែងផ្សេងៗ ដោយលើកដៃទូលឬបាំងក្បាលហើយរត់យ៉ាងលឿនតម្រង់ឬសំដៅទៅថ្នាក់រៀនឬកន្លែងសុវត្ថិភាពដែលបានកំណត់ក្នុងផែនទីជម្លៀស(ដែលជាអគារធន់នឹងខ្យល់កន្ត្រាក់)
- ក្នុងថ្នាក់នីមួយៗមានគ្រូប្រចាំ និងសិស្សក្រុមជម្លៀសដែលទទួលបន្ទុកតាមថ្នាក់(ទី៣ ទី៤ ទី៥ ទី៦)និងមានទឹកស្អាតសម្រាប់សិស្ស
- សិស្សជម្លៀសគ្រប់គ្នាចូលអង្គុយក្រោមតុ ដៃលើកបាំងក្បាល មានទឹកមុខភ័យខ្លាច រីឯគ្រូនិងសិស្សទទួលបន្ទុកដើរបិទបង្អួច ទ្វារថ្នាក់ឱ្យបានលឿនរហ័ស។ បន្ទាប់មក គ្រូប្រចាំថ្នាក់ឬសិស្សច្បងទទួលបន្ទុកថ្នាក់ រាប់ចំនួនសិស្សវត្តមាន និងអវត្តមាន។
- ក្រុមសន្តិសុខមានពាក់មួកសុវត្ថិភាព ដើរសួរអវត្តមានតាមថ្នាក់មានសិស្សជម្លៀស។ ឧទាហរណ៍
  - បន្ទប់ទី១ បាត់កុមារា១នាក់
  - បន្ទប់ទី៣ បាត់កុមារី១នាក់
- ក្រុមសន្តិសុខ ប្រាប់ព័ត៌មានទៅក្រុមសង្គ្រោះនិងរុករក
- ក្រុមសង្គ្រោះនិងរុករក៤នាក់បានឈរនៅមុខទីចាត់ការសាលារៀន ពេលទទួលបានដំណឹងថាមានបាត់សិស្ស ពួកគេពាក់មួកសុវត្ថិភាពហើយចូលទៅយកប្រដាប់កាឬសម្ភារៈសែង សំដៅទៅរកអ្នករបួសដែលត្រៀមទុកនៅជិតមាត់ទ្វារ រួចដើរតម្រង់ទៅបន្ទប់ទឹក និងក្រោមដើមឈើក្រោយសាលារៀនដើម្បីរកសិស្សបាត់ខ្លួន
- ក្រុមរុករក និងសង្គ្រោះបានជួប
  - កុមារាមួយនាក់ដួលគ្រេចជើងហើយក៏បានលើកគ្រាឬសែងសំដៅមកបន្ទប់សង្គ្រោះបឋមដែលសាលាបានត្រៀមជាស្រេច
  - កុមារីមួយនាក់ទៀតដួលសន្លប់ នៅជិតបន្ទប់ទឹកព្រោះភ័យពេក

- ក្រុមរុករកនិងសង្គ្រោះបានលើកកុមារីដាក់លើប្រង់កា រួចសែងរត់សំដៅមកបន្ទប់សង្គ្រោះបឋម។
- ក្រុមសង្គ្រោះបឋម នៅក្នុងបន្ទប់មួយមានសុវត្ថិភាព មានគ្រែសម្រាប់ទទួលកុមារដែលជួបគ្រោះថ្នាក់និងមានសម្ភារៈសង្គ្រោះបឋម ហើយពួកគេកំពុងរង់ចាំអនុវត្តការសង្គ្រោះដោយ
  - ធ្វើចលនាសង្គ្រោះអ្នកសន្លប់ និងធ្វើចលនាឱ្យមានខ្យល់ដកដង្ហើមបានស្រួល (អ្នកជំនាញសង្គ្រោះបឋម)
  - រុំរបួស លាបប្រេងខ្យល់ជើង របស់អ្នកគ្រេចជើង
- ក្រុមប្រកាសអាសន្នចាប់ផ្តើមប្រកាសម្តងទៀតថា « មិត្តភក្តិទាំងអស់គ្នា នៅខាងក្រៅខ្យល់ព្យុះបានស្ងប់ហើយ យើងមានសុវត្ថិភាពហើយ មិត្តទាំងអស់គ្នាអាចចេញមកក្រៅបាន»
- ក្រុមជម្លៀសទាំងអស់ បើកទ្វារបន្ទប់និងបង្អួច រួចដើរចេញមកបរិវេណសាលារៀន
- អនុញ្ញាតឱ្យសិស្សអ្នកចូលរួមទាំងអស់សម្រាក(ញ៉ាំ ផឹក) រួចឱ្យទៅផ្ទះ និងត្រូវប្រាកដថាទៅផ្ទះប្រកបដោយសុវត្ថិភាព(មានអ្នកមកទទួល)។

**ឃ- ដំណើរការអនុវត្តលំហាត់សមយុទ្ធតាមសាលារៀន**

**ជំហានទី១ ប្រជុំក្រុមការងាររៀបចំលំហាត់សមយុទ្ធ និងបែងចែកភារកិច្ចការងារ**

- កំណត់ប្រភេទមុខសញ្ញាគ្រោះថ្នាក់សម្រាប់ធ្វើសមយុទ្ធ ឱ្យសិស្សដឹង (អ្វីកើតឡើង មូលហេតុ អ្វីគួរធ្វើមុនពេល អំឡុង និងក្រោយពេល)
- ការពិនិត្យមើល និងអង្កេតក្នុងថ្នាក់រៀន
  - គូរប្លង់ថ្នាក់រៀន ( តុគ្រូ តុសិស្ស ទូសៀវភៅ ទ្វារ- - - )
  - កំណត់កន្លែងសុវត្ថិភាពដែលអាចចូលបានក្នុងថ្នាក់ ( តុគ្រូ តុសិស្ស ទ្វារ ជ្រុងថ្នាក់រៀន- - - )
  - កំណត់កន្លែងគ្រោះថ្នាក់ (បង្អួច កញ្ចក់ ធ្នើ/ទូសៀវភៅ ម៉ាស៊ីន របស់របរព្យួរ របស់ធ្ងន់ៗដែលអាចធ្លាក់ (បញ្ហាផ្នែកសម្ភារៈនៃអគារ)
  - កំណត់តំបន់ដែលមិនអាចចូលទៅបាន
  - បង្ហាញផែនទីជម្លៀស និងពន្យល់ពីផ្លូវត្រូវជម្លៀស និងតំបន់ដែលបានកំណត់ទុកសម្រាប់ជម្លៀសទៅ។ ត្រូវឱ្យសិស្សណាម្នាក់មើលទ្វារកុំឱ្យបិទ នៅពេលចាប់ផ្តើមជម្លៀស
  - ត្រូវណែនាំសិស្ស ដូចខាងក្រោម អំពីការជម្លៀស នៅពេលដែលកន្តឹងឈប់រោទ៍៖
    1. ត្រូវត្រៀមខ្លួនរួចជាស្រេច
    2. ស្តាប់ការណែនាំរបស់គ្រូ
    3. ដើរចេញពីថ្នាក់រៀនតាមលំដាប់លំដោយ ដោយមិនដេញឬរត់ដែងគ្នា

4. ជួយដល់សិស្សមានពិការភាព
5. នៅពេលដើរចេញពីអគារឬសាលារៀន ត្រូវមើល ឬប្រុងប្រយ័ត្នរបស់របរឬសំរាម ដែលអាចធ្លាក់ ឬប៉ើងមកចំ
6. កុំរត់ កុំរុញ កុំនិយាយ កុំត្រឡប់ក្រោយ កុំយកឬកាន់របស់ផ្សេងៗមកជាមួយ
7. មិនត្រូវត្រឡប់ទៅក្នុងអគារវិញទេ នៅពេលចេញមករួចហើយនោះ។ រង់ចាំនៅកន្លែងជួបជុំរហូតដល់មានការណែនាំបន្ត។

**ជំហានទី២ កំណត់សញ្ញាជូនដំណឹង/ប្រកាសអាសន្ន**



- ត្រូវកំណត់យកឧបករណ៍ណាមួយ ធ្វើជាសញ្ញាប្រាប់ថាគ្រោះមហន្តរាយកើតឡើង ដូចជា កញ្ចែ ជួង ស៊ីរ៉ែន មេក្រូ...
- ត្រូវណែនាំសិស្ស ឱ្យយល់ពីសញ្ញានោះនៅពេលធ្វើសមយុទ្ធ ហើយត្រូវមានសញ្ញាអ្វីមួយសម្រាប់អ្នកផ្សេង (អ្នកទស្សនាផ្សេង ឬសិស្សគរ ថ្លង់ ដឹងពីសញ្ញានោះ ដែលអាចជាទង់ជាតិ ឬរូបភាពផ្សេង )

**ជំហានទី៣ ឆ្លើយតប ឬជម្លៀសចេញពីកន្លែងគ្រោះថ្នាក់** (**រត់នៅក្នុងថ្នាក់ ចូលក្រោមតុ "ឱនចុះ គ្របក្បាល នៅស្ងៀម**)

- នៅពេលឮសូរសំឡេង មេក្រូ កន្ទឹងរោទិ៍ ជួង កញ្ចែឬ ទង់លើកជាសញ្ញា សិស្សត្រូវជម្លៀសចេញពីអគារ ឬរត់ចូលអគារ។ ការជម្លៀសត្រូវធ្វើឡើងតាមលំដាប់លំដោយដូចបានកំណត់ទុក និងសម្របសម្រួលដោយក្រុមការងារជម្លៀស និងគ្រូ ។

- គួរជម្លៀសទៅតាមផ្លូវដែលបានកំណត់រួច តាមលំដាប់លំដោយ កុំឱ្យមានការរត់ជាន់គ្នា។ សិស្សដែលមិនមានពិការភាព ត្រូវជួយសិស្សដែលមានពិការភាព ដើម្បីជម្លៀសផងដែរ។



**ជំហានទី៤ ជួបជុំនៅកន្លែងដែលបានកំណត់ទុក**

- នៅកន្លែងដែលបានកំណត់ទុក សិស្សទាំងអស់ ត្រូវជុំគ្នាតាមការណែនាំ ឬនៅតាមថ្នាក់នីមួយៗ ដែលបានកំណត់...
- ត្រូវណែនាំសិស្ស ឱ្យយល់ពីសញ្ញានោះនៅពេលធ្វើសមយុទ្ធ ហើយត្រូវមានសញ្ញាអ្វីមួយ សម្រាប់អ្នកផ្សេង (អ្នកទស្សនាផ្សេង ឬសិស្សគរ ថ្លង់) ដឹងពីសញ្ញានោះ ដែលអាចជាទង់ជាតិ ឬរូបភាពផ្សេង





**ជំហានទី៥ រាប់ចំនួនសិស្ស និងផ្ទៀងផ្ទាត់**

- គ្រូប្រចាំថ្នាក់ ត្រូវរាប់ចំនួនសិស្ស ក្រែងមានសិស្សណាបាត់។ ដើម្បីឱ្យលំហាត់សមយុទ្ធកាន់តែជាក់ស្តែង គ្រូអាចរៀបចំឱ្យមានសិស្សរបួស ដើម្បីឱ្យក្រុមរុករក និងសង្គ្រោះ ស្វែង



រកសិស្សដែលបាត់ និងយកទៅកន្លែងសុវត្ថិភាព។ បន្ទាប់មក ក្រុមសង្គ្រោះបឋម ចាប់ផ្តើមអនុវត្តជំនាញសង្គ្រោះ។

**ជំហានទី៦ ឱ្យសិស្សចូលថ្នាក់រៀនឬទៅផ្ទះតាមធម្មតា**

- ក្រោយពីគ្រូប្រចាំថ្នាក់រាប់ចំនួនសិស្ស ក្នុងថ្នាក់និងផ្ទៀងផ្ទាត់ឃើញថា អត់មានបាត់សិស្សណាទេ គ្រូអាចបង្រៀនបន្ត ឬ ដល់ម៉ោងសម្រាក គ្រូអាចឱ្យសិស្សទៅផ្ទះវិញបានដោយសុវត្ថិភាព។

**ជំហានទី៧ រៀនសូត្រ និងឆ្លុះបញ្ចាំង**

- ជំហានចុងក្រោយ បន្ទាប់ពីធ្វើលំហាត់សមយុទ្ធចប់។ នាយកសាលារៀន ត្រូវដឹកនាំសមាជិកក្រុមការងារធ្វើលំហាត់សមយុទ្ធទាំងអស់ ប្រជុំឆ្លុះបញ្ចាំងពីចំណុចល្អ និងចំណុច

ខ្វះចន្លោះក្នុងការធ្វើលំហាត់សមយុទ្ធ ដើម្បីដកស្រង់បទពិសោធនិងដោះស្រាយបញ្ហាផ្សេងៗ ។

**ខ- ឆ្លុះបញ្ចាំងពីការអនុវត្តក្រោយពេលអនុវត្តលំហាត់សមយុទ្ធ**

បន្ទាប់ពីអនុវត្តលំហាត់សមយុទ្ធ នាយកសាលាត្រូវប្រជុំឆ្លុះបញ្ចាំង ជាមួយគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន ដើម្បីកំណត់ពីបញ្ហាក្នុងពេលអនុវត្ត ក្នុងការកែលម្អ ហើយវាគួរតែរៀបចំរៀងរាល់ត្រីមាស។ មុនពេលលំហាត់សមយុទ្ធ យើងក៏គួរប្រាប់ពីការរៀបចំនេះ ដល់សហគមន៍ក្បែរៗនោះឱ្យបានដឹងជាមុន ដើម្បីកុំឱ្យមានភាពចលាចលឬការភ័យខ្លាចផ្សេងៗដែលមិនរំពឹងទុកកើតឡើង។



- ជួបប្រជុំអ្នកចូលរួម(អ្នកទទួលបន្ទុកក្នុងគណៈកម្មការទាំង៦ និងអ្នកតាមដានត្រួតពិនិត្យ)
- នាយកសាលា ឬអ្នកទទួលបន្ទុកដឹកនាំសមយុទ្ធ ជាប្រធានអង្គប្រជុំ ដែលដំណើរការនៃកិច្ចប្រជុំប្រព្រឹត្តទៅតាមរយៈការសួរសំណួរមួយចំនួនដូចខាងក្រោម៖

 ១- តើក្រុមទាំង៤ ដែលបានអនុវត្តលំហាត់សមយុទ្ធ មានគុណសម្បត្តិអ្វីខ្លះ?

 ២- តើការអនុវត្តលំហាត់សមយុទ្ធ មានចំណុចខ្វះខាតអ្វីខ្លះ?

 ៣- តើយើងគួរកែលម្អសកម្មភាពលំហាត់សមយុទ្ធដូចម្តេចបន្តទៀត?

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

ការយល់ដឹង និងអនុវត្តបានទៅតាមនីតិវិធីប្រតិបត្តិស្តង់ដា SOP និងគោលការណ៍សាលារៀនសុវត្ថិភាព ឆ្លើយតបគ្រោះអាសន្ននៅក្នុងសាលារៀន ដូចជាខ្យល់ព្យុះ និងទឹកជំនន់ មានសារៈសំខាន់បំផុត ចំពោះ

សាលារៀន ដែលប្រឈមនឹងគ្រោះអាសន្នញឹកញាប់។ ពិសេស ការណែនាំនូវដំណើរការក្នុង ការណែនាំការធ្វើសមយុទ្ធឆ្លើយតបគ្រោះមហន្តរាយ ការជូនដំណឹងដល់ឪពុកម្តាយនិងស្ថាប័នពាក់ព័ន្ធក្នុងអំឡុងពេលគ្រោះមហន្តរាយ ការកំណត់សកម្មភាពនៃសេណារីយ៉ូ សម្រាប់អនុវត្តលំហាត់សមយុទ្ធ ការអនុវត្តលំហាត់សមយុទ្ធតាមសាលារៀន និងការឆ្លុះបញ្ចាំងពីការអនុវត្តក្រោយពេលអនុវត្តលំហាត់សមយុទ្ធជាដើមបានអនុវត្តបាននូវការគ្រប់គ្រង និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយបានកាន់តែល្អប្រសើរ សិស្សម្នាក់ៗទទួលបាននូវ



ទម្លាប់ បំណិនការពារសុវត្ថិភាពផ្ទាល់ខ្លួនក្នុងការសិក្សា បង្កើនបានការលើកកម្ពស់សុខភាព សុវត្ថិភាព និងការការពារកុមារ ចៀសផុតពីគ្រោះមហន្តរាយ ដែលអាចកើតមានឡើងក្នុងសាលារៀនហើយសាលារៀនក្លាយជាសាលារៀនដែលមានសុវត្ថិភាពពិតប្រាកដ និងថែមទាំងបានរួមចំណែកយ៉ាងសំខាន់ ក្នុងការសម្រេចបានឬឆ្លើយតប គោលនយោបាយ "ក្របខណ្ឌសាលារៀនសុវត្ថិភាព" សាលារៀនជាសាលាកុមារមេត្រី។

**២- ៥ ឯកសារសិក្សាបន្ថែម**

- ក្រសួងអប់រំ យុវជន និងកីឡា (2023) កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារ: *ក្របខណ្ឌសាលារៀនសុវត្ថិភាព*

**២-៦ ការអនុវត្ត**

ការសិក្សាពីការណែនាំ និងដំណើរការអនុវត្តលំហាត់សមយុទ្ធឆ្លើយតបគ្រោះមហន្តរាយ តាមនីតិវិធីប្រតិបត្តិស្តង់ដា និងគោលការណ៍សាលារៀនសុវត្ថិភាពជាការងារសំខាន់សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន។ដូច្នេះ សាលារៀននីមួយៗ មិនត្រឹមតែបង្កើតយន្តការឬរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់សាលារៀន ប៉ុណ្ណោះទេ សាលារៀននីមួយៗត្រូវអនុវត្តការធ្វើសមយុទ្ធនៅតាមសាលារៀននីមួយៗឱ្យបាន២ដងក្នុង១ឆ្នាំ។

**សំណួរ**

១-ដូចម្ដេចហៅថា លំហាត់សមយុទ្ធ?

២-មុននាំសិស្សធ្វើលំហាត់សមយុទ្ធ តើគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀននីមួយៗ ត្រូវត្រៀមនិងរៀបចំធ្វើអ្វីខ្លះ?

៣-ចូរជ្រើសរើសមុខសញ្ញាគ្រោះថ្នាក់ចំនួនមួយ(ទឹកជំនន់ ខ្យល់ខ្លាំង ឬអគ្គីភ័យ) ហើយសរសេរ ជាសេណារីយ៉ូ ឆ្លើយតបគ្រោះអាសន្ន តាមលំនាំបង្ហាញមេរៀនឱ្យបានត្រឹមត្រូវហើយដឹកនាំហ្វឹកហាត់សិស្ស និងអនុវត្ត ។

៤-តើលោកអ្នក រៀនសូត្របានអ្វីខ្លះពីការអនុវត្តលំហាត់សមយុទ្ធ តាមសាលារៀនរបស់លោកអ្នក?

៥-តើការអនុវត្តលំហាត់សមយុទ្ធ មានសារៈសំខាន់អ្វីខ្លះចំពោះសាលារៀន?

# ជំពូកទី៦ ការរៀបចំនិរន្តរភាពសាលារៀនមានសុវត្ថិភាព

**សេចក្តីណែនាំ**

ជំពូកនេះ យើងនឹងសិក្សាប្រធានបទអំពីការរៀបចំនិរន្តរភាពសាលារៀនមានសុវត្ថិភាព។ នៅក្នុងជំពូកនេះ មានមេរៀនចំនួន២ដែលបង្ហាញពី (១)ការបញ្ចូលសកម្មភាពផែនការសាលារៀនមានសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ (២)ការរៀបចំសារអប់រំសម្រាប់សាលារៀន។

# មេរៀនទី១៖ ការបញ្ចូលសកម្មភាពផែនការសាលារៀនសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ សង្កាត់

## ១- វត្ថុបំណង

- ប្រាប់បានពីដំណើរការរៀបចំផែនការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងនោះមានផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ និងផែនការវិនិយោគបីឆ្នាំរំកិល
- ដឹងពីរបៀបបញ្ចូលសកម្មភាពផែនការសាលារៀនសុវត្ថិភាព និងតម្រូវការធនធាន ថវិកា ក្នុងផែនការផែនការវិនិយោគឃុំ សង្កាត់
- មានស្មារតី និង អាកប្បកិរិយាជំរុញឱ្យមានការរៀបចំ និងអនុវត្តផែនការសាលារៀនសុវត្ថិភាពពេញលេញ ដោយស្វែងរកជំនួយពីប្រភពផ្សេងៗ។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

នៅក្នុងមេរៀននេះ នឹងសិក្សាអំពី(១)- ដំណើរការរៀបចំផែនការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង(២)- ការបញ្ចូលសកម្មភាពផែនការសាលារៀនសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ សង្កាត់។

ការផ្សារភ្ជាប់ផែនការសាលារៀនសុវត្ថិភាព ទៅនឹងផែនការវិនិយោគឃុំ សង្កាត់មានសារៈសំខាន់បំផុតដែលទាមទារឱ្យសាលារៀននីមួយៗ រៀបចំឡើងដើម្បីស្វែងរកការគាំទ្រការអនុវត្តពេញលេញសាលារៀនមានសុវត្ថិភាព ។

### ២- ២ ពាក្យគន្លឹះ

- ***ផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឬផែនការសាលារៀនសុវត្ថិភាព*** គឺជាផែនការរបស់សាលារៀនដែលបានរៀបចំឡើងសម្រាប់អនុវត្តមុនមានគ្រោះមហន្តរាយកើតឡើង សំដៅ ការពារ កាត់បន្ថយ និងត្រៀមលក្ខណៈឆ្លើយតបគ្រោះមហន្តរាយក្នុងសាលារៀនប្រកបដោយសុវត្ថិភាព។
- ***ផែនការវិនិយោគឃុំ សង្កាត់*** គឺជាឯកសារផែនការដែលគូសបញ្ជាក់ពីអាទិភាពនៃការអភិវឌ្ឍន៍ និងគម្រោងវិនិយោគសម្រាប់ឃុំ សង្កាត់ជាក់លាក់មួយ ។ វាត្រូវបានរៀបចំឡើងដោយអាជ្ញាធរមូលដ្ឋាន ដោយសហការជាមួយសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ ដូចជាទីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

### ២- ៣ ខ្លឹមសារមេរៀន

#### ២- ៣- ១ ដំណើរការរៀបចំផែនការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់ថា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ និងផែនការវិនិយោគបីឆ្នាំរំកិល។ ច្បាប់នេះមានគោលការណ៍បច្ចេកទេសក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាពតម្លាភាព គណនេយ្យភាព និងការចូល

រួមពេញលេញរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាក់ទងនឹងបញ្ហាបច្ចុប្បន្ន សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍនៅថ្នាក់ឃុំ សង្កាត់មានកិច្ចការធំពីរ។ ទី ១ រៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់រយៈពេល ៥ ឆ្នាំ ពេញលេញ និងទី ២ ពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការវិនិយោគឃុំប្រចាំឆ្នាំ ។ នៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ពិចារណាលើយុទ្ធសាស្ត្រសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តដែលមានគោលបំណងដោះស្រាយសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ដំណើរការរៀបចំផែនការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បង្ហាញពីកម្រិតជាក់លាក់នៃការចូលរួមពីប្រជាពលរដ្ឋ និងភាពជាដៃគូរវាងអ្នកពាក់ព័ន្ធ។ សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកបង្ហាញពីសារៈសំខាន់នៃការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល បណ្តាមន្ទីរ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចែករំលែកព័ត៌មានដើម្បីឆ្លើយតបទៅនឹងអាទិភាពឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចធ្វើការស្នើសុំ និងអំពាវនាវឱ្យមានការគាំទ្រពីខាងក្រៅដល់តំបន់របស់ពួកគេផងដែរ។

### វដ្តនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងផែនការវិនិយោគឃុំ សង្កាត់




ជារៀងរាល់ឆ្នាំ ឃុំ សង្កាត់មានការសម្រេចចិត្តសំខាន់ៗចំនួន ៣ ទាក់ទងនឹងការអភិវឌ្ឍថវិការបស់ខ្លួន។ ទីមួយគឺត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំរបស់ពួកគេដើម្បីធ្វើឱ្យប្រាកដថា គម្រោងទាំងនេះត្រូវបានអនុវត្តស្របតាមអាទិភាពរបស់ពួកគេ។ បញ្ជីអាទិភាពនៃសកម្មភាពអាទិភាពត្រូវបានដាក់ជូននៅឯសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ដែលផ្តល់វេទិកាសម្រាប់អង្គការក្រៅរដ្ឋាភិបាល និងមន្ទីរពាក់ព័ន្ធដើម្បីដោះស្រាយអាទិភាពឃុំដោយធ្វើការប្តេជ្ញាចិត្តបណ្តោះអាសន្ន។ បន្ទាប់ពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តសេចក្តីសម្រេច

ចុងក្រោយស្តីពីការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ផ្ទាល់ខ្លួនសម្រាប់ឆ្នាំនេះដោយពិចារណាលើអនុសាសន៍របស់គណៈកម្មាធិការផែនការ និងថវិកា។

ការសម្រេចចិត្តសំខាន់ទី ២ គឺសំដៅទៅលើដំណាក់កាលអនុវត្តគម្រោងដោយខ្លួនឯង។ ឃុំ សង្កាត់ត្រូវជ្រើសរើសភ្នាក់ងារអនុវត្ត ឬអ្នកសាងសង់ដែលសមស្របដើម្បីអនុវត្តការវិនិយោគ។ ការសម្រេចចិត្តនេះត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិលទ្ធកម្មដែលចែងថា វាត្រូវតែធ្វើតាមរយៈដំណើរការដេញថ្លៃដែលសម្របសម្រួលដោយមន្ត្រីខេត្ត។

ចុងបញ្ចប់ជារៀងរាល់ឆ្នាំ ឃុំ សង្កាត់ត្រូវផ្តល់សិទ្ធិឱ្យអ្នកសាងសង់បង់ប្រាក់នៅពេលដែលដំណាក់កាលនីមួយៗនៃការអនុវត្តត្រូវបានបញ្ចប់។ នេះជាជំហានចាំបាច់ក្នុងដំណើរការត្រួតពិនិត្យ ព្រោះក្រុមប្រឹក្សាត្រូវតែធានានូវគុណភាពគម្រោង ហើយនៅពេលដែលមិនបានបំពេញតាមស្តង់ដារគុណភាព ក្រុមប្រឹក្សាគួរតែធ្វើការជាមួយអ្នកសាងសង់ដើម្បីជួយពួកគេឱ្យសម្រេចនូវអ្វីដែលចាំបាច់។

### ២- ៣- ២ ការបញ្ចូលសកម្មភាពផែនការសាលារៀនសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ សង្កាត់

**តើសាលារៀនបញ្ចូលសកម្មភាពផែនការសាលារៀនសុវត្ថិភាព ឬផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការវិនិយោគឃុំ សង្កាត់យ៉ាងដូចម្តេច?**

សាលារៀនរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន ដឹកនាំដោយគណៈគ្រប់គ្រងសាលារៀន និងមានការចូលរួមពីក្រុមប្រឹក្សាកុមារ គ្រូបង្រៀន គណៈកម្មការថ្នាក់រៀន និងគណៈកម្មាការគ្រប់គ្រងសាលារៀន។ ផែនការសាលារៀនសុវត្ថិភាព ឬផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយត្រូវបានធ្វើឡើងជាប្រព័ន្ធដើម្បីកំណត់ វាយតម្លៃ និងដោះស្រាយហានិភ័យ និងគ្រោះថ្នាក់ដែលអាចកើតមាននៅក្នុង និងជុំវិញសាលារៀន។ ផែនការនេះ មានសកម្មភាពការពារ និងកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយមកលើសិស្ស បុគ្គលិកអប់រំ និងហេដ្ឋារចនាសម្ព័ន្ធសាលារៀន ហើយត្រូវបានដាក់ជាឧបសម្ព័ន្ធនៃផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន។

ដើម្បីស្វែងរកមតិគាំទ្រ និងបញ្ចូលសកម្មភាពសាលារៀនសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ សង្កាត់ គណៈគ្រប់គ្រងសាលារៀនអាចអនុវត្តតាមបទពិសោធន៍ដូចខាងក្រោម៖

- ដឹកនាំរៀបចំផែនការសាលារៀនសុវត្ថិភាព ដោយមានការចូលរួមពីក្រុមប្រឹក្សាកុមារ គ្រូបង្រៀន គណៈកម្មការថ្នាក់រៀន និងគណៈកម្មាការគ្រប់គ្រងសាលារៀន។ ផែនការសាលារៀនសុវត្ថិភាពនេះ មានបង្ហាញពី សកម្មភាព ឬវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ពេលវេលា អ្នកទទួលខុសត្រូវ ធនធានមានស្រាប់ ធនធានត្រូវការ និង ភ្នាក់ងារគាំទ្រ (ថវិកា បច្ចេកទេស)។
- កំណត់សកម្មភាព និងតម្រូវការ ធនធាន ថវិកា ដែលគ្រោងសុំបញ្ចូលក្នុងផែនការផែនការវិនិយោគឃុំ សង្កាត់ ។ សកម្មភាពសំខាន់ៗ ឬ វិធានការទាំងនេះ ត្រូវមានលក្ខណៈច្បាស់លាស់ ទើបយក

ទៅដាក់បញ្ចូលក្នុងផែនការវិនិយោគឃុំបាន ។ ការដាក់បញ្ចូលក្នុងផែនការវិនិយោគឃុំ ក៏ត្រូវមានកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន គ្រប់សមាសភាពពាក់ព័ន្ធ ដើម្បីស្វែងរកកិច្ចសហការ និងភ្នាក់ងារគាំទ្រ ទាំងធនធាន ថវិកា និងបច្ចេកទេស ធ្វើយ៉ាងណាឱ្យមានការឯកភាព ទើបការដាក់បញ្ចូលក្នុងផែនការវិនិយោគឃុំទទួលបានជោគជ័យ។ ឆ្លងកាត់បទពិសោធ សាលារៀន គួរកំណត់យកសកម្មភាព ឬ វិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយណាដែលអាទិភាពចំនួន ៤ ឬ៥ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំ សង្កាត់។

- បង្កើតសំណើរសុំដែលមានបញ្ជាក់ពីសកម្មភាពជាក់លាក់ ធនធាន ថវិកា ដែលគ្រោងសុំបញ្ចូលក្នុងផែនការផែនការវិនិយោគឃុំ សង្កាត់ ។ ក្នុងនោះ គួរបង្ហាញពីអត្ថប្រយោជន៍នៃសកម្មភាពឬវិធានការទាំងនេះដែលសំខាន់ក្នុងលើកកម្ពស់បរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព។ សាលារៀនគួរតែប្រមូលទិន្នន័យ និងផ្តល់ភស្តុតាងដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងស្វែងរកមតិគាំទ្ររបស់ពួកគេ។ នេះអាចរួមបញ្ចូលសក្ខីកម្មពីសិស្ស មាតាបិតា និងគ្រូបង្រៀន ។
- ចូលរួមក្នុងដំណើរការធ្វើផែនការវិនិយោគឃុំ សង្កាត់ អាចត្រូវបានធ្វើតាមរយៈការប្រជុំ ការបង្ហាញ និង ការពិភាក្សា ដើម្បីបង្កើនការយល់ដឹងអំពីសកម្មភាព តម្រូវការធនធាន ថវិកា ដែលសុំបញ្ចូលក្នុងផែនការវិនិយោគឃុំ សង្កាត់។ អ្នកចូលរួមក្នុងដំណើរការធ្វើផែនការវិនិយោគឃុំ សង្កាត់រួមមាននាយក នាយិកាសាលរៀន គណៈកម្មាការគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាកុមារ។
- តាមដាន និងរក្សាការប្រាស្រ័យទាក់ទងជាទៀងទាត់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីទទួលបានព័ត៌មានថ្មីៗ អំពីដំណើរការពិនិត្យ និងការសម្រេចចិត្តលើសំណើសុំរបស់សាលារៀន។
- សូមសិក្សាពីឧទាហរណ៍សំណើរសុំរបស់សាលារៀនបញ្ចូលក្នុងផែនការផែនការវិនិយោគឃុំ សង្កាត់ក្នុងឯកសារឧបសម្ព័ន្ធ។

## ២-៤ ចំណុចសំខាន់ៗគួរចងចាំ

ដើម្បីបញ្ចូលសកម្មភាពផែនការសាលារៀនសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ សង្កាត់បាន គណៈគ្រប់គ្រងសាលារៀន៖

- ត្រូវយល់ដឹងពីដំណើរការរៀបចំផែនការវិនិយោគឃុំ សង្កាត់ រួមទាំងពេលវេលា នីតិវិធីធ្វើសេចក្តីសម្រេចចិត្ត និងអ្នកពាក់ព័ន្ធសំខាន់ៗដែលត្រូវចូលរួម ។ ការយល់ដឹងអំពីដំណើរការនេះ នឹងជួយគណៈគ្រប់គ្រងសាលារៀន ឱ្យដាក់សំណើទៅឃុំ សង្កាត់ សមស្រប នឹងពេលវេលានៃការពិគ្រោះយោបល់ និងការសម្រេចចិត្ត។
- រៀបចំផែនការសាលារៀនសុវត្ថិភាពជាមុន បន្ទាប់មកកំណត់សកម្មភាព និងតម្រូវការធនធានថវិកាដែលគ្រោងសុំបញ្ចូលក្នុងផែនការផែនការវិនិយោគឃុំ សង្កាត់។ ការស្នើសុំ អាចជាសកម្មភាព

លើកកម្ពស់ការយល់ដឹងអំពីហានិភ័យ និងគ្រោះថ្នាក់ កែលម្អហេដ្ឋារចនាសម្ព័ន្ធដើម្បីទប់ទល់នឹងគ្រោះមហន្តរាយ ការរៀបចំប្រព័ន្ធព្រមានទុកជាមុន។ល។

- ចូលរួមក្នុងដំណើរការធ្វើផែនការវិនិយោគឃុំ សង្កាត់ ជាកិច្ចការសំខាន់ ដើម្បីពន្យល់ពីតម្រូវការចាំបាច់ពីការស្នើសុំ ជាពិសេសវត្តមានរបស់នាយក នាយិកាសាលារៀន និង មានតាមដាន និងរក្សាការប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាប្រចាំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីទទួលបានព័ត៌មានទាក់ទងការសម្រេចចិត្តលើសំណើសុំរបស់សាលារៀន។

**២- ៥ ឯកសារសិក្សាបន្ថែម**

- ឯកសារសេចក្តីណែនាំស្តីពី ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់

**២-៦ ការអនុវត្ត**

បន្ទាប់ពីរៀនមេរៀននេះរួច សូមអ្នកឆ្លើយសំណួរ និងអនុវត្តដូចខាងក្រោម៖

១- ចូរអ្នកពិពណ៌នាចំណុចសំខាន់ៗដែលអ្នកបានសិក្សាពីមេរៀននេះ ?

២- តើអ្នកចែករំលែកចំណេះដឹងពីមេរៀននេះដល់អ្នកពាក់ព័ន្ធក្នុងសាលារៀន( ដូចជាគណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន ) ឬស្ថាប័នអប់រំដទៃទៀតតាមវិធីណា ?

៣- តើការបញ្ចូលសកម្មភាពសាលារៀនសុវត្ថិភាពទៅក្នុងផែនការវិនិយោគឃុំ សង្កាត់មានសារៈសំខាន់អ្វីខ្លះ ?

៤- តើសកម្មភាពសាលារៀនសុវត្ថិភាពអ្វីខ្លះ ដែលអាចបញ្ចូលក្នុងផែនការវិនិយោគឃុំ ?

៥- តើវដ្តនៃផែនការវិនិយោគឃុំ សង្កាត់មានអ្វីខ្លះ ? តើសកម្មភាពសាលារៀនសុវត្ថិភាព អាចបញ្ចូលក្នុងដំណាក់កាលណា ?

៦- តើអ្នកបង្កើតសំណើសុំបញ្ចូលសកម្មភាពសាលារៀនមានសុវត្ថិភាពក្នុងផែនការផែនការវិនិយោគឃុំ សង្កាត់ដូចម្តេចដែរ ?

# មេរៀនទី២៖ ការរៀបចំសារអប់រំ សម្រាប់សាលារៀនមានសុវត្ថិភាព

## ១- វត្ថុបំណង

- ពន្យល់បានពីដំណើរការរៀបចំបង្កើតសារអប់រំសម្រាប់សាលារៀនមានសុវត្ថិភាព និងលក្ខណៈវិនិច្ឆ័យសារអប់រំដែលមានគុណភាព និងប្រសិទ្ធភាព។
- បង្កើតបានសារអប់រំជាគំរូបែបសង្ខេប ច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងការព័ត៌មានទាក់ទងនឹងសាលារៀនមានសុវត្ថិភាពដល់សិស្ស បុគ្គលិកអប់រំ និងសហគមន៍។
- មានស្មារតី និង អាកប្បកិរិយាជួយសាលារៀនឱ្យរៀបចំសារអប់រំសម្រាប់សាលារៀនមានសុវត្ថិភាពរបស់ខ្លួន។

## ២- ខ្លឹមសារណែនាំ

### ២-១ សេចក្តីណែនាំ

នៅក្នុងមេរៀននេះ ខ្លឹមសារដែលត្រូវសិក្សារួមមាន(១)- ដំណើរការរៀបចំបង្កើតសារអប់រំសម្រាប់សាលារៀនមានសុវត្ថិភាព និង (២) - លក្ខណៈសារអប់រំដែលមានប្រសិទ្ធភាព និង (៣)- ឧទាហរណ៍សារអប់រំសម្រាប់សាលារៀនមានសុវត្ថិភាព។

### ២- ២ ពាក្យគន្លឹះ

*ការអប់រំ* សំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬ ការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឱ្យ អ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឱ្យក្លាយខ្លួនជា បុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

*សារអប់រំ* (សា-អប់-រំ)(ន) ព័ត៌មានខ្លីណាមួយសម្រាប់ឱ្យមនុស្សយល់ដឹង និងពិចារណាលើបញ្ហាអ្វីមួយ។

*សារ* ជាផ្នែកមួយនៃការទាក់ទងរវាងគ្នានិងគ្នា ដោយមានប្រភព និងគោលដៅដែលត្រូវបញ្ជូន។ សារអាចត្រូវបានបញ្ជូនឱ្យគ្នាបានតាមច្រើនរបៀបដូចជា សត្វព្រាប មនុស្ស និងឧបករណ៍អេឡិចត្រូនិចផ្សេងៗ។ សារគឺបង្កប់នូវពត៌មានដើម្បីអោយនរណាម្នាក់បានដឹង ពីពត៌មានហ្នឹងដែរ។ ការប្រាស្រ័យទាក់ទងគ្នាជាលក្ខណៈអន្តរកម្មទៅវិញទៅមក បង្កើតបានជាការសន្ទនា។ ការផ្ញើសំបុត្រទៅកាន់នរណាម្នាក់ ជាឧទាហរណ៍នៃការផ្ញើសារ។

### ២-៣ ខ្លឹមសារមេរៀន

#### ២-៣-១ ដំណើរការរៀបចំបង្កើតសារអប់រំសម្រាប់សាលារៀនមានសុវត្ថិភាព

ការរៀបចំសារអប់រំសម្រាប់សាលារៀន ចាំបាច់ត្រូវបានរៀបចំសម្រាប់ មុនពេល កំឡុងពេល ក្រោយពេលមានគ្រោះមហន្តរាយ។ សារអប់រំទាំងនេះផ្តល់ព័ត៌មាន និងការណែនាំអំពីការអនុវត្តប្រកបដោយសុវត្ថិ

ភាព បង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ដែលអាចកើតមាន និងផ្តល់ចំណេះដឹង និងជំនាញដល់សិស្ស សិស្ស បុគ្គលិកអបរំ មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សដើម្បីការពារខ្លួន។ សារអប់រំនេះ ត្រូវមានព័ត៌មាន ភស្តុតាងជាមូលដ្ឋាន ជាសេចក្តីសង្ខេប និងអាចអនុវត្តបាន។ គ្រប់សាលារៀនទាំងអស់ គួរតែលើកទឹកចិត្តឱ្យ រៀបចំសារអប់រំសម្រាប់សាលារៀនរបស់ខ្លួន ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាព និងសុខមាភាពរបស់ សិស្ស គ្រូបង្រៀន សហគមន៍ ។

គណៈគ្រប់គ្រងសាលារៀន គួរតែរៀបចំសារអប់រំសម្រាប់ពិភាក្សាជាមុន រួចត្រូវប្រជុំពិភាក្សាគ្រប់ក្រុម មុខពាក់ព័ន្ធ ដើម្បីសម្រេចបានសារអប់រំដែលមានន័យគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្សព្វផ្សាយដល់សិស្ស បុគ្គលិកអបរំ និងសហគមន៍ ។ នេះគឺជាជំហានមួយចំនួនដែលអ្នកអាចអនុវត្តដើម្បីបង្កើតសារអប់រំសម្រាប់ សាលារៀនអំពីគ្រោះមហន្តរាយ៖

1- ការកំណត់ប្រភេទ និងក្រុមគោលដៅដែលជាអ្នកទទួលសារ៖ កំណត់ថាតើសាររបស់អ្នក គឺសម្រាប់ អ្នកណា ជា សិស្ស គ្រូ ឪពុកម្តាយ ឬ ទាំងអស់គ្នា។ ក្នុងនោះដែរ នឹងមានការវិភាគពីតម្រូវការ កង្វល់ និងចំណាប់អារម្មណ៍របស់ក្រុមគោលដៅទាក់ទងនឹងសាលារៀនដែលមានសុវត្ថិភាព ព្រមទាំង ស្រាវជ្រាវ និងប្រមូលទិន្នន័យលើការយល់ឃើញរបស់ក្រុមគោលដៅអំពីសុវត្ថិភាពសាលារៀន។
2- ការកំណត់គោលបំណងនៃសារ៖ កំណត់គោលបំណងនៃសារឱ្យបានច្បាស់លាស់ និង អ្វីដែលអ្នក ចង់ឱ្យអ្នកទទួលសារយល់ដឹង និងអនុវត្តអំពីសាររបស់អ្នក។
3- ការជ្រើសរើសប្រធានបទនៃសារ៖ ជ្រើសរើសប្រធានបទដែលទាក់ទងឱ្យទាក់ទងនឹងសាលារៀន បុគ្គលិកអប់រំ សិស្ស និង សហគមន៍ ដែលអាចរងគ្រោះដោយមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ ដូចជា ទឹក ជំនន់ រន្ទះបាញ់ ខ្យល់ព្យុះ លង់ទឹក គ្រោះថ្នាក់ចរាចរណ៍ ជាដើម។ល។
4- ការស្រាវជ្រាវ៖ ប្រមូលព័ត៌មានអំពីប្រធានបទដែលអ្នកជ្រើសរើសពីប្រភពដែលអាចទុកចិត្តបាន។
5- ការបង្កើតគម្រោង៖ រៀបចំព័ត៌មានខ្លីណាមួយមានន័យគ្រប់គ្រាន់សម្រាប់ឱ្យសិស្ស បុគ្គលិកអប់រំ សហគមន៍ យល់ដឹង ងាយចាំ ។
6- ការបង្កើត ឬសរសេរសារ ៖ ប្រើភាសាច្បាស់លាស់ដែលងាយយល់ និងមានទាក់ទាញ។ ប្រើ បច្ចេកទេសនិទានរឿងដើម្បីបង្កើតទំនាក់ទំនងអារម្មណ៍ជាមួយអ្នកទទួលសារ។ បញ្ចូលភាសា បញ្ចុះបញ្ចូល និង ភស្តុតាងដើម្បីគាំទ្រសារ។
7- ទម្រង់សារអាចជាសំណេរ សម្លេង រូបភាព និង វីដេអូ។
8- ការពិនិត្យឡើងវិញ៖ ពិនិត្យមើលសារអប់រំ ដើម្បីធានាភាពត្រឹមត្រូវ ភាពច្បាស់លាស់ និងពេញលេញ មុនផ្សព្វផ្សាយ។
9- ការសាកល្បង៖ ចែករំលែកសារអប់រំ ជាមួយអ្នកទទួលសារ(សិស្ស គ្រូ )ដើម្បីពិភាក្សាក្រុម ឬតាមរយៈ ការស្ទង់មតិដើម្បីទទួលបានមតិកែលម្អ។

10- ការពិនិត្យ និងកែសម្រួលឡើងវិញឡើងវិញ៖ កែសម្រួលសារឡើងវិញ ដោយផ្អែកលើមតិកែលម្អដែលទទួលបានអ្នកចូលរួមក្នុងការសាកល្បង ឬអ្នកជំនាញដើម្បីបង្កើនប្រសិទ្ធភាពនៃសារ។

11- ការផ្សព្វផ្សាយសារអប់រំ៖ ធ្វើឡើងតាមរយៈមធ្យោបាយសមស្រប ដូចជា ការប្រាស្រ័យទាក់ទងផ្ទាល់ (ការជួបជុំពេលគោរពទង់ជាតិ ការប្រជុំក្រុមប្រឹក្សាកុមារ ការប្រជុំគ្រូ ប្រជុំអ្នកអាណាព្យាបាលសិស្ស ព្រឹត្តិការណ៍ផ្សេងៗនៅសាលារៀន និងសហគមន៍...) ការប្រើសម្ភារៈជារូបភាព (បង្ហាញផ្ទាំងរូបភាព ផ្លាកសញ្ញា និងខិត្តប័ណ្ណ...) និង ប្រព័ន្ធផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក យូធូប តេឡេក្រាម...)។

**២-៣-២ លក្ខណៈសារអប់រំដែលមានប្រសិទ្ធភាព**

តើលក្ខណៈនៃសារគន្លឹះល្អមានអ្វីខ្លះ?

សារគន្លឹះដែលមានប្រសិទ្ធភាពរួមមាន៖

- សង្ខេប៖ ផ្តោតលើសារសំខាន់ៗចំនួនពី ៣ ទៅ ៥ ប៉ុណ្ណោះមួយប្រធានបទ។ សរសេរ ១ ទៅ ៣ ប្រយោគ សម្រាប់សារគន្លឹះនីមួយៗ ដែលគួរអាន ឬនិយាយក្នុងរយៈពេល ៣០ វិនាទី ឬតិចជាងនេះ។
- យុទ្ធសាស្ត្រ៖ កំណត់ បែងចែកភាពខុសគ្នានៃការប្រតិបត្ត និងបង្ហាញនូវអត្ថប្រយោជន៍។
- សមស្រប៖ ថ្លឹងថ្លែងនូវអ្វីដែលអ្នកត្រូវផ្តល់ព័ត៌មានមួយអ្វីដែលអ្នកទទួលសាររបស់អ្នកត្រូវការដឹង។
- ទាក់ទាញ៖ រៀបចំព័ត៌មានឱ្យមានអត្ថន័យ ដើម្បីជំរុញសកម្មភាព។
- សាមញ្ញ៖ ប្រើភាសាងាយយល់ និង ជៀសវាងពាក្យបច្ចេកទេស និងអក្សរកាត់។
- ងាយចងចាំ៖ ត្រូវប្រាកដថាសារមានភាពងាយស្រួលក្នុងការរំលឹក និងនិយាយឡើងវិញ។ ជៀសវាងប្រយោគវែងឆ្ងាយ។
- ពិត៖ ប្រើទម្រង់សរសេរសកម្ម មិនមែនអកម្មទេ។ កុំប្រើពាក្យស្លោកផ្សាយពាណិជ្ជកម្ម។
- សម្រប៖ ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយក្រុមគោលដៅផ្សេងៗគ្នាដោយការសម្របតាមភាសា និងជម្រៅនៃព័ត៌មាន។

**២-៣-៣ ឧទាហរណ៍សារអប់រំសម្រាប់សាលារៀនមានសុវត្ថិភាព**

ខាងក្រោមនេះ គឺជាឧទាហរណ៍សារអប់រំខ្លះៗ អំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលរៀបចំជាស្រេចមុនគ្រោះមហន្តរាយ៖

1- ទឹកជំនន់

- ស្តាប់វិទ្យុ និង មើលទូរទស្សន៍ដើម្បីតាមដានពត៌មានពីស្ថានភាពទឹកជំនន់ ខ្យល់ព្យុះ និង ទឹកភ្លៀងដោយប្រុងប្រយ័ត្ន
- រៀបចំទុកដាក់សម្ភារសិក្សា និងឯកសារសំខាន់ៗ ច្រកថង់ដែលមិនជ្រាបទឹក និងដាក់លើធ្នើរឱ្យបានត្រឹមត្រូវ

2- ព្យុះ និងខ្យល់ខ្លាំង

- ពេលកំពុងមានព្យុះ មិនត្រូវធ្វើដំណើរទៅសាលា ឬទៅផ្ទះ ប្រសិនបើពុំទាន់ចាំបាច់

3- រន្ទះបាញ់

- ពេលកំពុងមានខ្យល់ព្យុះ មិនត្រូវប្រើទូរស័ព្ទ ឬឧបករណ៍អគ្គិសនី

4- អគ្គីភ័យ

- អនុវត្តតាមផែនការជម្លៀសអគ្គីភ័យរបស់សាលារៀន
- ទុកវត្ថុងាយឆេះឱ្យឆ្ងាយពីប្រភពកំដៅ
- រៀបចំផែនការ និងអនុវត្តសមយុទ្ធជម្លៀសភ្លើងនៅសាលារៀនយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ

5- គ្រោះរាំងស្ងួត និងរលកកំដៅ

- ពិសាទឹកឱ្យបានញឹកញាប់លើសពី ២លីត្រ ក្នុងមួយថ្ងៃ ទោះបីមិនស្រេកទឹកក៏ដោយ
- ចូលរួមសន្សំសំចៃការប្រើប្រាស់ទឹក និងថាមពលអគ្គិសនីឱ្យបានសមស្របទាំងអស់គ្នា ដើម្បីរក្សាបរិមាណទឹក និងថាមពលអគ្គិសនីឱ្យបានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងសហគមន៍
- ចៀសវាងស្ថិតក្រោមកម្តៅថ្ងៃដោយផ្ទាល់យូរពេក ដោយត្រូវរកកន្លែងជ្រក ឬរបាំងការពារកម្តៅព្រះអាទិត្យ

6- សុខភាព និងអនាម័យ

- ការសេពគ្រឿងញៀន នាំមកនូវក្តីវិនាសដល់ខ្លួន
- ត្រូវស្វែករកសេវាថែទាំ ប្រសិនអ្នក មានគ្រុនក្តៅ ក្អក និង ពិបាកដកដង្ហើម
- លាងសំអាតដៃរបស់អ្នក ជាមួយសាប៊ូ និង ទឹកស្អាត នៅពេលឃើញដៃកខ្វក់ឬប្រលាក់

7- អាហារូបត្ថម្ភ និងសុវត្ថិភាពចំណីអាហារ

- សុវត្ថិភាពចំណីអាហារនៅតាមសាលារៀន គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា
- សត្វឈឺ និងសត្វដែលស្លាប់ដោយជំងឺ មិនត្រូវបរិភោគ។

8- សុវត្ថិភាពចរាចរណ៍

- ការពារជីវិតអ្នក ត្រូវពាក់មួកសុវត្ថិភាពដែលមានគុណភាពល្អឱ្យបានត្រឹមត្រូវជានិច្ចនៅពេលបើកបរ

- កុំប្រើទូរស័ព្ទពេលបើកបរ អ្នកអាចបង្ករគ្រោះថ្នាក់ចរាចរណ៍

**២-៤ ចំណុចសំខាន់ៗគួរចងចាំ**

- ការបង្កើតសារអប់រំឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវមានការរៀបចំ និងការពិចារណាដោយប្រុងប្រយ័ត្នទៅតាមដំណាក់ជាច្រើនដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ។
- សារគន្លឹះដែលមានប្រសិទ្ធភាព គឺមានលក្ខណៈសង្ខេប យុទ្ធសាស្ត្រ សមស្រប ទាក់ទាញ សាមញ្ញ ងាយចងចាំ ពិត និងសម្រប ។
- ការរៀបចំសារអប់រំសម្រាប់សាលារៀន គួរត្រូវបានរៀបចំអនុវត្ត មុនពេលមាន កំឡុងពេល ក្រោយពេលមានគ្រោះមហន្តរាយ

**២- ៥ ឯកសារសិក្សាបន្ថែម**

- សូមទំនាក់ទំនងលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីទទួលបានសារអប់រំទាក់ទងនឹងសាលារៀនមានសុវត្ថិភាព។

**២-៦ ការអនុវត្ត**

បន្ទាប់ពីរៀនមេរៀននេះរួច សូមអ្នកឆ្លើយសំណួរ និងអនុវត្តដូចខាងក្រោម៖

១- ចូរអ្នករៀបរាប់ចំណុចសំខាន់ៗដែលអ្នករៀនបានពីមេរៀននេះ?

២- តើអ្នកចែករំលែកចំណេះដឹងពីមេរៀននេះដល់អ្នកពាក់ព័ន្ធក្នុងសាលារៀន( ដូចជាគណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន )ឬ ស្ថាប័នអប់រំដទៃទៀតតាមវិធីណា?

៣- តើអ្នកជួយគណៈគ្រប់គ្រងសាលារៀនដូចម្តេចដើម្បីឱ្យគាត់អាចអនុវត្តនិង ផ្សព្វផ្សាយសារអប់រំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដល់សិស្សានុសិស្ស ឪពុកម្តាយ ឬអាណាព្យាបាលកុមារ អាជ្ញាធរមូលដ្ឋាន គ្រូ នាយក និងអ្នកពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងសហគមន៍?

៤- តើការរៀបចំសារអប់រំពីការតាត់បន្ថយហានិភ័យគ្រោះមហន្តរាយអាចមានលើប្រធានបទអ្វីខ្លះ?

៥- ហេតុអ្វីបានជាសាលារៀននីមួយៗ ត្រូវការរៀបចំសារអប់រំពីការតាត់បន្ថយហានិភ័យគ្រោះមហន្តរាយ? ហើយមានសំខាន់អ្វីខ្លះ?

៦- តើសាលារៀននីមួយៗត្រូវធ្វើដូចម្តេចខ្លះ ដើម្បីការរៀបចំសារអប់រំ ពីការតាត់បន្ថយហានិភ័យគ្រោះមហន្តរាយ?

៧- នៅសាលារៀន តើអ្នកណាខ្លះអាចចូលរួមរៀបចំសារអប់រំពីការតាត់បន្ថយហានិភ័យគ្រោះមហន្តរាយ? តើត្រូវការសម្ភារៈអ្វីខ្លះ? ប្រភពធនធានថវិកាពីណាខ្លះ?

៨- តើសាលារៀន ផ្សព្វផ្សាយសារអប់រំពីគ្រោះមហន្តរាយនេះ តាមវិធីណាខ្លះ?

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ជំពូកទី១ មេរៀនទី១

- ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, «ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ» ឆ្នាំ២០១៥
- អង្គការសហប្រជាជាតិ *«ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយូហ្គោ ២០០៥-២០១៥»* ឆ្នាំ ២០០៥
- អង្គការសហប្រជាជាតិ *«ក្របខ័ណ្ឌសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០១៥-២០៣០»* ឆ្នាំ ២០១៥

## ជំពូកទី១ មេរៀនទី៣

- **ឧបសម្ព័ន្ធ ក ធនធានសម្ភារៈ និងឧបករណ៍ខាងក្នុងសាលារៀន**

**(គំរូតារាងបំពេញដោយ សាលាបឋមសិក្សា បឹងកាឆាង ស្រុកមណ្ឌលសីមា ខេត្តកោះកុង)**

| សម្ភារៈ/ធនធានសំខាន់ៗ | លំអិតអំពីសម្ភារៈ/ធនធាន | ឈ្មោះ និងតួនាទី មនុស្សសំខាន់ៗសំរាប់ទាក់ទង | លេខទូរស័ព្ទ |
|---|---|---|---|
| ស៊ីទែនទឹក | ចំនួន2(ចំនុះ2000លx2=4000ល) | លោក ង៉ែត ឡូច<br>ប្រធានគណៈគ្រប់គ្រងសាលា | |
| បង្គន់អនាម័យ | 7 បន្ទប់ | លោក ម៉ាត់សើហ្វីអ៊ី<br>គ្រូបង្រៀន | |
| រោងអាហារ | 1 កន្លែង | កញ្ញា បាន រចនា<br>គ្រូបង្រៀន | |
| សួនដើមកោងកាង និងព្រៃកោងកាង | 1 កន្លែង (ទំហំ 20មx10ម មានដើមឈើចម្រុះ9មុខ) | ម៉ែបង្គោល និងនាយកសាលា | |
| ព្យ៉ាណូ | 0ឈុត | | |

- **ឧបសម្ព័ន្ធ ខ ធនធានសម្ភារៈ និងឧបករណ៍ខាងក្រៅសាលារៀន**

| សំភារៈ/ធនធានសំខាន់ៗ | លំអិតអំពីសំភារៈ/ធនធាន | ចំងាយពីទីតាំងសាលារៀន | ឈ្មោះ និងតួនាទី មនុស្សសំខាន់ៗសំរាប់ទាក់ទង | លេខទូរស័ព្ទ |
|---|---|---|---|---|
| ទីស្នាក់ការសហគមន៍ | 1 កន្លែង | 150 ម៉ែត្រ | លោក ឡុន រិទ្ធ<br>(ប្រធានសហគមន៍) | 016 962 156 |
| ទូកឬ អូប័រ | 1គ្រឿង | 250 ម៉ែត្រ | លោក ឡុន រិទ្ធ<br>(ប្រធានសហគមន៍) | 016 962 156 |
| សាលាឃុំ | 1 កន្លែង | 2 គីឡូម៉ែត្រ | លោក អៀរ កុសល<br>(មេឃុំ) | |
| សាលាស្រុក | 1 កន្លែង | 30 គីឡូម៉ែត្រ | លោក ជា គឹម សេង<br>(អភិបាលស្រុក) | |

| | | | | |
|---|---|---|---|---|
| មណ្ឌលសុខភាព | 1 កន្លែង | 250ម៉ែត្រ | ល.ស សុំ សុខេន (អ្នកស្ម័គ្រចិត្តភូមិ) | |
| ប៉ុស្តិ៍រដ្ឋបាល | 1 កន្លែង | 150 ម៉ែត្រ | លោក ង៉ែត លុច (អ្នកស្ម័គ្រចិត្តភូមិ) | |
| កំព្យូទ័រ កាមេរ៉ា ម៉ាស៊ីនព្រីន ម៉ាស៊ីនថតចំលង និងម៉ាស៊ីនបញ្ចាំងស្លាយ | 1 ធុត | 150 ម៉ែត្រ | លោក ឡុន រិទ្ធ (ប្រធានសហគមន៍) | 016 962 156 |
| ធុងបាស និងមេក្រូ | 1 ធុត | 150 ម៉ែត្រ | លោក ឡុន រិទ្ធ (ប្រធានសហគមន៍) | 016 962 156 |
| ហិបសង្គ្រោះបឋម | 1 ហិប | 150 ម៉ែត្រ | ល.ស សុំ សុខេន (អ្នកស្ម័គ្រចិត្តភូមិ) | |
| ហិបសង្គមសង្គ្រោះ | 1 ហិប | 150 ម៉ែត្រ | ល.ស សុំ សុខេន (អ្នកស្ម័គ្រចិត្តភូមិ) | |
| ក្រុមសន្សំប្រាក់ | 40 លាន | 150 ម៉ែត្រ | លោក ឡុន រិទ្ធ (ប្រធានសហគមន៍) | 016 962 156 |
| ក្តារខៀនព័ត៌មានសហគមន៍ | 1 ក្តារ | 150 ម៉ែត្រ | លោក ង៉ែត លុច (អ្នកស្ម័គ្រចិត្តភូមិ) | |
| ទូកដឹកស៊ីទែនទឹក | 1 ទូក | 150 ម៉ែត្រ | លោក ង៉ែត លុច (អ្នកស្ម័គ្រចិត្តភូមិ) | |
| ម៉ាស៊ីនភ្លើង | 1 គ្រឿង | 150 ម៉ែត្រ | លោក ឡុន រិទ្ធ (ប្រធានសហគមន៍) | 016 962 156 |

- **ឧបសម្ព័ន្ធ គ ការកំណត់ពីធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍**

**(គំរូតារាងបំពេញដោយ សាលាបឋមសិក្សា កោះស្តេច ស្រុកគីរីសាគរ ខេត្តកោះកុង)**

| ស្ថាប័នពាក់ព័ន្ធ | ឈ្មោះ | ភេទ | តួនាទី | សមត្ថភាពជំនាញ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| អាជ្ញាធរមូលដ្ឋាន | សុខ ចេង | ប្រុស | មេឃុំ | គាំទ្រសាលារៀន | 097 466 636 3 |
| | ស្រី ចំរើន | ប្រុស | មេភូមិ | គាំទ្រសាលារៀន | 016 731 440 |
| | ចំរើន ចំរុង | ប្រុស | មេប៉ុស្តិ៍ | ការពារសន្តិសុខ | 016 604 501 |
| គណៈកម្មការទ្រទ្រង់សាលា | សាយ ហេង | ប្រុស | ជំទប់ទី១ | ទំនាក់ទំនងសប្បុរសជន | 016 935 807 |
| | យិត យ៉ាត | ស្រី | នាយិកាសាលា | ទំនាក់ទំនងសប្បុរសជន | 016 863 646 |
| | ឌី វិធូពង្ស | ប្រុស | គ្រូបង្រៀន | ទំនាក់ទំនងសប្បុរសជន | 071 858 595 4 |
| | ពេជ្រ ធន | ស្រី | សហគមន៍ | បច្ចេកទេសកសិកម្ម | 097 273 599 5 |
| មណ្ឌលសុខភាព | សុខ សារិន | ប្រុស | គ្រូពេទ្យ | ថ្នាំព្រូន វ៉ាក់សាំង | |

| | | | | | |
|---|---|---|---|---|---|
| | សួន សុវណ្ណារិទ្ធ | ស្រី | ធ្មប | | |
| ក្រុមសង្គ្រោះបឋម | សុខ សារិន | ប្រុស | គ្រូពេទ្យ | គាំទ្រ និងសង្គ្រោះបឋម | |
| កម្លាំងយុវជន ឬ អ្នកស្ម័គ្រចិត្ត កាកបាទក្រហម | ជួន ណារីន | ស្រី | សិស្ស | គ្រប់គ្រង | |
| ក្រុមប្រឹក្សាកុមារ | ពោធិ៍ ជីវ៉ា | ប្រុស | សិស្ស | ផ្សព្វផ្សាយ | |
| | ឌឹម ហួយ | ស្រី | សិស្ស | សង្គ្រោះបឋម | |
| | ញ៉ សុភ័ណ្ឌ | ប្រុស | សិស្ស | ជម្លៀស | |

- **ឧបសម្ព័ន្ធ ឃ ការវិភាគស្ថាប័នដៃគូពាក់ព័ន្ធ**

**(គំរូតារាងបំពេញដោយ សាលាបឋមសិក្សា កោះស្តេច ស្រុកគីរីសាគរ ខេត្តកោះកុង)**

| ឈ្មោះស្ថាប័នពាក់ព័ន្ធ | បទអន្តរាគមន៍ ឬសកម្មភាព ឬវិស័យការងារ | កម្រិតនៃការចូលរួម/ពាក់ព័ន្ធ (១ តិច,២ មធ្យម, ៣ ច្រើន) | ឈ្មោះ តួនាទី និងលេខទូរស័ព្ទទាក់ទង |
|---|---|---|---|
| អាជ្ញាធរភូមិ | ជួយដោះស្រាយបញ្ហាទំនាស់ផ្សេងៗ<br>ជួយអន្តរាគមន៍ពេលគ្រោះមហន្តរាយ | | |
| សប្បុរសជន | ផ្តល់សំភារៈ និងថវិកា កំលាំងពលកម្ម | | |
| មន្ទីរបរិស្ថាន | ផ្សព្វផ្សាយអនាម័យ បរិស្ថាន និងដាំកូនឈើ | | |
| មន្ត្រីបរិស្ថានុរក្ស | ផ្តល់បច្ចេកទេសដាំកូនកោងកាង | | |
| អង្គការ Save the Children | សង់សាលារៀន ជួយកុមារពិការលើការសិក្សា ស្រាវជ្រាវ និងអប់រំអន្តរាគមន៍អំពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | | |
| មន្ទីរអប់រំ/ការិយាល័យស្រុក | ជួយបច្ចេកទេសបង្រៀន ពិនិត្យតាមដានវាយតម្លៃ | | |
| សាលាស្រុក/ឃុំ | ជួយអង្ករ និងដាំកូនឈើ | | |
| ច្រករបៀងអភិរក្សជីវៈចម្រុះមហាអនុតំបន់មេគង្គ | ដាំ និងស្តារព្រៃឈើឡើងវិញ | | |
| មន្ទីរជលផល | ផ្តល់បច្ចេកទេសចិញ្ចឹមត្រី | | |

## ជំពូកទី១ មេរៀនទី៤

- **ឧបសម្ព័ន្ធ ក ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់សាលារៀន (គំរូ)**

| ហានិភ័យដែលប៉ះពាល់ដែលអាចកើតមាន (ទាំងពេលខ្លី និងវែង) | ភាពងាយរងគ្រោះ (ហេតុអ្វីបានជា មានហានិភ័យទាំងនេះ?) | សកម្មភាព ត្រូវធ្វើ | អាទិភាពសកម្មភាព | ធនធានសម្រាប់អនុវត្ត | ពេលវេលា | អ្នកដឹកនាំអនុវត្ត |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| **ខ្យល់ព្យុះ (ខ្យល់កន្ត្រាក់)** | | | | | | |
| 1-កុមារប្រឈមនឹងការលង់ទឹកស្លាប់ រឺពេលធ្វើដំណើរ | 1.1 ពេលឆ្លងទន្លេអាចជួបខ្យល់ខ្លាំងពេល ឆ្លងទន្លេមករៀន | 1.1.1 អប់រំណែនាំកុមារសិស្សហាមមិន ឱ្យធ្វើដំណើរពេល មានខ្យល់ខ្លាំងនិង មានទឹកជ្រៅ<br>1.1.2បង្រៀនសិស្សឱ្យរៀនហែលទឹក និងចែវទូក | 1.1 | - ឯកសារណែនាំកម្មវិធីសាលាកុមារមេត្រីសមាសភាគទី៣<br>- ទូក<br>- អាវពោង | ឧសភា មិថុនា កក្កដា | នាយកគ្រូ សហគមន៍ អាជ្ញាធរ |
| 2-កុមារប្រឈមនឹងរបួសស្នាម | 2.1 មែកឈើ រឺ របស់របរផ្សេងៗបាក់ធ្លាក់ចំ សង្កត់ | 2.1 ដាក់ស្លាកសញ្ញាហាមឃាត់<br>2.2 ណែនាំសិស្សកុំឱ្យរត់ លេងក្នុងទីធ្លាពេលមានភ្លៀងធ្លាក់និង ខ្យល់បក់បោកខ្លាំង | 2.1 | - ស្លាកសញ្ញាហាមឃាត់<br>- ពន្យល់សិស្សពីផលប៉ះពាល់ | ឧសភា មិថុនា កក្កដា | នាយកគ្រូ សហគមន៍ អាជ្ញាធរ |
| 3-ដំណើរការរៀនសូត្រនិងការបង្រៀនត្រូវរំខាន រឺអាក់ខាន | 3.1 ហេដ្ឋារចនាសម្ព័ន្ធសាលារៀនរងការខូចខាត (របើកដំបូល ជាដើម) | 3.1 ជម្លាសសិស្សចេញពីអាគារទ្រុឌទ្រោម<br>3.2 ដាក់សញ្ញាហាមឃាត់នៅអាគារទ្រុឌទ្រោម | 3.1<br>3.2 | - ស្លាកសញ្ញាហាមឃាត់ | ឧសភា មិថុនា កក្កដា | នាយកគ្រូ សហគមន៍ អាជ្ញាធរ |
| **ទឹកជំនន់ទន្លេ** | | | | | | |
| 1.ខូចខាតសម្ភារបរិក្ខាសិក្សា តាមសាលា និងការសិក្សា របស់កុមារ | 1.1 កម្មវិធីពេលវេលាសិក្សាចំ ពេលរដូវទឹកជំនន់<br>1.2 សាលានិងកុមារមិនមានព័ត៌មានទាន់ពេលវេលាពីស្ថានភាពទឹកជំនន់ដែលកើតឡើងជាហេតុមិនបានរៀបចំ ទាន់ពេលវេលា | 1.1 ថ្នាក់ដឹកនាំសាលាសិក្សាពីលទ្ធភាព ផ្លាស់ប្តូរពេលវេលាសិក្សាប្រសិនបើចាំបាច់<br>1.2 បង្កើតឲ្យមានប្រព័ន្ធ ផ្តល់ព័ត៌មានជាមុន ពីគ្រោះទឹកជំនន់និងគ្រោះមហន្តរាយផ្សេងៗទៀត ដោយហៅទៅលេខ១២៩២ ហើយស្តាប់ការណែនាំ (សូមមើលលំអិតនៅឧបសម្ព័ន្ធទី ២) | 1.1 | វិទ្យុ ទូរស័ព្ទ | កញ្ញា តុលា វិច្ឆិកា | - ក្រសួង - មន្ទីរ - ការិយាល័យ - អង្គការ - នាយក - គ្រូ |
| 2.ដំណើរការរៀនសូត្រត្រូវបានរំខានរឺអាក់ខាន | 2.1កម្មវិធីពេលវេលា សិក្សាចំពេលរដូវ ទឹកជំនន់<br>2.2 កុមារមិនមានមធ្យោបាយធ្វើដំណើរមកសាលា រៀន | 2.1 ថ្នាក់ដឹកនាំសាលា សិក្សាពីលទ្ធភាព ផ្លាស់ប្តូរពេលវេលា សិក្សាប្រសិន បើចាំ បាច់ | 2.2 | ទីទួលសុវត្ថិភាព | មិថុនា កក្កដា សីហា | នាយក - គ្រូ សហគមន៍ កុមារ |

| | | | | | | |
|---|---|---|---|---|---|---|
| | 2.3 សាលាត្រូវលិចទឹកមិនមានកន្លែងរៀន | 2.2 សហការនឹងអ្នកពាក់ព័ន្ធដើម្បី រៀបចំ ក្រុមសម្រាប់ដឹក សិស្សនៅ ពេលទឹកលិច<br>2.3 សិក្សារៀបចំផែនការជាមុនឲ្យមានកន្លែងរៀនបណ្តោះអាសន្ន | | | | |
| 3.កុមារប្រឈមនឹងការលង់ទឹកស្លាប់រឺរបួសស្នាម ផ្សេងៗ នៅក្នុងកំឡុងពេលមានគ្រោះទឹក ជំនន់ | 3.1 កុមារមិនទាន់ចេះហែលទឹក<br>3.2 ខ្វះការយកចិត្តទុកដាក់ពេញលេញពីមាតាបិតា<br>3.3 នៅសាលាមិនមានទាន់មានក្រុមការងារ ឆ្លើយតបនិង គ្រប់គ្រងគ្រោះ មហន្តរាយដើម្បីបំពេញការងារគ្រប់ គ្រងគ្រោះមហន្តរាយនៅឡើយ<br>3.4 ក្រុមការងារនៅសាលាមិនទាន់ទទួលបានការបណ្តុះបណ្តាលពីការងារគ្រប់គ្រងគ្រោះមហន្តរាយនៅឡើយនៅសាលាមិនទាន់មានជំនាញសង្គ្រោះបឋម ដើម្បីជួយសង្គ្រោះទាន់ពេលវេលា | 3.1 យុទ្ធនាការជាតិ និងទិវាអន្តរជាតិនៃ ការកាត់បន្ថយគ្រោះ មហន្តរាយ<br>3.2 អប់រំបង្កើនការយល់ដឹងដល់ឪពុកម្តាយ អាណាព្យាបាលយល់ អំពីការបង្ការពីគ្រោះថ្នាក់ ដោយសារលង់ទឹក<br>3.3 រៀបចំ និងពង្រឹង យន្តការគ្រប់គ្រងគ្រោះមហន្តរាយរបស់សាលារៀន<br>3.4 រៀបចំបណ្តុះបណ្តាលជំនាញគ្រប់គ្រងគ្រោះមហន្តរាយ | 3.3 | - ប្រអប់ សង្គ្រោះ បឋម<br>- ផ្តល់ខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយអំពីទឹកជំនន់ | មិថុនា កក្កដា សីហា | អង្គការនាយកគ្រូ សហគមន៍ |

## ជំពូកទី២ មេរៀនទី១

- **ឧបសម្ព័ន្ធ ក តារាងសមាសភាព តួនាទី និងភារកិច្ចក្រុមការងារត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយកម្រិតសាលារៀន**

**(គំរូតារាងបំពេញដោយ សាលាបឋមសិក្សា បឹងកាឆាង ស្រុកមណ្ឌលសីមា ខេត្តកោះកុង)**

| ល-រ | គោត្តនាម និងនាម | ភេទ | តួនាទីក្រុមគ្រោះមហន្តរាយ | តួនាទីក្នុងការងារសង្គម | អាស័យដ្ឋាន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|
| ១- ក្រុមប្រកាសអាសន្ន និងផ្សព្វផ្សាយព័ត៌មាន | | | | | | |
| ១ | ង៉ែត លុច | ប | ប្រធាន | មេភូមិ | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 0978828809 |
| ២ | សុំ សុខេន | ស | អនុប្រធាន | អ្នកស្មគ្រចិត្តភូមិ | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 010272807 |
| ៣ | ប៊ិច ម៉ានីន | ស | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៤ | ជឹម វ៉ាឡែន | ស | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ២- ក្រុមជម្លៀស | | | | | | |
| ១ | ម៉ាត់ សើហ្វីអ៊ី | ស | ប្រធាន | គ្រូបង្រៀន | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 081606106 |
| ២ | ចាន់ បូរី | ប | អនុប្រធាន | អនុភូមិ | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៣ | ពែក មីស៊ីល | ស | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៤ | ម៉ាត ស្រីឡឿន | ស | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |

| | | | | | | |
|---|---|---|---|---|---|---|
| ៣- ក្រុមរុករក និងសង្គ្រោះ | | | | | | |
| ១ | មួង មួយលីន | ស | ប្រធាន | គ្រូបង្រៀន | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 0318883373 |
| ២ | សុខ នាង | ស | អនុប្រធាន | ម៉ែបង្គោល | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៣ | ពៅ ពិសា | ប | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៤ | ឆែត បញ្ញា | ប | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៥ | មួង មួយលីន | ស | ប្រធាន | គ្រូបង្រៀន | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 0318883373 |
| ៤- ក្រុមសង្គ្រោះបឋម | | | | | | |
| ១ | ភឿន ស្រីណាត់ | ស | ប្រធាន | គ្រូបង្រៀន | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 081953259 |
| ២ | សោម យី | ប | អនុប្រធាន | គណៈកម្មការ | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 0972364633 |
| ៣ | ថៃ ហេងហួត | ប | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៤ | ភោន ស្រីនាន | ស | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៥- ក្រុមសន្តិសុខ | | | | | | |
| ១ | រ៉ា ចាន់ទិត | ស | ប្រធាន | គ្រូបង្រៀន | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 016567071 |
| ២ | អ៊ំ រីនួ | ស | អនុប្រធាន | គណៈកម្មការ | ភូមិបឹងកាឆាង ប៉ាក់ខ្លង | 0889330584 |
| ៣ | ហួត គាន់សាយ | ប | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |
| ៤ | ធៀម លីហៃ | ប | សមាជិក | សិស្ស | ភូមិបឹងកាឆាង ប៉ាក់ខ្លង | គ្មាន |

- **ឧបសម្ព័ន្ធ ខ តារាងព័ត៌មានទំនាក់ទំនងឪពុក ម្តាយ និងស្ថាប័នពាក់ព័ន្ធក្នុងកំឡុងពេលគ្រោះមហន្តរាយ**

**(គំរូតារាងបំពេញដោយ សាលាបឋមសិក្សា បឹងកាឆាង ស្រុកមណ្ឌលសីមា ខេត្តកោះកុង)**

| ស្ថាប័នពាក់ព័ន្ធ | ឈ្មោះ | ភេទ | តួនាទី | សមត្ថភាពជំនាញ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| អាជ្ញាធរមូលដ្ឋាន | អៀវ កុសល្យ | ប្រុស | មេឃុំ | | 016 91 72 24 |
| | ង៉ែត លុច | ប្រុស | មេភូមិ | បើកទូក | 016 73 14 40 |
| | លឹម ឌី | ប្រុស | មេប៉ុស្តិ៍ | | 097 822 22 42 |
| គណៈកម្មការទ្រទ្រង់សាលា | ង៉ែត លុច | ប្រុស | មេភូមិ | សង្គ្រោះបឋម | 016 917 224 |
| | ឡុន រិទ្ធ | ប្រុស | នាយកសាលា | កម្មវិធីសន្សំប្រាក់ | 016 96 21 56 |
| | ម៉ម សុភារម្យ | ប្រុស | គ្រូបង្រៀន | | 016 36 03 14 |
| | សុខ នាង | ស្រី | សហគមន៍ | | 016 43 21 78 |
| មណ្ឌលសុខភាព | កេ ប៊ុនថន | ប្រុស | គ្រូពេទ្យ | | 016 17 43 23 |
| | សំ សុខេន | ស្រី | ឆ្មប | សង្គ្រោះបឋម | 016 49 66 84 |
| ក្រុមសង្គ្រោះបឋម | ឈួន ក្អួន | ប្រុស | អ្នកស្ម័គ្រចិត្តកាកបាទក្រហម | សង្គ្រោះបឋម | 088 75 82 023 |
| | ហាយ មិថុនា | ស្រី | ពេទ្យភូមិ | | 016 72 47 00 |
| | ប៊ិន សុភ័ក្រ្ត | ស្រី | ជំនួយការភូមិ | | 016 89 21 34 |
| កម្លាំងយុវជន/ អ្នកស្ម័គចិត្ត កាកបាទក្រហម | ស៊ឹម ស្រីខេម | ស្រី | តំណាងយុវជន | | |
| អង្គការដៃគូពាក់ព័ន្ធ | សុក សំណាង | ប្រុស | ប្រធានអង្គការ Save the Children | | |
| មន្ទីរអេយក- រាជធានី /ខេត្ត | សុខ រីន | ប្រុស | ប្រធានការិ.បឋមសិក្សា | | 015 28 40 30 |
| ការិ- អេយក- ខណ្ឌ/ក្រុង/ស្រុក- - - | ស្រេង មង្គល | ប្រុស | ប្រធាន ការិ.ស្រែអំបិល | | |

| | | | | | |
|---|---|---|---|---|---|
| ក្រុមប្រឹក្សាកុមារ | ស៊ឹម ពិសី | ស្រី | ប្រធាន ក្រុមប្រឹក្សាកុមារ | | |
| ឪពុកម្តាយ/អាណាព្យាបាលសិស្ស | ស សុទ្ធ | ប្រុស | តំណាងមាតាបិតា | | |

- ឧបសម្ព័ន្ធ គ រចនាសម្ព័ន្ធគំរូ បំពេញដោយ សាលាបឋមសិក្សា បឹងការឆាង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

**ប្រធាន**

លោក ឡុន រិទ្ធ (នាយក)

**ក្រុមប្រកាសអាសន្ននិងផ្សព្វផ្សាយព័ត៌មាន**

១. លោក ង៉ែត លុច ប្រធាន
២.ល.ស សុំ សុខេន អនុប្រធាន
៣. កុមារី ប៊ិច ម៉ានីន សមាជិក
៤. កុមារី ជីម វ៉ាឡែន សមាជិក

**ក្រុមរុករកនិងសង្គ្រោះ**

១. អ្នកគ្រូ មួង មួយលីន ប្រធាន
២.លោកស្រី សុខ នាង អនុប្រធាន
៣.កុមារ ពៅ ពិសា សមាជិក
៤. កុមារា ឆែត បញ្ញា សមាជិក

**ក្រុមជម្លៀស**

១. លោក ម៉ាត់ សើហ្វីអ៊ី ប្រធាន
២.លោក ចាន់ បូរី អនុប្រធាន
៣.កុមារ ពែក មីស៊ីល សមាជិក
៤. កុមារី ម៉ាត ស្រីឡឿន សមាជិក

**ក្រុមសង្គ្រោះបឋម**

១.អ្នកគ្រូ កឿន ស្រីណាត់ ប្រធាន
២.លោក សោម យី អនុប្រធាន
៣.កុមារ ថៃ ហេងហួត សមាជិក
៤. កុមារី ភោន ស្រីនាន សមាជិក

**ក្រុមសន្តិសុខ**

១. លោក វ៉ា ចាន់ទិត ប្រធាន
២.លោកស្រី អ៊ុំ រីនួ អនុប្រធាន
៣.កុមារ ហួតគាន់សាយ សមាជិក
៤. កុមារា ជៀមលីហៃ សមាជិក

## ជំពូកទី២ មេរៀនទី៣

- **ឧបសម្ព័ន្ធ ក  អនុសញ្ញាស៊ី ដ អនុសាសន៍ទូទៅលេខ៣៧ របស់គណៈកម្មាធិការCEDAW ស្តីពីសមភាពយេនឌ័រ ក្នុងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**

**តាមការពិនិត្យទៅលើសមភាពយេនឌ័រ និងបរិយាបន្ន ក្នុងអនុសាសន៍នេះ បង្ហាញឱ្យឃើញថា**

១- កម្រិតមរណភាពនិងកម្រិតនៃការកើតជំងឺក្នុងចំណោមស្ត្រីនិងក្មេងស្រីក្នុងស្ថានភាពគ្រោះមហន្តរាយ គឺខ្ពស់ជាងក្នុងចំណោមបុរស និងក្មេងប្រុស[7]។ ដោយសារវិសមភាពផ្នែកសេដ្ឋកិច្ចដែលផ្អែកតាមយេនឌ័រ ស្ត្រី និងស្ត្រីជាមេគ្រួសារ ប្រឈមនឹងហានិភ័យខ្ពស់នៃភាពក្រីក្រ និងច្រើនតែរស់នៅក្នុងលំនៅដ្ឋានដែលមានភាពខ្វះខាតក្នុងតំបន់ប្រជុំជន និងទីជនបទដែលដីមិនសូវមានគុណតម្លៃ ដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងអាកាសធាតុ ដូចជា ទឹកជំនន់ ខ្យល់ព្យុះ ការបាក់ធ្លាក់ផ្ទាំងទឹកកក គ្រោះរញ្ជួយដី និងមុខសញ្ញាគ្រោះថ្នាក់ផ្សេងទៀត[៨]។ កម្រិតកាន់តែខ្ពស់នៃមរណភាព និងការកើតជំងឺក្នុងចំណោមស្ត្រីក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ ក៏បណ្តាលមកពីវិសមភាពក្នុងការទទួលបានការថែទាំសុខភាពគ្រប់ គ្រាន់ អាហារ និងអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ ការអប់រំ បច្ចេកវិទ្យា និងព័ត៌មានផងដែរ[៩]។ ជារឿយៗ ការខកខានមិនចូលរួមក្នុងការរៀបចំ និងការអនុវត្តផែនការគ្រោះមហន្តរាយដែលឆ្លើយតបនឹងយេនឌ័រ ក៏នាំឱ្យមានការបង្កើតមូលដ្ឋាននិងហេដ្ឋារចនាសម្ព័ន្ធការពារដែលមិនគិតគូរពីភាពចាំបាច់នៃការបង្កលក្ខណៈងាយស្រួលដល់ក្រុមស្ត្រីចម្រុះ ដូចជា ស្ត្រីមានពិការភាព ស្ត្រីចំណាស់ និងស្ត្រីជនជាតិដើមភាគតិចផងដែរ[10] (ដូចជា យន្តការជូនដំណឹងជាមុន ជម្រក និងកម្មវិធីជំនួយសង្គ្រោះ)។ ក្រៅពីនេះ ស្ត្រី និងក្មេងស្រីប្រឈមនឹងហានិភ័យខ្ពស់នៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ។ នៅពេលគ្មានរបបគាំពារសង្គម និងក្នុងស្ថានភាពដែលមានបញ្ហាអសន្តិសុខស្បៀង បូករួមនឹងនិទណ្ឌភាពសម្រាប់ការប្រព្រឹត្តអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ស្ត្រី និងក្មេងស្រីច្រើនតែប្រឈមនឹងអំពើហិង្សាផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ នៅពេលពួកគេព្យាយាមទទួលបានអាហារ និងតម្រូវការមូលដ្ឋានផ្សេងទៀតសម្រាប់សមាជិកគ្រួសារ និងសម្រាប់ខ្លួនឯង។ ក្នុងជំរំ និងជម្រកបណ្តោះអាសន្ន កង្វះសន្តិសុខផ្លូវការ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលមានសុវត្ថិភាព និងផ្តល់ភាពងាយស្រួល ដូចជា ទឹកពិសា និងអនាម័យ ក៏បង្កើនកម្រិតនៃការប្រព្រឹត្តអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រលើស្ត្រី និងក្មេងស្រីផងដែរ។ អំពើហិង្សាក្នុងគ្រួសារ ការរៀបការវ័យក្មេង និង/ឬអាពាហ៍ពិពាហ៍ដោយបង្ខំ ការជួញដូរមនុស្ស និងពេស្យាចារដោយបង្ខំ ច្រើនតែកើតឡើងក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ។

២- ស្ត្រី ក្មេងស្រី បុរស និងក្មេងប្រុស ទទួលរងផលប៉ះពាល់ខុសគ្នាដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ដោយមានស្ត្រី និងក្មេងស្រីជាច្រើនប្រឈមនឹងហានិភ័យ បន្ទុក និងផលប៉ះពាល់កាន់តែច្រើន។ ស្ថានភាពវិបត្តិ បានបង្កើនវិសមភាពយេនឌ័រដែលមានស្រាប់ និងរួមផ្សំជាមួយទម្រង់ប្រសព្វគ្នានៃការរើសអើសលើស្ត្រីក្រីក្រ ស្ត្រីជាជនជាតិដើមភាគតិច ស្ត្រីមកពីក្រុមជាតិពន្ធុភាគតិច ក្រុមពូជសាសន៍ភាគតិច ក្រុមសាសនាភាគតិច និងក្រុមមាននិន្នាការភេទភាគតិច ស្ត្រីមានពិការភាព ស្ត្រីជាជនភៀសខ្លួន និងស្ត្រីស្វែងរកសិទ្ធិជ្រកកោន ស្ត្រីដែលត្រូវបានផ្លាស់ទីលំនៅក្នុងស្រុក ស្ត្រីដែលគ្មានប្រទេស និងស្ត្រីជាជនទេសន្តរប្រវេសន៍ ស្ត្រីរស់នៅជនបទ ស្ត្រីដែលមិនរៀបការ ស្ត្រីវ័យជំទង់ និងស្ត្រីវ័យចំណាស់ ដែលជារឿយៗ ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងបុរស និងស្ត្រីផ្សេងទៀត។

៣- ក្នុងបរិបទជាច្រើន វិសមភាពយេនឌ័របានរឹតត្បិតការគ្រប់គ្រងរបស់ស្ត្រី និងក្មេងស្រីលើការសម្រេចចិត្តដែលគ្របដណ្តប់លើជីវិតរបស់ពួកគេ ក៏ដូចជាលទ្ធភាពទទួលបានធនធាន ដូចជា អាហារ ទឹក ជាតុចូល កសិកម្ម ដីធ្លី ឥណទាន ថាមពល បច្ចេកវិទ្យា ការអប់រំ សេវាសុខភាព លំនៅដ្ឋានសមរម្យ កិច្ចគាំពារសង្គម និងការងារ។ វិសមភាពទាំងនោះធ្វើឱ្យស្ត្រី និងក្មេងស្រីងាយប្រឈមនឹងហានិភ័យដែលបង្កឱ្យមានគ្រោះមហន្តរាយ និងការខាតបង់ដែលពាក់ព័ន្ធនឹងរបរចិញ្ចឹមជីវិត និងធ្វើឱ្យពួកគេមិនសូវមានលទ្ធភាពបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ ទោះបីជាកម្មវិធីកាត់បន្ថយផលប៉ះពាល់ និងបន្សាំនឹងប្រែប្រួលអាកាសធាតុអាចផ្តល់ឱកាសការងារ និងរបរចិញ្ចឹមជីវិតថ្មីៗក្នុងវិស័យផ្សេងៗដូចជា ផលិតកម្មកសិកម្ម ការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព និងថាមពលស្អាតក៏ដោយ ក៏ការខកខានមិនដោះស្រាយឧបសគ្គ ផ្នែករចនាសម្ព័ន្ធទាំងនេះដែលជាបញ្ហាប្រឈមរបស់ស្ត្រីក្នុងការទទួលបានសិទ្ធិរបស់ពួកគេ នឹងបង្កើនវិសមភាពផ្អែកតាមយេនឌ័រ និងទម្រង់ចម្រុះនៃការរើសអើង។ ព្រមទាំង **ផ្នែកជាក់លាក់ដែលបង្កជាការព្រួយបារម្ភ** អំពីសិទ្ធិមនុស្សមូលដ្ឋានទាំង ៦ ដែលត្រូវបានកំណត់ក្នុងអនុសាសន៍ទូទៅលេខ ៣៧ ដូចជា(១)- សិទ្ធិរស់នៅដោយគ្មានការប្រព្រឹត្តអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រលើស្ត្រី និងក្មេងស្រី (២)- សិទ្ធិទទួលបានការអប់រំ និងព័ត៌មាន (៣)- សិទ្ធិទទួលបានការងារ និងកិច្ចគាំពារសង្គម (៤)- សិទ្ធិមានសុខភាពល្អ (៥)- សិទ្ធិមានជីវភាពសមរម្យ (៦)- សិទ្ធិមានសេរីភាពក្នុងការដើរហើរ ។

៤- គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ(CEDAW) សេចក្តីសង្កេតសន្និដ្ឋានលើរបាយការណ៍តាមកាលកំណត់ទី៦របស់កម្ពុជា ឆ្នាំ២០១៩បានបញ្ជាក់ថា

- ស្ត្រី ជាពិសេសស្ត្រីដែលរស់នៅទីជនបទ ត្រូវបានផាត់ចេញពីការចូលរួមក្នុងការបង្កើត និងការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ

និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទោះបីជាស្ត្រីទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយក៏ដោយ ព្រោះស្ត្រីក្នុងរដ្ឋជាភាគីច្រើនតែពឹងផ្អែកលើវិស័យកសិកម្ម ជាងបុរស។

- ដោយរំលឹកឡើងវិញនូវអនុសាសន៍ទូទៅលេខ ៣៧ របស់ខ្លួន (២០១៨) ស្តីពីទិដ្ឋភាពដែលពាក់ព័ន្ធនឹងយេនឌ័រ គណៈកម្មាធិការ CEDAW ស្នើឱ្យរដ្ឋជាភាគី

  ក)- ធានាការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រី មិនត្រឹមតែក្នុងនាមជាអ្នកដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរទៀតផង ក្នុងការបង្កើត និងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ ក៏ដូចជាការឆ្លើយតបនឹងគ្រោះមហន្តរាយ និងការកាត់បន្ថយហានិភ័យ

  ខ)- ធានាថា គោលនយោបាយ និងផែនការដែលពាក់ព័ន្ធនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទស្សនៈយេនឌ័រ និងពិចារណាពីតម្រូវការជាក់លាក់របស់ស្ត្រី ជាពិសេសស្ត្រីនៅជនបទ។




- **ឧបសម្ព័ន្ធ ខ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព**

  **គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១ ភាពក្រីក្រ**

ក្នុងករណីដែលមានទិន្នន័យបែងចែកតាមភេទ មានការបញ្ជាក់ថា អត្រាមរណភាពរបស់ស្ត្រីក្នុងតំបន់នេះនៅពេលកើតមានគ្រោះមហន្តរាយ គឺខ្ពស់ខ្លាំងជាងអត្រាមរណភាពរបស់បុរស ដោយសារភាពក្រីក្រ។ សូម្បីតែក្នុងករណីដែលគ្មានការប្រមូលព័ត៌មានស្តីពីទិន្នន័យបែងចែកតាមភេទក៏ដោយ ក៏វាបង្ហាញពីអត្រាមរណភាពខ្ពស់ក្នុងចំណោមស្ត្រីជាងក្នុងចំណោមបុរសដែរ។ ស្ត្រី និងក្មេងស្រីមានសមាសភាគភាគច្រើននៃប្រជាជនក្រីក្រក្នុងតំបន់។ គ្រោះមហន្តរាយក៏បង្កផលប៉ះពាល់ធ្ងន់ធ្ងរលើអាយុសង្ឃឹមរស់របស់ស្ត្រីផងដែរ ព្រោះស្ត្រីមានស្ថានភាពសង្គម និងសេដ្ឋកិច្ចទាបជាងបុរស។

**តារាង អត្រាមរណភាពរបស់ស្ត្រីនៅពេលកើតមានគ្រោះមហន្តរាយធំៗនៅអាស៊ីប៉ាស៊ីហ្វិក ឆ្នាំ ១៩៩១ដល់២០១៦ (%)**

| ឆ្នាំ | គ្រោះមហន្តរាយ/ប្រទេស<br>* ** | % - អត្រាមរណភាពស្ត្រី (ចំនួនស្ត្រីក្នុងចំណោមអ្នកដែលបានស្លាប់) |
|---|---|---|
| ១៩៩១ | ព្យុះកំបុតត្បូង 0B2– បង់ក្លាដេស | ៩០ |
| ២០០៤ | រលកយក្ស Tsunami – ខេត្តអាសេ ឥណ្ឌូនេស៊ី ** | ៧៧ |
| ២០០៨ | ព្យុះកំបុតត្បូង Nargis – មីយ៉ាន់ម៉ា | ៦១ |
| ២០០៩ | រលកយក្ស Tsunami – សាម៉ាវ និងតុងហ្កា ** | ៧០ |
| ២០១៣ | ព្យុះទីហ្វុង Haiyan – ហ្វីលីពីន | ៦០ |
| ២០១៤ | ទឹកជំនន់នៅដែនកោះសូឡូម៉ុង - ស្ត្រី និងកុមារ * | ៩៦ |
| ២០១៥ | គ្រោះរញ្ជួយដីនៅនេប៉ាល់ ** | ៥៥ |
| ២០១៦ | ព្យុះកំបុតត្បូង Winston – ហ្វីជី | ៥០ |

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ២ ភាពអត់ឃ្លាន

ប្រជាជនចំនួន ៤៨៩ លាននាក់ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នៅតែគ្មានអាហារបរិភោគគ្រប់គ្រាន់ ដែលក្នុងចំណោមនេះគឺស្ត្រី និងក្មេងស្រីមានចំនួនច្រើនលើសលប់។ លទ្ធភាពរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានអាហារ រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៅកម្រិតគ្រួសារ ជាពិសេសក្នុងពេលកើតមានគ្រោះមហន្តរាយ និងនៅពេលស្បៀងអាហារឡើងថ្លៃ។ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ស្ត្រីចំនួន ៤០០ លាននាក់ដែលដល់វ័យបន្តពូជមានបញ្ហាខ្វះគ្រាប់ឈាមក្រហមក្នុងអំឡុងវិបត្តិកូវីដ-១៩។ អសន្តិសុខស្បៀងដែលពាក់ព័ន្ធនឹងគ្រោះមហន្តរាយ នាំឱ្យមានការរួមភេទជាថ្នូរនឹងអ្វីមួយ ការជួញដូរមនុស្ស ការកេងប្រវ័ញ្ច ការងារដោយបង្ខំ និងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងចំណោមស្ត្រី និងក្មេងស្រីក្នុងតំបន់នេះ។ ជំងឺរាតត្បាតជាសកលកូវីដ-១៩

បានបង្កើនអសន្តិសុខស្បៀងក្នុងតំបន់ និងធ្វើឱ្យក្រុមងាយរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ងាយប្រឈមនឹងគ្រោះអត់ឃ្លាន និងបញ្ហាកង្វះអាហារូបត្ថម្ភ។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៣ ការអប់រំប្រកបដោយគុណភាព**

មុនវិបត្តិកូវីដ-១៩ ក្មេងស្រីចំនួន ១៥ លាននាក់ក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក មិនបានចូលរៀននៅសាលា។ យោងតាមអង្គការ UNESCO ក្មេងស្រីចំនួន ១,២ លាននាក់បន្ថែមទៀតនឹងបោះបង់ការសិក្សា។ ជំងឺកូវីដ-១៩ ក៏ធ្វើឱ្យមានការកើនឡើងនៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ការរៀបការវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ផងដែរ ដែលបញ្ហាទាំងនេះបង្កផលប៉ះពាល់អវិជ្ជមានលើសមត្ថភាពរបស់ក្មេងស្រីក្នុងការទទួលបានការអប់រំ និងរៀនសូត្រ។ គ្រោះមហន្តរាយបានបង្ខំឱ្យកុមារ (ភាគច្រើនគឺក្មេងស្រី) បោះបង់ការសិក្សា ដោយសារបន្ទុកកិច្ចការផ្ទះសម្បែង ការមើលថែបងប្អូន និងពលកម្មកុមារ។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ សុខភាពល្អ**

ស្ត្រីងាយរងគ្រោះដោយសារជំងឺមួយចំនួនជាងបុរស និងប្រឈមនឹងឧបសគ្គក្នុងការទទួលបានសេវាថែទាំសុខភាពជាញឹកញាប់ ជាពិសេសក្នុងពេលកើតមានគ្រោះមហន្តរាយ ហើយការប្រែប្រួលអាកាសធាតុបានធ្វើឱ្យបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរ។ ប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងអសន្តិសុខស្បៀងក្នុងគ្រួសារ និងការគ្មានអាហារបរិភោគគ្រប់គ្រាន់ដែលកើតមានលើស្ត្រី និងក្មេងស្រី បានបង្កផលប៉ះពាល់អវិជ្ជមានលើសុខភាព និងសុខុមាលភាពជារួមរបស់ពួកគេ។ ការវិភាគស្តីពីវិសមភាពយេនឌ័រក្នុងវិស័យសុខាភិបាលក្នុងប្រទេសចំនួន ៤០ នៅតំបន់អាស៊ីប៉ាស៊ីហ្វិចក បានរកឃើញថា ក្មេងស្រីដែលមានអាយុ ១៥-១៩ ឆ្នាំប្រឈមនឹងហានិភ័យខ្ពស់នៃការកើតជំងឺដែលបណ្តាលមកពីបញ្ហាអាហារូបត្ថម្ភ ហើយក្នុងប្រទេសភាគច្រើន ក្មេងស្រីដែលមានអាយុ ១០-១៤ ឆ្នាំមានអត្រាខ្ពស់នៃការកើតជំងឺដោយសារការធ្វើបាបខ្លួនឯងជាងក្មេងប្រុស។ ក្មេងស្ត្រីដែលមានអាយុ ១៥-១៩ ឆ្នាំ ក៏ងាយប្រឈមនឹងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាផ្លូវកាយដែលបង្កដោយដៃគូស្និទ្ធស្នាលផងដែរ ជាពិសេសក្នុងបណ្តាប្រទេសនៅអាស៊ីខាងត្បូង។ ប្រេវ៉ាឡង់ខ្ពស់នៃការប្រើប្រាស់អាពាហ៍ពិពាហ៍កុមារជាយន្តការដោះស្រាយ ជាពិសេសក្នុងពេលកើតមានគ្រោះមហន្តរាយនៅតាមបណ្តាប្រទេសជាច្រើនក្នុងតំបន់ បង្កផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរលើសុខភាពរបស់ក្មេងស្រី។ ស្ត្រីជាអ្នកទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរលើផ្លូវកាយ ផ្លូវអារម្មណ៍ និងផ្លូវចិត្តដោយសារជំងឺកូវីដ-១៩។ ការកើនឡើងនៃការងារថែទាំដោយមិនទទួលបានប្រាក់ឈ្នួល និងកិច្ចការផ្ទះសម្បែង ការបាត់បង់ការងារ និងប្រាក់ចំណូល និងផលប៉ះពាល់នៃការបិទខ្ទប់ លើអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ បានបង្កភាពតានតឹង និងភាពថប់បារម្ភកាន់តែខ្លាំងលើស្ត្រី។ នៅទូទាំងពិភពលោក ស្ត្រីរួមចំណែកជាង ២/៣ នៃកម្លាំងពលកម្មសរុបក្នុងវិស័យសុខាភិបាល និងវិស័យសង្គម។ ដូច្នេះ ស្ត្រីជាអ្នកដើរជួរមុខក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩ និងងាយឆ្លងជំងឺនេះ ប៉ុន្តែស្ត្រីនៅតែមានគម្លាតប្រាក់ឈ្នួលផ្អែកតាមយេនឌ័រ និងកាន់តែមុខតំណែងដឹកនាំតិចជាង។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥ សមភាពយេនឌ័រ**

ស្ត្រី និងក្មេងស្រីក្នុងតំបន់នេះ ងាយប្រឈមនឹងហានិភ័យគ្រោះមហន្តរាយ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាងបុរស និងក្មេងប្រុស។ ការណ៍នេះធ្វើឱ្យស្ត្រី និងក្មេងស្រីរងគ្រោះដោយសារអត្រាមរណភាពខ្ពស់ ការកើតជំងឺ និងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរលើបរចិញ្ចឹមជីវិត និងសុខុមាលភាពជារួមរបស់ពួកគេ។ ស្ត្រី និងក្មេងស្រីក៏មានសក្តានុពលយ៉ាងច្រើនក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងកសាងភាពធន់របស់ហាគមន៍ផងដែរ។ ជំងឺកូវីដ-១៩ បានបង្កើនភាពក្រីក្រពីមួយជំនាន់ទៅមួយជំនាន់។ កូវីដ-១៩ បានកាត់បន្ថយសមត្ថភាពដោះស្រាយរបស់ប្រជាជនក្រីក្របំផុត ជាពិសេសស្ត្រី និងក្មេងស្រី ដោយពួកគេត្រូវកាត់បន្ថយរបបអាហារ និងលក់ទ្រព្យសម្បត្តិផលិតកម្មដើម្បីបន្តរស់រាន។ វាបានបង្ខំឱ្យពួកគេជំពាក់បំណុលអ្នកចងការប្រាក់ក្រៅផ្លូវការ និងធ្លាក់ចូលក្នុងវដ្តដ៏អាក្រក់នៃភាពក្រីក្រ ដោយសារពួកគេមិនសូវមានលទ្ធភាពទទួលបានសំណាញ់សុវត្ថិភាពសង្គម និងការសម្រួលផ្តល់ឥណទាន។ ភាពក្រីក្របានបង្កផលប៉ះពាល់លើសមត្ថភាពរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានសេវាសុខភាព នៅពេលពួកគេត្រូវការសិទ្ធិ និងសុខភាពបន្តពូជ ការថែទាំសុខភាពមាតា និងការគាំទ្រផ្នែកចិត្តសង្គម។ការរើសអើងអ្នកដែលមាននិន្នាការភេទ អត្តសញ្ញាណភេទ និងការបង្ហាញអត្តសញ្ញាណភេទ និងលក្ខណៈភេទក្នុងវដ្តនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ភស្តុតាងពីព្រឹត្តិការណ៍គ្រោះមហន្តរាយធំៗក្នុងតំបន់ បានរំលេចគោលនយោបាយ និងការអនុវត្តបែបរើសអើងយ៉ាងច្រើនលើយេនឌ័រចម្រុះ។ ក្នុងប្រទេសឥណ្ឌា ប៉ាគីស្ថាន ហ្វីលីពីន និងនេប៉ាល់ សហគមន៍អ្នកប្តូរយេនឌ័រ ទទួលរងការបៀតបៀន និងការសើចចំអក ឬត្រូវបានផាត់ចេញទាំងស្រុងពីការចែកជំនួយ។ ក្នុងអំឡុងគ្រោះមហន្តរាយរលកយក្សស៊ូណាមិ នៅ Tamil Nadu ប្រទេសឥណ្ឌាក្នុងឆ្នាំ ២០០៤ សហគមន៍ភេទទី ៣ aravani ត្រូវបានផាត់ចេញពីជំនួយមនុស្សធម៌ ដូចជា អាហារ ជម្រក និងប្រាក់ ដោយសារតែមនុស្សភេទទី ៣ មិនសូវមានប័ណ្ណរបបដែលចេញដោយរដ្ឋាភិបាល។ ដោយសារសហគមន៍ aravani ជាក្រុមមនុស្សភេទទី ៣ ដែលមិនត្រូវបានកំណត់អត្តសញ្ញាណជាបុរស ឬជាស្ត្រី មន្ត្រីបានផាត់ចេញសហគមន៍នេះពីការផ្តល់ប័ណ្ណរបបដោយអចេតនា។ ក្នុងអំឡុងគ្រោះមហន្តរាយខ្យល់ព្យុះទីហ្វុង Haiyan/Yolanda ក្នុងប្រទេសហ្វីលីពីន (២០១៥) អ្នកដែលមានទំនាក់ទំនងភេទដូចគ្នា ត្រូវបានរើសអើង និងមិនមានជាអាទិភាពក្នុងកម្មវិធីផ្តល់ជំនួយ និងកម្មវិធីស្តារឡើងវិញទាន់ពេលវេលា ដែលខិតខំកសាងបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយឡើងវិញ។ អ្នកដែលមាននិន្នាការភេទ អត្តសញ្ញាណភេទ និងការបង្ហាញអត្តសញ្ញាណភេទ និងលក្ខណៈភេទចម្រុះ ប្រឈមនឹងបញ្ហាជាច្រើនក្នុងអំឡុងព្រឹត្តិការណ៍គ្រោះរញ្ជួយដីក្នុងប្រទេសនេប៉ាល់កាលពីឆ្នាំ ២០១៥ ព្រោះពួកគេត្រូវបាន "ផាត់ចេញ" ក្រោមលេសថា ពួកគេមានស្ថានភាពរស់នៅបិទជិត និងក្រៅផ្លូវការនៅក្នុងជំរំ។ ព្រឹត្តិការណ៍ព្យុះត្រូពិក Winston ក្នុងប្រទេសហ្វីជី គូសបញ្ជាក់ពីភាពមិនអើពើចំពោះអ្នកដែលមាននិន្នាការភេទ អត្តសញ្ញាណភេទ និងការបង្ហាញអត្តសញ្ញាណភេទ និងលក្ខណៈភេទចម្រុះ ក្នុងអំឡុងពេលនៃការវាយតម្លៃតម្រូវការក្រោយពេលកើតមានគ្រោះមហន្តរាយ និងក្នុងការវាយតម្លៃផ្សេងទៀត ការឆ្លើយតប និងសកម្មភាពស្តារឡើងវិញ និងការអំពាវនាវឱ្យផ្ត

ល់ជំនួយមូលនិធិ។ ការរើសអើង និងភាពងាយរងគ្រោះរបស់អ្នកដែលមាននិន្នាការភេទ អត្តសញ្ញាណភេទ និងការបង្ហាញអត្តសញ្ញាណភេទ និងលក្ខណៈភេទចម្រុះនៅអាស៊ីប៉ាស៊ីហ្វិច បណ្តាលមកពីកម្រិតខុសៗគ្នា នៃការកំណត់ជាបទឧក្រិដ្ឋ ការរើសអើងក្នុងវិស័យច្បាប់ និងវិស័យយុត្តិធម៌ និងការជួបការលំបាកក្នុងគ្រួសារ សហគមន៍ សាសនា សាលារៀន កន្លែងធ្វើការ ស្ថាប័នផ្តល់សេវា ទីសាធារណៈ និងស្ថាប័ន និងបរិបទផ្សេងទៀត។ ទោះជាយ៉ាងណា ភស្តុតាងពីគ្រោះមហន្តរាយដែលបានកើតឡើងថ្មីៗនេះក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ក៏បង្ហាញផងដែរពីសមត្ថភាពរបស់ប្រជាជនដែលមាននិន្នាការភេទ អត្តសញ្ញាណភេទ និងការបង្ហាញអត្តសញ្ញាណភេទ និងលក្ខណៈភេទចម្រុះក្នុងការដោះស្រាយផលវិបាកនៃគ្រោះមហន្តរាយ និងទាញប្រយោជន៍ពីបណ្តាញសង្គមក្នុងដំណាក់កាលត្រៀមខ្លួន ជំនួយសង្គ្រោះ និងដំណាក់កាលស្តារឡើងវិញសម្រាប់ខ្លួនឯង និងសហគមន៍របស់ពួកគេ។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៦ ទឹកស្អាត និងអនាម័យ**

ស្ត្រីដែលជាកសិករខ្នាតតូច និងស្ត្រីជាអ្នកនេសាទ ច្រើនតែមិនសូវមានសមត្ថភាពបន្សាំដើម្បីប្រឈមមុខជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ដូចជា ផលប៉ះពាល់អវិជ្ជមានលើគុណភាព និងភាពអាចរកបានទឹក។ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មានប្រជាជនចំនួន ២៦០ លាននាក់ដែលគ្មានលទ្ធភាពទទួលបានទឹកស្អាត ហើយប្រជាជនចំនួន ១,៥ ពាន់លាននាក់ មិនសូវមានលទ្ធភាពទទួលបានអនាម័យមូលដ្ឋាន។ ការទទួលបានទឹកស្អាតជាកត្តាដ៏សំខាន់ក្នុងការសម្រេចបានសមភាពយេនឌ័រ។ ជារឿយៗស្ត្រីជាអ្នករ៉ាប់រងបន្ទុកកិច្ចការផ្ទះសម្បែង និងជាអ្នកទទួលខុសត្រូវលើការផ្គត់ផ្គង់ទឹក មើលថែកូន ថែទាំផ្ទះសម្បែង និងរៀបចំម្ហូបអាហារ។ ការដងទឹកច្រើនតែជាកិច្ចការដែលលំបាក ចំណាយពេលច្រើន និងគ្រោះថ្នាក់។ កិច្ចការនេះក៏រឹតត្បិតមិនឱ្យស្ត្រីចូលរួមក្នុងការងាររកប្រាក់ចំណូល ឬសកម្មភាពអប់រំផងដែរ។ ភារៈដងទឹកធ្វើឱ្យស្ត្រីងាយរងរបួស និងងាយទទួលរងអំពើហិង្សផ្លូវភេទ។

ឧទាហរណ៍ ក្នុងតំបន់ជនបទនៅប្រទេសឥណ្ឌា ស្ត្រីអាចធ្វើដំណើរទៅដងទឹក ៦ លើក ដែលក្នុងមួយលើកស្ត្រីអាចដងទឹកបានរហូតដល់ ១៥ លីត្រ។ ជាញឹកញាប់ ភាពហត់នឿយ រួមផ្សំជាមួយនឹងការភ័យខ្លាចការបៀតបៀន ភាពតានតឹងផ្នែកចិត្តសង្គម និងហានិភ័យនៃអំពើហិង្សា នៅពេលស្ត្រីធ្វើដំណើរការទៅមកដើម្បីដងទឹក។ កង្វះលទ្ធភាពនេះ គឺជា "វិបត្តិលាក់មុខ" ដែលបង្កឱ្យមានការស្លាប់ជាច្រើនដោយសារជំងឺ។ លទ្ធភាពទទួលបានទឹកស្អាតដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ក៏ដូចជាការឆ្លងរាលដាលនៃជំងឺផ្សេងទៀតក្នុងតំបន់សំណង់អនាធិបតេយ្យ លំនៅដ្ឋានក្រៅផ្លូវការ និងជំរំជនភៀសខ្លួន។ ជាទូទៅ គ្រោះមហន្តរាយស្តែងឱ្យមានបញ្ហាទឹក។ ក្នុងវិបត្តិកូវីដ-១៩ ស្ត្រីចំណាយពេលយូរជាងបុរសក្នុងការទៅរកអុស និងដងទឹក។ ដូច្នេះ វាបានបង្កើនហានិភ័យនៃការប្រឈមនឹងជំងឺកូវីដ-១៩ ក៏ដូចជាកាត់បន្ថយពេលវេលាសម្រាប់ធ្វើការងារទទួលបានប្រាក់ឈ្នួល ការអប់រំ ឬសម្រាក។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១០ កាត់បន្ថយវិសមភាព**

ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ភាគច្រើននៃប្រជាជនដែលមានការងារធ្វើ ប្រឡូកក្នុងការងារក្រៅផ្លូវការ ហើយកង្វះកិច្ចគាំពារសង្គមបានធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះ។ ស្ត្រីក្នុងតំបន់នេះមានលទ្ធភាពទទួលបាន និងគ្របដណ្តប់ដោយការធានារ៉ាប់រងសង្គម ជំនួយ និងកម្មវិធីការងារ តិចជាងបុរស។ វិបត្តិកូវីដ-១៩ បាន និងកំពុងបង្កើនភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គមយ៉ាងគំហុក។ តាមការប៉ាន់ស្មានគឺប្រជាជនចំនួន ៨៣% ដែលបានបាត់បង់ការងារ ឬមិនធ្វើការ មិនបានទទួលអត្ថប្រយោជន៍និកម្មភាព ឬជំនួយផ្សេងទៀតពីរដ្ឋាភិបាលឡើយ។ សម្រាប់ស្ត្រី តួលេខនេះគឺ ៨៤%។ ស្ត្រី និងក្មេងស្រីភាគច្រើនដែលមកពីតំបន់ងាយរងគ្រោះបំផុត និងទទួលបានការការពារតិចបំផុត (ដូចជា ជនក្រីក្រ និងជនដែលត្រូវបានផាត់ចេញពីសង្គម កម្មករ និងផលិតករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពលករទេសន្តរប្រវេសន៍ អ្នកប្រឈមនឹងការរើសអើង និងអ្នករស់នៅក្នុងស្ថានភាពប្រឈម ជម្លោះ និងការកើតមានគ្រោះមហន្តរាយធម្មជាតិជាច្រើនលើកច្រើនសា) កំពុងទទួលរងផលប៉ះពាល់កាន់តែខ្លាំងដោយសារការជំពាក់បំណុល និងទម្រង់ផ្សេងទៀតនៃការងារដោយបង្ខំ។ ដូច្នេះ វិបត្តិនេះនឹងធ្វើឱ្យពួកគេកាន់តែងាយប្រឈមនឹងហានិភ័យនៃពលកម្មកុមារ ការងារដោយបង្ខំ ការរើសអើងក្នុងការងារ និងមុខរបរ និងការមិនទទួលបានសិទ្ធិអំណាច។

ការស្រាវជ្រាវ និងនវានុវត្តន៍ដែលជំរុញឱ្យមានការផ្លាស់ប្តូរបច្ចេកវិទ្យានិងការរចនាហេដ្ឋារចនាសម្ព័ន្ធ នៅតែគ្របដណ្តប់ដោយបុរស ទោះបីជាស្ត្រីមានកម្រិតអប់រំកាន់តែខ្ពស់ក៏ដោយ។ ការធានាថា ហេដ្ឋារចនាសម្ព័ន្ធឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី មានសារៈសំខាន់សម្រាប់សមភាពយេនឌ័រ។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលផ្តោតការយកចិត្តទុកដាក់លើយេនឌ័រ និងពិការភាព ជួយការពារស្ត្រីក្នុងពេលកើតមានគ្រោះមហន្តរាយ សម្រួលដល់ការងារថែទាំដែលមិនទទួលបានប្រាក់ឈ្នួល និងការទទួលខុសត្រូវរបស់ស្ត្រី និងក្មេងស្រីក្នុងគ្រួសារ និងពង្រីកជម្រើសរបស់ពួកគេដើម្បីឱ្យពួកគេ និងក្រុមគ្រួសារអាចរួចផុតពីភាពក្រីក្រ។

ឧ- ក្នុងតំបន់ជនបទជាច្រើននៅបង់ក្លាដេស ភាគច្រើននៃផ្ទះដែលសង់ពីភក់ ត្រូវបានបំផ្លាញក្នុងស្ថានភាពជាំទឹក។ ការរំលោភបំពានផ្លូវភេទក្នុងជម្រកដែលរចនាមិនបានល្អសម្រាប់ទប់ទល់នឹងព្យុះកំបុតត្បូងជាមូលហេតុសំខាន់ដែលបង្ខំឱ្យស្ត្រី និងក្មេងស្រីភាគច្រើនមិនជ្រកកោនក្នុងទម្រកទាំងនោះ។ ចំណុចនេះបានបង្កភាពងាយរងគ្រោះក្នុងសង្គមចំពោះស្ត្រីដែលជ្រកកោនលើទំនប់ការពារទឹក ពោលគឺស្ត្រីត្រូវរស់នៅកណ្តាលវាលដោយគ្មានភាពឯកជន និងការការពារសម្រាប់ខ្លួនឯង និងកូន។ ការបាត់បង់ជម្រក និងមូលដ្ឋានអនាម័យបានក្លាយជាក្តីកង្វល់ដ៏ធំសម្រាប់ស្ត្រី និងក្មេងស្រី ព្រោះពួកគេមិនអាចបន្ទោរបង់ពាសវាលពាសកាលតាមដងទន្លេបានទេ។ ជារឿយៗ ស្ត្រី និងក្មេងស្រីត្រូវរង់ចាំរហូតដល់ពេលព្រលប់ និងត្រូវប្រឈមនឹងស្ថានភាពដែលគ្មានអនាម័យ គ្មានសន្តិសុខ និងគ្មានសុវត្ថិភាព។

ភាពប្រសព្វគ្នានៃអត្តសញ្ញាណដែលជួបការលំបាកក្នុងយេនឌ័រចម្រុះ បានធ្វើឱ្យក្រុមដែលងាយរងគ្រោះបំផុត ប្រឈមនឹងហានិភ័យខ្លាំងបំផុត ដូចជា ជនមានពិការភាព ចាស់ជរា ទារក និងកុមារ ពលករទេសន្តរប្រវេសន៍ និងកម្មករក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជនគ្មានប្រទេស ជនជាតិដើមភាគតិច ក្រុមសាសនា

ភាគតិច និងក្រុមជាតិពន្ធុភាគតិច ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន អ្នកគ្មានដីធ្លី និងជនក្រីក្រដែលរស់នៅទីប្រជុំជន និងអ្នកមានផ្ទុកមេរោគអេដស៍។ល។

គ្រោះមហន្តរាយបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើស្ត្រី និងក្មេងស្រី ដោយសារតែពួកគេមានស្ថានភាពសេដ្ឋកិច្ចសង្គមទាបជាងបុរស និងក្មេងប្រុស លទ្ធភាពទាបក្នុងការទទួលបានការងារផ្តល់ប្រាក់ឈ្នួល អំណាចតិចក្នុងការធ្វើការសម្រេចចិត្ត និងកង្វះលទ្ធភាពទទួលបានព័ត៌មាន និងការជូនដំណឹងជាមុន កង្វះការគ្រប់គ្រង និងលទ្ធភាពទទួលបានធនធានសេដ្ឋកិច្ច ច្បាប់ដែលមានលក្ខណៈរើសអើង កង្វះការវិនិយោគ និងកម្រិតខ្ពស់នៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១១ ទីក្រុង និងសហគមន៍ដែលមាននិរន្តរភាព

ស្ត្រីដែលរស់នៅក្នុងសំណង់អនាធិបតេយ្យ មានស្ថានភាពដុនដាបជាងបុរសដែលរស់នៅក្នុងសំណង់អនាធិបតេយ្យ និងស្ត្រីដែលមិនរស់នៅក្នុងសំណង់អនាធិបតេយ្យ ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានការងារ មូលដ្ឋានសុខាភិបាល លំនៅដ្ឋានជាប់លាប់ និងការបញ្ចប់ការអប់រំ។ ជំងឺកូវីដ-១៩ កំពុងធ្វើឱ្យបញ្ហានេះកាន់តែរីកធំ និងបង្កើនភាពក្រីក្រធ្ងន់ធ្ងរ។ ការងាររបស់ស្ត្រីភាគច្រើនដែលរស់នៅក្នុងសំណង់អនាធិបតេយ្យហាក់ផ្តល់ប្រាក់ឈ្នួលទាប មានលក្ខណៈបណ្តោះអាសន្ន ធ្វើឱ្យហត់នឿយ និងប្រឈមនឹងការកេងប្រវ័ញ្ច ដូច្នេះ វាធ្វើឱ្យស្ត្រីក្លាយជា "អ្នកធ្វើការដែលមានជីវភាពក្រីក្រ" (មានការងារធ្វើ ប៉ុន្តែរកចំណូលបានតិចជាង ១,៩០ ដុល្លារក្នុងមួយថ្ងៃ)។ វិបត្តិកូវីដ-១៩ បានធ្វើឱ្យស្ថានភាពរស់នៅរបស់អ្នករស់នៅក្នុងសំណង់អនាធិបតេយ្យកាន់តែដុនដាប។ ពួកគេមានការលំបាកក្នុងការអនុវត្តវិធានការការពារ ដោយសារភាពណែនតាន់តាប់ និងកង្វះសេវាមូលដ្ឋាន ដូចជា ទឹកស្អាត និងអនាម័យ។ ស្ត្រី និងក្មេងស្រីដែលរស់នៅក្នុងសំណង់អនាធិបតេយ្យ បានលើកឡើងពីការកើនឡើងនៃអំពើហិង្សាក្នុងគ្រួសារ ការបាត់បង់ការងារ ការកេងប្រវ័ញ្ច និងកិច្ចការថែទាំដែលមិនទទួលបានប្រាក់ឈ្នួល។

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៣ សកម្មភាពអាកាសធាតុ

ស្ត្រី និងក្មេងស្រីក្នុងតំបន់នេះ ពឹងផ្អែកចម្បងលើការធ្វើកសិកម្ម និងការនេសាទទ្រង់ទ្រាយតូច និងទទួលខុសត្រូវលើការដងទឹក និងរកអុស។ ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលអវិជ្ជមានលើបរិចិញ្ចឹមជីវិត ប្រាក់ចំណូល និងឱកាសការងាររបស់ស្ត្រី ដោយបានបង្កហានិភ័យលើសុខភាព និងរឹតត្បិតពេលវេលារបស់ស្ត្រី។ ទន្ទឹមនឹងនេះ ស្ត្រីក៏ដើរតួនាទីសំខាន់ផងដែរក្នុងការកាត់បន្ថយផលប៉ះពាល់ និងការបន្សាំខ្លួនទៅនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ។ ជារៀងរាល់ឆ្នាំ គេប៉ាន់ស្មានថា ប្រជាជនចំនួន ២២,៧ លាននាក់ដែលភាគច្រើនជាស្ត្រី និងកុមារ ត្រូវបានផ្លាស់ទីលំនៅដោយសារព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកកាន់តែច្រើនរស់នៅក្នុងស្ថានភាពផ្លាស់ទីលំនៅកាន់តែយូរ ជាទីដែលពួកគេត្រូវរ៉ាប់រងកូនក្នុងបន្ទុក បញ្ហាអសន្តិសុខស្បៀង និងសេដ្ឋកិច្ច និងប្រឈមនឹងអំពើហិង្សា។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៤ និងទី ១៥ ជីវិតនៅក្រោមទឹក និងជីវិតនៅលើដី**

ភាពហិចហោចប្រព័ន្ធអេកូឡូស៊ី បានកាត់បន្ថយភាពធន់របស់សហគមន៍ និងប្រជាជាតិនានា តាមរយៈការធ្វើឱ្យសហគមន៍ និងប្រជាជាតិទាំងនោះប្រឈមនឹងហានិភ័យ និងផលប៉ះពាល់នៃគ្រោះមហន្តរាយកាន់តែច្រើន។ ស្ត្រីដែលកសិករខ្នាតតូច និងស្ត្រីជាអ្នកនេសាទ ហាក់មិនសូវមានសមត្ថភាពបន្សាំ ដើម្បីប្រឈមមុខជាមួយនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ដូចជា ផលប៉ះពាល់អវិជ្ជមានលើគុណភាព និងភាពអាចរកបានទឹក ក៏ដូចជាធនធានតាមតំបន់ឆ្នេរ និងធនធានសមុទ្រ។ ស្ត្រី ជាពិសេសស្ត្រីមកពីគ្រួសារដែលគ្មានដីធ្លី និងគ្រួសារមិនសូវមានដីធ្លី អាស្រ័យផលពីព្រៃឈើ តាមរយៈការប្រមូលផលិតផលដែលមានអាយុកាលប្រើប្រាស់ខ្លី ដូចជា អុស ចំណីសត្វ និងអាហារ និងអនុផលព្រៃឈើផ្សេងទៀត (ដោយសារពួកគេមានភារៈចម្អិន មើលគោក្របី បំពេញបន្ថែមអាហារូបត្ថម្ភក្នុងគ្រួសារ និងធ្វើកិច្ចការពាក់ព័ន្ធ។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៦ សន្តិភាព និងយុត្តិធម៌**

ប្រទេសចំនួន ៤៩ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មិនសូវមានច្បាប់ដែលការពារស្ត្រីពីអំពើហិង្សាក្នុងគ្រួសារ។ អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ មានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងពេលកើតមានគ្រោះមហន្តរាយ និងវិបត្តិ ប៉ុន្តែមិនត្រូវបានរាយការណ៍ញឹកញាប់នោះទេ។ គ្មានទំនាក់ទំនងគ្នារវាង NDMOs និងក្រសួងកិច្ចការនារី ហើយអំពើហិង្សាផ្លូវភេទ និងពាក់ព័ន្ធនឹងយេនឌ័រ នៅតែមិនត្រូវបានកំណត់ក្រោមអាណត្តិនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ក្នុងពេលកើតមានគ្រោះមហន្តរាយ។ ស្ត្រី និងក្មេងស្រីជាច្រើនប្រឈមនឹងហានិភ័យខ្ពស់នៃអំពើហិង្សាក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ ដែលស្ថានភាពនេះកាន់តែដុនដាបនៅពេលដែលគ្រោះមហន្តរាយ ធ្វើឱ្យមានការផ្លាស់ទីលំនៅប្រជាជនយ៉ាងច្រើន។ ស្ត្រីដែលជាជនភៀសខ្លួន និងស្ត្រីដែលត្រូវបានផ្លាស់ទីលំនៅក្នុងប្រទេសដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ ងាយរងគ្រោះដោយសារហានិភ័យចម្រុះ។

ការការពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា ជាចំណុចស្នូលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលដៅទី ១៦ និងចំណុចដៅ ១៦- ២ គូសបញ្ជាក់ពីភាពចាំបាច់ក្នុងការខិតខំបញ្ឈប់ "ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរ និងគ្រប់ទម្រង់នៃអំពើហិង្សា និងការធ្វើទារុណលើកុមារ"។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅប្រទេសកម្ពុជា**

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពគឺជាការអំពាវនាវឱ្យធ្វើសកម្មភាពជាសាកលដើម្បីបញ្ចប់ភាពក្រីក្រ ការពារបរិស្ថាន និងអាកាសធាតុរបស់ផែនដី ហើយធានាថាមនុស្សនៅគ្រប់ទីកន្លែងអាចទទួលបានសន្តិ



ភាព និងវិបុលភាព។ ទាំងនេះគឺជាគោលដៅដែលអង្គការសហប្រជាជាតិកំពុងបំពេញបេសកកម្មការងារនៅកម្ពុជា។

- **ឧបសម្ព័ន្ធ គ ចក្ខុវិស័យអាស៊ាន ឆ្នាំ ២០២៥**
    - ការសំឡឹងឆ្ពោះទៅមុខទាំងអស់គ្នា ប្រមើលមើលការឆ្ពោះទៅសម្រេចបានសហគមន៍មួយដែលកាន់តែមានបរិយាបន្ន។ ការណ៍នេះពាក់ព័ន្ធនឹងការលើកកម្ពស់លទ្ធភាពទទួលបានឱកាសប្រកបដោយសមធម៌សម្រាប់ប្រជាជនអាស៊ាន និងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សរបស់ស្ត្រី កុមារ យុវជន ចាស់ជរា ជនមានពិការភាព ពលករ ទេសន្តរប្រវេសន៍ ក្រុមជាតិពន្ធុភាគតិច និងក្រុមងាយរងគ្រោះ និងជួបការលំបាក ក្នុងវដ្តជីវិតរបស់ពួកគេ ដោយផ្អែកតាមអភិក្រមវដ្តជីវិត និងការអនុលោមតាមគោលការណ៍ផ្អែកលើសិទ្ធិមនុស្សក្នុងការលើកកម្ពស់គោលនយោបាយ និងកម្មវិធីអាស៊ានក្នុងសសរស្តម្ភ ASCC។ ចក្ខុវិស័យនេះលើកឡើងពីការ "បង្កើនគំនិតផ្តួចផ្តើមថ្នាក់តំបន់ និងការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើង (ក្នុងស្ថាប័ន ឬក្រៅស្ថាប័ន) ការកេងប្រវ័ញ្ច ការជួញដូរ ការអនុវត្តដែលបង្កគ្រោះថ្នាក់ និងអំពើហិង្សា និងការរំលោភបំពានកុមារ ស្ត្រី ជនមានពិការភាព យុវជន ពលករទេសន្តរប្រវេសន៍ ចាស់ជរា និងជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្រុមជាតិពន្ធុភាគតិច និងក្រុមងាយរងគ្រោះ និងជួបការលំបាក" (ទំ- ១០៩)។
    - មានផែនការបង្កើតយុទ្ធសាស្ត្រថ្នាក់តំបន់ និងបង្កើនសមត្ថភាពស្ថាប័នក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ កម្មវិធី និងថវិកាអាស៊ាន នៅទូទាំងសសរស្តម្ភ និងវិស័យនានា។ ចក្ខុវិស័យនេះមានគោលបំណងគាំទ្រដល់គំនិតផ្តួចផ្តើមរបស់រដ្ឋជាសមាជិកអាស៊ាន ក្នុងការពង្រឹង

មូលដ្ឋានទិន្នន័យជាតិដែលត្រូវបានបែងចែកតាមយេនឌ័រ និងអាយុ និងការវិភាគ ដូចជា ភាពក្រីក្រ និងសមធម៌ និងបង្កើតមូលដ្ឋានទិន្នន័យថ្នាក់តំបន់ដែលអាចជឿទុកចិត្តបានសម្រាប់វិស័យសំខាន់ៗ ដើម្បីគាំទ្រដល់គោលនយោបាយ និងកម្មវិធីអាស៊ាន (ឯកសារគោលរបស់ ASCC ឆ្នាំ ២០២៥, A2 វិធានការយុទ្ធសាស្ត្រ vii។ B2 វិធានការយុទ្ធសាស្ត្រ ii, v និង B3)។ ចក្ខុវិស័យអាស៊ានក៏មានគោលបំណងធ្វើការសិក្សាដើម្បីលើកកម្ពស់ការបញ្ជ្រាបយេនឌ័រក្នុងការកសាងសន្តិភាព ដំណើរការសន្តិភាព និងការដោះស្រាយជម្លោះផងដែរ (ឯកសារគោលរបស់ APSC ឆ្នាំ ២០២៥, A- 3- 2 (v) និង B- 4- 4 (i)) និង B- 5- 5, D- 2- 2 (iii) និងឯកសារគោលរបស់ AEC ឆ្នាំ ២០២៥ ស្តីពីភាពធន់ D1- 69- 1)។







- **ឧបសម្ព័ន្ធ ឃ កម្មវិធីផែនការការងារ** AADMER (**កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់**) **ឆ្នាំ ២០២១-២០២៥**





សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ ។
រដ្ឋជាសមាជិករួមមាន : ប្រ៊ុយណេ ដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ារ សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។ លេខាធិការដ្ឋានអាស៊ាន មានទីស្នាក់ការប្រចាំនៅទីក្រុង ហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង :
និយកដ្ឋានសង្គមស៊ីវិល និងទំនាក់ទំនងសាធារណៈ
លេខាធិការដ្ឋានអាស៊ាន
៧០A, ចាឡាន, ស៊ីស៊ីងម៉ង្គារ៉ាចា
ហ្សាកាតា ១២១១០
ប្រទេសឥណ្ឌូនេស៊ី
ទូរស័ព្ទ : (៦២.២១) ៧២៤-៣៣៧២, ៧២៦-២៩៩១
ទូរសារ : (៦២.២១) ៧៣៩-៨២៣៤, ៧២៤-៣៥០៤
សារអេឡិចត្រូនិច : public.div@asean.org

ព័ត៌មានទូទៅស្តីពីសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ត្រូវបានបង្ហាញ
នៅក្នុងគេហទំព័រសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ : www.asean.org

ឯកសារដែលបានបោះពុម្ពផ្សាយ

កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់
លេខាធិការដ្ឋានអាស៊ាន
ហ្សាកាតា : លេខាធិការដ្ឋានអាស៊ាន ខែកុម្ភៈ ឆ្នាំ២០១០

បោះពុម្ព ២ពណ៌ ចំនួន ២៤ទំព័រ ទំហំ ១៥ x ២១ ស.ម

ចំណាត់ថ្នាក់លេខ : ៣៦៣.៣៤៨០៦៨
ចំណងជើង : ១. កិច្ចព្រមព្រៀងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
២. កិច្ចព្រមព្រៀងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ស្តីពីការគ្រប់គ្រងការជួយសង្គ្រោះបន្ទាន់

លេខសៀវភៅជាស្តង់ដារ : ៩៧៩-៣៤៩៦-២៤-x

បោះពុម្ពលើកទី ១ : ខែកក្កដា ឆ្នាំ២០០៦
បោះពុម្ពឡើងវិញលើកទី ១ : ខែមករា ឆ្នាំ២០០៧
បោះពុម្ពឡើងវិញលើកទី ២ : ខែឧសភា ឆ្នាំ២០០៨
បោះពុម្ពឡើងវិញលើកទី ៣ : ខែធ្នូ ឆ្នាំ២០០៩
បោះពុម្ពឡើងវិញលើកទី ៤ : ខែកុម្ភៈ ឆ្នាំ២០១០
បោះពុម្ពនៅប្រទេសឥណ្ឌូនេស៊ី

បោះពុម្ពលើកទី ១ ជាភាសាខ្មែរ ខែមិថុនា ឆ្នាំ២០១១ ដោយក្រុមសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (A.P.G)

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

រាល់អត្ថបទរបស់សៀវភៅនេះ អាចដកស្រង់សំរាប់ការបោះពុម្ពឡើងវិញតាមអង្គភាពត្រឹមត្រូវ និងសមស្របតាមច្បាប់ដើម

រក្សាសិទ្ធិដោយលេខាធិការដ្ឋានអាស៊ាន ២០០៩

ផ្តោតសំខាន់លើលទ្ធផលចុងក្រោយនៃការបង្កើនភាពអង់អាចរបស់ក្រុមងាយរងគ្រោះ និងលទ្ធផលរំពឹងទុកសំខាន់ៗដែលរួមបញ្ចូលយេនឌ័រ និងបរិយាបន្នសង្គមក្នុងកម្មវិធីអាទិភាព។

**១- សេចក្តីប្រកាសទីក្រុងហាណូយស្តីពីការលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍរបស់ស្ត្រី និងកុមារនៅអាស៊ាន (២០១០)**

កត់សម្គាល់ថា គម្លាតក្នុងការអភិវឌ្ឍ អំពើហិង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ច ការប្រែប្រួលអាកាសធាតុ ភាពក្រីក្រ និងការរើសអើងយេនឌ័រ នៅតែជាបញ្ហាប្រឈមធំៗដែលរារាំងការសម្រេចបានសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី និងកុមារនៅអាស៊ាន។ សេចក្តីប្រកាសនេះអំពាវនាវឱ្យមានការលើកស្ទួយអាស៊ានឱ្យក្លាយជាតំបន់ដែលផ្តោតការយកចិត្តទុកដាក់លើប្រជាជន ជាទីដែលស្ត្រី និងកុមារចូលរួមក្នុង និងទទួលបានអត្ថប្រយោជន៍ពីដំណើរការសមាហរណកម្មអាស៊ាន។ សេចក្តីប្រកាសនេះសម្រេចជំរុញកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានតាមរយៈកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ យ៉ាងស្អិតរមួតលើការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងសិទ្ធិកុមារ ជាពិសេសស្ត្រី និងកុមារដែលរស់នៅក្នុងស្ថានភាពក្រីក្រ និងងាយរងគ្រោះ ដូចជា ស្ថានភាពក្នុងគ្រោះមហន្តរាយ និងក្នុងតំបន់ដែលរងផលប៉ះពាល់ដោយសារជម្លោះ។ វិធានការរួមមាន ការរៀបចំការសិក្សា ការវាយតម្លៃ និងការដាក់សំណើដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលសេដ្ឋកិច្ច និងបរិស្ថាន ដូចជា ការប្រែប្រួលអាកាសធាតុ លើស្ត្រី និងកុមារ។

**២-សេចក្តីប្រកាសទីក្រុងវៀងចន្ទស្តីពីការលើកកម្ពស់ទស្សនៈយេនឌ័រនិងភាពជាដៃគូរបស់ស្ត្រីនៅអាស៊ានដើម្បីនិរន្តរភាពបរិស្ថាន(២០១២)**

ប្រកាសពីការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការលើកកម្ពស់កិច្ចការពារ និងសុវត្ថិភាពស្ត្រីឱ្យបានគ្រប់គ្រាន់ ក្នុងពេលកើតមានគ្រោះមហន្តរាយធម្មជាតិ និងមុខសញ្ញាគ្រោះថ្នាក់ដោយសារការប្រែប្រួលអាកាសធាតុ ចំណេះដឹង និងជំនាញរបស់ស្ត្រីក្នុងការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយ/ការសម្រាលហានិភ័យគ្រោះមហន្តរាយ ការគ្រប់គ្រងបរិស្ថាន និងការអភិរក្សជីវចម្រុះ ការអភិរក្សដី និងបច្ចេកវិទ្យាសមស្របក្នុងការប្រើប្រាស់ដីក្រោមកម្មវិធីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ (រេដបូក) និងការធានាថា ការអនុវត្តកម្មវិធីរេដបូកឆ្លើយតបនឹងតម្រូវការយេនឌ័រ សមត្ថភាពរបស់ស្ត្រីក្នុងការប្រឈមមុខជាមួយផលប៉ះពាល់សង្គម និងបរិស្ថានដោយសារការកាប់បំផ្លាញព្រៃឈើ និងការបំប្លែងដីកសិកម្មសម្រាប់ឧស្សាហូបនីយកម្ម និងនគរូបនីយកម្ម លទ្ធភាព ភាពម្ចាស់ការ និងការគ្រប់គ្រងរបស់ស្ត្រីលើធនធានដើម្បីទ្រទ្រង់របរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ការបញ្ជ្រាបយេនឌ័រ និងការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងការបង្កើត ការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ និងកម្មវិធីបរិស្ថាននៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ការចូលរួមពេញលេញ និងយ៉ាងសំខាន់របស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ជាពិសេសពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

និងការគ្រប់គ្រងធនធានធម្មជាតិនៅគ្រប់កម្រិត វិធានការច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីស្ដីពីនិរន្តរភាពបរិស្ថានសម្រាប់ស្ត្រី ជាពិសេសស្ត្រីមកពីក្រុមងាយរងគ្រោះ និងក្រុមជួបការលំបាក។

**៣-សេចក្ដីប្រកាសស្ដីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងការលុបបំបាត់អំពើហិង្សា លើកុមារក្នុងតំបន់អាស៊ាន (២០១៣)**

ទទួលស្គាល់សារៈសំខាន់នៃការបង្កើនកិច្ចខិតខំប្រឹងប្រែង របស់រដ្ឋជាសមាជិកអាស៊ានក្នុងការទប់ស្កាត់ និងការពារស្ត្រី និងកុមារពី និងឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចស្ត្រី និងកុមារ ជាពិសេសស្ត្រី និងកុមារដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ (ដូចជា ស្ត្រី និងកុមារដែលត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ ស្ត្រី និងកុមារមានពិការភាព ស្ត្រី និងកុមារដែលមានផ្ទុក និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ស្ត្រី និងកុមារដែលល្មើសច្បាប់ ការជួញដូរស្ត្រី និងកុមារ ស្ត្រី និងកុមារដែលស្ថិតក្នុងគ្រោះមហន្តរាយ ស្ត្រី និងកុមារដែលស្ថិតក្នុងជម្លោះប្រដាប់អាវុធ ស្ត្រី និងកុមារដែលស្ថិតក្នុងជំរំជនភៀសខ្លួន ស្ត្រី និងកុមារដែលកំពុងធ្វើបំលាស់ទី ស្ត្រី និងកុមារដែលគ្មានប្រទេស ស្ត្រី និងកុមារទេសន្តរប្រវេសន៍ ស្ត្រី និងកុមារដែលមកពីក្រុមជាតិពន្ធ និងក្រុមជនជាតិដើមភាគតិច។ សេចក្ដីប្រកាសនេះកត់សម្គាល់ថា អំពើហិង្សាលើស្ត្រី និងអំពើហិង្សាលើកុមារ កើតឡើងនៅដំណាក់កាលនានានៃវដ្ដជីវិត មិនថានៅផ្ទះ នៅសាលារៀន នៅកន្លែងធ្វើការ នៅកន្លែងសាធារណៈ ឬកន្លែងឯកជន (រួមទាំងក្នុងប្រព័ន្ធអ៊ីនធឺណិត) ដោយសារភាពលម្អៀងយេនឌ័រ និងការអនុវត្តក្នុងប្រពៃណីដែលមានលក្ខណៈរើសអើង និងបង្កគ្រោះថ្នាក់។ ចាំបាច់ត្រូវលុបបំបាត់អំពើហិង្សានេះ ព្រោះវាធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ស្ត្រី និងកុមារ។ សេចក្ដីប្រកាសនេះ ចែងពីវិធានការនានាសម្រាប់ការបង្កើតប្រព័ន្ធដែលឆ្លើយតបនឹងយេនឌ័រ។

**៤- ផែនការសកម្មភាពតំបន់អាស៊ានស្ដីពីការលុបបំបាត់អំពើហិង្សាលើកុមារ**

សេចក្ដីប្រកាសនេះ ចែងពីសកម្មភាពទាំងនៅថ្នាក់តំបន់និងថ្នាក់ជាតិ ១)- បង្កើតយុទ្ធសាស្ត្រទប់ស្កាត់ជារួម និងគ្រប់ជ្រុងជ្រោយដែលផ្ដោតការយកចិត្តទុកដាក់លើកុមារ ដែលអាចអនុវត្តបានក្នុងបរិបទចម្រុះ (ការអភិវឌ្ឍ វិបត្តិ ជម្លោះ ការត្រៀមខ្លួនទប់ទល់គ្រោះអាសន្ន និងគ្រោះមហន្តរាយ) ដូចជា ការបង្កើតប្រព័ន្ធគាំពារគ្រប់ជ្រុងជ្រោយដែលផ្ដោតការយកចិត្តទុកដាក់លើកុមារ និងគិតគូរពីយេនឌ័រ (ថ្នាក់ជាតិ) ២)- បង្កើតគោលការណ៍ណែនាំថ្នាក់តំបន់ដោយអនុលោមតាមស្តង់ដាអន្តរជាតិ ស្ដីពីប្រព័ន្ធគាំពារកុមារ ដូចជា ការថែទាំដែលមានគុណភាព កិច្ចការពារ ការស្ដារនីតិសម្បទា និងសមាហរណកម្មឡើងវិញ សេវាគាំទ្រ ការដោះស្រាយ និងការផ្ដល់សំណងជំងឺចិត្តសមស្របដល់ជនរងគ្រោះជាកុមារក្នុងគ្រប់ស្ថានភាពទាំងអស់ (ឧ- គ្រោះមហន្តរាយធម្មជាតិ អស្ថិរភាពសង្គម-នយោបាយ និងជម្លោះប្រដាប់អាវុធ ថ្នាក់តំបន់)។

**៥- សេចក្ដីប្រកាសអាស៊ានស្ដីពីការពង្រឹងកិច្ចគាំពារសង្គម (២០១៦)**

គោលបំណងមួយក្នុងចំណោមគោលបំណងទាំង ៤ របស់សេចក្ដីប្រកាសនេះគឺការសម្រេចបានបរិយាបន្ន និងការបង្កើនលទ្ធភាពប្រកបដោយសមធម៌របស់ក្រុមក្រីក្រ ក្រុមងាយប្រឈមនឹងហានិភ័យ និងក្រុម

ងាយរងគ្រោះ ដែលរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមជនមានពិការភាព ចាស់ជរា យុវជន ស្ត្រី កុមារ អ្នកខ្វះអាហារូបត្ថម្ភ ជនរងគ្រោះដោយសារគ្រោះមហន្តរាយ ពលករទេសន្តរប្រវេសន៍ ក្នុងការទទួលបានឱកាស និងកិច្ចគាំពារសង្គម។ សេចក្តីប្រកាសនេះ លើកឡើងទៀតថា សន្តិសុខសង្គមគួរបន្សាំនឹងហានិភ័យផ្សេងៗ ដូចជា ហានិភ័យសង្គម ហានិភ័យដែលលេចឡើង និងភាពងាយរងគ្រោះក្នុងតំបន់ ដូចជា ការប្រែប្រួលសេដ្ឋកិច្ច និងទីផ្សារការងារ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងវិបត្តិសេដ្ឋកិច្ច។ ផែនការសកម្មភាពរួមបញ្ចូលការបង្កើនយន្តការសំណាញ់សុវត្ថិភាពសង្គម ក្នុងពេលកើតមានគ្រោះមហន្តរាយ។

**៦-សេចក្តីប្រកាសអាស៊ាន ស្តីពីការពង្រឹងការអប់រំសម្រាប់កុមារ និងយុវជនក្រៅសាលា (OOSCY)**

បញ្ជាក់ពីការទទួលខុសត្រូវចម្បងរបស់រដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ានទាំងអស់ក្នុងការអនុវត្តសិទ្ធិទទួលបានការអប់រំ ខិតខំអនុវត្តវិធានការគ្រប់ជ្រុងជ្រោយ ដូចជា ច្បាប់ គោលនយោបាយ និងផែនការសកម្មភាពពាក់ព័ន្ធដើម្បីធានានូវ ក) ការអប់រំដែលផ្អែកលើបរិយាបន្ន (ការអប់រំបរិយាបន្ន) ដោយអនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញា CEDAW និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដែលបំពេញបន្ថែមដោយការសម្រេចគោលដៅដែលកំណត់ដោយក្របខណ្ឌសកម្មភាពអប់រំឆ្នាំ ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីពង្រឹងប្រព័ន្ធអប់រំសម្រាប់កុមារ និងយុវជន រួមទាំងកុមារ និងយុវជនក្រៅសាលា ដោយពិចារណាពីបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងយេនឌ័រ ភូមិសាស្ត្រ ជាតិពន្ធុ ភាពចម្រុះ ភាពក្រីក្រ ទេសន្តរប្រវេសន៍ ស្ថានភាព និងភាពគ្មានប្រទេស ភាសា ការជួបការលំបាក ពិការភាព គ្រោះអាសន្ន (ដូចជា ជម្លោះ និងគ្រោះមហន្តរាយធម្មជាតិ) និងភាពងាយរងគ្រោះ។

**៧- ផែនការសកម្មភាពតំបន់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ**

សេចក្តីប្រកាសនេះចែងពីសកម្មភាពទាំងនៅថ្នាក់តំបន់ និងថ្នាក់ជាតិ ១)- បង្កើតយុទ្ធសាស្ត្រទប់ស្កាត់ជារួម និងគ្រប់ជ្រុងជ្រោយដែលផ្តោតការយកចិត្តទុកដាក់លើកុមារ ដែលអាចអនុវត្តបានក្នុងបរិបទចម្រុះ (ការអភិវឌ្ឍ វិបត្តិ ជម្លោះ ការត្រៀមខ្លួនទប់ទល់គ្រោះអាសន្ន និងគ្រោះមហន្តរាយ) ដូចជា ការបង្កើតប្រព័ន្ធគាំពារគ្រប់ជ្រុងជ្រោយដែលផ្តោតការយកចិត្តទុកដាក់លើកុមារ និងគិតគូរពីយេនឌ័រ (ថ្នាក់ជាតិ) ២)- បង្កើតគោលការណ៍ណែនាំថ្នាក់តំបន់ដោយអនុលោមតាមស្តង់ដាអន្តរជាតិ ស្តីពីប្រព័ន្ធគាំពារកុមារ ដូចជា ការថែទាំដែលមានគុណភាព កិច្ចការពារ ការស្តារនីតិសម្បទា និងសមាហរណកម្មឡើងវិញ សេវាគាំទ្រ ការដោះស្រាយ និងការផ្តល់សំណងជំងឺចិត្តសមស្របដល់ជនរងគ្រោះជាកុមារក្នុងគ្រប់ស្ថានភាពទាំងអស់ (ឧ- គ្រោះមហន្តរាយធម្មជាតិ អស្ថិរភាពសង្គម-នយោបាយ និងជម្លោះប្រដាប់អាវុធ) (ថ្នាក់តំបន់)។

- **ឧបសម្ព័ន្ធ ង ប្រទេសកម្ពុជា**

១- ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (NAP-DRR) ២០១៤-២០១៨ ទទួលស្គាល់ថា ទេសន្តរប្រវេសន៍ងាយនឹងបង្កើនផលវិបាកផ្នែកសង្គម និងសេដ្ឋកិច្ចលើស្ត្រី កុមារ ជនមានពិការភាព និងចាស់ជរាដែលរស់នៅក្នុងគ្រួសារក្រីក្របំផុត។ ក្រុមងាយរងគ្រោះទាំងនេះងាយកើតជំងឺ

បំផុត ព្រោះពួកគេមិនសូវមានធនធាន និងសមត្ថភាពបន្សាំខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជា កង្វះការត្រៀមខ្លួនសម្រាប់ការប្រឈមជាមួយហានិភ័យ និងមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជា ការហិនហោចជីវចម្រុះ អសន្តិសុខស្បៀង និងការកើនឡើងនៃគ្រោះមហន្តរាយ បានបង្កផលប៉ះពាល់លើស្ថានភាពសន្តិសុខដ៏ផុយស្រួយរបស់ស្ត្រី។ តួនាទីយេនឌ័របែបប្រពៃណី និងតួនាទីយេនឌ័រសម័យទំនើប ធ្វើឱ្យស្ត្រីកាន់តែងាយរងគ្រោះ និងមិនសូវមានលទ្ធភាពបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ ផលវិបាកមានភាពធ្ងន់ធ្ងរ ឧ- ការកើនឡើងនៃអំពើហិង្សាលើស្ត្រីក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ ការកើនឡើងនៃការងារថែទាំដែលមិនទទួលបានប្រាក់ឈ្នួល ដូចជា ការដងទឹក និងការរកឥន្ធនៈ ការលំបាកក្នុងទីផ្សារការងារ ការបង្ខំឱ្យក្មេងស្រីបោះបង់ការសិក្សា ភាពដុនដាបនៃសុខភាពបន្តពូជដោយសារការញ៉ាំទឹក និងអាហារមិនគ្រប់គ្រាន់ និងការកើនឡើងនៃការធ្វើទេសន្តរប្រវេសន៍ដោយឥតគ្រោងទុក និងការជួញដូរស្ត្រី និងក្មេងស្រី។ល។

២- ផែនការនារីរតនៈទី ៤ ផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ២០១៤-២០១៨ លើកឡើងថា ស្ត្រីមានពិការភាពងាយនឹងរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារបង្កឡើងដោយជនដែលមិនមែនជាដៃគូ បើធៀបនឹងស្ត្រីគ្មានពិការភាព។ ក្រៅពីនេះ ក្រុមស្រីស្រឡាញ់ស្រី ក្រុមស្រឡាញ់ទាំងពីរភេទ ក្រុមប្តូរយេនឌ័រនៅកម្ពុជា តែងទទួលរងការមាក់ងាយ ការបៀតបៀន និងការរើសអើង ប៉ុន្តែជារឿយៗ គឺគ្មានការគិតគូរ ឬការខ្វាយខ្វល់ចំពោះការទទួលរងការរំលោភបំពាន ឬការរើសអើងទាំងនេះដោយប្រព័ន្ធឆ្លើយតប ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេឡើយ។ ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០០៨-២០១៣) គូសបញ្ជាក់ថា អត្រាមរណភាពកុមារក្នុងអំឡុងគ្រោះទឹកជំនន់គឺខ្ពស់ណាស់។ គ្រោះទឹកជំនន់ធំៗ ដែលបង្កផលប៉ះពាល់លើប្រជាជនយ៉ាងច្រើន កើតឡើងរៀងរាល់ ៥ ឆ្នាំម្តង។ គ្រោះទឹកជំនន់ដ៏អាក្រក់បំផុតក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា បានកើតឡើងក្នុងឆ្នាំ ២០០០ ដែលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរាយការណ៍ថា បានសម្លាប់មនុស្ស ៣៤៧ នាក់ (៨០% ជាកុមារ)។ ក្នុងឆ្នាំ ២០០១ ទឹកជំនន់បានសម្លាប់មនុស្ស ៦២ នាក់ (៧០% ជាកុមារ) និងក្នុងឆ្នាំ ២០០២ បានសម្លាប់មនុស្ស ២៩ នាក់(៤០% ជាកុមារ)។

**ការប្តេជ្ញាចិត្តថ្នាក់ជាតិ និងវឌ្ឍនភាពឆ្ពោះទៅសម្រេចបានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយបែបបរិយាបន្ន**

នៅកម្រិតយុទ្ធសាស្ត្រ និងកម្រិតគោលនយោបាយ កម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធស្ថាប័នជាប្រព័ន្ធ និងធំទូលាយមួយស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជាច្បាប់កំពូលរបស់កម្ពុជា។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ ក្នុងខែ កក្កដា ឆ្នាំ ២០១៧ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណា

ចក្រកម្ពុជាបានចេញសេចក្តីសម្រេចមួយ ដែលបញ្ជាក់យ៉ាងច្បាស់ថា រាល់អនុសញ្ញាអន្តរជាតិទាំងអស់ ដូចជា អនុសញ្ញា CEDAW អនុសញ្ញាស្តីពីសិទ្ធិកុមារ បូករួមនឹងច្បាប់អន្តរជាតិទាំងអស់ផ្សេងទៀតដែលកម្ពុជាបានផ្តល់សច្ចាប័ន សុទ្ធតែអាចអនុវត្តបានដោយផ្ទាល់ក្នុងតុលាការកម្ពុជា។ ការបង្កើនភាពអង់អាចយេនឌ័រ ដូចជា អំពើហិង្សាលើស្រ្តី ក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) ក៏ដូចជាក្របខណ្ឌយុទ្ធសាស្រ្ត និងច្បាប់សវិាង្គស្តីពីវិមជ្ឈការ និងវិសហមជ្ឈការផងដែរ។

ក្នុងខែ មេសា ឆ្នាំ ២០០៤ កម្ពុជាបានកែសម្រួល និងពង្រីកគោលដៅអភិវឌ្ឍសហវត្សរ៍ ឱ្យឆ្លុះបញ្ចាំងពីបរិបទរបស់កម្ពុជា ដូចជា ការបង្កើនភាពអង់អាចយេនឌ័រ។ គោលដៅអភិវឌ្ឍសហវត្សរ៍កម្ពុជា រួមបញ្ចូលសូចនាករ និងចំណុចដៅ ៤ បន្ថែមទៀតស្តីពីការកាត់បន្ថយអំពើហិង្សាលើស្រ្តី។ គោលដៅទាំងនេះអំពាវនាវឱ្យមានការកាត់បន្ថយគ្រប់ទម្រង់នៃអំពើហិង្សាលើស្រ្តី និងអំពើហិង្សាលើកុមារឱ្យបានច្រើនបំផុតត្រឹមឆ្នាំ ២០១៥។ កម្ពុជាស្ថិតក្នុងចំណោមប្រទេសដំបូងគេនៅលើពិភពលោកដែលបញ្ចូលសូចនាករនៃការកាត់បន្ថយអំពើហិង្សាលើស្រ្តីក្នុងផែនការអភិវឌ្ឍន៍ជាតិ។ គោលដៅអភិវឌ្ឍសហវត្សរ៍កម្ពុជាត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់កម្ពុជា ២០០៦-២០១០ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នភាព ២០០៩-២០១៣។ ការកាត់បន្ថយអំពើហិង្សាលើស្រ្តីជាផ្នែកដ៏សំខាន់មួយនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិនេះ។ ក្នុងចំណោមចំណុចដៅទាំង ៩ និងសូចនាករទាំង ១៤ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥ រដ្ឋាភិបាលកម្ពុជាបានបញ្ចូលចំណុចដៅ ៧ និងសូចនាករ ១២ ទៅក្នុងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

កម្ពុជាបានតម្រឹមតម្រង់រវាងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥ ស្តីពីសមភាពយេនឌ័រ និងការរួមចំណែករបស់ជាតិ ចំណុចដៅ សកម្មភាព វិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងអាកាសធាតុ។ កម្ពុជាគ្រោងនឹងកាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ ភាពងាយរងគ្រោះតាមតំបន់ ភាពងាយរងគ្រោះយេនឌ័រ និងហានិភ័យសុខភាពដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) លើកឡើងថា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបង្កើតប្រព័ន្ធទិន្នន័យការបាត់បង់ និងខូចខាតបង្កដោយគ្រោះមហន្តរាយនៅកម្ពុជា (CamDi) និងបានវិភាគ និងបង្កើតទិន្នន័យបែងចែកជាប្រភេទស្តីពីការបាត់បង់ និងខូចខាតបង្កដោយគ្រោះមហន្តរាយ (២០០៥-២០១៧) ក្នុងប្រទេសកម្ពុជា។

ក- ច្បាប់ គោលនយោបាយ ផែនការ និងការកំណត់ក្នុងស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

១- ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០១៩-២០២៣) កំណត់ពីលទ្ធផលរំពឹងទុកដូចខាងក្រោម

- រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានបង្កើតឡើង និងកែលម្អទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទស្សនៈយេនឌ័រ តម្លាភាព គណនេយ្យភាព និងការចូលរួមក្នុងបណ្តាញដែលមានស្រាប់។
- ការយល់ដឹងពីហានិភ័យគ្រោះមហន្តរាយ និងសមត្ថភាពត្រៀមខ្លួន និងឆ្លើយតបនឹងគ្រោះអាសន្ន និងគ្រោះមហន្តរាយ និងភាពធន់នឹងមុខសញ្ញាគ្រោះថ្នាក់ ក៏ដូចជាលទ្ធភាពទទួលបានព័ត៌មាន និងការជូនដំណឹងជាមុន ត្រូវបានជូនដំណឹង និងយល់យ៉ាងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយដោយប្រជាជន ជាពិសេសស្ត្រី កុមារ និងក្រុមងាយរងគ្រោះ។
- ទីទួលសុវត្ថិភាពត្រូវបានកែលម្អ និងបំពាក់ដោយសម្ភារបរិក្ខារដើម្បីជានាស្ថានភាពរស់នៅសមស្របសម្រាប់បុរស ស្ត្រី កុមារ និងក្រុមងាយរងគ្រោះ និងធានាភាពម្ចាស់ការរបស់គ្រួសារ និងសហគមន៍លើទីទួលសុវត្ថិភាព ក្នុងការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ និងក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

២- លទ្ធផលរំពឹងទុកនៃ ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០១៤-២០១៨) គឺ "បុរស ស្ត្រី និងកុមារដែលងាយរងគ្រោះក្នុងតំបន់ជនបទ តំបន់ប្រជុំជន តំបន់ឆ្នេរ និងតំបន់ភ្នំ ទទួលបានព័ត៌មានគ្រប់គ្រាន់ និងមានសមត្ថភាពយល់ពីហានិភ័យបច្ចុប្បន្ន និងហានិភ័យនាពេលអនាគត និងមានសមត្ថភាពរៀបចំត្រៀមខ្លួនទប់ទល់ និងឆ្លើយតបនឹង និងធន់នឹងគ្រោះមហន្តរាយ"។ សមាសភាគយុទ្ធសាស្ត្រទី ៤ ធានាការដាក់បញ្ចូលស្ត្រីទៅក្នុងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ។

៣- ផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០០៨-២០១៣) ទទួលស្គាល់បន្ទុកធ្ងន់ធ្ងររបស់ស្ត្រីក្នុងការប្រឈមមុខជាមួយផលប៉ះពាល់នៃគ្រោះមហន្តរាយ និងលើកកម្ពស់យេនឌ័រ និងការបណ្តុះបណ្តាលការយល់ដឹងផ្នែកវប្បធម៌ ជាសមាសភាគដ៏សំខាន់នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

៤- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ២០១៥ បានជំរុញការបញ្ជ្រាបក្នុងស្ថាប័ននូវហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ប្រព័ន្ធ ការអនុវត្ត និងផែនការដែលមានស្រាប់ ទៅក្នុងឧបករណ៍ចងកាតព្វកិច្ចផ្លូវច្បាប់។ មាត្រា ១៨ នៃច្បាប់នេះចែងថា "ក្នុងករណីដែលមានព្រឹត្តិការណ៍ ឬឧបទ្ទវហេតុកើតឡើង អាជ្ញាធរមានសមត្ថកិច្ចដែលមានទីតាំងនៅតំបន់កើតហេតុត្រូវយកចិត្តទុកដាក់ខ្ពស់លើតម្រូវការរបស់ស្ត្រី កុមារ ចាស់ជរា ជនពិការ និងជនបាត់បង់លទ្ធភាពពលកម្ម"។ ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ ២០១៥ ក្នុងមាត្រា ៣ ស្តីពីតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចែងថា គណៈកម្មាធិការនេះនឹង "សម្របសម្រួលការអនុវត្តសកម្មភាពការកាត់បន្ថយហានិ

ភ័យគ្រោះមហន្តរាយ បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍប្រកបដោយចីរភាព យេនឌ័រ ដោយសារសហការជាមួយក្រសួងពាក់ព័ន្ធ អភិវឌ្ឍ និងពង្រឹងស្ថាប័ន យន្តការ និងសកម្មភាព គ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ជាន់ថ្នាក់ ជាពិសេសនៅថ្នាក់មូលដ្ឋានសហគមន៍ ធានាដល់ការឆ្លើយតបបានល្អប្រសើរ ពេលមានគ្រោះអាសន្ន។

ខ- កម្ពុជាបានចាត់វិធានការបុរេសកម្ម ឆ្ពោះទៅរកការគ្រប់គ្រងគ្រោះមហន្តរាយបែបបរិយាបន្ន តាំងពីមុនក្របខណ្ឌសេនដាយទៅទៀត។ ក្នុងឆ្នាំ ២០១០ ផ្អែកតាមសេចក្តីណែនាំលេខ ៣១៥ របស់ គជគម ក្រុមគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ភូមិ ត្រូវបានបង្កើតឡើងដើម្បីអនុវត្តការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយតាមសហគមន៍ នៅថ្នាក់មូលដ្ឋាន។ វិធានការនេះបានបំពេញហេដ្ឋារចនាសម្ព័ន្ធស្ថាប័នសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ រដ្ឋាភិបាលកម្ពុជាចាត់ទុកការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយតាមសហគមន៍ជាចំណុចស្នូលនៃកម្មវិធីអភិវឌ្ឍន៍ជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ។ ក្នុងក្រុមគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ភូមិនីមួយៗ គួរមានសមាជិកជាស្ត្រីយ៉ាងតិចម្នាក់ដែលយ៉ាងហោចណាស់ត្រូវកាន់តួនាទីជាអនុប្រធានភូមិ ឬជំនួយការភូមិនៅក្នុងក្រុមនេះ។ អ្វីដែលអាចទៅរួចផងដែរនោះគឺមេភូមិគួរតែជាស្ត្រី ហើយអនុប្រធានភូមិក៏គួរតែជាស្ត្រីដែរ។

ខ- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) ការពង្រឹងយន្តការបញ្ជ្រាបយេនឌ័រនៃកម្មវិធីតាមវិស័យ និងកម្មវិធីជាតិ ដូចជា ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

គ- របាយការណ៍បច្ចុប្បន្នភាពរៀងរាល់ ២ ឆ្នាំលើកទី ១ របស់ព្រះរាជាណាចក្រកម្ពុជា ២០២០ ឯកសារនេះទទួលស្គាល់តួនាទីរបស់ក្រសួងកិច្ចការនារីក្នុងការពង្រឹងយេនឌ័រ និងសមត្ថភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការសាកល្បងគម្រោងបន្ស៊ាំ/កាត់បន្ថយផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុដែលផ្អែកលើយេនឌ័រ។

ឃ- ឯកសារបច្ចុប្បន្នភាពនៃការរួមចំណែករបស់ជាតិរបស់កម្ពុជា ឆ្នាំ ២០២០ ទទួលស្គាល់តួនាទីដ៏សំខាន់របស់យេនឌ័រក្នុងផ្នែកអន្តរវិស័យ និងស្នើ សកម្មភាពយេនឌ័រចំនួន ៦ សម្រាប់ការអនុវត្តការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។ យេនឌ័រត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធតាមដានការរួមចំណែករបស់ជាតិតាមអនឡាញ ហើយសកម្មភាពអាទិភាពនីមួយៗដែលត្រូវបានស្នើឡើងសម្រាប់ការរួមចំណែករបស់ជាតិ សុទ្ធ តែមានការវាយតម្លៃផលប៉ះពាល់យេនឌ័រ។

ង- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) ទទួលស្គាល់តួនាទីដ៏សំខាន់របស់យេនឌ័រក្នុងផ្នែកអន្តរវិស័យ និងស្នើសកម្មភាពយេនឌ័រចំនួន ៦ សម្រាប់ការអនុវត្តការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។ យេនឌ័រត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធតាមដាន

ការរួមចំណែករបស់ជាតិតាមអនឡាញ ហើយសកម្មភាពអាទិភាពនីមួយៗដែលត្រូវបានស្នើឡើងសម្រាប់ការរួមចំណែករបស់ជាតិ សុទ្ធតែមានការវាយតម្លៃផលប៉ះពាល់យេនឌ័រ។

ច- ផែនការនារីរតនៈទី ៥ (២០១៩-២០២៣) ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៤-២០១៨ ដាក់បញ្ចូលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផ្នែកស្តីពីបញ្ហាអន្តរវិស័យ មានន័យថា ឯកសារនេះកត់សម្គាល់ពីផលប៉ះពាល់ផ្អែកតាមយេនឌ័រនៃការប្រែប្រួលអាកាសធាតុលើស្ត្រី និងបុរស ក្មេងស្រី និងក្មេងប្រុស និងក្រុមងាយរងគ្រោះផ្សេងទៀត។ បរិយាបន្នអាកាសធាតុពេញលេញ ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១៩-២០២៣ ដាក់បញ្ចូលពេញលេញនូវការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបញ្ចូលជាយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗទាំង ៥ ក្នុងគោលនយោបាយទី ៥ នូវគោលការណ៍ "រដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ និងផ្តល់ សារៈសំខាន់កាន់តែខ្លាំងលើបញ្ហានេះសម្រាប់ផែនការអនុវត្តន៍រយៈពេល ៥ ឆ្នាំ ធនធានហិរញ្ញវត្ថុ និងការពិនិត្យតាមដាន និងវាយតម្លៃ"។

ឆ- ផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៣-២០២៣) ការឆ្លើយតបជាយុទ្ធសាស្ត្ររបស់ផែនការនេះ ផ្តោតសំខាន់លើយុទ្ធសាស្ត្របន្សាំដែលខិតខំឆ្លើយតបនឹងតម្រូវការចំពោះមុខរបស់ស្ត្រី និងបុរសដែលងាយរងគ្រោះក្នុងតំបន់ជនបទ និងតំបន់ប្រជុំជន ក៏ដូចជាយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ ដែលខិតខំកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់តាមរយៈការបង្កើនឱកាសការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងស្អាត។ យុទ្ធសាស្ត្រទាំងនេះគាំទ្រដោយការបង្កើនការយល់ដឹងពីយេនឌ័រ ការកសាងសមត្ថភាពពាក់ព័ន្ធនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការចូលរួមក្នុងគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្តដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការស្រាវជ្រាវ និងការអភិវឌ្ឍ និងហិរញ្ញប្បទាន។ ផែនការយុទ្ធសាស្ត្រនេះគូសបញ្ជាក់ពីយេនឌ័រក្នុងក្របខណ្ឌយុទ្ធសាស្ត្រអាកាសធាតុ គោលដៅ និងគោលបំណង និងយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទាន និងយន្តការពាក់ព័ន្ធ។

ជ- ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៩-២០២៣) ផែនការសកម្មភាពទី ១ គឺសម្រាប់ ឆ្នាំ ២០១៤-២០១៨ ចំណែកផែនការសកម្មភាពទី ២ គឺសម្រាប់ឆ្នាំ ២០១៩-២០២៣។ ផែនការសកម្មភាពនេះមានគោលបំណងលើកឡើងពីស្ត្រីដែលងាយរងគ្រោះបំផុត និងក្រុមផ្សេងទៀត ដូចជា កុមារ និងចាស់ជរា តាមរយៈការកសាងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការអភិវឌ្ឍភាពជាអ្នកដឹកនាំ សកម្មភាពដែលពាក់ព័ន្ធនឹងរបរចិញ្ចឹមជីវិត និងកំណើនបៃតង។ ផែនការនេះត្រូវបានបង្កើតឡើងដោយយកលំនាំតាមផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៤-២០២៣។ ដំណើរការរៀបចំផែនការសកម្មភាពយេនឌ័រ

និងការប្រែប្រួលអាកាសធាតុ ត្រូវបានគាំទ្រដោយ និងផ្អែកតាមសម្ព័ន្ធការប្រែប្រួលអាកាសធាតុកម្ពុជា។ ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៤-២០១៨ លើកឡើងពីយេនឌ័រក្នុងក្របខណ្ឌយុទ្ធសាស្ត្រអាកាសធាតុ គោលដៅ និងគោលបំណង យុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទាន និងយន្តការពាក់ព័ន្ធ និងលក្ខខណ្ឌច្បាប់។ ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៩-២០២៣ គូសបញ្ជាក់ពីវិស័យអាទិភាព ៤ ជាមួយនឹងផែនការសកម្មភាពច្បាស់លាស់។ ទោះបីជាផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុនឹងត្រូវបានដាក់បញ្ចូលទៅក្នុងនីតិវិធីរៀបចំថវិកា និងផែនការប្រចាំឆ្នាំ ដោយអាចមានការចូលរួមផ្តល់មូលនិធិពីដៃគូអភិវឌ្ឍន៍អន្តរជាតិក្តី ក៏ក្រសួងកិច្ចការនារីនៅតែខ្វះខាតមូលនិធិក្នុងការអនុវត្ត។

ឈ- ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៩-២០៣០) ផែនការមេនេះប៉ាន់ប្រមាណពីការដាក់បញ្ចូលក្នុងស្ថាប័ននូវការបញ្ជ្រាបយេនឌ័រ ក្នុងការវិនិយោគលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយផលប៉ះពាល់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់ការរួមចំណែកដល់ភាពធន់នឹងអាកាសធាតុប្រកបដោយសមធម៌ និងសង្គមប្រកបដោយនិរន្តរភាពនៅកម្ពុជា។ ដើម្បីសម្រេចការផ្លាស់ប្តូរនេះ មានការកំណត់គោលដៅរយៈពេលខ្លី (២០១៨-២០១៩) គោលដៅរយៈពេលមធ្យម (២០១៩-២០២៣) និងគោលដៅរយៈពេលវែង (២០២៣-២០៣០) ដើម្បីបំពេញបន្ថែមលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការនារីរតនៈ និងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលពាក់ព័ន្ធ។ ការបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោងវិនិយោគការប្រែប្រួលអាកាសធាតុក្នុងរយៈពេលខ្លី (២០១៨-២០១៩) រយៈពេលមធ្យម (២០១៩-២០២៣) និងរយៈពេលវែង (២០២៣-២០៣០)។ សៀវភៅណែនាំ ៥ ក្បាលសម្រាប់គម្រោងវិនិយោគការប្រែប្រួលអាកាសធាតុក្នុងការអប់រំ សុខភាព ទឹកស្អាត និងអនាម័យ និងមធ្យោបាយធ្វើដំណើរសាធារណៈ។

**៣- ច្បាប់ស្តីពីអំពើហិង្សាលើស្ត្រី និងកុមារ**

ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ និងវិធានការសមស្របសម្រាប់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដូចខាងក្រោម

- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧
- ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ ២០០៩

- កំណត់ពន្យល់អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៧
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨
- កំណត់ពន្យល់អំពីច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១០។

ជ- ក្នុងខែ តុលា ឆ្នាំ ២០០៩ ក្រសួងកិច្ចការនារីបានដាក់ចេញផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ទី ១ (២០០៩-២០១២)។ គោលបំណងចម្បងនៃផែនការសកម្មភាពនេះគឺការលើកកម្ពស់ការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ ក្រសួងសាមី ក៏ដូចជាលើកទឹកចិត្តឱ្យមានការពង្រឹងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី។ ក្រោមការសម្របសម្រួលដោយក្រសួងកិច្ចការនារី សមិទ្ធផលនៃផែនការសកម្មភាពនេះត្រូវបានវាយតម្លៃរួមគ្នាដោយតំណាងរដ្ឋាភិបាល និងតំណាងសង្គមស៊ីវិល។ ការវាយតម្លៃរកឃើញថា ការយល់ដឹងច្រើនរបស់ប្រជាជនកម្ពុជាគឺជាកត្តាចម្បងដែលកំណត់ភាពជោគជ័យនៃការអនុវត្តផែនការសកម្មភាពនេះ។ ទោះជាយ៉ាងណា នៅតែចាំបាច់ត្រូវមានការផ្តល់សេវាដែលមានគុណភាពដល់ជនរងគ្រោះនៃអំពើហិង្សាលើស្ត្រី និងការសម្របសម្រួលសេវាដោយរដ្ឋាភិបាល។ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨) ទទួលស្គាល់ថា ស្ត្រី និងក្មេងស្រីកាន់តែងាយប្រឈមនឹងហានិភ័យនៃអំពើហិង្សាផ្លូវភេទ ការកេងប្រវ័ញ្ច ការរំលោភបំពាន ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារក្នុងពេលកើតមានគ្រោះមហន្តរាយ។ ស្ត្រីដែលទទួលរងអំពើហិង្សាមុនពេលកើតមានគ្រោះមហន្តរាយ ច្រើនតែទទួលរងអំពើហិង្សាធ្ងន់ធ្ងរជាងមុន ក្រោយពេលកើតមានគ្រោះមហន្តរាយ ព្រោះពួកគេត្រូវបានកាត់ផ្តាច់ចេញពីប្រព័ន្ធគាំទ្រ និងប្រព័ន្ធការពាររបស់ពួកគេ។ ស្ត្រីដែលងាយប្រឈមនឹងហានិភ័យ ច្រើនតែប្រឈមនឹងអំពើហិង្សា និងមិនសូវទទួលបានយុត្តិធម៌។

## ជំពូកទី៣ មេរៀនទី១

- **ឧបសម្ព័ន្ធ ក ទម្រង់បែបបទគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោករបស់នគរបាលចរាចរណ៍ផ្លូវគោក**

បង្កើតឡើងដោយ

MoI MoH MPWT

គ.ស.ច.គ

# ទម្រង់បែបបទគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោករបស់នគរបាលចរាចរណ៍

លេខរៀង

**ភាគទី១: ព័ត៌មានសំគាល់**

| រាជធានី/ខេត្ត:.............. | ឈ្មោះអង្គភាព នគរបាលចរាចរណ៍:.............................. | ឈ្មោះមន្ត្រីបំពេញទំរង់បែបបទ និងហត្ថលេខា: .............................. | ថ្ងៃសម្ភាស: |
|---|---|---|---|

**ភាគទី២: ព័ត៌មានគ្រោះថ្នាក់**

១.ថ្ងៃមានគ្រោះថ្នាក់:(ថថ-ខខ-ឆឆ) ២. ម៉ោងមានគ្រោះថ្នាក់ (គិតជា២៤ម៉ោង): ..............................

៣. គ្រោះថ្នាក់នេះបណ្តាលឱ្យ: 1 ☐ រងគ្រោះដល់ស្លាប់ 2 ☐ រងគ្រោះធ្ងន់ធ្ងរ 3 ☐ រងគ្រោះស្រាល 4 ☐ ខូចខាតសំភារៈ

៤. ទីកន្លែងមានគ្រោះថ្នាក់: ឈ្មោះផ្លូវ.................. ភូមិ.................. ឃុំ/សង្កាត់.................. ក្រុង/ស្រុក/ខណ្ឌ.................. រាជធានី/ខេត្ត..................
លម្អិតពីទីកន្លែងគ្រោះថ្នាក់:.............................................................. កូអរដោនេភូមិសាស្ត្រ: X=......................, Y=......................

៥. ប្រភេទផ្លូវ:
1 ☐ ផ្លូវត្រង់ 2 ☐ រង្វង់មូល 3 ☐ ផ្លូវកោង 4 ☐ ផ្លូវប្រសព្វរាងX 5 ☐ ផ្លូវប្រសព្វរាងT 6 ☐ ផ្លូវប្រសព្វរាងY 7 ☐ ស្ពាន 8 ☐ ផ្លូវចំណោត 89 ☐ ផ្សេងៗ..........
1 ☐ ផ្លូវជាតិ លេខ......... (ចំនុចKm ...............) 2 ☐ ផ្លូវខេត្ត លេខ.......... 3 ☐ មហាវិថី 4 ☐ វិថី 5 ☐ ផ្លូវលំ 89 ☐ ផ្សេងៗ.............
1 ☐ ក្រាលកៅស៊ូ 2 ☐ ក្រាលបេតុង 3 ☐ ផ្លូវដី 4 ☐ ផ្លូវការដ្ឋាន 89 ☐ ផ្សេងៗ..............................

៦. តើគ្រោះថ្នាក់កើតឡើងក្នុងទីប្រជុំជនមែនឬទេ? 1 ☐ មែន 2 ☐ មិនមែន

៧. មូលហេតុនៃគ្រោះថ្នាក់:

៧.ក-បណ្តាលពីកត្តាមនុស្ស:
1 ☐ ល្បឿន
2 ☐ មិនគោរពភ្លើងសញ្ញាចរាចរណ៍
3 ☐ មិនគោរពសិទ្ធិអាទិភាព
4 ☐ បើកបរបញ្ច្រាសទិស
5 ☐ មិនគោរពស្លាកសញ្ញា
6 ☐ វ៉ែងក្នុងស្ថានភាពគ្រោះថ្នាក់
7 ☐ ប្រើប្រាស់ទូរស័ព្ទដៃ
8 ☐ ជ្រុះ/ទ្រេតរ៉ាំង (ទំនិញលើសចំណុះ)
9 ☐ កំហុសប្រើភ្លើងហ្វា
10 ☐ មានជាតិស្រវឹង
11 ☐ ប្រើប្រាស់គ្រឿងញៀន
12 ☐ ប្តូរគន្លងផ្លូវដោយមិនប្រយ័ត្ន
13 ☐ ប្តូរទិសផ្លូវដោយមិនប្រយ័ត្ន
14 ☐ ហេវហត់/ បញ្ហាសុខភាព
89 ☐ ផ្សេងៗ..............................

៧.ខ-បណ្តាលពីយានជំនិះ:
1 ☐ ខូចហ្វ្រាំង
2 ☐ ផ្ទុះឬដាច់កង់
3 ☐ ខូចចង្កូត
4 ☐ ខូចចង្កៀងបំភ្លឺផ្លូវ
5 ☐ ដាច់ក្រឡេ
89 ☐ ផ្សេងៗ..............

៧.គ-បណ្តាលពីលក្ខខណ្ឌផ្លូវ:
ផ្ទៃផ្លូវ: 1 ☐ ផ្លូវគ្រលុក 3 ☐ ផ្លូវដី 4 ☐ ផ្លូវរអិល 8 ☐ ផ្លូវសើម 9 ☐ ផ្លូវរមួល 89 ☐ ផ្សេងៗ.........
សញ្ញាចរាចរណ៍: 1 ☐ ផ្លាកសញ្ញា 2 ☐ គំនូសសញ្ញា 3 ☐ ភ្លើងសញ្ញា 89 ☐ ផ្សេងៗ..............
ដំណើរចរាចរណ៍: 1 ☐ ចង្អៀត 2 ☐ មធ្យម 3 ☐ តិច
89 ☐ ផ្សេងៗ..............................

៧.ឃ-បណ្តាលពីអាកាសធាតុ:
1 ☐ ភ្លៀង
2 ☐ ចុះអ័ព្ទ
89 ☐ ផ្សេងៗ.........

៨. ប្រភេទនៃការប៉ះទង្គិច: 1 ☐ បុកគ្នាចំពីមុខ 2 ☐ បុករុញពីខាងក្រោយ 3 ☐ បុកពីចំហៀង 4 ☐ កៀរពីចំហៀង 5 ☐ ក្រឡាប់/ដួលខ្លួនឯង 6 ☐ បុកវត្ថុគ្មានចលនានៅលើទ្រូងផ្លូវ 7 ☐ បុកវត្ថុគ្មានចលនានៅចញ្ចើម/ជាយផ្លូវ 8 ☐ បុកយានដែលចត 9 ☐ បុកយានដែលឈប់ 10 ☐ បុកថ្មើរជើង 11 ☐ បុកសត្វ 89 ☐ ផ្សេងៗ:..........

៩. បុកប៉ះហើយ: 1 ☐ មិនរត់ 2 ☐ រត់ (បរិយាយ..............................................................................)

| | យានទី១ | យានទី២ | យានទី៣ |
|---|---|---|---|
| ១០.យានដែលពាក់ព័ន្ធ | 2 ☐ កង់ 3 ☐ ស៊ីក្លូ<br>1 ☐ ម៉ូតូ 4 ☐ យានយន្តកង់បី<br>1 ☐ ម៉ាស៊ីនមិនលើសពី១២៥សេសេ<br>2 ☐ ម៉ាស៊ីនលើសពី១២៥សេសេ<br>5 ☐ រថយន្តគ្រួសារ/ដឹកអ្នកដំណើរ<br>3 ☐ មិនលើសពី៩កៅអី<br>4 ☐ ពី១០ទៅ២០កៅអី<br>5 ☐ លើសពី២០កៅអី(..............................)<br>6 ☐ រថយន្តដឹកទំនិញ<br>6 ☐ មិនលើសពី៣,៥តោន(..............................)<br>7 ☐ លើសពី៣,៥តោន(..............................)<br>7 ☐ យានយន្តកសិកម្ម/កែច្នៃក្នុងស្រុក<br>89 ☐ ផ្សេងៗ...................... | 2 ☐ កង់ 3 ☐ ស៊ីក្លូ<br>1 ☐ ម៉ូតូ 4 ☐ យានយន្តកង់បី<br>1 ☐ ម៉ាស៊ីនមិនលើសពី១២៥សេសេ<br>2 ☐ ម៉ាស៊ីនលើសពី១២៥សេសេ<br>5 ☐ រថយន្តគ្រួសារ/ដឹកអ្នកដំណើរ<br>3 ☐ មិនលើសពី៩កៅអី<br>4 ☐ ពី១០ទៅ២០កៅអី<br>5 ☐ លើសពី២០កៅអី(..............................)<br>6 ☐ រថយន្តដឹកទំនិញ<br>6 ☐ មិនលើសពី៣,៥តោន(..............................)<br>7 ☐ លើសពី៣,៥តោន(..............................)<br>7 ☐ យានយន្តកសិកម្ម/កែច្នៃក្នុងស្រុក<br>89 ☐ ផ្សេងៗ...................... | 2 ☐ កង់ 3 ☐ ស៊ីក្លូ<br>1 ☐ ម៉ូតូ 4 ☐ យានយន្តកង់បី<br>1 ☐ ម៉ាស៊ីនមិនលើសពី១២៥សេសេ<br>2 ☐ ម៉ាស៊ីនលើសពី១២៥សេសេ<br>5 ☐ រថយន្តគ្រួសារ/ដឹកអ្នកដំណើរ<br>3 ☐ មិនលើសពី៩កៅអី<br>4 ☐ ពី១០ទៅ២០កៅអី<br>5 ☐ លើសពី២០កៅអី(..............................)<br>6 ☐ រថយន្តដឹកទំនិញ<br>6 ☐ មិនលើសពី៣,៥តោន(..............................)<br>7 ☐ លើសពី៣,៥តោន(..............................)<br>7 ☐ យានយន្តកសិកម្ម/កែច្នៃក្នុងស្រុក<br>89 ☐ ផ្សេងៗ...................... |
| ១១. យានមានសណ្ឋាន: | 1 ☐ មាន 2 ☐ មិនមាន 99 ☐ មិនដឹង | 1 ☐ មាន 2 ☐ មិនមាន 99 ☐ មិនដឹង | 1 ☐ មាន 2 ☐ មិនមាន 99 ☐ មិនដឹង |
| ១២. ផ្លាកលេខយាន: | .............................. | .............................. | .............................. |
| ១៣. ការបើកបរ: | 1 ☐ បើកត្រង់ទៅមុខ 6 ☐ បើកថយក្រោយ<br>2 ☐ បត់ស្តាំ 7 ☐ កញ្ឆក់ទៅមុខ<br>3 ☐ បត់ឆ្វេង 8 ☐ ឈប់ភ្លាមៗ<br>4 ☐ បត់ត្រឡប់ក្រោយ 9 ☐ ឈប់/ចតស្ងៀម<br>5 ☐ វ៉ែង/វ៉ា 89 ☐ ផ្សេងៗ.......... | 1 ☐ បើកត្រង់ទៅមុខ 6 ☐ បើកថយក្រោយ<br>2 ☐ បត់ស្តាំ 7 ☐ កញ្ឆក់ទៅមុខ<br>3 ☐ បត់ឆ្វេង 8 ☐ ឈប់ភ្លាមៗ<br>4 ☐ បត់ត្រឡប់ក្រោយ 9 ☐ ឈប់/ចតស្ងៀម<br>5 ☐ វ៉ែង/វ៉ា 89 ☐ ផ្សេងៗ.......... | 1 ☐ បើកត្រង់ទៅមុខ 6 ☐ បើកថយក្រោយ<br>2 ☐ បត់ស្តាំ 7 ☐ កញ្ឆក់ទៅមុខ<br>3 ☐ បត់ឆ្វេង 8 ☐ ឈប់ភ្លាមៗ<br>4 ☐ បត់ត្រឡប់ក្រោយ 9 ☐ ឈប់/ចតស្ងៀម<br>5 ☐ វ៉ែង/វ៉ា 89 ☐ ផ្សេងៗ.......... |
| ១៤. ការធ្វើដំណើរ: | ពីទិស..................ទៅទិស.................. | ពីទិស..................ទៅទិស.................. | ពីទិស..................ទៅទិស.................. |
| ១៥. លក្ខណៈយានយន្ត: | 1 ☐ ចង្កូតឆ្វេង 2 ☐ ចង្កូតស្តាំ 98 ☐ មិនពាក់ព័ន្ធ | 1 ☐ ចង្កូតឆ្វេង 2 ☐ ចង្កូតស្តាំ 98 ☐ មិនពាក់ព័ន្ធ | 1 ☐ ចង្កូតឆ្វេង 2 ☐ ចង្កូតស្តាំ 98 ☐ មិនពាក់ព័ន្ធ |
| ១៦.យានរងការខូចខាត: | 1 ☐ ខូចធ្ងន់ 2 ☐ ខូចស្រាល 3 ☐ មិនខូច | 1 ☐ ខូចធ្ងន់ 2 ☐ ខូចស្រាល 3 ☐ មិនខូច | 1 ☐ ខូចធ្ងន់ 2 ☐ ខូចស្រាល 3 ☐ មិនខូច |
| ១៧. លិខិតធានារ៉ាប់រង | 1 ☐ មាន 2 ☐ ហួសសុពលភាព 3 ☐ គ្មាន | 1 ☐ មាន 2 ☐ ហួសសុពលភាព 3 ☐ គ្មាន | 1 ☐ មាន 2 ☐ ហួសសុពលភាព 3 ☐ គ្មាន |

១៨. ពិពណ៌នាពីហេតុការណ៍គ្រោះថ្នាក់ (បរិយាយលម្អិតតាមដែលអាចធ្វើបាន): ..............................................................................
..............................................................................................................................

សូមមេត្តាបំពេញព័ត៌មានអ្នកបើកបរនិង/ឬ ជនរងគ្រោះនៅទំព័រខាងក្រោយទៀត

**តារាងទី៣: ព័ត៌មានស្តីពីអ្នកបើកបរ និង/ឬជនរងគ្រោះ**

**អ្នកបើកបរ / ជនរងគ្រោះទី ១**

១. ឈ្មោះ: ............................................................ | ២. ភេទ: ☐ ប្រុស ☐ ស្រី | ៣. អាយុ: .......... | ៤. ទំនងជាអ្នកបង្កហេតុ? ☐ មែន ☐ មិនមែន

៥. ទីលំនៅបច្ចុប្បន្ន: ភូមិ........................................ ឃុំ/សង្កាត់ ........................................ ស្រុក/ខ័ណ្ឌ........................................ខេត្ត/ក្រុង........................................

៦. មុខរបរ: ☐ កុមារ ☐ សិស្ស (☐ទៅឬត្រឡប់ពីសាលា ☐ មិនមែន) ☐ កម្មករ ☐ អ្នកជំនួញ ☐ បើកម៉ូតូឌុប ☐ បើកឡាន ☐ នៅផ្ទះ/មេផ្ទះ អ្នកជរា ☐ កសិករ ☐ អ្នកនេសាទ ☐ ទេសចរ/ជនបរទេស ☐ គ្រូបង្រៀន ☐ នគរបាល ☐ ទាហាន ☐ មន្ត្រីរាជការផ្សេងទៀត ☐ មិនមានការងារធ្វើ ☐ មិនដឹង ☐ ផ្សេងៗ...............

៧. ប្រភេទនៃអ្នកធ្វើដំណើរ: ☐ ថ្មើរជើង ☐ អ្នកបើកបរ ☐ អ្នករួមដំណើរ

៨. ធ្វើដំណើរដោយ: ☐ យានទី............. ☐ ថ្មើរជើង | ៩. អង្គុយនៅ ☐ កៅអីមុខ ☐ កៅអីក្រោយ ☐ មិនដឹង

១០. ពាក់មួកសុវត្ថិភាព/ខ្សែក្រវ៉ាត់សុវត្ថិភាព: ☐ ពាក់ ☐ មិនពាក់ ☐ មិនពាក់ព័ន្ធ ☐ មិនដឹង | ១១. មានប័ណ្ណបើកបរ : ☐ មាន ☐ មិនមាន ☐ មិនពាក់ព័ន្ធ ☐ មិនដឹង

១២. សារធាតុប្រើប្រាស់: <u>គ្រឿងស្រវឹង:</u> ☐ មាន / សង្ស័យ ☐ មិនមាន ☐ មិនដឹង | <u>ថ្នាំញៀន:</u> ☐ មាន /សង្ស័យ ☐ មិនមាន ☐ មិនដឹង

១៣. ភាពធ្ងន់ធ្ងរនៃរបួសស្នាម: ☐ គ្មានរបួសស្នាម ☐ របួសសើរស្បែក ☐ មធ្យម ត្រូវការដេរ ☐ ធ្ងន់ធ្ងរ (ត្រូវការវះកាត់ ឬ សង្គ្រោះបន្ទាន់) ☐ ស្លាប់ (☐នៅកន្លែង ☐ពេលដឹកជញ្ជូន ☐ នៅពេទ្យ)

១៤. តើអ្នករបួសបានដឹកទៅមន្ទីរពេទ្យដែរឬទេ? ☐ មិនដឹកទៅទេ ☐ ដឹកទៅ ( មន្ទីរពេទ្យមួយណា?........................................ដោយមធ្យោបាយអ្វី?........................................ )

១៥. តើជនរងគ្រោះបានទទួលការសង្គ្រោះបឋមឬទេ? ☐ បាន ☐ មិនបាន

១៦. តើអ្នកណាជាអ្នកផ្តល់ការសង្គ្រោះនេះ? ☐ នគរបាលចរាចរណ៍ ☐ រាជអាវុធហត្ថ ☐ សាមញ្ញ ☐ ផ្សេងៗ........................................

១៧. សង្គ្រោះបឋមផ្នែក: ☐ ការហូរឈាម ☐ សន្លប់ បាត់ស្មារតី ☐ រលាក ☐ វិបត្តិបេះដូង ☐ វិបត្តិដង្ហើម ☐ របួស ☐ បាក់ឆ្អឹង ☐ បំលាស់ទីជនរងគ្រោះ ☐ ផ្សេងៗ....................

**អ្នកបើកបរ / ជនរងគ្រោះទី ២**

១. ឈ្មោះ: ............................................................ | ២. ភេទ: ☐ ប្រុស ☐ ស្រី | ៣. អាយុ: .......... | ៤. ទំនងជាអ្នកបង្កហេតុ? ☐ មែន ☐ មិនមែន

៥. ទីលំនៅបច្ចុប្បន្ន: ភូមិ........................................ ឃុំ/សង្កាត់ ........................................ ស្រុក/ខ័ណ្ឌ........................................ខេត្ត/ក្រុង........................................

៦. មុខរបរ: ☐ កុមារ ☐ សិស្ស (☐ទៅឬត្រឡប់ពីសាលា ☐ មិនមែន) ☐ កម្មករ ☐ អ្នកជំនួញ ☐ បើកម៉ូតូឌុប ☐ បើកឡាន ☐ នៅផ្ទះ/មេផ្ទះ អ្នកជរា ☐ កសិករ ☐ អ្នកនេសាទ ☐ ទេសចរ/ជនបរទេស ☐ គ្រូបង្រៀន ☐ នគរបាល ☐ ទាហាន ☐ មន្ត្រីរាជការផ្សេងទៀត ☐ មិនមានការងារធ្វើ ☐ មិនដឹង ☐ ផ្សេងៗ...............

៧. ប្រភេទនៃអ្នកធ្វើដំណើរ: ☐ ថ្មើរជើង ☐ អ្នកបើកបរ ☐ អ្នករួមដំណើរ

៨. ធ្វើដំណើរដោយ: ☐ យានទី............. ☐ ថ្មើរជើង | ៩. អង្គុយនៅ ☐ កៅអីមុខ ☐ កៅអីក្រោយ ☐ មិនដឹង

១០. ពាក់មួកសុវត្ថិភាព/ខ្សែក្រវ៉ាត់សុវត្ថិភាព: ☐ ពាក់ ☐ មិនពាក់ ☐ មិនពាក់ព័ន្ធ ☐ មិនដឹង | ១១. មានប័ណ្ណបើកបរ : ☐ មាន ☐ មិនមាន ☐ មិនពាក់ព័ន្ធ ☐ មិនដឹង

១២. សារធាតុប្រើប្រាស់: <u>គ្រឿងស្រវឹង:</u> ☐ មាន / សង្ស័យ ☐ មិនមាន ☐ មិនដឹង | <u>ថ្នាំញៀន:</u> ☐ មាន /សង្ស័យ ☐ មិនមាន ☐ មិនដឹង

១៣. ភាពធ្ងន់ធ្ងរនៃរបួសស្នាម: ☐ គ្មានរបួសស្នាម ☐ របួសសើរស្បែក ☐ មធ្យម ត្រូវការដេរ ☐ ធ្ងន់ធ្ងរ (ត្រូវការវះកាត់ ឬ សង្គ្រោះបន្ទាន់) ☐ ស្លាប់ (☐នៅកន្លែង ☐ពេលដឹកជញ្ជូន ☐ នៅពេទ្យ)

១៤. តើអ្នករបួសបានដឹកទៅមន្ទីរពេទ្យដែរឬទេ? ☐ មិនដឹកទៅទេ ☐ ដឹកទៅ ( មន្ទីរពេទ្យមួយណា?........................................ដោយមធ្យោបាយអ្វី?........................................ )

១៥. តើជនរងគ្រោះបានទទួលការសង្គ្រោះបឋមឬទេ? ☐ បាន ☐ មិនបាន

១៦. តើអ្នកណាជាអ្នកផ្តល់ការសង្គ្រោះនេះ? ☐ នគរបាលចរាចរណ៍ ☐ រាជអាវុធហត្ថ ☐ សាមញ្ញ ☐ ផ្សេងៗ........................................

១៧. សង្គ្រោះបឋមផ្នែក: ☐ ការហូរឈាម ☐ សន្លប់ បាត់ស្មារតី ☐ រលាក ☐ វិបត្តិបេះដូង ☐ វិបត្តិដង្ហើម ☐ របួស ☐ បាក់ឆ្អឹង ☐ បំលាស់ទីជនរងគ្រោះ ☐ ផ្សេងៗ....................

**អ្នកបើកបរ / ជនរងគ្រោះទី ៣**

១. ឈ្មោះ: ............................................................ | ២. ភេទ: ☐ ប្រុស ☐ ស្រី | ៣. អាយុ: .......... | ៤. ទំនងជាអ្នកបង្កហេតុ? ☐ មែន ☐ មិនមែន

៥. ទីលំនៅបច្ចុប្បន្ន: ភូមិ........................................ ឃុំ/សង្កាត់ ........................................ ស្រុក/ខ័ណ្ឌ........................................ខេត្ត/ក្រុង........................................

៦. មុខរបរ: ☐ កុមារ ☐ សិស្ស (☐ទៅឬត្រឡប់ពីសាលា ☐ មិនមែន) ☐ កម្មករ ☐ អ្នកជំនួញ ☐ បើកម៉ូតូឌុប ☐ បើកឡាន ☐ នៅផ្ទះ/មេផ្ទះ អ្នកជរា ☐ កសិករ ☐ អ្នកនេសាទ ☐ ទេសចរ/ជនបរទេស ☐ គ្រូបង្រៀន ☐ នគរបាល ☐ ទាហាន ☐ មន្ត្រីរាជការផ្សេងទៀត ☐ មិនមានការងារធ្វើ ☐ មិនដឹង ☐ ផ្សេងៗ...............

៧. ប្រភេទនៃអ្នកធ្វើដំណើរ: ☐ ថ្មើរជើង ☐ អ្នកបើកបរ ☐ អ្នករួមដំណើរ

៨. ធ្វើដំណើរដោយ: ☐ យានទី............. ☐ ថ្មើរជើង | ៩. អង្គុយនៅ ☐ កៅអីមុខ ☐ កៅអីក្រោយ ☐ មិនដឹង

១០. ពាក់មួកសុវត្ថិភាព/ខ្សែក្រវ៉ាត់សុវត្ថិភាព: ☐ ពាក់ ☐ មិនពាក់ ☐ មិនពាក់ព័ន្ធ ☐ មិនដឹង | ១១. មានប័ណ្ណបើកបរ : ☐ មាន ☐ មិនមាន ☐ មិនពាក់ព័ន្ធ ☐ មិនដឹង

១២. សារធាតុប្រើប្រាស់: <u>គ្រឿងស្រវឹង:</u> ☐ មាន / សង្ស័យ ☐ មិនមាន ☐ មិនដឹង | <u>ថ្នាំញៀន:</u> ☐ មាន /សង្ស័យ ☐ មិនមាន ☐ មិនដឹង

១៣. ភាពធ្ងន់ធ្ងរនៃរបួសស្នាម: ☐ គ្មានរបួសស្នាម ☐ របួសសើរស្បែក ☐ មធ្យម ត្រូវការដេរ ☐ ធ្ងន់ធ្ងរ (ត្រូវការវះកាត់ ឬ សង្គ្រោះបន្ទាន់) ☐ ស្លាប់ (☐នៅកន្លែង ☐ពេលដឹកជញ្ជូន ☐ នៅពេទ្យ)

១៤. តើអ្នករបួសបានដឹកទៅមន្ទីរពេទ្យដែរឬទេ? ☐ មិនដឹកទៅទេ ☐ ដឹកទៅ ( មន្ទីរពេទ្យមួយណា?........................................ដោយមធ្យោបាយអ្វី?........................................ )

១៥. តើជនរងគ្រោះបានទទួលការសង្គ្រោះបឋមឬទេ? ☐ បាន ☐ មិនបាន

១៦. តើអ្នកណាជាអ្នកផ្តល់ការសង្គ្រោះនេះ? ☐ នគរបាលចរាចរណ៍ ☐ រាជអាវុធហត្ថ ☐ សាមញ្ញ ☐ ផ្សេងៗ........................................

១៧. សង្គ្រោះបឋមផ្នែក: ☐ ការហូរឈាម ☐ សន្លប់ បាត់ស្មារតី ☐ រលាក ☐ វិបត្តិបេះដូង ☐ វិបត្តិដង្ហើម ☐ របួស ☐ បាក់ឆ្អឹង ☐ បំលាស់ទីជនរងគ្រោះ ☐ ផ្សេងៗ....................

- ឧបសម្ព័ន្ធ ខ ទម្រង់បែបបទប្រមូលទិន្នន័យរបស់មន្ទីរពេទ្យ ប្រើប្រាស់ប្រមូលព័ត៌មានពីជនរងគ្រោះ

ក្រសួងសុខាភិបាល

**ទម្រង់ទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់ផ្សេងៗ**

គ.ស.ច.ក

លេខកូដទំរង់ទិន្នន័យ: ☐ លេខកូដខេត្ត/ក្រុង ☐

**ព័ត៌មានទូទៅ**

ឈ្មោះមន្ទីរពេទ្យ/មណ្ឌលសុខភាព/សេវាឯកជន.......... ឈ្មោះអ្នកសំភាសន៍.......... ថ្ងៃ ខែ ឆ្នាំ សំភាសន៍ |__|__|__|__|__|__|

**១.ឈ្មោះជនរងគ្រោះ**.......... **២.ភេទ:** ☐១ ប្រុស ☐២ ស្រី **៣.អាយុ**..........ឆ្នាំ **៤.អាស័យដ្ឋាន:** ភូមិ..........ឃុំ/សង្កាត់..........

**ឈ្មោះអ្នកដែលត្រូវបានសំភាសន៍**.......... **សញ្ជាតិ** ☐១ ខ្មែរ ☐២ បរទេស ស្រុក/ខ័ណ្ឌ..........ខេត្ត..........

**៥.មុខរបរ:** ☐១ កុមារ ☐២ សិស្ស/និស្សិត ☐៣ កម្មករ ☐៤ អ្នកជំនួញ/អ្នកលក់ដូរ ☐៥ អ្នករត់ម៉ូតូឌុប ☐៧ មេផ្ទះ/អ្នកបំរើ ☐៨ កសិករ ☐៩ អ្នកនេសាទ ☐១០ អ្នកទេសចរ ☐១២ នគរបាល ☐១៣ ទាហាន ☐១៤ មន្ត្រីរាជការផ្សេងៗទៀត ☐៨៨ ផ្សេងៗ ☐៩៩ មិនដឹង

**៦. ថ្ងៃ ខែ ឆ្នាំ មានគ្រោះថ្នាក់** |__|__|__|__|__|__| **វេលា ម៉ោង** (រាប់តាម២៤ម៉ោង)..........:..........

**៧.អាស័យដ្ឋានកន្លែងគ្រោះថ្នាក់:** ភូមិ..........ឃុំ/សង្កាត់..........ស្រុក/ខ័ណ្ឌ..........ខេត្ត/ក្រុង..........

**៨. ហេតុការណ៍នៃគ្រោះថ្នាក់:** តើមានមនុស្សប៉ុន្មាននាក់ដែលរងរបួស? .......... តើមានមនុស្សប៉ុន្មាននាក់ដែលស្លាប់?..........

**៩.វត្ថុមានរបស់:** ☐១ រដ្ឋអំណាចមូលដ្ឋាន ☐៣ សប្បុរសជន ☐៤ នគរបាលចរាចរណ៍/រាជអាវុធហត្ថ ☐៨៨ ផ្សេងៗ.......... ☐៩៩ មិនដឹង

**១០.ប្រភេទនៃរបួស:** **បាក់** (☐១ ដៃ ☐២ ជើង ☐៣ ត្រគាក) **ផ្លាច/ភ្លាត់ឆ្អឹង** (☐៤ ដៃ ☐៥ ជើង ☐៦ ត្រគាក) **របេក** (☐៧ ដៃ ☐៨ ជើង ☐៩ ត្រគាក ☐១០ ថ្ពាល់មុខ ☐១១ ទ្រូង ☐១២ ពោះ) ☐១៣ របួសក្បាល-ក **ដាច់,រលាត់/ទឹក,ចិច** (☐១៤ ដៃ ☐១៥ ជើង ☐១៦ ត្រគាក) **ជាំ/របួសលើស្បែក** (☐១៧ ដៃ ☐១៨ ជើង ☐១៩ ត្រគាក) ☐២០ របួសក្នុងសរីរាង្គ ☐២១ ពុល ☐២២ របួសទ្រូង ☐២៣ របួសពោះ ☐៨៨ ផ្សេងៗ.......... ☐៩៩ មិនដឹង

**១១.ភាពធ្ងន់ធ្ងរនៃរបួសស្នាម:** ☐១ គ្មានរបួស ☐២ របួសលើស្បែក ☐៣ របួសមធ្យម ☐៤ របួសធ្ងន់ធ្ងរ

**១២.សង្គ្រោះបឋម:** នៅកន្លែងកើតហេតុ ☐១ មាន ☐២ មិនមាន ☐៩៩ មិនដឹង **សង្គ្រោះដោយ:** ☐១ នគរបាលចរាចរណ៍/រាជអាវុធហត្ថ ☐៣ បុគ្គលិកសុខាភិបាល
ពេលដឹកជញ្ជូន ☐១ មាន ☐២ មិនមាន ☐៩៩ មិនដឹង ☐៨៨ ផ្សេងៗ.......... ☐៩៩ មិនដឹង

**១៣.ចូលមកធ្វើការព្យាបាលនៅមន្ទីរពេទ្យ/មណ្ឌលសុខភាពនៅ ថ្ងៃ ខែ ឆ្នាំ** |__|__|__|__|__|__| **វេលា ម៉ោង** (រាប់តាម២៤ម៉ោង)..........:..........

**១៤.ការមកដល់មន្ទីរពេទ្យ/មណ្ឌលសុខភាព :**
ជនរងគ្រោះបញ្ជូនមកពី ☐១ ពីកន្លែងកើតហេតុ ☐២ មន្ទីរពេទ្យ/មណ្ឌលសុខភាព/សេវាឯកជន ☐៣ សហគមន៍ ☐៨៨ ផ្សេងៗ.......... ☐៩៩ មិនដឹង
ជនរងគ្រោះមកដោយសារ: ☐ រថយន្តពិលាទសង្គ្រោះ (☐១ មន្ទីរពេទ្យ ☐២ គ្លីនិក ☐៣ នគរបាលចរាចរណ៍) ☐៤ មធ្យោបាយផ្ទាល់ខ្លួន ☐៨៨ ផ្សេងៗ.......... ☐៩៩ មិនដឹង

**១៥. ចាកចេញពីមន្ទីរពេទ្យ/មណ្ឌលសុខភាពនៅ ថ្ងៃ ខែ ឆ្នាំ** |__|__|__|__|__|__| **វេលា ម៉ោង** (រាប់តាម២៤ម៉ោង)..........:..........

**១៦.របៀបនៃការចាកចេញពីមន្ទីរពេទ្យ/មណ្ឌលសុខភាព/សេវាឯកជន :** ☐១ ជាសះស្បើយ ☐២ ស្លាប់នៅមន្ទីរពេទ្យ ☐៣ ពិការភាព (តទៅសំណួរទី១៧) ☐៤ បញ្ជូនបន្តទៅមន្ទីរពេទ្យ.......... ☐៥ ជនរងគ្រោះសុំចេញទៅព្យាបាលនៅកន្លែងផ្សេងទៀត ☐ ស្លាប់មុនដល់មន្ទីរពេទ្យ (☐៦ ស្លាប់នៅកន្លែង ☐៧ តាមផ្លូវ ☐៨ ស្លាប់នៅផ្ទះ)

**១៧.ស្ថានភាពនៃពិការភាពពេលចេញពីមន្ទីរពេទ្យ :** ☐១ ការមើល ☐២ ការស្តាប់ ☐៣ ការសិក្សានិងចងចាំ ☐៤ ការធ្វើចលនា ☐៥ ញ្ញាណ ☐៦ ផ្លូវចិត្ត ☐៨៨ ផ្សេងៗ..........

**ព័ត៌មានគ្រោះថ្នាក់ចរាចរណ៍**

**១៨.គ្រោះថ្នាក់ចរាចរណ៍**

ប្រភេទនៃអ្នកដំណើរ
☐១ ថ្មើរជើង
☐២ អ្នកបើកបរ
☐៣ អ្នកដំណើរ
☐៩៩ មិនដឹង

ពាក់មួក/ខ្សែក្រវ៉ាត់:
☐១ ពាក់ ☐៨៨ មិនពាក់ត្រឹម
☐២ មិនពាក់ ☐៩៩ មិនដឹង

សារធាតុប្រើប្រាស់ គ្រឿងស្រវឹង:
☐១ មាន/សង្ស័យ ☐២ មិនមាន
☐៩៩ មិនដឹង

ប្រភេទនៃមធ្យោបាយធ្វើដំណើរ

**ផ្លូវគោក**
☐១ ម៉ូតូ ☐២ កង់ ☐៣ ស៊ីក្លូ
☐៤ យានយន្តកង់បី
☐៥ រថយន្តដឹកអ្នកដំណើរ
☐៣ មិនលើសពី៩កៅអី
☐៤ ពី១០ទៅ២០កៅអី
☐៥ លើសពី២០កៅអី
☐៦ រថយន្តដឹកទំនិញ
☐៦ មិនលើសពី៣.៥តោន
☐៧ លើសពី៣.៥តោន
☐៧ យានយន្តកសិកម្ម/គោយន្តក្នុងស្រុក
☐៨ ថ្មើរជើង
☐៩ រទេះភ្លើង

**ផ្លូវទឹក**
☐១០ កប៉ាល់/សាឡាង
☐១១ ទូកដៃ/ទូកម៉ាស៊ីន
| | | | | | | | | | | |
| **២២.វាយតម្លៃលទ្ធផលសិក្សា** | | | | | | | | | | |
| ភាគរយថ្នាក់រៀនបានធ្វើតេស្តស្តង់ដាដើមឆ្នាំសិក្សា ប្រចាំខែ ឆមាស និងចុងឆ្នាំសិក្សា ទៀងទាត់ | ធ្វើតេស្តស្តង់ដាដើមឆ្នាំសិក្សា ប្រចាំខែ ឆមាស និងចុងឆ្នាំសិក្សា គ្រប់កម្រិតថ្នាក់ | | | | | | | | | |
| ភាគរយសិស្សជាប់តេស្តស្តង់ដា ថ្នាក់ទី៣ និងទី៦ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | ធ្វើតេស្តស្តង់ដា ថ្នាក់ទី៣ និងទី៦ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា នៅដំណាច់ឆ្នាំ | | | | | | | | | |
| ចំនួនដងនៃកិច្ចប្រជុំ ឬកម្មវិធីបំប៉នសិស្សរៀនយឺត ដោយឡែកត្រូវបានដំណើរការ | ប្រជុំផ្សព្វផ្សាយលទ្ធផលតេស្តស្តង់ដា ជាមួយមាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីកៀរគរថវិកាបំប៉នសិស្សរៀនយឺត និងការចំណាយលើការរៀបចំសន្លឹកកិច្ចការតេស្ត | | | | | | | | | |
| | | | | | | | | | | |
| **២៣.ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ** | | | | | | | | | | |
| ការលក់ដូរចំណីអាហារ និងអាហារតាមសាលារៀន ឬចំនួនផ្ទាំងរូបភាពចំណីអាហារដែលហាមឃាត់ និងអនុញ្ញាតឱ្យលក់ក្នុងសាលារៀន ត្រូវបានដាក់បង្ហាញ នៅទីតាំងកន្លែងលក់ចំណីអាហារ | រៀបចំផ្ទាំងរូបភាពចំណីអហារដែលអនុញ្ញាត និងហាមឃាត់ នៅទីតាំងកន្លែងលក់ចំណីអាហារ ក្នុងសាលារៀន | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ភាគរយអ្នកលក់ចំណីអាហារក្នុងសាលារៀនដែលបានចុះកិច្ចព្រមព្រៀង ជាមួយ គណៈកម្មការសុខភាពសិក្សា | ចុះកិច្ចព្រមព្រៀង ស្តីពីការលក់ចំណីអាហារក្នុងសាលារៀនជាមួយអ្នកលក់ | | | | | | | | | |
| ភាគរយអ្នកលក់ចំណីអហារដែលបានអនុវត្តតាមកិច្ចព្រមព្រៀង<br>និងចំនួនអ្នកលក់ដែលត្រូវបានអនុវត្តវិធានការតាមកិច្ចព្រមព្រៀង | ចុះពិនិត្យការលក់ចំណីអាហារ និងការអនុវត្តវិធានការអនាម័យ នៅកន្លែងលក់ចំណីអាហាររបស់គណៈកម្មការសុខភាពសិក្សា | | | | | | | | | |
| ការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា ឬចំនួនបង្គន់អនា<br>ម័យ( ខ្នង និងបន្ទប់ )ដែលមានដំណើរការ តាមស្តង់ដា | សាងសង់បង្គន់អនាម័យឱ្យស្របតាមស្តង់ដា ( សិស្សពិការ ) និងនិយាមអ្នកប្រើប្រាស់ | | | | | | | | | |
| | រៀបចំបន្ទប់សុខភាព បំពាក់បរិក្ខា ប្រអប់ និងសម្ភារសង្គ្រោះបឋម | | | | | | | | | |
| ភាគរយសិស្សដែលបានទទួលថ្នាំព្រូន , ពិនិត្យសុខភាព និងចាក់ថ្នាំបង្ការ | សហការជាមួយមណ្ឌលសុខភាពផ្តល់ថ្នាំព្រូនទៀងទាត់ ពិនិត្យសុខភាព ចាក់ថ្នាំបង្ការផ្សេងៗ | | | | | | | | | |
| ភាគរយសិស្សខ្សោយគំហើញ និងស្តាប់ដែកបានទទួលវ៉ែនតា និងឧបករណ៍ជំនួនឲយការស្តាប់ | ផ្តល់វ៉ែនតា និងឧបករណ៍ជំនួយការស្តាប់ដល់សិស្សខ្សោយគំហើញ និងស្តាប់ | | | | | | | | | |
| ភាគរយសិស្សដែលទទួលបានអាហារពេលព្រឹក នៅសាលារៀន | សហការជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធ ផ្តល់អាហារពេលព្រឹកដល់សិស្ស | | | | | | | | | |
| សាលារៀនអនុវត្តសកម្មភាព អប់រំកាយនិងកីឡា ឬភាគរយ<br>ថ្នាក់រៀនបានអនុវត្តកម្មវីធីអប់រំកាយ និងកីឡា ២ម៉ោងក្នុង<br>មួយសប្តាហ៍ | រៀបចំឱ្យមានព្រឹត្តិការណ៍ការប្រកួតកីឡា នៅកម្រិតសាលារៀន | | | | | | | | | |
| | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **២៤.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ** | | | | | | | | | | |
| ភាគរយថ្នាក់ដែលបានរៀបចំឱ្យមានស្តង់ដា | កែលម្អថ្នាក់រៀនឱ្យមានលក្ខណៈស្តង់ដា ដោយផ្អែកលើផែនការកែលម្អថ្នាក់រៀន និងចូលរួមគាំទ្រពីគណៈកម្មការគ្រប់គ្រងថ្នាក់រៀននីមួយៗ | | | | | | | | | |
| ភាគរយបន្ទប់រៀនមានអគ្គីសនី និងសេវាអ៊ីនធើណេត និងចំនួនបង្គោលភ្លើងអគ្គីសនី ឬសូឡាដែលបានដាក់បំភ្លឺពេលយប់ ក្នុងបរិវេណ និងខាងមុខសាលារៀន | តបណ្តាញអគ្គីសនី តាមបន្ទប់រៀន អ៊ីនធើណេត រួមទាំងដាក់ភ្លើងបំភ្លឺពេលយប់ ឬប្រើសូឡា តាមគោលដៅ ក្នុង និងខាងមុខសាលា តាមរយៈ ការអំពាវនាវពីសប្បុរសជន | | | | | | | | | |
| ចំនួនកុំព្យូទ័រ ឬថេតប្លេតដែលមានដំណើរការ ដើម្បីរៀនសូត្រ... | រៀបចំបន្ទប់កុំព្យូទ័រ ឬថេតប្លេត | | | | | | | | | |
| ចំនួនថ្នាក់រៀនឆ្លាតវៃ(Smart Class)ដែលបានរៀបចំ (តាមដំណាក់កាល) | រៀបចំឱ្យមានថ្នាក់រៀនវៃឆ្លាត (Smart Class) ដែលបំពាក់បរិក្ខាទំនើបដូចជា LCD, Smart TV, Smart Board... | | | | | | | | | |
| | | | | | | | | | | |
| **ស្តង់ដាទី៥៖ គណនេយ្យភាព** | | | | | | | | | | |
| **២៥.វេទិកាសាធារណៈ** | | | | | | | | | | |
| ចំនួនដង នៃការជួបប្រជុំមាតាបិតាសិស្ស (ទៅតាមប្រធានបទ៖ ណែនាំអំពីការកាត់បន្ថយនិងលុបបំបាត់អំពីហិង្សានៅក្នុងគ្រួសារ និងសាលារៀន, លទ្ធផលសិក្សានិងជំរុញការសិក្សារៀនសូត្រ, ការលើកកម្ពស់អាហារូបត្ថម្ភ, គ្រឿងញៀន, ច្បាប់ចរាចរណ៍ និងការងារផ្សេងៗទៀត) | មាននៅខាងលើមួយចំនួន នឹងត្រូវកាត់យកមកបំពេញនៅត្រង់នេះ វិញ | | | | | | | | | |
| | | | | | | | | | | |
| **២៦.ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ** | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួនទីកន្លែងនៃការបិទផ្សាយលទ្ធផលតេស្តវាយតម្លៃស្តង់ដានិងព័ត៌មាននានាត្រូវបានអនុម័តដោយ គ.គ.ស. | មាននៅខាងលើមួយចំនួន នឹងត្រូវកាត់យកមកបំពេញនៅត្រង់នេះ វិញ | | | | | | | | | |
| | | | | | | | | | | |
| **២៧.ការទទួលបានការគាំទ្រពីថ្នាក់ជាតិ** | | | | | | | | | | |
| ចំនួនដងនាយកសាលានិងនាយករង បានទទួលការហ្វឹកហាត់អនុវត្តស្តង់ដាសាលារៀនគំរូ ពីនាយកសាលាផ្សេង ឬមកពីថ្នាក់លើ | | | | | | | | | | |
| ភាគរយគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង និង/ឬ វិធីសាស្ត្របង្រៀនភាសាខ្មែរ និងគណិតវិទ្យា | | | | | | | | | | |

- ជំរុញឱ្យមានការរៀនពីចម្ងាយតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការ ដូចជា Facebook, YouTube, ទូរទស្សន៍ និង តាមរយៈ App ផ្លូវការនានា
- រៀបចំការបង្រៀនតាមកម្មវិធី Zoom, Google Meet និងតាមកម្មវិធីផ្សេងៗទៀតទៅតាមលទ្ធភាព និង សមត្ថភាព
- សិស្សធ្វើស្វ័យសិក្សាសន្លឹកកិច្ចការតាម Google Form ចំណែកគ្រូត្រូវផ្ទៀងផ្ទាត់លទ្ធផលស្វ័យសិក្សាតាម អនឡាញមាន Zoom ឬ Google Meet
- ផ្តល់និងកែសន្លឹកកិច្ចការ ក៏ដូចជាវីដេអូការបង្រៀន មេរៀនសង្ខេប តាមក្រុម ...Telegram ឬ Messenger
- ធ្វើការពន្យល់ និងបកស្រាយនូវចម្ងល់នានារបស់សិស្សតាមរយៈទូរស័ព្ទដោយផ្ទាល់ ឬ ក្រុម Telegram ឬ Messenger ជាដើម។

## ៥. ការវាយតម្លៃលទ្ធផលសិក្សា

គ្រឹះស្ថានមធ្យមសិក្សាសាធារណៈត្រូវអនុវត្តការប្រឡងប្រចាំខែតាមស្ថានភាព និងគ្រប់រូបភាព ដែល អាចអនុវត្តបាន ដោយយកលទ្ធផលពីការធ្វើតេស្តចាប់ពីខែកុម្ភៈ រហូតដល់ដំណាច់(វិច្ឆិកា)ឆ្នាំ២០២១។ ការ វាយតម្លៃសមត្ថភាពសិស្សម្នាក់ៗទៅលើមុខវិជ្ជាដែលសាលារៀននីមួយៗបានបង្រៀន និងរៀន ហើយសិស្សត្រូវ មានពិន្ទុគ្រប់មុខវិជ្ជា ដែលគ្រូបានបង្រៀនក្នុងខែ។ សម្រាប់ខែមេសា និងឧសភាត្រូវបូកសរុបធ្វើចំណាត់ថ្នាក់ តែមួយខែ ដោយសរសេរថា ចំណាត់ថ្នាក់ខែមេសា និងឧសភា។

### ៥.១-ការប្រឡងប្រចាំខែ

គ្រឹះស្ថានមធ្យមសិក្សាត្រូវរៀបចំឱ្យមានលទ្ធផលសិក្សាតាមខែនីមួយៗ ដោយយកពិន្ទុតាមសប្តាហ៍បូក សរុបបញ្ចូលគ្នា ឬប្រឡងប្រចាំខែទៅតាមស្ថានភាពសាលារៀន។

- រយៈពេលប្រឡង និងរបបពិន្ទុ អនុវត្តតាមសេចក្តីណែនាំលេខ ១៦ អយក.សណន ចុះថ្ងៃ ពុធ ទី៥ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២១
- ចំពោះមុខវិជ្ជាភាសាបរទេសពិន្ទុដែលត្រូវយកមកបូក គឺជាផលសង នៃពិន្ទុដែលសិស្សធ្វើបាន ដកនឹង ២៥។ ពិន្ទុនេះបូកជាមួយពិន្ទុមុខវិជ្ជាដទៃ រួចហើយទើបគណនារកមធ្យមភាគពិន្ទុប្រឡងឆមាសជា ក្រោយ។

**បង្រៀន និងរៀនបាន**

- សម្រាប់ថ្នាក់ទី ៩ និងទី១២ សូមអនុវត្តដូចមានក្នុងសេចក្តីណែនាំលេខ ១៦ អយក.សណន ចុះថ្ងៃ ពុធ ទី ៥ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២១
- **មធ្យមភាគពិន្ទុប្រចាំខែ = ផលបូកពិន្ទុគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i (គិត៥០ពិន្ទុ)**

  **សម្គាល់៖** សន្ទស្សន៍ i = ៨.៤ (ថ្នាក់ទី៩) សន្ទស្សន៍ i = ១២.៥(ថ្នាក់ទី១២)
- សម្រាប់ថ្នាក់ទី៧ ទី៨ ទី១០ និងទី១១សូមអនុវត្តដូចខាងក្រោម៖
  - ការរកសន្ទស្សន៍នៃមុខវិជ្ជានីមួយៗគឺ ស្មើនឹងពិន្ទុអតិបរមានៃមុខវិជ្ជានីមួយៗ ចែកនឹង ៥០
  - មធ្យមភាគពិន្ទុប្រចាំខែគឺ ស្មើនឹងផលបូកពិន្ទុគ្រប់មុខវិជ្ជាបានប្រឡង ចែកនឹងផលបូកនៃសន្ទស្សន៍ គ្រប់មុខវិជ្ជាបានប្រឡង

**មធ្យមភាគពិន្ទុប្រចាំខែ = $\dfrac{\text{ផលបូកពិន្ទុជាក់ស្តែង (មុខវិជ្ជាបានប្រឡង)}}{\text{ផលបូកសន្ទស្សន៍ (មុខវិជ្ជាបានប្រឡង)}}$**

ក្រោយការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រចាំខែនីមួយៗ បើពិនិត្យឃើញថាមានសិស្សរៀនយឺត គ្រូទទួលបន្ទុកថ្នាក់ត្រូវសហការជម្រាបព័ត៌មានទៅមាតាបិតា ឬអ្នកអាណាព្យាបាលឱ្យជួយណែនាំ និងពង្រឹង បន្ថែមទៀត កិច្ចការនេះត្រូវអនុវត្តន៍ឱ្យបានទៀងទាត់។

### ៥.២-ការប្រឡងប្រចាំឆមាស

**បង្រៀន និងរៀនបាន**

- សម្រាប់ថ្នាក់ទី៩ និងទី១២ សូមអនុវត្តដូចមានក្នុងសេចក្តីណែនាំលេខ ១៦ អយក.សណន ចុះថ្ងៃ ពុធ ទី ៥ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២១
- សម្រាប់ថ្នាក់ទី៧ ទី៨ ទី១០ និងទី១១សូមអនុវត្តដូចខាងក្រោម៖
  - **មធ្យមភាគពិន្ទុខែប្រចាំឆមាស=ផលបូកមធ្យមភាគពិន្ទុប្រចាំខែក្នុងឆមាសចែកនឹងចំនួនខែក្នុង ឆមាស (គិត៥០ពិន្ទុ)**
  - ករណីពុំអាចដំណើរការប្រឡងឆមាស៖ ត្រូវយក **មធ្យមភាគពិន្ទុខែប្រចាំឆមាស** ធ្វើជា **មធ្យម ភាគពិន្ទុប្រចាំឆមាស**
  - ករណីអាចដំណើរប្រឡងឆមាស៖ **មធ្យមភាគពិន្ទុប្រចាំឆមាស** ស្មើនឹង **ផលបូកមធ្យមភាគពិន្ទុ ខែប្រចាំឆមាស និងមធ្យមភាគពិន្ទុប្រឡងឆមាស** ចែកនឹង២។
  - **មធ្យមភាគពិន្ទុប្រចាំឆ្នាំ** ស្មើនឹង**ផលបូកមធ្យមភាគពិន្ទុប្រចាំឆមាសទី១** និង**មធ្យមភាគពិន្ទុប្រចាំ ឆមាសទី១** ចែកនឹង២។
- ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់លោកគ្រូ អ្នកគ្រូមាតាបិតា ឬអ្នកអាណាព្យាបាល និងគណៈ កម្មការគ្រប់គ្រងសាលារៀន ឱ្យដឹងពីការធ្វើតេស្តឬប្រឡងបែបថ្មីដើម្បីចូលរួមជួយជំរុញការសិក្សាបន្ថែម
- ត្រូវផ្សព្វផ្សាយលទ្ធផលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ឬផ្ញើសៀវភៅតាមដានការសិក្សារបស់សិស្ស ជូនទៅមាតាបិតា/អ្នកអាណាព្យាបាលសិស្សបានពិនិត្យ និងផ្តល់យោបល់
- ត្រូវរក្សាទុកសន្លឹកវិញ្ញាសា កិច្ចការតេស្ត និងលទ្ធផលសិក្សានៅទីចាត់ការសាលារៀន
- ត្រូវរក្សាទុកសៀវភៅបញ្ជីពិន្ទុ និងសៀវភៅហៅឈ្មោះសិស្សនៅទីចាត់ការសាលារៀន។

## ៦. ការគាំទ្រ និងអន្តរាគមន៍ផ្សេងៗ

- ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូ ដូចជាផ្តល់ការរៀនសូត្រពីចម្ងាយ តាមរយៈវីដេអូការបង្រៀនដែលបាន ផ្សព្វផ្សាយនាពេលកន្លងមក
- អាជ្ញាធរដែនដី(ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក) គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ ត្រូវលើកទឹកចិត្តសិស្សឱ្យបានចូលរៀន និងចូលរួមរៀនសូត្រ តាមគ្រប់រូបភាព
- អាជ្ញាធរដែនដី( ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក) ជួយបង្កលក្ខណៈងាយស្រួល ដល់ ការចុះបំពេញការងាររបស់លោកគ្រូ អ្នកគ្រូ ជាពិសេសការបង្រៀនតាមបណ្តុំ និងការបង្រៀន តាមរយៈ សិស្សមកទទួលសន្លឹកកិច្ចការដោយផ្ទាល់នៅសាលារៀន
- វាយតម្លៃលើផលប៉ះពាល់នៃការសិក្សា និងកំណត់ចំណុចខ្វះខាតដែលសិស្សជួបប្រទះក្នុងការរៀនសូត្រ ដោយផ្តោតការយកចិត្តទុកដាក់លើក្រុមកុមារងាយរងគ្រោះ
- បន្តលើកទឹកចិត្តសិស្សដែលងាយរងគ្រោះតាមរយៈការផ្តល់ការគាំទ្រជាសម្ភារសិក្សា សម្លៀកបំពាក់ និង សម្ភារៈចាំបាច់ផ្សេងទៀត
- បន្តគាំទ្រដល់សិស្សរៀនយឺត ផ្អែកតាមលទ្ធផលតេស្តវាយតម្លៃ និងរៀបចំក្រុមសិស្សរៀនយឺតសម្រាប់ ការបង្រៀនបន្ថែម
- បន្តទំនាក់ទំនងល្អជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស ដោយផ្តល់ព័ត៌មានអំពីការសិក្សា របស់ កូនទៅពួកគាត់ជាប្រចាំ។

## ៧- ការពិនិត្យតាមដាន អធិការកិច្ច និងរបាយការណ៍

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យតាមដានដំណើរការរបស់គ្រឹះស្ថានសិក្សា និងថ្នាក់រៀន និងអធិការកិច្ច ដើម្បីផ្តល់ការគាំទ្រ និង កែលម្អជាប្រចាំនៅតាមគ្រឹះស្ថានមធ្យមសិក្សា។

គណៈគ្រប់គ្រងសាលារៀនត្រូវរៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ឆមាស ស្តីពីដំណើរការបង្រៀន និង រៀនតាមគ្រប់រូបភាពឱ្យបានទៀងទាត់តាមឋានានុក្រម។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និង កីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ បុគ្គលិកអប់រំ អាជ្ញាធរ ដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

  **"ដើម្បីជ្រាបជាព័ត៌មាន"**
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន លោកគ្រូ អ្នកគ្រូ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ... ខែផល្គុន ឆ្នាំជូត ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២១
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ កាលប្បវត្តិ

- **ឧបសម្ព័ន្ធទី៤** សេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាបង្រួញនិងកាលវិភាគសិក្សា សម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ឆ្នាំសិក្សា ២០២០-២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០១ អយក.សណន

**សេចក្តីណែនាំ**
**ស្តីពី**
**ការអនុវត្តកម្មវិធីសិក្សាបង្រួញ និងកាលវិភាគសិក្សា**
**សម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ឆ្នាំសិក្សា ២០២០-២០២១**

ក្នុងឆ្នាំសិក្សា ២០២០-២០២១ គ្រឹះស្ថានបឋមសិក្សាសាធារណៈទាំងអស់ត្រូវអនុវត្តតាម "**កម្មវិធីសិក្សាបង្រួញ**" ដែលក្នុងនោះរួមមាន មុខវិជ្ជាកាតព្វកិច្ច និងមុខវិជ្ជាជម្រើស។ នៅក្នុងមុខវិជ្ជាកាតព្វកិច្ចមានមុខវិជ្ជាចំនួនពីរគឺ ភាសាខ្មែរ និងគណិតវិទ្យា ដែលមុខវិជ្ជាទាំង២នេះត្រូវអនុវត្តទាំងស្រុងតាមកម្មវិធីសិក្សា។ ចំពោះមុខវិជ្ជាជម្រើសនឹងត្រូវអនុវត្តតាមរូបភាព៖ ១).ការបង្រៀនបត់បែនទៅតាមម៉ោងសិក្សាដែលនៅសល់ពីការបង្រៀនមុខវិជ្ជាកាតព្វកិច្ច ២).ការជ្រើសរើសមុខវិជ្ជា និងមេរៀនជាអាទិភាពមកបង្រៀន និងត្រូវអនុវត្តវិធីសាស្ត្របង្រៀនតាមបែបចម្រុះ ដូចជា៖ ក).ការបង្រៀនក្នុងថ្នាក់ ខ).ការបង្រៀនដោយប្រើប្រាស់វីដេអូ គ).ការប្រើប្រាស់កម្រងកិច្ចការផ្ទះ ដែលក្រសួងបានរៀបចំ និង ឃ).ការធ្វើស្វ័យសិក្សា។

ដើម្បីធានាថា ការអនុវត្តកម្មវិធីសិក្សាបង្រួញ និងកាលវិភាគសិក្សាមានប្រសិទ្ធភាព ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ មាតាបិតា អ្នកអាណាព្យាបាល និងសិស្សានុសិស្ស ដូចខាងក្រោម៖

**១. ការរៀបចំសិស្សក្នុងថ្នាក់**

ការរៀបចំសិស្សសម្រាប់ថ្នាក់រៀននីមួយៗ ត្រូវអនុលោមទៅតាមសេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។ ផ្អែកតាមគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ-១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ ការរៀបចំសិស្សក្នុងថ្នាក់ត្រូវអនុវត្ត ដូចខាងក្រោម៖

**ក. ថ្នាក់ទី១-៣**
- ករណី សិស្សតិចជាង ឬស្មើ ៣៥នាក់ ត្រូវរៀបចំតែមួយថ្នាក់ ដោយរៀនថ្ងៃចន្ទ អង្គារ ពុធ សុក្រ និងសៅរ៍ (ថ្ងៃព្រហស្បតិ៍ គ្រូបង្រៀនត្រូវអញ្ជើញមកសាលារៀន ដើម្បីរៀបចំសម្ភារឧបទេស និងកែកិច្ចការសិស្សជាដើម)
- ករណី សិស្សលើសពី ៣៥នាក់ ត្រូវរៀបចំជា ២ក្រុម ក្នុងមួយថ្នាក់ ក្នុងនោះក្រុមទី១ ត្រូវរៀននៅថ្ងៃចន្ទ ពុធ សុក្រ និងក្រុមទី២ ត្រូវរៀននៅថ្ងៃអង្គារ ព្រហស្បតិ៍ សៅរ៍។

1

info@moeys.gov.kh / administration@moeys.gov.kh www.moeys.gov.kh

**ខ. ថ្នាក់ទី៤-៦**
- ករណី សិស្សតិចជាង ឬស្មើ ៤០នាក់ ត្រូវរៀបចំតែមួយថ្នាក់ ដោយរៀនថ្ងៃចន្ទ អង្គារ ពុធ សុក្រ និងសៅរ៍ (ថ្ងៃព្រហស្បតិ៍ គ្រូបង្រៀនត្រូវរៀបចំសម្ភារឧបទេស និងកែកិច្ចការសិស្សជាដើម)
- ករណី សិស្សលើសពី ៤០នាក់ ត្រូវរៀបចំជា ២ក្រុម ក្នុងមួយថ្នាក់ ក្នុងនោះក្រុមទី១ ត្រូវរៀននៅថ្ងៃចន្ទ ពុធ សុក្រ និងក្រុមទី២ ត្រូវរៀននៅថ្ងៃអង្គារ ព្រហស្បតិ៍ សៅរ៍។

**២. ការបែងចែកកម្មវិធីសិក្សា និងមេរៀនសិក្សា**

ក្រសួងបានកំណត់ជាមុខវិជ្ជាកាតព្វកិច្ច រួមមាន៖ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា និងមុខវិជ្ជាជម្រើស រួមមាន៖ មុខវិជ្ជាវិទ្យាសាស្ត្រ និងសិក្សាសង្គម ព្រមទាំងមុខវិជ្ជាផ្សេងទៀត។ នៅក្នុងត្រីមាសទី១ (ចាប់ពីថ្ងៃទី១១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១) ការបែងចែកកម្មវិធីសិក្សា ត្រូវអនុវត្តដូចខាងក្រោម៖

- ចាប់ពីថ្ងៃបើកបវេសនកាល រហូតដល់ថ្ងៃទី៣១ ខែមករា គណៈគ្រប់គ្រងសាលានិងគ្រូបង្រៀនត្រូវអនុវត្តដូចតទៅ៖
  - ថ្នាក់រៀននីមួយៗ ត្រូវដំណើរការបង្រៀននិងរៀន ៥ម៉ោងសិក្សាក្នុងមួយថ្ងៃ
  - ធ្វើតេស្តវាយតម្លៃសមត្ថភាពសិស្ស (តេស្តដើមឆ្នាំ) លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា
  - រៀបចំខ្លឹមសារមេរៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា នៃថ្នាក់ឆ្នាំសិក្សាចាស់ ដើម្បីបំពេញសមត្ថភាពសិស្ស ដែលបានបាត់បង់នាពេលកន្លងមក
  - បន្សីផ្សារភ្ជាប់ខ្លឹមសារមេរៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ថ្នាក់ឆ្នាំសិក្សាចាស់ និងចាប់ផ្តើមខ្លឹមសារមេរៀនឆ្នាំសិក្សាថ្មី។

**បញ្ជាក់៖** សម្រាប់ថ្នាក់ទី១ គ្រូបង្រៀនត្រូវចាប់ផ្តើមបង្រៀនខ្លឹមសារមេរៀនចាប់ពីដើមឆ្នាំសិក្សា។

- ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ដល់ថ្ងៃទី៣១ ខែមីនា គណៈគ្រប់គ្រងសាលានិងគ្រូបង្រៀនត្រូវអនុវត្តដូចតទៅ៖
  - ថ្នាក់រៀននីមួយៗ ត្រូវដំណើរការបង្រៀននិងរៀន ៥ម៉ោងសិក្សាក្នុងមួយថ្ងៃ
  - ថ្នាក់រៀនដែលមានតែ ១ក្រុម ត្រូវបង្រៀនមុខវិជ្ជាភាសាខ្មែរ ចំនួន ១៦ម៉ោងសិក្សា និងគណិតវិទ្យា ចំនួន ៩ម៉ោងសិក្សា
  - ថ្នាក់រៀនដែលចែកជា ២ក្រុម ក្នុងក្រុមនីមួយៗ ត្រូវបង្រៀនមុខវិជ្ជាភាសាខ្មែរ ចំនួន ១០ម៉ោងសិក្សា និងគណិតវិទ្យា ចំនួន ៥ម៉ោងសិក្សា
  - ថ្នាក់រៀនដែលចែកជា ២ក្រុម ក្នុងរយៈពេល៣ថ្ងៃ ដែលសិស្សមិនបានមកសាលារៀន គ្រូបង្រៀន ត្រូវណែនាំនិងសម្របសម្រួលឱ្យសិស្សធ្វើស្វ័យសិក្សា សិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈវីដេអូនៃការបង្រៀន សៀវភៅសិក្សាគោល និងកម្រងកិច្ចការផ្ទះ ដែលក្រសួងបានរៀបចំ
  - គ្រូបង្រៀនត្រូវរៀបចំបំណែងចែកកម្មវិធីសិក្សាប្រចាំសប្តាហ៍ និងប្រចាំខែ ទៅតាមចំនួនម៉ោងនៃក្រុមថ្នាក់ (ថ្នាក់រៀនដែលបែងចែក ១ក្រុម ឬ ២ក្រុម) នៃសប្តាហ៍នីមួយៗ ខាងលើ។
- ចាប់ពីថ្ងៃទី០១ ខែមេសា តទៅ ក្រសួងនឹងចេញសេចក្តីណែនាំអនុវត្តបន្ថែម។

2

- **ឧបសម្ព័ន្ធទី៦** សេចក្តីប្រកាសព័ត៌មានស្តីពីដំណើរការរៀនពីចម្ងាយតាមប្រព័ន្ធអេឡិកត្រូនិកសម្រាប់ជំនួយដល់សិស្សានុសិស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ___ អយក.

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ដំណើរការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ជាជំនួយដល់សិស្សានុសិស្ស**

ដើម្បីជាជំនួយដល់ការសិក្សារបស់សិស្សានុសិស្ស ក្នុងអំឡុងពេលនៃផ្អាកការសិក្សាជាបណ្តោះអាសន្ន ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ឱ្យគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាសាធារណៈទាំងអស់ ត្រូវអនុវត្តមុខវិជ្ជាភាគច្រើន គ្រប់កម្រិតថ្នាក់តាម "កម្មវិធីសិក្សាបង្រួញ" ដូចមានក្នុងសេចក្តីណែនាំស្តីពី ការអនុវត្តកម្មវិធីសិក្សាបង្រួញ និងកាលវិភាគសិក្សាសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈឆ្នាំសិក្សា ២០២០-២០២១។

ក្រៅពីនេះ ដើម្បីធានាបានថាសិស្សានុសិស្សនៅតែអាចបន្តការសិក្សាបាន ក្រសួងបានលើកទឹកចិត្តឱ្យលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់បន្តការសិក្សាពីចម្ងាយ និងតាមអេឡិចត្រូនិកទៅតាមលទ្ធភាព ជាពិសេសការទាញយកនូវធនធានអប់រំឌីជីថល ដែលមានស្រាប់សម្រាប់ជាជំនួយដល់ការសិក្សា រួមមាន៖ សៀវភៅសិក្សាគោលអេឡិចត្រូនិក វីដេអូបង្រៀនគ្រប់កម្រិតភូមិសិក្សា និងសន្លឹកកិច្ចការមេរៀននីមួយៗ។ ម្យ៉ាងវិញទៀត សិស្សានុសិស្សទាំងអស់អាចសិក្សាបន្ថែមដោយខ្លួនឯងបានគ្រប់ពេលវេលា និងនៅគ្រប់ទីកន្លែង ដែលមានលក្ខណៈបត់បែន តាមរយៈមធ្យោបាយដូចខាងក្រោម៖

១-កម្មវិធីទូរសព្ទដៃ "MoEYS E-Learning" ដោយមានសៀវភៅសិក្សា បណ្ណាល័យវីដេអូមេរៀន ការធ្វើតេស្ត ព្រមទាំងព័ត៌មានអប់រំ ដែលមានសារៈប្រយោជន៍ជាច្រើនទៀត
២-បណ្តាញ YouTube ផ្លូវការរបស់ក្រសួង៖ www.youtube.com/moeyscambodia ដោយមានវីដេអូបង្រៀនទាំងអស់
៣-គេហទំព័រគ្រូរបស់ក្រសួង៖ www.krou.moeys.gov.kh ដោយមានកិច្ចតែងការបង្រៀន គំនូសជីវចលអប់រំ ល្បែងសិក្សា បទបង្ហាញ សន្លឹកកិច្ចការនិងលំហាត់ជាច្រើន ដែលអាចទាញយកសម្រាប់ការបង្រៀននិងរៀន
៤-ទំព័រហ្វេសប៊ុកគ្រូរបស់ក្រសួង៖ www.facebook.com/krou.moeys.gov.kh
៥-មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង៖ www.elearning.moeys.gov.kh ដោយសិស្សានុសិស្សអាចចូលទៅសិក្សាបានដោយចូលទៅជ្រើសរើសវគ្គសិក្សា ឬមេរៀនដែលត្រូវសិក្សាដោយឥតគិតថ្លៃ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកគ្រូ អ្នកគ្រូ មាតាបិតា អ្នកអាណាព្យាបាលសិស្ស ចូលរួមជំរុញ និងលើកទឹកចិត្តដល់សិស្សានុសិស្សទាំងអស់ ជាពិសេសផ្តល់លទ្ធឱកាសតាមគ្រប់រូបភាព ដើម្បីអាចបន្តការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យបានជាប់ជាប្រចាំ តាមរយៈការចូលប្រើប្រាស់និងទាញយកពីគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដូចបានបង្ហាញជូនខាងលើ តាមការគួរ។

ថ្ងៃ ... ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ... ឆ្នាំ២០២១

ទាញយកកម្មវិធី "MoEYS E-Learning"
នៅក្នុង Appstore និង Playstore

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ជំពូកទី៨ មេរៀនទី៣

- **ឧបសម្ព័ន្ធទី១** សេចក្តីណែនាំស្តីពីការបង្រៀន និងរៀនពីចម្ងាយ និងរៀនតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ឆ្នាំសិក្សា២០២០-២០២១

ឧបសម្ព័ន្ធ ក នីតិវិធីប្រតិបត្តិស្តង់ដារ (SOP) សម្រាប់ជម្លៀសប្រកបដោយសុវត្ថិភាព សេណារីយូទឹកជំនន់

# នីតិវិធីប្រតិបត្តិស្តង់ដារ (SOP)
# សម្រាប់ជម្លៀសប្រកបដោយសុវត្ថិភាព



# សាលាបឋមសិក្សា បឹងកាឆាង

## ភូមិបឹងកាឆាង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង



**សេចក្តីផ្តើមរួម**

សាលាបឋមសិក្សា **បឹងកាឆាង** បានកសាងឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០០(ខ្ទីដីសហគមន៍ សាងសង់៣៥ម៉ែត្រការេ )មានអគារ១ខ្នង២បន្ទប់ដំបូលប្រកហ្វីប្រូដញ្ញាំងបាំងក្តារដែលគណៈបក្សប្រជាជន បានផ្តល់ជូនឃ្លាំង សាប៊ូចាស់១ខ្នងទទឹង៨មបណ្តោយ១៥ម និងសាលាខេត្តកោះកុងផ្តល់ថវិកាចំនួន១លាន រៀលតាមរយៈមេឃុំស្តីទី ប៉ាក់ខ្លងលោកដៅហេងព្រមទាំងមានការគាំទ្រពីអាជ្ញាធរភូមិការិ.អយកស្រុក មណ្ឌលសីមាមន្ទីរអេយកខេត្ត ជាពិសេស ការចូលពី២០០៧សិស្សកើនខ្វះបន្ទប់រៀនបង្រៀនក្រោមដើមឈើ គម្រោង សាលាមិនគ្រប់កម្រិតរបស់ក្រសួង សហ គមន៍ ក្នុងភូមិទាំងថវិកានិងកម្លាំងពលកម្មរហូតដល់សាលា

នេះ បានដំណើរការបើកទ្វារឱ្យសិស្ស ចូលរៀន ចាប់ពី ឆ្នាំសិក្សា ២០០០-២០០១ដែលមានសិស្សសរុប៩៧ នស្រី៤០នគ្រូ២នស្រី១ (កិច្ចសន្យា១) រហូតដល់ឆ្នាំសិក្សា២០០៦ អប់រំបានសាងសង់អគារ១ខ្នង១បន្ទប់ សរុបមាន ៣ បន្ទប់មកដល់ឆ្នាំសិក្សា២០០៨-២០០៩អគារ១ខ្នងមាន២បន្ទប់ដែលបានសាងសង់ដោយ សហគមន៍នោះទ្រុឌទ្រោមមិនអាចឱ្យសិស្សរៀនបានក៏សហការជាមួយសហគមន៍ ធ្វើខ្ទះឯបក្រោមដើមឈើ ដែលមានទទឹង៣មបណ្ដោយ២៥មប្រកស្លឹកយកកូនឈើមកដាំបាំងខ្យល់និងពន្លឺថ្ងៃក្នុងថ្នាក់យកក្រណាត់ រាំងននបាំងខ័ណ្ឌចែកបន្ទប់រៀន។

បច្ចុប្បន្នសហគមន៍ **បឹងកាឆាង** បានសហការជាមួយអាជ្ញាធរគ្រប់លំដាប់ ថ្នាក់ការិ.យាល័យអយក-មន្ទីរអយក ធ្វើសំណើរសុំដី ១កន្លែង ទទឹង ១០០ម បណ្ដោយ ២៥០ម (25,000ម៉ែតការេ) ស្ថិតក្នុងដែន ជម្រកសត្វព្រៃពាម ក្រសោប ដើម្បីសាងសង់សាលារៀនទៅរដ្ឋមន្ត្រីក្រសួងបរិស្ថានបានសម្រេច។នៅឆ្នាំ សិក្សា២០០៩-២០១០ក្រសួងអប់រំ យុវជន និង កីឡា បានសាងសង់អគារថ្ម១ខ្នងមាន៥បន្ទប់បន្ទប់ទឹក៤ បន្ទប់ស៊ីទែនចំណុះ២០០០លចំនួន២តុសិស្ស៩៦កៅអីសិស្ស១៩២តុគ្រូ៥កៅអីគ្រូ៥ក្ដារខៀន៤ក្រោម ជំនួយរបស់FTIកម្មវិធីពន្លឿនវិស័យអប់រំ រហូតមកដល់ឆ្នាំសិក្សា ២០១៨- ២០១៩ មានសិស្សចូលរៀនចំនួន សរុប ៨៥នាក់ ស្រី៤៤នាក់ មានសិស្សមត្តេយ្យ ២០នាក់ ស្រី ១២នាក់ មានគ្រូចំនួនសរុប ៥នាក់ ស្រី២នាក់ គ្រូក្របខ័ណ្ឌបឋម សរុប៥នាក់ ២នាក់ គ្រូក្របខ័ណ្ឌមត្តេយ្យ សរុប០នាក់ ក្នុងនោះគ្មានសិស្សពិការទេ។

សាលារៀននេះធ្លាប់ទទួលរងមុខសញ្ញាគ្រោះថ្នាក់ ក្នុងនោះមានពីរមុខសញ្ញាគ្រោះថ្នាក់ដែលមានផល ប៉ះពាល់ខ្លះដល់សាលារៀនតាំងពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៩ មានគ្រោះមហន្តរាយ ទី១គឺរន្ទះបាញ់ ធ្វើ បាត់បង់អាយុជីវិតមនុស្សម្នាក់ និងព្រៃឈើ។ គ្រោះមហន្តរាយទី២ ខ្យល់ព្យុះ ប៉ើងដំបូលផ្ទះជាច្រើនខូចខាត សម្ភារៈប្រើប្រាស់ខ្នង គ្រោះមហន្តរាយទី៣ ជំនោរសមុទ្រឡើងខ្ពស់ ធ្វើឱ្យផ្ទះសំបែងប្រជាពលរដ្ឋ ខូចខាត ក្រៅពីនេះមានគ្រោះហានិភ័យផ្សេងៗទៀតដូចជា ទឹកឡើងខ្លាំង បណ្ដាលឱ្យកុមារផ្អាកការសិក្សា ២-៣ថ្ងៃ រអិលដួលរលាត់ដៃជើង មុតដៃមុតជើង ។ល។

មូលដ្ឋាននៃនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) សម្រាប់ជម្លៀសប្រកបដោយសុវត្ថិភាពមាន ៦ ចំណុច ហើយវាអាស្រ័យលើប្រភេទមុខសញ្ញាគ្រោះថ្នាក់ និងបត់បែនទៅតាមកាលៈទេសៈជាក់លាក់ណាមួយរបស់ សាលារៀន។ ខាងក្រោមនេះ ជានីតិប្រតិបត្តិស្តង់ដារទាំង ៦។

1. ការជម្លៀសចេញពីអគារ
2. ជួបជុំ និងជ្រកខាងក្រៅបន្ទប់/អគារ
3. ជម្លៀសទៅរកកន្លែងសុវត្ថិភាព
4. ជួបជុំ និងជ្រកក្នុងបន្ទប់រៀន

5. ការឃាំង/ហាមការចូលដោយហឹង្សា

6. ការវិលទៅជួបក្រុមគ្រួសារវិញដោយសុវត្ថិភាព

ជាក់ស្តែងនៅក្នុងសាលារៀននេះ គណៈកម្មការទ្រទ្រង់សាលា បានជ្រើសរើសយកនីតិវិធីប្រតិបត្តិស្តង់ដារ (SOP)ទី១ "**ជួបជុំ និងជ្រកក្នុងបន្ទប់រៀន**" ដើម្បីរៀបចំជាវិធានការក្នុងការត្រៀមបង្ការនឹងមុខសញ្ញាគ្រោះថ្នាក់ "**ខ្យល់ខ្លាំង/ខ្យល់កន្ទ្រាក់**"។ ដោយឡែកនីតិវិធិស្តង់ដាទី២"**ការជម្លៀសទៅកន្លែងសុវត្ថិភាព**"និងនីតិវិធិស្តង់ដាទី៣"**ការវិលទៅជួបក្រុមគ្រួសារវិញដោយសុវត្ថិភាព**" ដើម្បីរៀបចំជាវិធានការត្រៀមបង្កានឹងមុខសញ្ញាគ្រោះថ្នាក់"**ជំនោរសមុទ្រសូណាមិ/និងជំនោរសមុទ្រឡើងខ្ពស់**" ដែលតែង កើតមានឡើងក្នុងសាលារៀន។ ការកំណត់នេះត្រូវបានធ្វើឡើងតាមរយៈការសិក្សាអំពីហានិភ័យ និងសមត្ថភាពនៅក្នុងសាលារៀនដោយក្នុងនោះគេសង្កេតឃើញថា អគារសិក្សានៅក្នុងសាលារៀននេះមានភាពរឹងមាំគ្រប់គ្រាន់ដែលអាចអោយសិស្សជម្លៀសចូលធ្វើជាកន្លែងសុវត្ថិភាព ដើម្បីគេចចេញពីឥទ្ធិពល និងផលប៉ះពាល់ផ្សេងៗពីខ្យល់ខ្លាំង។

**១.សញ្ញាប្រកាសអោយដឹងមុនពេលនៃមុខសញ្ញាគ្រោះថ្នាក់**




## ២.សញ្ញាប្រកាសអាសន្នសម្រាប់ជម្លៀស

គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន បានសម្រេចយកសំលេងស៊ីរ៉ែនជាសញ្ញាបញ្ជាក់ថាមានជំនោរសមុទ្រស៊ូណាមិ។ យកសំលេងកញ្ចែជាសញ្ញាបញ្ជាក់ថាមានខ្យល់ព្យុះ។ តាមរយៈការចាក់បំពងសំលេងស៊ីរ៉ែនគណៈពេលជំនោរសមុទ្រស៊ូណាមិមកដល់។ ផ្លុំសំលេងកញ្ចែគណៈពេលមានខ្យល់ព្យុះកើតឡើង។សំលេងបន្លឺឡើងដើម្បីផ្សព្វផ្សាយជូនដំណឹងដល់គ្រប់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូទាំងអស់ ឱ្យបានដឹងតាមរយៈក្រុមប្រកាសអាសន្នជាអ្នកផ្សព្វផ្សាយ។ ដោយសារសាលារៀននេះ គ្មានសិស្សពិការផ្នែកគរ ឬថ្លង់ ទើបគ្មានសញ្ញាប្រកាសអាសន្នពិសេសណាមួយផ្សេងទៀត ត្រូវបានបង្កើតឡើងឡើយ។ នៅពេលសមយុទ្ធបញ្ចប់ ក្រុមប្រកាសអាសន្នបានជូនដំណឹងតាមរយៈមេក្រូ បញ្ជាក់ថាសមយុទ្ធត្រូវបានបញ្ចប់ជាស្ថាពរ។

## ៣.សំណួរគន្លឹះសំខាន់ៗក្នុងការសម្រេចចិត្តជ្រើសរើសនីតិវិធីណាមួយ

- *សំណួរទី ១៖ តើមានសញ្ញាប្រកាសណាមួយអោយដឹងមុនពេលនៃមុខសញ្ញាគ្រោះថ្នាក់នោះដែរឬទេ?*
- *សំណួរទី ២៖ តើអគារសាលារៀនមានសុវត្ថិភាពដែរឬទេ?*
- *សំណួរទី ៣៖ តើទីធ្លាសាលារៀនមានសុវត្ថិភាពដែរឬទេ?*
- *សំណួរទី ៤៖ តើនៅក្នុងសហគមន៍ មានសុវត្ថិភាពដែរឬទេ?*

## ៤.ផែនទីជម្លៀស

ផែនទីខាងលើជាផែនទីមុខសញ្ញាគ្រោះថ្នាក់ដែលត្រូវបានគូសដោយសិស្សានុសិស្សដោយមានការណែ នាំអំពីលោក-អ្នកគ្រូនៅក្នុងសាលារៀននោះ នៅអំឡុងពេលប្រជុំពិភាក្សារៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រោះមហន្តរាយកម្រិតសាលារៀន។ នៅលើផែនទីនោះ មានសញ្ញាត្រីកោណពណ៌ក្រហម ដែលជាសញ្ញាបញ្ជាក់អំពីកន្លែងអាចមានគ្រោះថ្នាក់(គល់ឈើ)ដល់សិស្សនៅពេលមានហេតុការណ៍ណាមួយដូចជាមានខ្យល់ខ្លាំងជាដើម។ ដោយឡែកនៅលើទីតាំងណាដែលមានគ្មានសញ្ញាខ្វែង បញ្ជាក់ថាជាកន្លែងមានសុវត្ថិភាព ដូចជាអគារសិក្សា ដែលអាចអោយសិស្សចូលជ្រកជម្លៀសគេចចេញពីហេតុការណ៍គ្រោះថ្នាក់នៅខាងក្រៅអគារ។ ក្នុងស្ថានភាពនៅសាលារៀននេះ សិស្សត្រូវរកកន្លែងជម្លៀសនៅក្នុងអគារសិក្សា នៅពេលមានខ្យល់ខ្លាំង ឬហេតុការណ៍គ្រោះថ្នាក់ដែលអាចកើតឡើងនៅខាងក្រៅអគារសិក្សា។




## ៥.នីតិវិធីប្រតិបត្តិស្តង់ដារ

### ក. ការជួបជុំ និងជ្រកខាងក្នុងអគារ/បន្ទប់

**គោលបំណង៖** ការពារសិស្ស មន្ត្រីអប់រំ ក្នុងករណីមានមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្រៅអគារ/បន្ទប់ ដូចជាទឹកជំនន់ អាកាសធាតុអាក្រក់ ដើម្បីធានាសុវត្ថិភាពរបស់ពួកគេរហូតអាចត្រឡប់ទៅជួបជុំគ្រួសាររបស់ពួកគេវិញ។ ការជួបជុំ និងជ្រកខាងក្នុងអគារ/បន្ទប់ ត្រូវបានអនុវត្ត នៅពេលណាដែលការជម្លៀសមិនចាំបាច់ ឬមិនទាន់ដល់ពេលត្រូវជម្លៀស។

រដ្ឋបាលសាលារៀន៖ ប្រកាសឱ្យនៅក្នុងបន្ទប់អគារ ឬឱ្យវិលត្រឡប់ចូលក្នុងអគារវិញ។ ត្រូវមើលរាល់ការទំនាក់ទំនងទាំងអស់ និងផ្តល់ការណែនាំផ្សេងៗតាមចាំបាច់។ ប្រកាសថា "បញ្ចប់" នៅពេលអាសន្នឈប់។

**បុគ្គលិក៖**

1- បិទទ្វារ និងបង្អួច បើចាំបាច់
2- កត់ត្រាវត្តមានសិស្ស
3- ត្រួតពិនិត្យមើលស្ថានការណ៍ និងផ្តល់ព័ត៌មានផ្សេងៗនៅពេលមាន។ ត្រូវនៅឱ្យជាប់ទូរស័ព្ទ ដើម្បីទាក់ទងផ្សេងៗ
4- មើលថែទាំសិស្សក្នុងថ្នាក់ ដោយឱ្យសិស្សរៀន លេងខ្លះ ហូប សម្រាក...ដើម្បីកុំអោយពួកគេមានអារម្មណ៍តក់ស្លុក (បត់បែនជាក់ស្តែង)
5- រៀបចំកន្លែងបត់ដែបត់ជើងបណ្តោះអាសន្ន (ដូចជាប្រើថង់ ធុង...)

**សិស្ស៖**

ត្រូវចូលរួម និងជួយការងារផ្សេងៗតាមអាចជួយបានតើសាលារៀនរបស់អ្នកអាចមានការបត់បែនអ្វីផ្សេង ឬទេ?

## ខ. ការជម្លៀសទៅកន្លែងសុវត្ថិភាព




**គោលបំណង៖** ការពារសិស្ស មន្ត្រីអប់រំ ក្នុងករណីមានអគ្គីភ័យ ឬមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្នុងបរិស្ថានសាលារៀននោះ។

**រដ្ឋបាលសាលារៀន៖** ចំពោះសាលារៀនទាំងឡាយណាដែលប្រឈមនឹងទឹកជំនន់ បាក់ដី ការហូរល្បាប់ដី ឬសាលារៀនដែលគ្មានកន្លែងជួបជុំ គួរតែរៀបចំកន្លែងនេះ នៅកន្លែងផ្សេងទៀត និងរៀបចំឱ្យមានផ្លូវជម្លៀសឱ្យបានមុនពេល។ ត្រូវប្រាប់ដល់ឪពុកម្ដាយ និងអាណាព្យាបាលសិស្សឱ្យបានដឹងពីកន្លែងជួបជុំនោះ។ បើជម្លៀសត្រូវជម្លៀសទៅរកទីតាំងជួបជុំណាដែលបានកំណត់ពីមុនរួចហើយ។ កុំភ្លេចយកប្រអប់ជំនួយ/សង្គ្រោះបឋមទៅជាមួយផង។

**បុគ្គលិក៖**

1- រំលឹកសិស្សពីគោលការណ៍ជម្លៀសសុវត្ថិភាព៖ កុំរត់ កុំនិយាយ កុំរុញ កុំត្រលប់ក្រោយ។

2- ពេលជម្លៀសត្រូវមានមនុស្សធំម្នាក់នៅខាងមុខ ដើម្បីមើលថាផ្លូវជម្លៀសមានសុវត្ថិភាពឬទេ ហើយត្រូវមានគ្រូ/សិស្សមានសមត្ថភាពម្នាក់ទៀតនៅខាងក្រោយក្រុមសិស្សជម្លៀសនោះ ដើម្បីពិនិត្យមើលថាសិស្សទាំងអស់ជុំគ្នា។ អាចធ្វើជាពីរថ្នាក់ចូលគ្នាបាន។

3- ត្រូវយកសម្ភារៈ/ព័ត៌មាននៅក្នុងបន្ទប់របស់អ្នក (ប្រអប់សង្គ្រោះបឋម ផែនទីផ្លូវជម្លៀស សោរបន្ទប់ កញ្ចែ ទូរស័ព្ទ លេខទូរស័ព្ទទាក់ទងសំខាន់ បញ្ជីគណៈកម្មការ....)។

4- ដឹកនាំសិស្សទៅរកកន្លែងជួបជុំពេលអាសន្ន និងហៅឈ្មោះសិស្សម្ដងម្នាក់។

5- នៅពេលមានសុវត្ថិភាពហើយ ត្រូវនាំសិស្សត្រលប់មកវិញ ដោយអនុវត្តគោលការណ៍ជម្លៀសដូចខាងលើ។

**សិស្ស៖**

ត្រូវអង្គុយតាមក្រុម បំលាស់ទីឱ្យបានលឿន និងស្ងាត់ស្ងៀម។ នៅកន្លែងជួបជុំ ត្រូវអនុវត្តតាមគោលការណ៍ជួបជុំ និងជ្រកខាងក្រៅបន្ទប់/អគារ គឺត្រូវអង្គុយតាមកន្លែង ស្ងាត់ស្ងៀម។ ត្រូវជួយរៀបចំទឹក ម្ហូប ជម្រក និងអនាម័យផ្សេងៗនៅពេលគ្រូស្នើឱ្យជួយ។

តើកន្លែងជួបជុំនៅកន្លែងណា? តើអ្នកមានសម្ភារៈដែលត្រូវការដែរឬទេ? តើមានការផ្លាស់ប្តូរចំពោះសាលារបស់អ្នកឬទេ?

## គ. ការវិលទៅជួបក្រុមគ្រួសារវិញដោយសុវត្ថិភាព

**គោលបំណង៖** ដើម្បីធានាថាក្រុមគ្រួសារពួកគេជួបគ្នាវិញដោយសុវត្ថិភាព។ ក្មេងមានអាយុក្រោម ១៦ ឆ្នាំ មិនអាចអញ្ញាតឱ្យចេញទៅដោយគ្មានការអនុញ្ញាតពីអាណាព្យាបាលឡើយ លុះត្រាមានការអនុញ្ញាតជាមុនសិន។

**អាណាព្យាបាលសិស្ស និងរដ្ឋបាលសាលារៀន៖** អាណាព្យាបាលត្រូវផ្តល់ព័ត៌មានទំនាក់ទំនងពេលមានអាសន្ន ដល់សាលារៀន ក្នុងការមកទទួលយកសិស្សចេញ។ នៅពេលមានអាសន្ន សិស្សនឹងអនុញ្ញាតឱ្យចេញបានតែជាមួយបុគ្គលណាដែលអាណាព្យាបាលអនុញ្ញាតដែលមានក្នុងបញ្ជីតែប៉ុណ្ណោះ។

**បុគ្គលិក៖**

1- ត្រូវធានាថា សិស្ស និងអាណាព្យាបាលស្គាល់គ្នាត្រឹមត្រូវ

2- ផ្ទៀងផ្ទាត់ប័ណ្ណសម្គាល់ និងធានាថាបុគ្គលនោះមានក្នុងបញ្ជីអនុញ្ញាតពីអាណាព្យាបាលអោយមកយកសិស្សបាន

3- ធ្វើកំណត់ត្រាផ្សេងៗ

**សិស្ស៖**

4- ត្រូវស្គាល់អាណាព្យាបាលឱ្យច្បាស់ និងអនុវត្តតាមនីតិវិធីជួបជុំគ្រួសារ។

# នីតិវិធីប្រតិបត្តិស្តង់ដារ (SOP)
# សម្រាប់ជម្លៀសប្រកបដោយសុវត្ថិភាព




## សាលាបឋមសិក្សា ហ៊ុន សែន កោះស្តេច

## ភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង



## សេចក្តីផ្តើមរួម

សាលាបឋមសិក្សា **ហ៊ុនសែនកោះស្តេច** មានទីតាំងស្ថិតនៅតំបន់ដីកោះ ដែលមានទីតាំងស្ថិតនៅភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង ដែលមានព្រំប្រទល់ ខាងជើង ខាងត្បូង ខាងកើត និងខាងលិច ជាប់នឹងសមុទ្រ ។ក្នុងឆ្នាំ១៩៨០ សាលារៀនមានអគារសិក្សាមួយខ្នងស្មើនឹង២បន្ទប់ ដែលមានសិស្សចំនួន ៦០នាក់ សិស្សស្រី ២៥នាក់ និងអ្នកគ្រូ ១នាក់។ក្នុងឆ្នាំ១៩៨៨ សាលារៀនបានប្តូរទីតាំងពីសាលាស្រុកមកតាំងនៅចង្កេះភ្នំ(ដូចបច្ចុប្បន្ន) ដែលមានអគារសិក្សា១ខ្នង ស្មើនឹង ៤បន្ទប់ប្រក់ស័ង្កសី(គ្មានកម្រាល) ហើយមានផ្ទៃដី ១៩៨២៥ម២។ រហូតមកដល់ឆ្នាំ១៩៩៥ ដោយអគារនោះមានសភាពទ្រុឌទ្រោមខ្លាំង គេបានរុះរើអគារសិក្សានោះមកសាងសង់ថ្មីឡើងវិញ បានចំនួន០២បន្ទប់ ដែលគាំទ្រដោយមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា។ក្នុងឆ្នាំ១៩៩៧ អគារសិក្សា១ខ្នង មាន៥បន្ទប់បានដុះឡើងក្នុងបរិវេនសាលារៀននោះផងដែរ ដោយសង់អំពីថ្មប្រក់ហ្វ្រីប្រូស៊ីម៉ង់ ជាអំណោយរបស់លោកឧកញ្ញា កុក អាន។ក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានផ្តល់អគារសិក្សា១ខ្នងទៀត ស្មើនឹង៥បន្ទប់ ដែលសង់អំពីថ្មប្រក់ក្បឿង។

បច្ចុប្បន្នសាលារៀន មានផ្ទៃដីសរុបចំនួន ៣៦០០m2 មានអគារសិក្សាចំនួន៣ខ្នង ស្មើនឹង១២បន្ទប់ ប៉ុន្តែដោយអគារសិក្សា១ខ្នង ស្មើ៥បន្ទប់ដែលជាអំណោយរបស់លោកឧកញ្ញា កុក អាននោះ បានចាស់ទ្រុឌទ្រោមមិនអាចដំណើរការបង្រៀន និងរៀនបានឡើយ ដែលជាហេតុធ្វើឱ្យសាលារៀនខ្វះបន្ទប់សិក្សាជាខ្លាំង។ សាលារៀនយើងខ្ញុំមានរបងថ្មនៅខាងមុខនិងចំហៀងខាងត្បូង មានក្លោងទ្វាចូល មានដងទង់ជាតិ មានបង្គន់ ១ខ្នង ស្មើ៤បន្ទប់ រូបសំណាកព្រះបាទជ័យវរ្ម័នទី៧ ក្នុងនោះមានសិស្សក្នុងឆ្នាំសិក្សា ២០១៨ - ២០១៩ ចំនួន៤៤៣ នាក់ ស្រី ២១៩ នាក់ ក្នុងនោះសិស្សបឋមចំនួន ៣៤២នាក់ សិស្សស្រី១៧៦នាក់ ហើយមានបុគ្គលិក ចំនួន ១៥នាក់ ស្រី ១០នាក់ ក្នុងនោះមានបុគ្គលិកបឋមចំនួន ១២នាក់ ស្រី ៧នាក់ ចំណែកបុគ្គលិកមត្តេយ្យសរុប ចំនួន ៣នាក់ ស្រី ៣នាក់។

សាលាបឋមសិក្សា **ហ៊ុន សែនកោះស្តេច** ធ្លាប់ទទួលរងមុខសញ្ញាគ្រោះថ្នាក់បយនមុខសញ្ញា ក្នុងនោះមានពីរមុខសញ្ញាគ្រោះថ្នាក់ដែលមានផលប៉ះពាល់ខ្លះដល់សាលារៀនតាំងពីឆ្នាំ២០១៦រហូតដល់ឆ្នាំ២០១៩ មានគ្រោះមហន្តរាយទី១គឺខ្យល់ព្យុះ ធ្វើឱ្យប៉ើងដំបូលផ្ទះប្រជាជន១៩គ្រួសារ បាក់ស្ពាន២ខ្សែ ប្រវែង១៥ម ប្រជាជនមិនបានចេញទៅនេសាទ រយៈពេល១៥ថ្ងៃ លិចអូប័រ២គ្រឿង បាក់ដើមឈើធំមួយដើមរលំបង្គោលភ្លើង២ដើមធ្វើឱ្យដាច់ចរន្តអគ្គិសនី ១០ថ្ងៃ រលំអង់តែនម៉ូប៊ីតែល(០១២)កម្ពស់៦៧ម៉ែត្រដល់ដី លិចអូប័រចំនួន៣គ្រឿង អ្នកនេសាទមិនបាននេសាទជាច្រើនថ្ងៃ រលំដើមឈើបានផ្តាច់ចរន្តអគ្គិសនីអស់ជាច្រើនថ្ងៃ។ ក្នុង២០១៦មានគ្រោះមហន្តរាយទី២ មានភ្លៀងខ្លាំង(យូរ) សិស្សភាគច្រើនមករៀនយឺត និងមិនបានមករៀន បាក់របងសាលារៀនប្រវែង២០ម ផ្លូវ និងដណ្តើរ ដែលសិស្សដើរមកសាលារៀនរអិលមានស្លែទឹកហូរ

ជាប់មិនដាច់មានកាលំបាកដល់សិស្សានុសិស្សក្នុងការធ្វើដំណើរឡើងមកសាលារៀន។ក្រៅពីនេះមានគ្រោះហានិភ័យផ្សេងៗទៀតដូចជា រអិលដួលរលាត់ដៃជើង មុតដៃមុតជើង ។ល។

មូលដ្ឋាននៃនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) សម្រាប់ជម្លៀសប្រកបដោយសុវត្ថិភាពមាន ៦ ចំណុច ហើយវាអាស្រ័យលើប្រភេទមុខសញ្ញាគ្រោះថ្នាក់ និងបត់បែនទៅតាមកាលៈទេសៈជាក់លាក់ណាមួយរបស់សាលារៀន។ ខាងក្រោមនេះ ជានីតិប្រតិបត្តិស្តង់ដារទាំង ៦។

- **ការជម្លៀសចេញពីអគារ**
- **ជួបជុំ និងជ្រកខាងក្រៅបន្ទប់/អគារ**
- **ជម្លៀសទៅរកកន្លែងសុវត្ថិភាព**
- **ជួបជុំ និងជ្រកក្នុងបន្ទប់រៀន**
- **ការឃាំង/ហាមការចូលដោយហឹង្សា**
- **ការវិលទៅជួបក្រុមគ្រួសារវិញដោយសុវត្ថិភាព**

ជាក់ស្តែងនៅក្នុងសាលារៀននេះ គណៈកម្មការទ្រទ្រង់សាលា បានជ្រើសរើសយកនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) "**ជួបជុំ និងជ្រកក្នុងបន្ទប់រៀន**" ដើម្បីរៀបចំជាវិធានការក្នុងការត្រៀមបង្ការនឹងមុខសញ្ញាគ្រោះថ្នាក់ "**ខ្យល់ខ្លាំង/ខ្យល់កន្ទ្រាក់**" ដែលតែងកើតមានឡើងក្នុងសាលារៀន។ ការកំណត់នេះត្រូវបានធ្វើឡើងតាមរយៈការសិក្សាអំពីហានិភ័យ និងសមត្ថភាពនៅក្នុងសាលារៀន ដោយក្នុងនោះគេសង្កេតឃើញថា អគារសិក្សានៅក្នុងសាលារៀននេះមានភាពរឹងមាំគ្រប់គ្រាន់ដែលអាចអោយសិស្សជម្លៀសចូលធ្វើជាកន្លែងសុវត្ថិភាព ដើម្បីគេចចេញពីឥទ្ធិពល និងផលប៉ះពាល់ផ្សេងៗពីខ្យល់ខ្លាំង។

**១.សញ្ញាប្រកាសអោយដឹងមុនពេលនៃមុខសញ្ញាគ្រោះថ្នាក់**



## ២.សញ្ញាប្រកាសអាសន្នសម្រាប់ជម្លៀស

គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសាលារៀន បានសម្រេចយកសំលេងសីរ៉ែន ដោយចាក់បំពងសំលេងសីរ៉ែន ខណៈពេលដែលគ្រោះមហន្តរាយនឹងមកដល់។ សំលេងសីរ៉ែនត្រូវបានពេទ៏ដើម្បីផ្សព្វផ្សាយជូនដំណឹងដល់គ្រប់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូទាំងអស់ ឱ្យបានដឹងតាមរយៈក្រុមប្រកាសអាសន្នជាអ្នកផ្សព្វផ្សាយ។ ដោយសារសាលានេះ គ្មានសិស្សពិការផ្នែកគរ ឬថ្លង់ ទើបគ្មានសញ្ញាប្រកាសអាសន្នពិសេសណាមួយផ្សេងទៀត ត្រូវបានបង្កើតឡើងឡើយ។ នៅពេលសមយុទ្ធបញ្ចប់ ក្រុមប្រកាសអាសន្នបានជូនដំណឹងតាមរយៈមេក្រូ បញ្ជាក់ថាសមយុទ្ធត្រូវបានបញ្ចប់ជាស្ថាពរ។

## ៣.សំណួរគន្លឹះសំខាន់ៗក្នុងការសម្រេចចិត្តជ្រើសរើសនីតិវិធីណាមួយ

- *សំណួរទី ១៖ តើមានសញ្ញាប្រកាសណាមួយអោយដឹងមុនពេលនៃមុខសញ្ញាគ្រោះថ្នាក់នោះដែរឬទេ ?*
- *សំណួរទី ២៖ តើអគារសាលារៀនមានសុវត្ថិភាពដែរឬទេ ?*
- *សំណួរទី ៣៖ តើទីធ្លាសាលារៀនមានសុវត្ថិភាពដែរឬទេ ?*
- *សំណួរទី ៤៖ តើនៅក្នុងសហគមន៍ មានសុវត្ថិភាពដែរឬទេ ?*

## ៤.ផែនទីជម្លៀស

ផែនទីខាងលើជាផែនទីមុខសញ្ញាគ្រោះថ្នាក់ដែលត្រូវបានគូសដោយសិស្សានុសិស្សដោយមានការណែ នាំអំពីលោក-អ្នកគ្រូនៅក្នុងសាលារៀននោះ នៅអំឡុងពេលប្រជុំពិភាក្សារៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រោះមហន្តរាយកម្រិតសាលារៀន។ នៅលើផែនទីនោះ មានសញ្ញាខ្វែង(X)ដែលជាសញ្ញាបញ្ជាក់អំពីកន្លែងអាចមានគ្រោះថ្នាក់(ដើមឈើ)ដល់សិស្សនៅពេលមានហេតុការណ៍ណាមួយដូចជាមានខ្យល់ខ្លាំងជាដើម។ ដោយឡែកនៅលើទីតាំងណាដែលមានគ្មានសញ្ញាខ្វែង បញ្ជាក់ថាជាកន្លែងមានសុវត្ថិភាព ដូចជាអគារសិក្សាដែលអាចអោយសិស្សចូលជ្រកជម្លៀសគេចចេញពីហេតុការណ៍គ្រោះថ្នាក់នៅខាងក្រៅអគារ។ ក្នុងស្ថានភាពនៅសាលារៀននេះ សិស្សត្រូវរកកន្លែងជម្លៀសនៅក្នុងអគារសិក្សា នៅពេលមានខ្យល់ខ្លាំង ឬហេតុការណ៍គ្រោះថ្នាក់ដែលអាចកើតឡើងនៅខាងក្រៅអគារសិក្សា។



### ៥.នីតិវិធីប្រតិបត្តិស្តង់ដារ "ការជួបជុំ និងជ្រកខាងក្នុងអគារ/បន្ទប់"

**គោលបំណង៖** ការពារសិស្ស មន្ត្រីអប់រំ ក្នុងករណីមានមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗនៅក្រៅអគារ/បន្ទប់ ដូចជាទឹកជំនន់ អាកាសធាតុអាក្រក់ ដើម្បីធានាសុវត្ថិភាពរបស់ពួកគេរហូតអាចត្រឡប់ទៅជួបជុំគ្រួសាររបស់ពួកគេវិញ។ ការជួបជុំ និងជ្រកខាងក្នុងអគារ/បន្ទប់ ត្រូវបានអនុវត្ត នៅពេលណាដែលការជម្លៀសមិនចាំបាច់ ឬមិនទាន់ដល់ពេលត្រូវជម្លៀស។

**រដ្ឋបាលសាលារៀន៖** ប្រកាសឱ្យនៅក្នុងបន្ទប់អគារ ឬឱ្យវិលត្រឡប់ចូលក្នុងអគារវិញ។ ត្រូវមើលរាល់ការទំនាក់ទំនងទាំងអស់ និងផ្តល់ការណែនាំផ្សេងៗតាមចាំបាច់។ ប្រកាសថា "**បញ្ចប់**" នៅពេលអាសន្នឈប់។

**បុគ្គលិក៖**

1- បិទទ្វារ និងបង្អួច បើចាំបាច់
2- កត់ត្រាវត្តមានសិស្ស
3- ត្រួតពិនិត្យមើលស្ថានការណ៍ និងផ្តល់ព័ត៌មានផ្សេងៗនៅពេលមាន។ រាល់ការទាក់ទងគ្នាផ្សេងៗមិនត្រូវអោយផ្តាច់ឡើយ ដើម្បីដឹងពីស្ថានការណ៍ និងចែករំលែកព័ត៌មានគ្នា។
4- មើលថែទាំសិស្សក្នុងថ្នាក់ ដោយឱ្យសិស្សរៀន លេងខ្លះ ហូប សម្រាក...ដើម្បីកុំអោយពួកគេមានអារម្មណ៍តក់ស្លុក (បត់បែនជាក់ស្តែង)
5- រៀបចំកន្លែងបត់ជែងបត់ជើងបណ្តោះអាសន្នដូចជាប្រើថង់ ឬធុង...ជាដើម (បត់បែនជាក់ស្តែង)

**សិស្ស៖**

6- ត្រូវចូលរួម និងជួយការងារផ្សេងៗតាមអាចជួយបាន

7- តើសាលារៀនរបស់អ្នកអាចមានការបត់បែនអ្វីផ្សេងឬទេ ?

## ជំពូកទី៥ មេរៀនទី៥

- **ឧបសម្ព័ន្ធទី១** សេចក្តីណែនាំស្តីពីការបង្រៀន និងរៀនពីចម្ងាយ និងរៀនតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ឆ្នាំសិក្សា២០២០-២០២១

**ឧបសម្ព័ន្ធ ក ឈ្មោះធនធានមនុស្សនៅក្នុងសាលារៀន និងសហគមន៍ ត្រូវប្រាប់ពេលធ្វើលំហាត់សមយុទ្ធ បំពេញដោយសាលាបឋមសិក្សា កោះស្តេច ស្រុកគីរីសាគរ ខេត្តកោះកុង**

| ស្ថាប័នពាក់ព័ន្ធ | ឈ្មោះ | ភេទ | តួនាទី | សមត្ថភាពជំនាញ | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| អាជ្ញាធរមូលដ្ឋាន | សុខ ចេង | ប្រុស | មេឃុំ | គាំទ្រសាលារៀន | 097-466-636-3 |
| | ស្រី ចំរើន | ប្រុស | មេភូមិ | គាំទ្រសាលារៀន | 016-731-440 |
| | ចំរើន ចំរុង | ប្រុស | មេប៉ុស្តិ៍ | ការពារសន្តិសុខ | 016-640-501 |
| គណៈកម្មការទ្រទ្រង់សាលា | សាយ ហេង | ប្រុស | ជំទប់ទី១ | ទំនាក់ទំនងសប្បុរសជន | 016-935-807 |
| | ឃិត យ៉ាត | ស្រី | នាយិកាសាលា | ទំនាក់ទំនងសប្បុរសជន | 016 863 646 |
| | ឌី វិធូពង្ស | ប្រុស | គ្រូបង្រៀន | ទំនាក់ទំនងសប្បុរសជន | 071-858-595-4 |
| | ពេជ្រ ធន | ស្រី | សហគមន៍ | បច្ចេកទេសកសិកម្ម | 097-273-599-5 |
| មណ្ឌលសុខភាព | សុខ សារិន | ប្រុស | គ្រូពេទ្យ | ថ្នាំព្រូន វ៉ាក់សាំង | |
| | សួន សុវណ្ណារិទ្ធ | ស្រី | ឆ្មប | | |
| ក្រុមសង្គ្រោះបឋម | សុខ សារិន | ប្រុស | គ្រូពេទ្យ | គាំទ្រ និងសង្គ្រោះបឋម | |
| ក្រុមប្រឹក្សាកុមារ | ជួន ណារីន | ស្រី | សិស្ស | គ្រប់គ្រង | |
| | ពោធិ៍ ជីវ៉ា | ប្រុស | សិស្ស | ផ្សព្វផ្សាយ | |
| | ឌឹម ហួយ | ស្រី | សិស្ស | សង្គ្រោះបឋម | |
| | ញ៉ សុភ័ណ្ឌ | ប្រុស | សិស្ស | ជម្លៀស | |
| | យឺវ ស្រីម៉ៅ | ស្រី | សិស្ស | គ្រប់គ្រង | |

ជំពូកទី៦ មេរៀនទី១

- **ឧបសម្ព័ន្ធទី១** សេចក្តីណែនាំស្តីពីការបង្រៀន និងរៀនពីចម្ងាយ និងរៀនតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ឆ្នាំសិក្សា២០២០-២០២១

**តារាង ផែនការកាត់បន្ថយគ្រោះមហន្តរាយក្នុងសាលារៀន ផ្សារភ្ជាប់ផែនការវិនិយោគឃុំ**

**ឧទាហរណ៍ទី១**

| សកម្មភាព/វិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | ភ្នាក់ងារគាំទ្រ | | ពេលណា | ធនធានមានស្រាប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| | ថវិកា | បច្ចេកទេស | | | |
| រៀបចំប្រក់ដំបូលកន្លែងលាងដៃ | អង្គការ CRF សហគមន៍ | នាយក | ២/៤/ ២០២៣ | ញញួរ ពូថៅ ដែកគោល ស័ង្កសី | នាយក មេភូមិ គណៈគ្រប់គ្រងសាលា |
| ជួសជុលរបងជុំវិញសាលា | អង្គការ CRF សហគមន៍ | នាយក | ៣០/៣/ ២០២៣ | បង្គោលក្រាក់ លួស ពូថៅ ញញួរ | នាយក មេភូមិ គណៈគ្រប់គ្រងសាលា |
| ដាំផ្កា និងដើមឈើបន្ថែម | អង្គការ CRF សាលារៀន | នាយក គ្រូបង្រៀន | ០៥/៤/ ២០២៣ | ផ្កានិងកំលាំងពលកម្ម | គ្រូបង្រៀន នាយក ក្រុមប្រឹក្សាកុមារ |
| ដាក់សញ្ញាហាមឃាត់តាមដើមឈើ | សាលារៀន ថវិកាPB | នាយក | ០៨/៤/ ២០២១ | ក្តារ ញញួរ | គ្រូបង្រៀន នាយក ក្រុមប្រឹក្សាកុមារ |

**ឧទាហរណ៍ទី២**

| សកម្មភាព/វិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ពេលណា? | អ្នកទទួលខុសត្រូវ | ធនធានមានស្រាប់(យកពីផែនទីកំណត់ធនធាន ឬសមត្ថភាព) | ធនធានត្រូវការ (សម្ភារៈឬបច្ចេកទេស) | ភ្នាក់ងារគាំទ្រ | |
|---|---|---|---|---|---|---|
| | | | | | ថវិកា | បច្ចេកទេស |
| - ដាក់សញ្ញាសម្គាល់អណ្តូងមានជាតិអាសេនិក | ខែតុលា ដល់ វិច្ឆិកា ២០១២ | ក្រុមប្រឹក្សាកុមារ | - ក្តារ<br>- ដែកគោល<br>- កូនឈើ | - ថ្នាំលាប<br>- ដក់ | - សាលា (ថវិកាPB) | - នាយក /នាយិកាសាលារៀន |

| | | | | | | |
|---|---|---|---|---|---|---|
| - **ផ្សព្វផ្សាយហាមប្រើប្រាស់ទឹកអណ្តូងសម្រាប់ហូប** | ១ខែម្តង (ពេលគោរពទង់ជាតិដើមខែ) | - ក្រុមប្រឹក្សាកុមារផ្នែកផ្សព្វផ្សាយ | - ឧបករណ៍បំពងសំឡេង(មេក្រូ) | - រូបភាពទីតាំងអណ្តូង | - គ្មាន | - **នាយក/នាយិកាសាលារៀន** |
| - **ជីកអណ្តូងថ្មី** | ខែកុម្ភៈឆ្នាំ ២០១៣ | -នាយក/នាយិកាសាលារៀន | - កម្លាំង<br>- ឥដ្ឋ<br>- ខ្សាច់ | - ឧបករណ៍ជីកអណ្តូង<br>- ស៊ីម៉ងត៍ | - សាលា (ថវិកាPB)<br>- មន្ទីរអភិវឌ្ឍន៍ជន<br>- អង្គការក្រៅរដ្ឋាភិបាល<br>- សប្បុរសជន<br>- ឃុំ/សង្កាត់ | - **មន្ទីរអភិវឌ្ឍន៍ជនបទ**<br>- **អង្គការក្រៅរដ្ឋាភិបាល** |
| - **ជីកស្រះបន្ថែម** | ខែកុម្ភៈឆ្នាំ ២០១២ | -នាយក/នាយិកាសាលារៀន | - គ្មាន | - អ្នកជីកស្រះ | - សាលារៀន (ថវិកាPB)<br>- មន្ទីរអភិវឌ្ឍន៍ជនបទ<br>- អង្គការក្រៅរដ្ឋាភិបាល<br>- សប្បុរសជន<br>- ឃុំ/សង្កាត់ | - **មន្ទីរអភិវឌ្ឍន៍ជនបទ**<br>- **អង្គការក្រៅរដ្ឋាភិបាល** |
| - **ដាំដើមឈើបន្ថែមធ្វើជារបាំងទប់ខ្យល់** | **ឧសភា ឆ្នាំ ២០១២** | - **ក្រុមប្រឹក្សាកុមារផ្នែកអនាម័យបរិស្ថាន និងបំណិនជីវិត** | - **ចបកាប់ បង្គីចបជីក កាំបិត**<br>- **ស៊ុមព័ទ្ធកូនឈើ**<br>- **កម្លាំងពលកម្ម** | - **កូនឈើ** | - **សាលារៀន (ថវិកាSOF)** | - នាយក/នាយិកាសាលារៀន<br>- កសិកម្មស្រុក |

## ឧទាហរណ៍ទី៣ សំណើរសុំរបស់សាលារៀនបញ្ចូលក្នុងផែនការផែនការវិនិយោគឃុំ សង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលស្រុក៖ រលាប្អៀរ**
**រដ្ឋបាលឃុំ៖ ស្វាយជ្រុំ**
**សាលាបឋមសិក្សា៖ ប្រាសាទជាងទង**

| លេខរៀង | ចំនួនគម្រោងស្នើដោយកុមារ | ចំនួនគម្រោងស្នើដោយរបស់កុមារ ដែលសាលារៀនទទួលយក | | ចំនួនគម្រោងស្នើដោយរបស់កុមារ ដែលរដ្ឋបាលឃុំទទួលយក | |
|---|---|---|---|---|---|
| | | តម្រូវការថវិកា | ចំនួនថវិកា(រៀល) | តម្រូវការថវិកា | ចំនួនថវិកា(រៀល) |
| ១ | សុំ ស៊ីម៉ងត៍ ២តោនចាក់សាបធ្វើឃ្លាំង | ទេ | | មាន | 800,000 ៛ |
| ២ | បណ្ណ័សម្គាល់ខ្លួនសិស្ស | មាន | 46,500 ៛ | ទេ | |
| ៣ | ផ្លាកសញ្ញាចរាចរណ៍ | មាន | 800,000 ៛ | មាន | 150,000 ៛ |
| ៤ | សាងសង់របងសាលាបន្ថែមទៀត | មាន | 600,000 ៛ | មាន | 1,200,000 ៛ |
| ៥ | ធ្វើរដាក់ស្បែកជើង(៧គ្រឿង) | មាន | 400,000 ៛ | មាន | 400,000 ៛ |
| ៦ | ធ្វើកន្លែងដាក់កង់សាជាថ្មីដោយរុំព័ទ្ធសំណាញ់ | មាន | 200,000 ៛ | មាន | 200,000 ៛ |
| ៧ | រៀបការ៉ូឡាបន្ថែម(៣០០ការ៉េ) | មាន | 500,000 ៛ | មាន | 600,000 ៛ |
| ៨ | ចាក់ខ្សាច់នៅកន្លែងក្មេងលេង | ទេ | | មាន | 220,000 ៛ |
| ៩ | ថ្មផេះ ៥ឡាន | មាន | 160,000 ៛ | មាន | 160,000 ៛ |
| ១០ | សុំអោយអាវកីឡាដូចគ្នា(តាមម៉ោង) | ទេ | | មាន | 600,000 ៛ |

ថ្ងៃអង្គារ ០៤រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ប្រាសាទជាងទងថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០២៣
**នាយកសាលា**

ភា_ទរណ្ណត

ចូលរួមពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជូនមកមេឃុំ
**ប្រធានគណៈគ្រប់គ្រងសាលារៀន**

មាស_[illegible]

**បានឃើញ និងឯកភាព**
ថ្ងៃ[illegible] ខែ[illegible]....ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ស្វាយជ្រុំថ្ងៃទី [illegible] ខែ [illegible]........ឆ្នាំ២០២៣
**មេឃុំស្វាយជ្រុំ**

រ៉េន_នួន

## ជំពូកទី៦ មេរៀនទី២

- **ឧបសម្ព័ន្ធទី១** សេចក្ដីណែនាំស្ដីពីការបង្រៀន និងរៀនពីចម្ងាយ និងរៀនតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ឆ្នាំសិក្សា២០២០-២០២១

## សារអប់រំ៖ ប្រការគួរយល់ដឹងដើម្បីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់



# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

- ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, "ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ," ឆ្នាំ២០១៥
- អង្គការសហប្រជាជាតិ, *«ក្របខ័ណ្ឌការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ហ៊ីយ៉ូហ្គោ ២០០៥-២០១៥,»* ឆ្នាំ ២០០៥
- អង្គការសហប្រជាជាតិ, *«ក្របខ័ណ្ឌសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០១៥-២០៣០,»* ឆ្នាំ ២០១៥
- ក្រសួងអប់រំ យុវជន និងកីឡា (2023), កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារ: ក្របខណ្ឌសាលារៀនសុវត្ថិភាព
- *Global Alliance for Disaster Risk Reduction and Resilience in the Education Sector (2022): Comprehensive School Safety Framework 2022-2030.*
- ក្រសួងអប់រំ យុវជន និងកីឡា (2023) , កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារៈ *ក្របខណ្ឌសាលារៀនសុវត្ថិភាព*
- ក្រសួងសុខាភិបាល (មេសា ២០២៤), សេចក្តីណែនាំក្រើនរំលឹកស្តីពីការរក្សាសុខភាព និងសុវត្ថិភាព ក្នុងអំឡុងពេលអាកាសធាតុក្តៅខ្លាំង
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និង អង្គការយូនីសេហ្វ, *ប្រការដែលគ្រួសារនីមួយៗត្រូវអនុវត្ត មុនពេល អំឡុងពេល ក្រោយពេលមានទឹកជំនន់*
- រាជរដ្ឋាភិបាលកម្ពុជា (2007), សេចក្តីណែនាំស្តីពី ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និង កម្មវិធីវិនិយោគឃុំ សង្កាត់

## សហការរៀបចំ និងគាំទ្រដោយ

តាមរយៈគម្រោង ការវិលត្រឡប់មកសាលារៀនវិញ

ប្រកបដោយសុវត្ថិភាពឆ្ពោះទៅរកសមធម៌ និងភាពធន់នៃវិស័យអប់រំ

The "Safe Back to School – Pathways in Educational Equity and Resilience" ( PEER )